# អង្គរ

## តំបន់បេតិកភណ្ឌពិភពលោក

## ផែនការគ្រប់គ្រងទេសចរណ៍



ខែធ្នូ ឆ្នាំ២០១២

*បកប្រែពីភាសាអង់គ្លេសដោយក្រុមការងារអនុវត្តផែនការគ្រប់គ្រងទេសចរណ៍ (TMP)*

*ពិនិត្យនិងគាំទ្រដោយរាជបណ្ឌិត្យសភាកម្ពុជា*

*(មិថុនា ២០១៤)*

# មាតិកា


មាតិកា ..... 2

បុព្វកថា ..... 3

បរិបទ សាវតារ និងដំណើរការ ..... 5

មូលន័យសង្ខេប ..... 7

លំនាំដើម ..... 21

តួនាទីនៃផែនការគ្រប់គ្រងទេសចរណ៍ ..... 28

ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ទេសចរណ៍២០១២–២០២០ ..... 29

តំបន់បេតិកភណ្ឌពិភពលោកអង្គរ ..... 31

រចនាសម្ព័ន្ធផែនការគ្រប់គ្រងទេសចរណ៍ ..... 35

គុណតម្លៃបេតិកភណ្ឌអង្គរ ..... 39

បញ្ហាចម្បង ..... 46

ការផ្តួចផ្តើមគោលនយោបាយ ..... 56

ការផ្តួចផ្តើមគោលនយោបាយTMPទី១ គឺការលើកកម្ពស់បទពិសោធជាវិជ្ជមានសម្រាប់អ្នកទស្សនា ..... 65

ការផ្តួចផ្តើមគោលនយោបាយTMPទី២ គឺការកាត់បន្ថយផលប៉ះពាល់ដល់ រមណីយដ្ឋាន ..... 87

ការផ្តួចផ្តើមគោលនយោបាយTMPទី៣ គឺភាពជាដៃគូជាមួយឧស្សាហកម្ម ទេសចរណ៍ ..... 111

ការផ្តួចផ្តើមគោលនយោបាយTMPទី៤ គឺការផ្តល់ផលប្រយោជន៍ដល់ប្រជាជនក្នុងតំបន់ ..... 125

ការផ្តួចផ្តើមគោលនយោបាយTMPទី៥ គឺការបង្កើនអភិបាលកិច្ចល្អ ..... 142

ការផ្តួចផ្តើមគោលនយោបាយTMPទី៦ គឺការចូលរួមស្វែងយល់ពីអ្នកពាក់ព័ន្ធ ..... 157

ការផ្តួចផ្តើមចម្បង ..... 166

សកម្មភាពអាទិភាព ..... 178

ផែនការអនុវត្ត ..... 185

សទ្ទានុក្រម ..... 258

# បុព្វកថា

រមណីយដ្ឋានបេតិកភណ្ឌពិភពលោកអង្គរ គឺជាផ្នែកមួយដ៏លេចធ្លោនៃបេតិកភណ្ឌរបស់មនុស្សជាតិ ដោយសាររមណីយដ្ឋាននេះតំណាងឲ្យតម្លៃវប្បធម៌ជាសកល។ នៅពេលដែលកម្ពុជាកំពុងត្រៀមធ្វើជាម្ចាស់ផ្ទះ រៀបចំសម័យប្រជុំលើកទី៣៧របស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក នៅឆ្នាំ២០១៣ ប្រទេសយើងមានមោទនភាពក្នុងការដាក់ចេញនូវ «ផែនការគ្រប់គ្រងទេសចរណ៍»នេះ សំដៅជួយអភិរក្ស និងបង្ហាញនូវរមណីយដ្ឋានបេតិកភណ្ឌពិភពលោកអង្គរដល់មនុស្សជំនាន់ក្រោយៗទៀត។

ការដាក់រូបប្រាសាទអង្គរវត្តនៅលើទង់ជាតិយើង បានបង្ហាញថា អង្គរ គឺជាផ្នែកមួយដ៏សំខាន់មិនអាចផ្តាច់ចេញពីអត្តសញ្ញាណវប្បធម៌របស់កម្ពុជា។ អង្គរក៏ជាទេសភាពសក្ការៈដ៏រស់រវើកមួយសម្រាប់អ្នកស្រុករាប់ពាន់នាក់។ ក៏ប៉ុន្តែ ក្រៅពីសារៈសំខាន់កម្រិតជាតិ អង្គរក៏បង្ហាញឲ្យឃើញផងដែរអំពីដំណាក់កាលដ៏អស្ចារ្យមួយនៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ ប្រកបដោយស្នាដៃច្នៃប្រឌិតនិងបច្ចេកទេសដ៏លេចធ្លោជាច្រើន និងជារមណីយដ្ឋានបុរាណវត្ថុវិទ្យាមួយ ក្នុងចំណោមរមណីយដ្ឋានបុរាណវត្ថុវិទ្យាដ៏ធំបំផុតនានានៅលើសកលលោក។

នៅពេលដែលអង្គរបានក្លាយទៅជាគោលដៅទេសចរណ៍ដ៏ពេញនិយម កាន់តែខ្លាំងឡើងៗសម្រាប់ភ្ញៀវទេសចរជាតិនិងអន្តរជាតិ យើងត្រូវជួបនឹងបញ្ហាប្រឈមធំៗក្នុងការអភិរក្សរមណីយដ្ឋាននេះ ខណៈដែលយើងត្រូវបង្កលក្ខណៈងាយស្រួលក្នុងការចេញចូលក្នុងរមណីយដ្ឋាន និងធ្វើឲ្យទស្សនកិច្ចរបស់ភ្ញៀវទេសចរកាន់តែមានអត្ថន័យប្រសើរឡើងថែមទៀត។ ការគ្រប់គ្រងបេតិកភណ្ឌអង្គរប្រកបដោយចីរភាព តម្រូវឲ្យមានការគ្រប់គ្រងវិស័យទេសចរណ៍។ កិច្ចសហការគ្នាយ៉ាងជិតស្និទ្ធរវាងរាជរដ្ឋាភិបាលកម្ពុជានិងឧស្សាហកម្មទេសចរណ៍ ពិតជាមានសារៈសំខាន់ណាស់ នៅក្នុងកិច្ចខិតខំប្រឹងប្រែងនេះ ហើយយើងត្រូវតែប្រើប្រាស់នូវធនធានរបស់រាជរដ្ឋាភិបាល ប្រកបដោយការគិតគូរនិងយកចិត្តទុកដាក់ខ្ពស់។

«ផែនការគ្រប់គ្រងទេសចរណ៍» នេះ នឹងបង្កលក្ខណៈងាយស្រួលដល់ការគ្រប់គ្រងនិងកិច្ចសម្របសម្រួលឧស្សាហកម្មទេសចរណ៍ដែលកំពុងមានការរីកចម្រើនយ៉ាងឆាប់រហ័សនៅអង្គរ តាមរយៈការធ្វើឲ្យប្រសើរឡើងនូវបទពិសោធទស្សនកិច្ចរបស់ភ្ញៀវទេសចរ ការ

កាត់បន្ថយផលប៉ះពាល់ឲ្យនៅកម្រិតអប្បបរមា ការបង្កើតភាពជាដៃគូជាមួយនឹងឧស្សាហកម្មទេសចរណ៍ ការផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនក្នុងតំបន់ និងការចូលរួមរបស់អ្នកពាក់ព័ន្ធទាំងអស់។

ការរៀបចំ «ផែនការគ្រប់គ្រងទេសចរណ៍»នេះ គឺជាកិច្ចខិតខំប្រឹងប្រែងរួម ដោយមានកិច្ចសហការនិងការពិគ្រោះយោបល់ពីអាជ្ញាធរអប្សរា ក្រសួងទេសចរណ៍និងអង្គការយូណេស្កូ ក៏ដូចជាតំណាងមកពីឧស្សាហកម្មទេសចរណ៍ និងពីសហគមន៍មូលដ្ឋានផងដែរ។ គម្រោងនេះត្រូវបានធ្វើឡើងនៅក្នុងក្របខ័ណ្ឌនៃគម្រោងធំគឺ «គម្រោងក្របខ័ណ្ឌគ្រប់គ្រងបេតិកភណ្ឌ» ដែលគាំទ្ររួមគ្នាដោយរាជរដ្ឋាភិបាលកម្ពុជា រដ្ឋាភិបាលអូស្ត្រាលី និងអង្គការយូណេស្កូ និងសម្របសម្រួលដោយក្រុមពិគ្រោះយោបល់អូស្ត្រាលីនៃក្រុមហ៊ុន Godden MacKay Logan។

«ផែនការគ្រប់គ្រងទេសចរណ៍» នេះ ត្រូវបានអនុម័តដោយអាជ្ញាធរអប្សរា អង្គការយូណេស្កូ និងគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារនិងការអភិវឌ្ឍន៍តំបន់ប្រវត្តិសាស្ត្រអង្គរ (ICC-Angkor)។

រាជរដ្ឋាភិបាលកម្ពុជា សូមសម្តែងនូវការកោតសរសើរនិងវាយតម្លៃខ្ពស់ ចំពោះអ្នកពាក់ព័ន្ធទាំងអស់ដែលបានចូលរួមចំណែកក្នុងការរៀបចំ «ផែនការគ្រប់គ្រងទេសចរណ៍» នេះ និងបានប្តេជ្ញាចិត្តចំពោះការអភិរក្សឲ្យបានយូរអង្វែង និងការបង្ហាញនូវរមណីយដ្ឋានបេតិកភណ្ឌពិភពលោកអង្គរ តាមរយៈការអនុវត្តនិងការធ្វើឲ្យសម្រេចនូវគោលនយោបាយនិងកម្មវិធីសំខាន់នានា នៅក្នុង «ផែនការគ្រប់គ្រងទេសចរណ៍» នេះ។

ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន**
ឧបនាយករដ្ឋមន្ត្រី
ប្រធានអាជ្ញាធរអប្សរា
ប្រធានគណៈកម្មាធិការដឹកនាំគម្រោង «ក្របខ័ណ្ឌគ្រប់គ្រងបេតិកភណ្ឌ»

# បរិបទ សាវតារ និងដំណើរការ

ផែនការគ្រប់គ្រងទេសចរណ៍ (ហៅកាត់តាមភាសាអង់គ្លេសថាTMP) ត្រូវបានរៀបចំដោយក្រុមគម្រោងក្របខ័ណ្ឌគ្រប់គ្រងបេតិកភណ្ឌអង្គរ (ហៅកាត់តាមភាសាអង់គ្លេសថាHMF) តាមសំណើរបស់គណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារនិងអភិវឌ្ឍរមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ (ICC-Angkor) និងអាជ្ញាធរអប្សរា ដោយមានការគាំទ្រពីអង្គការសហប្រជាជាតិសម្រាប់ការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌(UNESCO) រាជរដ្ឋាភិបាលកម្ពុជានិងប្រទេសអូស្ត្រាលី។

ការរៀបចំផែនការគ្រប់គ្រងទេសចរណ៍ ស្ថិតក្រោមការត្រួតពិនិត្យ របស់ប្រធានគម្រោងHMF ឯកឧត្តមបណ្ឌិត **ហង់ ពៅ** និងជាលទ្ធផលដែលបានមកពីទស្សនៈកិច្ចនៅនឹងកន្លែងផ្ទាល់ ការស្រាវជ្រាវ ការពិនិត្យឡើងវិញលើឯកសារសំខាន់ៗ ការប្រជុំពិភាក្សាជាមួយអាជ្ញាធរអប្សរា ការសម្ភាសជាមួយអ្នកធ្វើការក្នុងឧស្សាហកម្មទេសចរណ៍ និងសិក្ខាសាលាជាមួយនឹងគណៈកម្មាធិការបច្ចេកទេសនៃអាជ្ញាធរអប្សរាក្នុងក្របខ័ណ្ឌគ្រប់គ្រងបេតិកភណ្ឌអង្គរ។

ការរៀបចំ TMP ផ្អែកលើព័ត៌មានដែលផ្តល់ដោយអាជ្ញាធរអប្សរា ឆ្លើយតបទៅនឹងការពិពណ៌នាចំណុចគោលជាបឋម ដែលរៀបចំដោយក្រុមការងារ HMF នៅខែសីហា ឆ្នាំ២០១១។ សំណើរបស់អាជ្ញាធរអប្សរាដែលរៀបចំដោយលោកជំទាវ **ចៅ ស៊ុន កិរិយា** ត្រូវបានគាំទ្រដោយក្រសួងទេសចរណ៍ និងចុះហត្ថលេខាដោយឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ជាប្រធានអាជ្ញាធរអប្សរា នៅខែកញ្ញា ឆ្នាំ២០១១។

សិក្ខាសាលាជាមួយអ្នកពាក់ព័ន្ធនឹងឧស្សាហកម្មទេសចរណ៍ និងសិក្ខាសាលាជាមួយសហគមន៍ ព្រះសង្ឃនិងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានប្រារព្ធឡើងនៅខេត្តសៀមរាប ក្នុងខែមីនា ឆ្នាំ២០១២។ សេចក្តីព្រៀង TMP ត្រូវបានលើកយកមកត្រិះរិះពិចារណានិងផ្តល់ការគាំទ្រជាគោលការណ៍ នៅក្នុងសម័យប្រជុំបច្ចេកទេសរបស់គណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារនិងអភិវឌ្ឍរមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ (ICC-Angkor) លើកទី២១ ក្នុងខែមិថុនា នៅខេត្តសៀមរាប។ ក្រុមអ្នកជំនាញចំពោះកិច្ចរបស់ ICC-Angkor ផ្នែកអភិវឌ្ឍប្រកបដោយចីរភាព និងអាជ្ញាធរអប្សរាបានផ្តល់នូវព័ត៌មាន

ព្រមទាំងសំណូមពរដ៏មានតម្លៃនានា។ នៅខែកញ្ញាឆ្នាំ២០១២ មានកិច្ចប្រជុំពីរថ្ងៃបន្ថែមទៀតដោយមានការចូលរួមពីសំណាក់លេខាធិការវិទ្យាសាស្ត្រនៃ ICC-Angkor អាជ្ញាធរអប្សរា អង្គការយូណេស្កូ ក្រសួងទេសចរណ៍ និងក្រុមគម្រោងHMF ។ នៅខែធ្នូ ឆ្នាំ២០១២ មានសិក្ខាសាលាពេញមួយថ្ងៃស្តីពីការអនុវត្តផែនការគ្រប់គ្រងទេសចរណ៍ ដោយពិចារណា និងយល់ស្របដាក់បញ្ចូលការអនុវត្តសកម្មភាពអាទិភាព ក្នុងឯកសារTMP ។

នៅក្នុងអំឡុងខែតុលា ឆ្នាំ២០១២ មានការកែសម្រួលសេចក្តីព្រាងTMP ដែលក្នុងនោះសំណើជាង២០ ត្រូវបានទទួលយក។ លោកជំទាវ **ថៅ ស៊ុន កិរិយា** និងលោក **ហ្សង់-ម៉ារី ហ្វឺត** (Jean-Marie Furt) អ្នកជំនាញចំពោះកិច្ចរបស់ ICC-Angkor ផ្នែកអភិវឌ្ឍប្រកបដោយចីរភាព បានលើកយោបល់បន្ថែមជាច្រើនទៀត ដោយមានការយល់ស្របពីអគ្គនាយកអាជ្ញាធរអប្សរា ឯកឧត្តម **ប៊ុន ណារិទ្ធ**។ យោបល់ទាំងនេះត្រូវបានយកមកពិចារណានៅក្នុងការរៀបចំកែលម្អ TMP ជាលើកចុងក្រោយ មុននឹងដាក់ជូនសម័យប្រជុំពេញអង្គទី១៩ របស់ ICC-Angkor នៅខែធ្នូ ឆ្នាំ២០១២ ដើម្បីទទួលបានការគាំទ្រ។



# មូលន័យសង្ខេប

អង្គរជាតំបន់បេតិកភណ្ឌពិភពលោកដ៏ឆ្នើម ជាអត្តសញ្ញាណជាតិ និងបានជ្រួតជ្រាបក្នុងអារម្មណ៍ប្រជាជនកម្ពុជា ព្រមទាំងជាទិដ្ឋភាព ជាដួងព្រលឹងមួយដែលប្រជាជនខ្មែរបានរស់នៅជាមួយអស់កាលជាច្រើនជំនាន់មកហើយ។ មនុស្សនៅជុំវិញពិភពលោក កំពុងយល់ដឹងយ៉ាងច្រើនពីសារៈសំខាន់នៃអង្គរនៅក្នុងប្រវត្តិសាស្រ្តដ៏អស្ចារ្យនៃអរិយធម៌ខ្មែរ។ វិសាលភាព និមិត្តរូប និងភាពអស្ចារ្យរបស់អង្គរ បានទាក់ទាញអ្នកទស្សនាអស់រយៈពេលជាយូរ មុនពេលដែលពួកគេបានមកដល់អង្គរ ហើយក៏បានបន្តធ្វើឲ្យភ្ញៀវទេសចរមកពីទូទាំងពិភពលោកកាន់តែចាប់អារម្មណ៍បន្ថែមទៀត។

ការធ្វើទីផ្សារដ៏ជោគជ័យរបស់ក្រសួងទេសចរណ៍កម្ពុជា និងការចាប់ផ្តើមយល់ដឹងស្របពេលគ្នាពីសំណាក់សហគមន៍អន្តរជាតិ ចំពោះភាពអច្ឆរិយៈនៃអង្គរ បានធ្វើឲ្យមានលំហូរអ្នកទស្សនាកាន់តែច្រើនឡើង។ ការកើនឡើងនូវប្រជាប្រិយភាពនៃអង្គរដែលជាគោលដៅទេសចរណ៍មួយ បានផ្តល់នូវផលប្រយោជន៍ក៏ពិតមែន ប៉ុន្តែក៏បណ្តាលឲ្យមានផលប៉ះពាល់ផងដែររួមមាន សម្ពាធពីការអភិវឌ្ឍន៍និងបញ្ហាបរិស្ថាន ដែលបច្ចុប្បន្នត្រូវតែគ្រប់គ្រងដោយប្រុងប្រយ័ត្ន ដើម្បីអភិរក្សតម្លៃនិងភាពថ្លៃថ្នូរនៃបេតិកភណ្ឌអង្គរ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ កិច្ចខិតខំប្រឹងប្រែងរួមគ្នាពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាអាជ្ញាធរអប្សរា *(អាជ្ញាធរដើម្បីការពាររមណីយដ្ឋាននិងរៀបចំតំបន់អង្គរ)* និងសហគមន៍អន្តរជាតិក្នុងការលើកឡើងនូវបញ្ហាប្រឈមជាគន្លឹះ បានធ្វើឲ្យបេតិកភណ្ឌពិភពលោកអង្គរត្រូវបានគេដកចេញពី "បញ្ជីបេតិកភណ្ឌពិភពលោកដែលស្ថិតនៅក្នុងសភាពគ្រោះថ្នាក់"។ កិច្ចខិតខំប្រឹងប្រែងទាំងនេះត្រូវតែបន្តធ្វើឡើងដរាបណាបញ្ហាប្រឈមពីកំណើនភ្ញៀវទេសចរ និងសម្ពាធពីការអភិវឌ្ឍន៍ចេះតែបន្តកើនឡើង។

ការអភិវឌ្ឍន៍វិស័យទេសចរណ៍ បានផ្តល់នូវឱកាសយ៉ាងច្រើន ដល់បេតិកភណ្ឌពិភពលោកអង្គរផ្ទាល់ ដល់ប្រជាជន និងដល់សេដ្ឋកិច្ចជាតិ។ ឧស្សាហកម្មទេសចរណ៍មានចំណាប់អារម្មណ៍ក្នុងការធ្វើកិច្ចសហការជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើឲ្យវិស័យទេសចរណ៍នៅអង្គរមានលក្ខណៈកាន់តែប្រសើរឡើង ប្រកបដោយនិរន្តរភាព។ បច្ចុប្បន្នមានប្រតិបត្តិករទេសចរណ៍និងផលិតផលដ៏ល្អប្រសើរមួយចំនួន បន្ថែមពីនេះគេត្រូវស្វែងរកឲ្យឃើញនូវឱកាសថ្មីៗ ដើម្បីលើកតម្លៃបេតិកភណ្ឌខ្មែរ និងធ្វើឲ្យមានវិបុលភាពប្រសើរឡើងដល់ខេត្តសៀមរាប ដែលជាខេត្តក្រីក្របំផុតមួយក្នុងចំណោមខេត្តក្រីក្រនានានៅ

កម្ពុជា។ សុច្ឆន្ទៈក្នុងវិស័យទេសចរណ៍ អាចជួយគាំទ្រគំនិតផ្តួចផ្តើមសហគមន៍ក្នុងស្រុក ជំរុញការបន្តប្រតិបត្តិវប្បធម៌ និងទាក់ទាញនូវធនធានសម្រាប់ការអភិរក្សរមណីយដ្ឋាន។

ទន្ទឹមនឹងភាពវិជ្ជមានពីវិស័យទេសចរណ៍ ក៏មាននូវហានិភ័យផងដែរ ដោយសារផលប្រយោជន៍សេដ្ឋកិច្ចពីវិស័យទេសចរណ៍ មិនប្រាកដជាបានទៅដល់សហគមន៍ក្នុងតំបន់ដោយផ្ទាល់នោះទេ។ ស្របពេលនេះដែរ បទពិសោធរបស់អ្នកទស្សនា កំពុងចាប់ផ្តើមថយចុះដោយមានមនុស្សច្រើនកុះករពេក។ ការកកស្ទះនិងអាកប្បកិរិយាមិនសមរម្យរបស់ភ្ញៀវទេសចរមួយចំនួន អាចនាំឲ្យមានការខូចខាតដល់ទ្រង់ទ្រាយប្រាសាទទាំងឡាយពិសេសនៅពេលដែលពួកគាត់មិនបានកោតសរសើរសារៈសំខាន់ជាដួងព្រលឹង នៃតំបន់ប្រាសាទអង្គរ ហើយប្រព្រឹត្តអាកប្បកិរិយាឆ្គាំឆ្គង។ ការកើនឡើងនូវចំនួនភ្ញៀវទេសចរច្រើនជាងទ្វេដង នៅក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ ធ្វើឲ្យមានបញ្ហាប្រឈមក្នុងការការពារនិងគ្រប់គ្រងបេតិកភណ្ឌអង្គរ។

នៅចុងឆ្នាំ២០១០ ICC-Angkor និងអាជ្ញាធរអប្សរាបានស្នើឡើងថាត្រូវដាក់បញ្ចូលផែនការគ្រប់គ្រងទេសចរណ៍ក្នុង "គម្រោងក្របខ័ណ្ឌគ្រប់គ្រងបេតិកភណ្ឌអង្គរ" ដែលរៀបចំឡើងដោយមានការគាំទ្រពីអង្គការយូណេស្កូ និងរាជរដ្ឋាភិបាលកម្ពុជានិងប្រទេសអូស្ត្រាលី។ ដូច្នេះ TMP ត្រូវបានដាក់បញ្ចូលនិងរៀបចំឡើង ដោយផ្អែកលើសមិទ្ធផលដ៏ច្រើនសម្បើមរបស់អាជ្ញាធរអប្សរានិងក្រសួងទេសចរណ៍ ដោយរួមបញ្ចូលការផ្តួចផ្តើមក្នុងការគ្រប់គ្រងអ្នកទស្សនាដែលមានស្រាប់ និងការកំណត់អត្តសញ្ញាណបញ្ហាមួយចំនួនធំនាពេលបច្ចុប្បន្ន។ TMP ក៏បានដាក់បញ្ចូលនូវការរួមចំណែកដ៏សំខាន់របស់ភាគីពាក់ព័ន្ធក្នុងឧស្សាហកម្មទេសចរណ៍ទាំងឡាយ និងឆ្លើយតបជាពិសេសចំពោះបញ្ហានិងគំនិតនានានៅក្នុងសិក្ខាសាលាជាមួយឧស្សាហកម្មទេសចរណ៍និងសហគមន៍ ដែលរៀបចំដោយ រាជរដ្ឋាភិបាលកម្ពុជានិងប្រទេសអូស្ត្រាលី អង្គការយូណេស្កូ ក្រសួងទេសចរណ៍កម្ពុជា និងអាជ្ញាធរអប្សរា នៅខែមីនា ឆ្នាំ២០១២ ក្នុងខេត្តសៀមរាប។ ដូច្នេះ TMP ឆ្លុះបញ្ចាំងពីទស្សនៈវិស័យសម្រាប់អ្នកធ្វើការសម្រេចចិត្តនានារួមមាន រាជរដ្ឋាភិបាលកម្ពុជានិងអ្នកចូលរួមក្នុងឧស្សាហកម្មទេសចរណ៍ទាំងអស់។

## បញ្ហាចម្បងនៅអង្គរ

បញ្ហាប្រទាក់ក្រឡាគ្នា ដែលពេលខ្លះមានទំនាស់នឹងគ្នា បានជះឥទ្ធិពលដល់វិស័យទេសចរណ៍នៅអង្គរ។ ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងច្រើនសន្ធឹកសន្ធាប់ដើម្បីគ្រប់គ្រងទេសចរណ៍នៅអង្គរក៏ដោយ ក៏ការកើនឡើងយ៉ាងលឿននៃចំនួនភ្ញៀវទេសចរបានបង្កឲ្យ

មានផលប៉ះពាល់ដោយផ្ទាល់និងដោយប្រយោលពីវិស័យទេសចរណ៍ ដែលនេះជាការគំរាមកំហែងដល់សេចក្ដីថ្លៃថ្នូរនិងគុណតម្លៃបេតិកភណ្ឌពិភពលោកអង្គរ។ បញ្ហានានាដែលកើតឡើងពីវិស័យទេសចរណ៍ បានទាក់ទាញចំណាប់អារម្មណ៍រាជរដ្ឋាភិបាលកម្ពុជា ICC-Angkor សហគមន៍អភិរក្សអន្តរជាតិ និងភាគីដែលពាក់ព័ន្ធផ្សេងៗ។ ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងមួយចំនួនទាក់ទងនឹងកំណើននិងផលប៉ះពាល់ពីវិស័យទេសចរណ៍ក៏ដោយ ក៏បញ្ហាជាច្រើននៅតែទាមទារឲ្យមានការយកចិត្តទុកដាក់ជាបន្ទាន់។

បញ្ហាចម្បងមួយចំនួនរួមមាន :

- **ការគ្រប់គ្រងអ្នកទស្សនានៅអង្គរក្នុងខណៈដែលចំនួនអ្នកទស្សនាកើនឡើង** : ក្នុងខណៈដែលចំនួនអ្នកទស្សនានៅអង្គរបន្តកើនឡើង ចាំបាច់ត្រូវមានការត្រួតពិនិត្យលើវិស័យទេសចរណ៍ឲ្យបានតឹងរ៉ឹងជាមុន ហើយជាចុងក្រោយ ចាំបាច់ត្រូវអនុវត្តការកំណត់នូវចំនួនអ្នកទស្សនានៅតាមផ្នែកមួយចំនួននៃតំបន់ប្រាសាទនានា។
- **ការយល់ដឹងនិងការប្រាស្រ័យទាក់ទងនូវគុណតម្លៃបេតិកភណ្ឌ** : គោលដៅគន្លឹះនៃការគ្រប់គ្រងនិងការបកស្រាយព័ត៌មាននៅតំបន់អង្គរ គួរឆ្លើយតបទៅនឹងការអភិរក្សនិងផ្សព្វផ្សាយពីគុណតម្លៃបរិស្ថាន ធារាសាស្ត្រ និងសង្គមវប្បធម៌ ជាជាងការផ្ដល់បទពិសោធដល់អ្នកទស្សនាត្រឹមតែអំពីគុណតម្លៃផ្នែកបុរាណវិទ្យា សោភ័ណវិទ្យា ស្ថាបត្យកម្ម ឬសិល្បៈ។ ដោយឡែក អង្គរគឺជាទីពិសិដ្ឋមួយ ប៉ុន្តែភ្ញៀវទេសចរ មគ្គុទ្ទេសក៍ និងប្រតិបត្តិករមួយចំនួន មិនបានគោរពគុណតម្លៃខាងផ្នែកសាសនានេះឡើយ។
- **ផលប៉ះពាល់ដល់តំបន់ប្រាសាទ** : ផលប៉ះពាល់នៅតំបន់អង្គរពីវិស័យទេសចរណ៍រួមមាន ការខូចខាតរមណីយដ្ឋាននិងការរេចរិលបរិស្ថាន កកស្ទះចរាចរណ៍ ការចោលសំរាម ការចតយានយន្តមិនសមស្រប និងការខូចខាតផ្លូវធ្វើដំណើរ។ ផលប៉ះពាល់បន្ថែមផ្សេងទៀតទាក់ទងនឹងសម្ពាធនៃការអភិវឌ្ឍន៍ ផ្សារភ្ជាប់នឹងកំណើនប្រជាជននៅតាមមូលដ្ឋាននិងក្រុងសៀមរាបរួមមាន ការគ្រប់គ្រងកាកសំណល់ គុណភាពនិងការផ្គត់ផ្គង់ទឹកប្រព័ន្ធដឹកជញ្ជូន និងការបំពុលបរិយាកាសកាន់តែខ្លាំងឡើងនាពេលអនាគត។
- **បទពិសោធ អាកប្បកិរិយា និងសុវត្ថិភាពអ្នកទស្សនា** : ការគ្រប់គ្រងវិស័យទេសចរណ៍នៅអង្គរនាពេលបច្ចុប្បន្នមិនបានឆ្លើយតបនឹងតម្រូវការផ្សេងៗរបស់ទីផ្សារឡើយ ហើយបញ្ហាអាចកើតឡើងនៅពេលដែលទីផ្សារផ្សេងគ្នា ប្រើប្រាស់ទីតាំងដូចគ្នា ស្របពេលជាមួយគ្នា ប៉ុន្តែមានការរំពឹងទុកនិងតម្រូវការខុសៗគ្នា។ អាកប្បកិរិយានៃការគ្រប់គ្រងបុគ្គលិក មគ្គុទ្ទេសក៍ និងប្រតិបត្តិករ អាចមានឥទ្ធិពលលើអ្នកទស្សនា និងកម្រិតសេវាកម្មដូច្នេះហើយអាចបង្កឲ្យមានឬបញ្ចៀសផលប៉ះពាល់ដល់តំបន់ប្រាសាទ។ ហានិភ័យចំពោះអ្នកទស្សនារួមមាន កង្វះខាតសេវាសង្គ្រោះបឋម ការឡើងលើប្រាសាទខ្ពស់ៗមួយចំនួន និងការរំខានពីសំណាក់អ្នកលក់ដូរនិងអ្នកទស្សនាដទៃទៀត។

- **ហេដ្ឋារចនាសម្ព័ន្ធនិងការដឹកជញ្ជូន** : ហេដ្ឋារចនាសម្ព័ន្ធបច្ចុប្បន្នមិនទាន់បានបំពេញតម្រូវការនៃកំណើនចំនួនអ្នកទស្សនានៅឡើយទេ ហើយត្រូវធ្វើការគ្រប់គ្រងបន្ថែមទៀតលើលំហូរនៃការដឹកជញ្ជូននិងការកាត់បន្ថយការកកស្ទះចរាចរណ៍។ ត្រូវរៀបចំហេដ្ឋារចនាសម្ព័ន្ធចាំបាច់នៅក្នុងនិងជុំវិញបរិវេណប្រាសាទដូចជា ទីធ្លាខាងមុខ បង្គន់អនាម័យ ចំណតរថយន្តក្រុង រថយន្តធុនតូចនិងរ៉ឺម៉ក ផ្លូវដើរ និងកន្លែងឈប់សម្រាក ឲ្យបានប្រសើរជាងមុន។
- **ប្រជាជនក្នុងតំបន់** : ទោះបីជាអាជ្ញាធរអប្សរាបានអនុវត្តគម្រោងដែលមានការចូលរួមពីសហគមន៍ក៏ដោយ ក៏ប្រជាជនក្នុងតំបន់ជាច្រើនមិនអាចទប់ទល់នឹងសម្ពាធសេដ្ឋកិច្ចឬមិនអាចចាប់យកឱកាសផ្សេងៗពីវិស័យទេសចរណ៍នៅអង្គរបានឡើយ។ សហគមន៍ក្នុងតំបន់ក៏ព្រួយបារម្ភចំពោះការបាត់បង់សេចក្តីថ្លៃថ្នូរខាងប្រពៃណីនិងវប្បធម៌ អាកប្បកិរិយាមិនសមរម្យនិងមិនគោរពម្ចាស់ស្រុក និងការផ្លាស់ប្តូរទីលំនៅខណៈដែលចំនួនអ្នកទស្សនាកាន់តែច្រើនឡើង។
- **ការចូលរួមស្វែងយល់ពីអ្នកពាក់ព័ន្ធ** : ទំនាក់ទំនងរវាងអ្នកចូលរួមក្នុងវិស័យទេសចរណ៍នៅអង្គរ ទាមទារឲ្យមានកិច្ចខិតខំប្រឹងប្រែងដើម្បីធ្វើឲ្យការប្រាស្រ័យទាក់ទងកាន់តែប្រសើរឡើងរវាងអ្នកពាក់ព័ន្ធទាំងអស់រួមមាន រាជរដ្ឋាភិបាល សហគមន៍ ប្រតិបត្តិករទេសចរណ៍ និងសមាគមដឹកជញ្ជូន ព្រមទាំងមគ្គុទ្ទេសក៍ទេសចរណ៍។
- **អភិបាលកិច្ចល្អ** : ការគ្រប់គ្រងទេសចរណ៍តាមរយៈអភិបាលកិច្ចល្អ ទាមទារនូវការប្រើប្រាស់ធនធានឲ្យបានប្រសើរ ព្រមទាំងការពង្រឹងច្បាប់នានាដែលមានលក្ខណៈជាប្រព័ន្ធនិងស៊ីចង្វាក់គ្នា។ ត្រូវពង្រឹងការគ្រប់គ្រងធនធានមនុស្សនិងធនធានដទៃទៀតប្រកបដោយប្រសិទ្ធភាព។ មានឱកាសជាច្រើននៅក្នុងការប្រើប្រាស់ចំណូលពីវិស័យទេសចរណ៍ដើម្បីធានាឲ្យបាននូវការការពារ ការអភិរក្ស និងការគ្រប់គ្រងអង្គរ។





**ការផ្តួចផ្តើមគោលនយោបាយគន្លឹះ**

ផែនការគ្រប់គ្រងទេសចរណ៍ ផ្តល់នូវមូលដ្ឋាននៃការគ្រប់គ្រងនិងសម្របសម្រួលជាមួយឧស្សាហកម្មទេសចរណ៍ដែលមានកំណើនយ៉ាងលឿននៅតំបន់អង្គរ តាមរយៈការវាយតម្លៃលើគុណតម្លៃ ការវិភាគបញ្ហានិងការអភិវឌ្ឍន៍ ការផ្តួចផ្តើមគោលនយោបាយគន្លឹះទាំង៦។ ចំពោះការផ្តួចផ្តើមនីមួយៗ មានបង្ហាញលម្អិតពីគោលដៅគ្រប់គ្រង ការវិភាគបញ្ហាជាក់ស្តែង ប្រព័ន្ធយុទ្ធសាស្ត្រ ព្រមទាំងអនុសាសន៍ជាក់លាក់ស្តីពីសកម្មភាព។ ការផ្តួចផ្តើមទាំង៦នោះមានជាអាទ៍ះ

១- ការលើកកម្ពស់បទពិសោធជាវិជ្ជមានសម្រាប់អ្នកទស្សនា
២- ការកាត់បន្ថយផលប៉ះពាល់ដល់រមណីយដ្ឋាន
៣- ភាពជាដៃគូជាមួយឧស្សាហកម្មទេសចរណ៍
៤- ការផ្តល់ផលប្រយោជន៍ដល់ប្រជាជនក្នុងតំបន់
៥- ការបង្កើនអភិបាលកិច្ចល្អ និង
៦- ការចូលរួមពីអ្នកពាក់ព័ន្ធ

- **បទពិសោធជាវិជ្ជមានសម្រាប់អ្នកទស្សនា** : ផែនការគ្រប់គ្រងទេសចរណ៍ ស្នើឲ្យមានការពង្រឹងគុណភាពនៃបទពិសោធសម្រាប់ភ្ញៀវទេសចរគ្រប់គ្នាជាអតិបរមា តាមរយៈការផ្តល់ឱកាសផ្សេងគ្នាសម្រាប់អ្នកទស្សនា ព្រោះថាអ្នកទស្សនាខុសគ្នាមានក្តីរំពឹងទុកនិងតម្រូវការផ្សេងគ្នា។ ដូច្នេះដើម្បីឲ្យភ្ញៀវទេសចរមានឱកាសសប្បាយរីករាយនឹងសម្បត្តិបេតិកភណ្ឌវប្បធម៌និងធម្មជាតិនៅតំបន់អង្គរ យើងត្រូវរៀបចំបង្កើតគោលដៅទស្សនាថ្មីៗ សកម្មភាពនានា ក៏ដូចជាផ្លូវទស្សនាប្លែកៗ (នៅក្នុងឧទ្យានបេតិកភណ្ឌពិភពលោកនៃតំបន់អង្គរ ក្រុងសៀមរាប និងតំបន់ជុំវិញដូចជា តំបន់ចុងឃ្នាសឬកោះកែរ)។ ផែនការនេះក៏តម្រូវឲ្យមានការវាស់ស្ទង់មតិស្តីពីការពេញចិត្តរបស់អ្នកទស្សនា តាមរយៈការបង្កើនគុណភាពសេវាកម្មនៅអង្គរផងដែរ។
- **កាត់បន្ថយផលប៉ះពាល់ដល់រមណីយដ្ឋាន** : ផែនការគ្រប់គ្រងទេសចរណ៍ សំដៅលុបបំបាត់ បង្កា ឬកាត់បន្ថយផលប៉ះពាល់ពីទេសចរណ៍ តាមរយៈការបែងចែកឲ្យមានការទស្សនានៅតាមគោលដៅផ្សេងៗ ការអប់រំអ្នកទស្សនា ការគ្រប់គ្រងលំហូរអ្នកទស្សនា និងបង្កើនការដាក់ស្លាកសញ្ញា និងការបកស្រាយព័ត៌មាន។ ការផ្តួចផ្តើមទាំងនេះនឹងផ្លាស់ប្តូរអាកប្បកិរិយានិងទស្សនៈរបស់អ្នកទស្សនា ព្រមទាំងបែងចែកអ្នកទស្សនា ដូច្នេះវានឹងកាត់បន្ថយផលប៉ះពាល់លើប្រាសាទសំខាន់ៗ។
- **ភាពជាដៃគូជាមួយឧស្សាហកម្មទេសចរណ៍** : ការសិក្សាផែនការគ្រប់គ្រងទេសចរណ៍បង្ហាញថា ទេសចរណ៍នៅអង្គរទាមទារឲ្យមានភាពជាដៃគូសហការជាមួយនឹងឧស្សាហកម្មទេសចរណ៍ និងការប្រាស្រ័យទាក់ទងគ្នាជាទៀងទាត់ ដើម្បីជាការលើកទឹកចិត្តដល់ប្រតិបត្តិករនានា និងដើម្បីផ្លាស់ប្តូរប្រព័ន្ធនិងផលិតផលដែលមានស្រាប់ទៅតាមវិធី

សាស្ត្រដែលអាចបង្កើនបទពិសោធនានា កាត់បន្ថយការប៉ះពាល់ទៅលើរមណីយដ្ឋាន និងផ្តល់ផលប្រយោជន៍ដល់ប្រជាជនក្នុងតំបន់។

- **ការផ្តល់ផលប្រយោជន៍ដល់ប្រជាជនក្នុងតំបន់** ៖ ផែនការគ្រប់គ្រងទេសចរណ៍ជំរុញឲ្យប្រជាជនក្នុងតំបន់ចូលរួមកាន់តែច្រើនក្នុងប្រតិបត្តិការវិស័យទេសចរណ៍ ដើម្បីផ្តល់ផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចដោយផ្ទាល់ និងកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ។ ដំណើរការពិគ្រោះយោបល់នឹងជំរុញឲ្យមានការទទួលស្គាល់និងគាំទ្រការប្រតិបត្តិជំនឿវប្បធម៌ និងប្រពៃណីរបស់ប្រជាជនក្នុងតំបន់និងភ្ញៀវទេសចរ។ ប្រជាជនក្នុងតំបន់ត្រូវការជំនួយក្នុងការអភិវឌ្ឍន៍ការផលិតនិងការលក់ផលិតផលក្នុងស្រុកទៅដល់អ្នកទស្សនាដោយផ្ទាល់ (សកម្មភាព សិប្បកម្ម)។
- **អភិបាលកិច្ចល្អ** ៖ ផែនការគ្រប់គ្រងទេសចរណ៍ទទួលស្គាល់ថា ដើម្បីឲ្យស៊ីចង្វាក់នឹងវិធានទី៨ នៃវិធានទាំងឡាយស្តីពីការគ្រប់គ្រងទេសចរណ៍ប្រកបដោយចីរភាព នៅតំបន់បេតិកភណ្ឌពិភពលោក រាជរដ្ឋាភិបាលកម្ពុជាត្រូវធានាថា រចនាសម្ព័ន្ធស្ថាប័ននិងធនធានដែលមាន ឆ្លុះបញ្ចាំងពីតម្រូវការក្នុងការគ្រប់គ្រងទេសចរណ៍ប្រកបដោយប្រសិទ្ធភាព ដោយរួមបញ្ចូលទាំងការអនុវត្តផែនការគ្រប់គ្រងទេសចរណ៍ផងដែរ។
- **ការចូលរួមពីអ្នកពាក់ព័ន្ធ** ៖ ផែនការគ្រប់គ្រងទេសចរណ៍ បើកចំហឲ្យមានការចូលរួមស្វែងយល់ក្នុងការគ្រប់គ្រងទេសចរណ៍នៅតំបន់អង្គរ តាមរយៈការប្រាស្រ័យទាក់ទងគ្នាជាទៀងទាត់ ការពិគ្រោះយោបល់ និងកិច្ចសហការរវាងរាជរដ្ឋាភិបាល ឧស្សាហកម្មទេសចរណ៍ អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ក្នុងតំបន់។




## ការផ្តួចផ្តើមចម្បង

ការផ្តល់អនុសាសន៍ជាក់លាក់លើសកម្មភាព នៅក្នុងការផ្តួចផ្តើមទាំងអស់នេះ គឺជាសំណើក្នុងការផ្លាស់ប្តូរដ៏សំខាន់ដែលតម្រូវឲ្យមានការគាំទ្រ និងការចូលរួមពីរាជរដ្ឋាភិបាល និងឧស្សាហកម្មទេសចរណ៍។ ដូច្នេះ TMP សង្កត់ធ្ងន់លើតម្រូវការក្នុងការប្រាស្រ័យទាក់ទងនិងកិច្ចសហការជានិរន្តរ៍។ TMP ផ្តល់អនុសាសន៍ឲ្យមានការជជែកដេញដោលលើកម្មវិធីដែលបានដាក់ចេញដោយអាជ្ញាធរអប្សរានិងក្រសួងទេសចរណ៍ រួមទាំងការផ្តួចផ្តើមចម្បងផ្សេងៗទៀតតាមផ្នែកនានាដូចខាងក្រោម៖

ក. **គ្រប់គ្រងប្រាសាទដោយរួមបញ្ចូលគ្រប់ផ្នែកពាក់ព័ន្ធ** : បញ្ហានិងការប្រឈមជាច្រើននៅអង្គរ ទាក់ទងនឹងប្រតិបត្តិការប្រចាំថ្ងៃនៅប្រាសាទសំខាន់ៗមួយចំនួន។ មានឱកាសធ្វើឲ្យការគ្រប់គ្រងនៅតាមប្រាសាទមានលក្ខណៈប្រសើរឡើង តាមរយៈការប្រើប្រាស់ធនធានដែលមានស្រាប់ ដូច្នេះយើងនឹងអាចមានវិធីសាស្ត្រឆ្លើយតបទៅនឹងតម្រូវការដ៏ប្រសើរណាមួយ នៅក្នុងកាលៈទេសៈផ្សេងគ្នា និងនៅតាមប្រាសាទផ្សេងគ្នា។ ការតែងតាំងអ្នកគ្រប់គ្រងនៅតាមប្រាសាទសំខាន់ៗមួយចំនួន គឺជាសមាសភាពមួយដ៏សំខាន់នៃការផ្តួចផ្តើមនេះ។

ខ. **ការគ្រប់គ្រងលំហូរអ្នកទស្សនា** : បច្ចុប្បន្ន មានព័ត៌មានតិចតួចណាស់ទាក់ទងនឹងទីកន្លែងដែលអ្នកទស្សនាអង្គរអាចទៅបាន ហើយអ្វីខ្លះដែលពួកគាត់អាចធ្វើបាន។ កំណើនចំនួនអ្នកទស្សនាយ៉ាងលឿន ធ្វើឲ្យវិធីសាស្ត្រនេះគ្មាននិរន្តរភាព ដូច្នេះរាជរដ្ឋាភិបាល និងឧស្សាហកម្មទេសចរណ៍ត្រូវទទួលស្គាល់តម្រូវការក្នុងការកំណត់ចំនួនភ្ញៀវ និងគ្រប់គ្រងលំហូរអ្នកទស្សនាឲ្យបានកាន់តែសកម្មឡើង។

គ. **ប្រព័ន្ធដឹកជញ្ជូន** : ដើម្បីគ្រប់គ្រងលំហូរអ្នកទស្សនានៅឧទ្យានអង្គរ ចាំបាច់ត្រូវមានប្រព័ន្ធដឹកជញ្ជូនដ៏សមស្របមួយ។ ដើម្បីរៀបចំនិងអនុវត្តប្រព័ន្ធដឹកជញ្ជូនមួយបែបនេះបាន គួរមានការពិគ្រោះយោបល់គ្នាជាមួយនឹងផ្នែកឧស្សាហកម្មទេសចរណ៍ជាមុនសិន។ ប្រព័ន្ធនេះត្រូវគិតបញ្ចូលទាំងការប្រើប្រាស់ផ្លូវសម្រាប់យានយន្ត និងផ្លូវមិនមានយានយន្ត មធ្យោបាយដឹកជញ្ជូន ទិសដៅលំហូរទេសចរ និងចំនួនភ្ញៀវទេសចរ។ ទិសដៅនាពេលអនាគតគឺបញ្ឈប់រថយន្តក្រុងនិងយានជំនិះធុនធំដោយផ្តើមចេញពីឧទ្យានអង្គរ ប៉ុន្តែក្នុងរយៈពេលខ្លីត្រូវបញ្ឈប់រថយន្តទាំងនេះនៅក្នុងបរិវេណអង្គរធំជាមុនសិន។

ឃ. **ការតម្រង់ទិសអ្នកទស្សនា** : ការគ្រប់គ្រងភ្ញៀវទេសចរនៅអង្គរ ចាំបាច់ត្រូវមានការតម្រង់ទិសអ្នកទស្សនាជាមុនសិន។ ការតម្រង់ទិសបែបនេះអាចជាសេចក្តីណែនាំអំពីអាកប្បកិរិយាសមរម្យក្នុងអំឡុងពេលទស្សនា និងជាព័ត៌មានមូលដ្ឋានស្តីពីប្រវត្តិ

និងសារៈសំខាន់នៃទីតាំងបេតិកភណ្ឌពិភពលោកអង្គរ ក៏ដូចជាជម្រើសវង់ទស្សនាតាមប្រធានបទនានានិងការណែនាំពីក្រុមសម្រាប់អ្នកទស្សនាអង្គរផងដែរ។

**ង. បទពិសោធនិងសេវាកម្មសម្រាប់អ្នកទស្សនា** : តាមយោបល់របស់ភាគីពាក់ព័ន្ធក្នុងវិស័យទេសចរណ៍ មានឱកាសជាច្រើនក្នុងការធ្វើឲ្យប្រសើរឡើងនូវបទពិសោធរបស់អ្នកទស្សនានៅអង្គរ។ ជាយុទ្ធសាស្ត្រ ត្រូវរៀបចំកែលម្អសម្ភារៈរូបវន្តដែលមានស្រាប់នៅឧទ្យានអង្គរឲ្យប្រសើរឡើង ដូចជាបន្ទប់ទឹក ហាងលក់អាហារនិងភេសជ្ជៈ។

**ច. ការបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍** : កិត្តិសព្ទរបស់អង្គរនិងចំនួនអ្នកទស្សនានាពេលបច្ចុប្បន្ន តម្រូវឲ្យមានការយកចិត្តទុកដាក់ជាបន្ទាន់លើស្តង់ដាមគ្គុទ្ទេសក៍ និងវិធីសាស្ត្រសហការរវាងសមាគមន៍មគ្គុទ្ទេសក៍ ឧស្សាហាកម្មទេសចរណ៍ និងរាជរដ្ឋាភិបាល។ ចំណុចសំខាន់ក្នុងការពង្រឹងគុណភាពមគ្គុទ្ទេសក៍ គឺអាជ្ញាធរអប្សរា ត្រូវធ្វើការបណ្តុះបណ្តាលមគ្គុទ្ទេសក៍ដែលមានស្រាប់ឡើងវិញ។

**ឆ. សិប្បកម្មក្នុងតំបន់** : ឱកាសមួយក្នុងចំណោមឱកាសជាច្រើនសម្រាប់ប្រជាជនក្នុងតំបន់ទទួលផលប្រយោជន៍សេដ្ឋកិច្ចពីវិស័យទេសចរណ៍នៅអង្គរ គឺការផលិតនិងការលក់ដូរសម្ភារៈសិប្បកម្មក្នុងតំបន់។ ជាទូទៅភ្ញៀវទេសចរចាប់អារម្មណ៍និងពេញចិត្តទិញផលិតផលក្នុងតំបន់ជាងផលិតផលពីរោងចក្រ។ រដ្ឋាភិបាលនិងឧស្សាហាកម្មទេសចរណ៍អាចផ្តល់ការបណ្តុះបណ្តាលនិងឱកាសដល់សិប្បករក្នុងតំបន់ លក់ដូរផលិតផលរបស់ពួកគាត់។

**ជ. ការលក់សំបុត្រ** : ដំណើរការលក់សំបុត្រនៅអង្គរមិនបានដើរស្របនឹងកំណើនទីផ្សារទេសចរណ៍ បច្ចេកវិទ្យាទំនើប និងគំរូលក់សំបុត្រនៅតាមតំបន់បេតិកភណ្ឌពិភពលោកដទៃទៀតនោះទេ។ បច្ចុប្បន្ន ការលក់សំបុត្រនៅតំបន់អង្គរ មិនបានឆ្លុះបញ្ចាំងពីតម្រូវការទីផ្សារនិងកាត់បន្ថយផលប៉ះពាល់លើប្រាសាទ និងធ្វើឲ្យបទពិសោធអ្នកទស្សនានៅទីតាំងប្រាសាទសំខាន់ៗបានប្រសើរឡើងនោះទេ។ តម្លៃសំបុត្រ គឺជាឧបករណ៍ដ៏មានសក្តានុពលក្នុងការផ្លាស់ប្តូរអាកប្បកិរិយាអ្នកទស្សនា។

**ឈ. ទំនាក់ទំនងនិងការប្រាស្រ័យទាក់ទងជាមួយឧស្សាហាកម្មទេសចរណ៍** : ភាពជាដៃគូក្នុងវិស័យទេសចរណ៍នៅអង្គរ មិនអាចកើតឡើងដោយគ្មានកិច្ចសហការរវាងឧស្សាហាកម្មទេសចរណ៍ និងរាជរដ្ឋាភិបាលបានឡើយ។ ឧស្សាហាកម្មទេសចរណ៍មានបំណងចូលរួមស្វែងយល់ជាមួយនឹងរដ្ឋាភិបាលដើម្បីសិក្សាបន្ថែម ផ្តល់យោបល់ និងក្តាប់ឱកាសក្នុងការវិនិយោគលើផលិតផលទេសចរណ៍ថ្មីៗនៅអង្គរ។ ដើម្បីឲ្យកិច្ចសហការប្រកបដោយជោគជ័យ ត្រូវមានវិធីសាស្ត្រសហការថ្មី ឆន្ទៈរបស់រាជរដ្ឋាភិបាល និងការកែលម្អ

ទំនាក់ទំនងជាមួយគ្នា។ ដូច្នេះការបង្កើតឲ្យមានក្រុមពិគ្រោះយោបល់ឧស្សាហកម្មទេសចរណ៍គឺមានសារៈសំខាន់ជាទីបំផុត។

ញ. **សៀមរាប ទន្លេសាប និងភ្នំគូលែន :** តំបន់បេតិកភណ្ឌពិភពលោកអង្គរ គឺជាធាតុស្នូលដែលមានទិដ្ឋភាពវប្បធម៌ទូលំទូលាយមួយ ដោយក្តោបបញ្ចូលទាំងក្រុងសៀមរាប ទន្លេសាប និងភ្នំគូលែន ហើយគ្រប់ផ្នែកទាំងអស់ជាចំណែកនៃបណ្តុំរូបវន្ត និងវប្បធម៌សម្រាប់ទេសចរណ៍នៅអង្គរ។ ដូច្នេះ ត្រូវយកចិត្តទុកដាក់លើការគ្រប់គ្រងទេសចរណ៍ និងធ្វើសមាហរណកម្មការអភិរក្ស និងទេសចរណ៍នៅតំបន់អង្គរ និងនៅតាមទីតាំងទាំងបីខាងលើ។

ដ. **ការត្រួតពិនិត្យវឌ្ឍនភាពដោយ ICC-Angkor:** ការអនុវត្តផែនការគ្រប់គ្រងទេសចរណ៍ គឺជាមូលដ្ឋានអភិរក្ស និងគ្រប់គ្រងតំបន់បេតិកភណ្ឌពិភពលោកអង្គរសម្រាប់រយៈពេលវែង។ អាជ្ញាធរអប្សរាគួរផ្តល់នូវរបាយការណ៍លម្អិតស្តីពីវឌ្ឍនភាពនិងសមិទ្ធផលជាក់លាក់នៃការអនុវត្ត"សកម្មភាពអាទិភាព" ដែលមានចែងនៅក្នុង TMP ទៅកាន់កិច្ចប្រជុំបច្ចេកទេសរបស់ ICC-Angkor។ អាជ្ញាធរអប្សរានិងICC-Angkor គួរតែសហការពិនិត្យ និងសម្រេចលើ "សកម្មភាពអាទិភាព" ដែលមានចែងនៅក្នុងឯកសារ TMP ឡើងវិញនៅចន្លោះពេលមិនតិចជាង៥ឆ្នាំ។




## សកម្មភាពអាទិភាព

យើងដឹងយ៉ាងច្បាស់ថា ការអនុវត្ត TMP ជាដំណើរការដែលនឹងធ្វើបន្តិចម្តងៗនិងជាបន្តបន្ទាប់។ ការផ្តួចផ្តើមគំនិតមួយចំនួន មានភាពស្មុគស្មាញ និងត្រូវការពេលវេលាដឹកនាំច្រើន ដើម្បីដាក់ផែនការនិងអនុវត្តឲ្យបានពេញលេញ។ ផ្ទុយមកវិញ នៅក្នុងរយៈពេលខ្លី

យើងក៏អាចសម្រេចបានលទ្ធផលដ៏ល្អប្រសើរផងដែរ ។ ដូច្នេះ TMP ជាឧបករណ៍ជំនួយក្នុងការកែលម្អការអនុវត្តនៅក្នុងតំបន់អង្គរឲ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន តាមរយៈការផ្តល់អនុសាសន៍លើ "សកម្មភាពអាទិភាព" បន្ទាប់ពីរាជរដ្ឋាភិបាលឯកភាព និងផ្តល់នូវធនធានចាំបាច់។

១- អាជ្ញាធរអប្សរា ក្រសួងទេសចរណ៍ និងអាជ្ញាធរខេត្តសៀមរាបគួរតែផ្តល់អាទិភាពខ្ពស់ក្នុងការតែងតាំងបុគ្គលិកទទួលខុសត្រូវអនុវត្ត TMP និងធានាថាបុគ្គលិកនោះអាចលះបង់ពេលវេលានិងទទួលបានធនធានចាំបាច់

ក. អាជ្ញាធរអប្សរា គួរតែតែងតាំងមន្រ្តីជាន់ខ្ពស់០១រូប ឲ្យទទួលខុសត្រូវក្នុងការគ្រប់គ្រងទេសចរណ៍នៅអង្គរ ដោយអនុលោមទៅតាមTMP។

ខ. ក្រសួងទេសចរណ៍គួរតែតែងតាំងមន្រ្តី០១រូប ឲ្យទទួលខុសត្រូវក្នុងការអនុវត្ត TMP ដែលទាក់ទងនឹងក្រសួងទេសចរណ៍។

គ. អភិបាលខេត្តសៀមរាប គួរតែតែងតាំងមន្រ្តី១រូប ឲ្យទទួលខុសត្រូវក្នុងការអនុវត្ត TMP ដែលទាក់ទងនឹងអាជ្ញាធរខេត្តសៀមរាប។

ឃ. គួរតែផ្តល់តួនាទីនិងទំនួលខុសត្រូវជាក់លាក់ក្នុងការអនុវត្ត TMP ដល់បុគ្គលិកអាជ្ញាធរអប្សរាទូទាំងអង្គភាព ។

២- អាជ្ញាធរអប្សរាគួរតែកំណត់វិធីសាស្រ្ត រៀបចំផែនការការងារលម្អិត និងរៀបចំគណៈកម្មការសិក្សា"សមត្ថភាពផ្ទុក" សម្រាប់តំបន់បេតិកភណ្ឌពិភពលោកអង្គរ និងប្រាសាទសំខាន់ៗផ្សេងទៀតឲ្យបានជាបន្ទាន់។ វិធីសាស្រ្តនិងផែនការការងារនេះគួរតែផ្អែកលើព័ត៌មានស្តីពីការអនុវត្តល្អបំផុតនៅតំបន់បេតិកភណ្ឌពិភពលោកដទៃទៀត និង "ផែនទីហានិភ័យ" ដែលជាផ្នែកមួយនៃគម្រោងHMF។ យើងអាចស្វែងរកម្ចាស់ជំនួយអន្តរជាតិដែលសមស្របណាមួយ ដើម្បីស្នើសុំថវិកាសម្រាប់ការសិក្សានេះ។

៣- ប្រតិបត្តិការប្រចាំថ្ងៃនៅប្រាសាទសំខាន់ៗ ដែលមានភ្ញៀវទេសចរច្រើន(ដូចជាអង្គរវត្ត បាយ័ន តាព្រហ្ម ភ្នំបាខែង អង្គរធំ បេងមាលា និងបន្ទាយស្រី) គួរតែអនុវត្តតាមការគ្រប់គ្រងដោយរួមបញ្ចូលគ្រប់ផ្នែកពាក់ព័ន្ធ ហើយអ្នកគ្រប់គ្រងប្រាសាទនីមួយៗ គួរតែ

មានសិទ្ធិក្នុងការសម្រេចចិត្ត និងដឹកនាំបុគ្គលិកប្រចាំការនៅទីនោះ។ អ្នកគ្រប់គ្រងប្រាសាទ ត្រូវទទួលបានការបណ្តុះបណ្តាលលើផ្នែកគ្រប់គ្រងរមណីយដ្ឋាន និងមានជំនួយពី "សៀវភៅណែនាំសម្រាប់អ្នកគ្រប់គ្រងរមណីយដ្ឋាន"។ គ្រប់បុគ្គលិកទាំងអស់នៅតាមប្រាសាទនានា គួរតែជាផ្នែកមួយនៃការគ្រប់គ្រង ដែលទទួលបានការបណ្តុះបណ្តាលសមស្រប និងអាចរួមចំណែកគ្រប់គ្រងប្រាសាទតាមការចង់បាន។ គួរតែអនុវត្តប្រព័ន្ធនេះទៅតាមដំណាក់កាល ដោយចាប់ផ្តើមពីប្រាសាទបេងមាលា មុននឹងជ្រើសរើសយកប្រាសាទណាមួយនៅក្នុងឧទ្យានអង្គរមកអនុវត្តក្នុងជំហានបន្ទាប់។

៤- គួររៀបចំ "ប្រព័ន្ធចាត់ថ្នាក់ប្រាសាទ" ដោយប្រើប្រាស់លទ្ធផលពី "ការសិក្សាសមត្ថភាពផ្ទុក" ក៏ដូចជាការផ្តល់គំនិតពិគ្រោះយោបល់ និងកិច្ចសហការដែលបានមកពីឧស្សាហកម្មទេសចរណ៍និងអាជ្ញាធរអប្សរា។ ប្រព័ន្ធចាត់ថ្នាក់ប្រាសាទគួរតែអាចជួយឲ្យរកឃើញនូវបំណែកទីផ្សារទេសចរណ៍ផ្សេងគ្នា និងអាចបែងចែកប្រាសាទទៅតាមបទពិសោធទាក់ទងនឹងបំណែកទីផ្សារទាំងនោះ។

៥- អាជ្ញាធរអប្សរា គួរតែចាប់ផ្តើមរៀបចំឯកសារ ស្រាវជ្រាវ និងវិភាគ ដើម្បីរៀបចំប្រព័ន្ធដឹកជញ្ជូនថ្មីសម្រាប់ឧទ្យានអង្គរ។ ប្រព័ន្ធនេះគួរតែគិតបញ្ចូលទាំងផ្លូវសម្រាប់យានយន្ត និងផ្លូវគ្មានយានយន្ត មធ្យោបាយដឹកជញ្ជូន ទិសដៅលំហូរទេសចរ ការធ្វើដំណើរ និងការហាមឃាត់នានា។ ប្រព័ន្ធនេះគួរតែសំដៅកាត់បន្ថយការប្រើប្រាស់រថយន្តធុនធំនាពេលអនាគត និងផ្តោតលើការដឹកជញ្ជូនធុនតូច តាមបែបប្រពៃណី។

៦- អាជ្ញាធរអប្សរាគួរតែរៀបចំផែនការថ្មី ក្នុងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធសេវាកម្មទេសចរណ៍ ដោយផ្តោតជាពិសេសលើចំណតរថយន្ត បន្ទប់ទឹក និងហាងលក់ម្ហូបអាហារនិងភេសជ្ជៈ។

៧- អាជ្ញាធរអប្សរាគួរតែរៀបចំកម្មវិធី "បណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍ឡើងវិញ" ទាក់ទងនឹងព័ត៌មានតម្រង់ទិសអ្នកទស្សនា ក្រុមអ្នកទស្សនានៅអង្គរ ព័ត៌មានថ្មីអំពីប្រវត្តិសាស្ត្រ និងសារៈសំខាន់នៃបេតិកភណ្ឌពិភពលោកអង្គរឲ្យបានត្រឹមត្រូវ។ ការ

បណ្តុះបណ្តាលនេះគួរតែផ្អែកលើវិធីសាស្ត្រសហការគ្នារវាងសមាគមមគ្គុទ្ទេសក៍ឧស្សាហកម្មទេសចរណ៍និងរាជរដ្ឋាភិបាល។

៨- គួររៀបចំក្រមប្រតិបត្តិសម្រាប់អ្នកទស្សនា មគ្គុទ្ទេសក៍ និងប្រតិបត្តិករក្នុងឧស្សាហកម្មទេសចរណ៍ជាអាទិភាពដំបូងបំផុតក្នុងការរៀបចំក្រមអ្នកទស្សនានៅអង្គរ។ ត្រូវផ្សព្វផ្សាយក្រមនេះឲ្យបានទូលំទូលាយ ហើយជាទូទៅគួររៀបចំជាច្រើនភាសា និងមានលក្ខណៈច្នៃប្រឌិតថ្មី ដើម្បីធានាការប្រាស្រ័យទាក់ទងយ៉ាងល្អនៅក្នុងវិស័យទេសចរណ៍នៅអង្គរ។ គួរតែប្រើប្រាស់បទបញ្ញាក្នុងការទស្សនាដែលមានស្រាប់ ជាចំណុចចាប់ផ្តើមក្នុងការរៀបចំក្រមទាំងនេះ។

៩- ដើម្បីធានាភាពជាដៃគូប្រកបដោយប្រសិទ្ធភាពរវាងភ្នាក់ងារឯកជននិងរាជរដ្ឋាភិបាលកម្ពុជា គួរកោះប្រជុំក្រុមពិគ្រោះយោបល់ឧស្សាហកម្មទេសចរណ៍ដែលរួមមានតំណាងមកពីឧស្សាហកម្មទេសចរណ៍ និងស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធ រៀងរាល់បីខែម្តងដើម្បីរកឲ្យឃើញនិងពិភាក្សាពីគំនិតផ្តួចផ្តើម បញ្ហា និងឱកាសនានា។

១០- អាជ្ញាធរអប្សរា ក្រសួងទេសចរណ៍ អាជ្ញាធរខេត្តសៀមរាប និងសមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា (CATA) សមាគមដឹកជញ្ជូនភ្ញៀវទេសចរ សមាគមមគ្គុទ្ទេសក៍ និងទីភ្នាក់ងារផ្តល់សេវាកម្មទេសចរណ៍ដទៃទៀត គួរតែរៀបចំប្រជុំពង្រឹងទំនាក់ទំនងក្នុងតំបន់ឲ្យបានទៀងទាត់។

១១- អាជ្ញាធរអប្សរា គួរតែងតាំងមន្ត្រីសម្របសម្រួលទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍ម្នាក់(ឬមន្ត្រីច្រើននាក់) ដែលជាបុគ្គលដែលអាចទំនាក់ទំនងនិងជាអ្នកដោះស្រាយបញ្ហាជាមួយឧស្សាហកម្មទេសចរណ៍។

១២- មន្ត្រីសម្រួលទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍របស់អាជ្ញាធរអប្សរា គួរមានលេខទូរស័ព្ទ "ខ្សែពិសេស" ជាជំនួយសម្រាប់ឲ្យអ្នកទស្សនា ឬប្រតិបត្តិករអាចហៅនៅពេលដែលត្រូវការជំនួយ។

១៣- គួរដាក់បញ្ចូលព័ត៌មានថ្មីៗក្នុងគេហៈទំព័រផ្លូវការរបស់អាជ្ញាធរអប្សរា និងតែងតាំងអ្នកបញ្ចូលទិន្នន័យក្នុងអ៊ីនធឺណិតជាអចិន្ត្រៃយ៍ម្នាក់ ដែលមានទាំងសម្ភារៈនិងសិទ្ធិក្នុងការបញ្ចូលព័ត៌មានក្នុងគេហៈទំព័រនេះ។ អ្នកត្រួតពិនិត្យនិងបញ្ចូលទិន្នន័យក្នុងគេហៈទំព័រអាជ្ញាធរអប្សរា ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់របស់អគ្គនាយកអាជ្ញាធរអប្សរា និងអាចទទួលបានសម្ភារៈចាំបាច់ក្នុងការធ្វើបច្ចុប្បន្នកម្ម និងគ្រប់គ្រងគេហៈទំព័រ។ អ្នកបញ្ចូលទិន្នន័យ គួរតែផ្ញើព័ត៌មានអេឡិចត្រូនិចថ្មីប្រចាំខែជាទៀងទាត់ដល់ឧស្សាហកម្មទេសចរណ៍។ អគ្គនាយកគួរអនុញ្ញាតឲ្យអ្នកបញ្ចូលទិន្នន័យក្នុងគេហៈទំព័រប្រមូលព័ត៌មានពីប្រភពផ្សេងៗនិងចែកចាយព័ត៌មានដែលចាំបាច់។

១៤- រដ្ឋាភិបាលគួរតែមានផែនការបម្រុងទុកជាមុនក្នុងការផ្តួចផ្តើមគំនិតដើម្បីជួយសម្រួលដល់ការផលិតនិងការលក់ផលិតផលសិប្បកម្មរបស់ប្រជាជនក្នុងតំបន់ ដោយផ្ទាល់ទៅដល់ភ្ញៀវទេសចរនៅអង្គរ។ អាជ្ញាធរអប្សរា រាជរដ្ឋាភិបាល និងវិស័យឯកជនដទៃទៀតគួរតែគាំទ្រយ៉ាងសកម្មចំពោះដំណើរការនេះ តាមរយៈការផ្តល់វិញ្ញាបនបត្រសមាគមសិប្បកម្មអង្គរ និងតាមរយៈការបណ្តុះបណ្តាលសិប្បករនៅក្នុងតំបន់។

១៥- អាជ្ញាធរអប្សរា គួរតែបង្កើត "ផ្សារលក់ផលិតផលសិប្បកម្មក្នុងតំបន់" នៅទីតាំងកណ្តាលណាមួយក្នុងឧទ្យានអង្គរ ដែលមានតែប្រជាជនក្នុងតំបន់ប៉ុណ្ណោះដែលអាចចូលទៅលក់ដូរ និងធានាបាននូវផលិតផលសុទ្ធក្នុងស្រុកដល់ភ្ញៀវទេសចរ។ គួរពិចារណាលើការ "កំណត់តម្លៃជាក់លាក់" ចំពោះគ្រប់ផលិតផលដែលដាក់លក់នៅក្នុងផ្សារនេះ។

១៦- អាជ្ញាធរអប្សរានិងអាជ្ញាធរខេត្តសៀមរាបគួរតែសហការគ្នាក្នុងការអភិរក្ស និងបង្ហាញពីបេតិកភណ្ឌវប្បធម៌ក្រុងសៀមរាប ដែលជាផ្នែកមួយនៃបទពិសោធរបស់អ្នកទស្សនាអង្គរផងដែរ។ ការគ្រប់គ្រងនេះគួរតែរួមបញ្ចូលទាំងការអភិរក្សនិងការបកស្រាយពីទម្រង់វប្បធម៌ ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងការកែលម្អសម្ភារៈរូបវន្ត ដើម្បីធានាថាខេត្តសៀមរាបមិនរងការគំរាមកំហែងពីទឹកជំនន់ ផ្តល់នូវសេវាដល់ភ្ញៀវទេសចរសំខាន់ៗ (ដូចជាចំណត) និងបង្ហាញពីឱកាសដ៏គួរឲ្យទាក់ទាញសម្រាប់ភ្ញៀវទេសចរ។

១៧- ដោយបានទទួលស្គាល់ថាការផ្សារភ្ជាប់រវាងភ្នំគូលែននិងអង្គរមានសារៈសំខាន់ រាជរដ្ឋាភិបាលកម្ពុជាគួរតែរៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្រក្នុងការបញ្ឈប់ការកាប់បំផ្លាញព្រៃឈើ ការបង្កើតឲ្យមានការដាំដើមឈើឡើងវិញ ការការពាររមណីយដ្ឋានប្រវត្តិសាស្ត្រនិងការការពារបរិស្ថានភ្នំគូលែន។

## លទ្ធផលរំពឹងទុក

ការផ្តួចផ្តើមគោលនយោបាយគន្លឹះ ការផ្តួចផ្តើមចម្បង និងសកម្មភាពអាទិភាពដែលពណ៌នាខាងលើ បានផ្តល់នូវវិធីសាស្ត្រជាមូលដ្ឋាន ដើម្បីគ្រប់គ្រងទេសចរណ៍នៅអង្គរ។ ការយកចិត្តទុកដាក់ និងការអនុវត្តមួយចំនួនពិតជាសំខាន់ណាស់ក្នុងការទទួលបានភាពជោគជ័យក្នុងការអនុវត្តTMP និងការគ្រប់គ្រងវិស័យទេសចរណ៍នៅអង្គរប្រកបដោយនិរន្តរភាព។ បញ្ហាទាំងនេះមានភាពស្មុគស្មាញ និងតម្រូវឲ្យមានការចូលរួមស្វែងយល់ពីមន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាលនិងអ្នកពាក់ព័ន្ធ ក៏ដូចជាអ្នកមានជំនាញក្នុងការដោះស្រាយបញ្ហា និងការផ្លាស់ប្តូរលើការអនុវត្តនាពេលបច្ចុប្បន្ន។

ការគ្រប់គ្រងបេតិកភណ្ឌនៅអង្គរ តម្រូវឲ្យមានការគ្រប់គ្រងវិស័យទេសចរណ៍ ដើម្បីវាយតម្លៃហានិភ័យ អភិរក្សគុណតម្លៃបេតិកភណ្ឌរូបីនិងអរូបី បង្កើនបទពិសោធអ្នកទស្សនា និងរៀបចំមគ្គុទ្ទេសក៍ទេសចរណ៍ឲ្យមានភាពថ្លៃថ្នូរ ផ្តល់ឱកាសនិងអត្ថប្រយោជន៍សម្រាប់ឧស្សាហកម្មទេសចរណ៍និងប្រជាជនកម្ពុជារាប់ពាន់នាក់ ព្រោះអង្គរគឺជាកន្លែងដ៏ពិសិដ្ឋមួយសម្រាប់ពួកគាត់ ជាលំនៅឋានដ៏ពិសេសនិងជានិមិត្តរូបដ៏អស្ចារ្យរបស់ជាតិ។



# លំនាំដើម

ផែនការគ្រប់គ្រងទេសចរណ៍ (TMP) ត្រូវបានរៀបចំឡើងតាមសំណើរបស់អាជ្ញាធរអប្សរា ស្របនឹងសេចក្តីសម្រេចនៃគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារនិងអភិវឌ្ឍរមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ (ICC-Angkor)។

TMP ជាឧបករណ៍ដ៏សំខាន់មួយនៅក្នុងគម្រោងក្របខ័ណ្ឌគ្រប់គ្រងបេតិកភណ្ឌអង្គរ (HMF)ដែលជាគម្រោងសហប្រតិបត្តិការ ក្នុងគោលបំណងផ្តល់នូវគោលនយោបាយនិងផែនការយុទ្ធសាស្ត្រសម្រាប់កិច្ចការពារគុណតម្លៃបេតិកភណ្ឌវប្បធម៌និងធម្មជាតិ។ គម្រោង HMF ផ្តល់នូវគោលនយោបាយដ៏សំខាន់ និងការផ្តួចផ្តើមគំនិតដែលមានលំដាប់លំដោយផ្តោតទៅលើ "ការអភិវឌ្ឍន៍ទេសចរណ៍ប្រកបដោយទំនួលខុសត្រូវ"។ TMP នឹងផ្តល់នូវមធ្យោបាយក្នុងការសម្រេចនូវគោលបំណងទាំងនេះ។

TMP បានទទួលស្គាល់និងដាក់បញ្ចូលការងារដែលអាជ្ញាធរអប្សរាកំពុងអនុវត្តដូចជាការផ្តួចផ្តើមគំនិតក្នុងការគ្រប់គ្រងវិស័យទេសចរណ៍ ការកំណត់បញ្ហា ការស្រង់មតិពីឧស្សាហកម្មទេសចរណ៍និងអ្នកទស្សនា ក៏ដូចជាការផ្តួចផ្តើមគំនិតរបស់ក្រសួងទេសចរណ៍។ TMP មានលក្ខណៈកាន់តែប្រសើរឡើង ដោយមានការស្រាវជ្រាវបន្ថែម ការត្រួតពិនិត្យដល់ទីកន្លែង ការពិគ្រោះយោបល់ជាមួយអ្នកចូលរួមពីផ្នែកឧស្សាហកម្មទេសចរណ៍ និងអ្នកតំណាងសហគមន៍ ក៏ដូចជាការរៀបចំសិក្ខាសាលាដែលមានការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធជាច្រើន។ ការគ្រប់គ្រងវិស័យទេសចរណ៍នៅអង្គរ ទាមទារឲ្យមានភាពជាដៃគូរវាងរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធមិនមែនរដ្ឋាភិបាល ហើយដំណើរការក្នុងការរៀបចំ TMP មានរួមបញ្ចូលមតិយោបល់អ្នកពាក់ព័ន្ធទាំងអស់។

ដោយការទទួលស្គាល់ពីសារៈសំខាន់នៃភាពជាដៃគូសហការនេះ ឯកសារ TMP ត្រូវបានរៀបចំឡើងដោយមានរចនាសម្ព័ន្ធសម្រាប់៖

- ស្ថាប័នរដ្ឋាភិបាលដូចជាអាជ្ញាធរអប្សរា ក្រសួងទេសចរណ៍ អាជ្ញាធរខេត្តសៀមរាប

- ICC-Angkor ក្នុងការផ្តល់អនុសាសន៍លើគោលនយោបាយ និងពិនិត្យមើលលក្ខខណ្ឌផ្សេងៗនៃតំបន់បេតិកភណ្ឌពិភពលោកអង្គរ
- មន្ត្រីដែលមានទំនួលខុសត្រូវក្នុងការគ្រប់គ្រងនាពេលបច្ចុប្បន្ន និងនាពេលអនាគតនៅតំបន់អង្គរ
- ស្ថាប័នអន្តរជាតិដែលកំពុងបំពេញភារកិច្ចនៅអង្គរ
- អ្នកចូលរួមក្នុងឧស្សាហកម្មទេសចរណ៍ ពីគ្រប់ផ្នែកនិងគ្រប់កម្រិតទាំងអស់
- សហគមន៍ ផ្លូវការ មិនផ្លូវការ ឬជាបុគ្គល។





ចំណុចសំខាន់របស់ TMP ផ្តោតទៅលើការដាក់ចេញនូវវិធីសាស្ត្រសាមញ្ញក្នុងការគ្រប់គ្រងទេសចរណ៍ដែលអាចទទួលយកបាននិងអាចប្រើប្រាស់បានពីគ្រប់ភាគី(ឬភាគីដទៃ) ដើម្បីសម្របសម្រួលការគ្រប់គ្រងទេសចរណ៍នៅអង្គរ។

អង្គរជាអត្តសញ្ញាណតំណាងវប្បធម៌ដ៏ល្បីល្បាញក្នុងពិភពលោក និងជាគោលដៅទេសចរណ៍ចម្បងនៅក្នុងប្រទេសកម្ពុជា ហើយក៏ជាគោលដៅទស្សនាមួយក្រៅពីរមណីយដ្ឋានឆ្នេរនិងរាជធានីភ្នំពេញ។ ទោះជាយ៉ាងណាក៏ដោយ ក៏មានតំបន់ទាក់ទាញទេសចរដែលមានស្រាប់ឬមានសក្តានុពលផ្សេងទៀតដែលមានទំនាក់ទំនងជាមួយអង្គរដូចជា បឹងទន្លេសាប ប្រាសាទព្រះវិហារ និងប្រាសាទកោះកេរ។ ការយល់ពីវិស័យទេសចរណ៍នៅក្នុងអង្គរតម្រូវឲ្យមានការយល់ដឹងយ៉ាងទូលាយអំពីសារៈសំខាន់នៃឧស្សាហកម្មទេសចរណ៍ ដែលជាធាតុមួយដ៏សំខាន់ក្នុងការធ្វើឲ្យសេដ្ឋកិច្ចកម្ពុជាលូតលាស់យ៉ាងលឿន។

ទំហំនៃវិស័យទេសចរណ៍នៅអង្គរបានរីកចម្រើនជាលំដាប់ ហើយបានបង្កើនល្បឿនយ៉ាងលឿនក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ កំណើនក្នុងវិស័យទេសចរណ៍នៅអង្គរត្រូវបានឆ្លុះបញ្ចាំងដោយកំណើនក្នុងវិស័យទេសចរណ៍របស់ប្រទេសកម្ពុជា ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ។




*រូបភាពទី១ កំណើនក្នុងវិស័យទេសចរណ៍នៅកម្ពុជាឆ្នាំ១៩៩៣-២០១២*
*(នាយកដ្ឋានស្ថិតិនិងព័ត៌មានទេសចរណ៍នៃក្រសួងទេសចរណ៍ឆ្នាំ២០១២)។*

តាមការសង្កេតជាក់ស្តែង បើចំនួនភ្ញៀវទេសចរនៅតែបន្តកើនឡើងនៅតំបន់អង្គរ វិស័យទេសចរណ៍នឹងបន្តដាក់សម្ពាធកាន់តែខ្លាំងទៅលើតំបន់អង្គរ។ បច្ចុប្បន្ននេះ តម្រូវឲ្យមានការគ្រប់គ្រងដែលមានផែនការបម្រុងទុកជាមុនជាបន្ទាន់និងការដាក់យុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពដើម្បីរក្សាតុល្យភាពរវាងផលវិជ្ជមាននិងអវិជ្ជមានពីវិស័យទេសចរណ៍។ យុទ្ធសាស្ត្រគ្រប់គ្រងវិស័យទេសចរណ៍នៅអង្គរមកដល់ចំណុចនេះ មានការវិវត្តតាមរយៈការផ្តួចផ្តើមដ៏សំខាន់ជាគន្លឹះមួយចំនួនៈ

នៅក្នុងឆ្នាំ១៩៩៥ ផែនការមេស្តីពីការអភិវឌ្ឍន៍ទេសចរណ៍ដែលបានរៀបចំដោយទទួលមូលនិធិពីទីភ្នាក់ងារអភិវឌ្ឍន៍បារាំង(AFD) បានសង្កត់ធ្ងន់ថា តួនាទីអាជ្ញាធរអប្សរានៅក្នុងវិស័យទេសចរណ៍ គួរតែជាកម្លាំងជំរុញឲ្យសេដ្ឋកិច្ចដំណើរការនិងបង្កើតការងារ

ដើម្បីឆ្លើយតបនឹងការរំពឹងទុករបស់អ្នកទស្សនា និងការរក្សាការពារប្រាសាទនានាពីភាពអន្តរាយ។ គោលការណ៍ឯកសារនេះលើកឡើងពីតម្រូវការក្នុងការធ្វើឲ្យចម្រើនជឿនលឿនដល់ "គុណភាព" បទពិសោធទស្សនា ដែលមានខេត្តសៀមរាបជា "មជ្ឈមណ្ឌលទេសចរណ៍បេតិកភណ្ឌអន្តរជាតិ" ក៏ដូចជាការលើកឡើងពីការគ្រប់គ្រងលំហូរអ្នកទស្សនាឆ្លងកាត់តំបន់ប្រាសាទ និងការលើកទឹកចិត្តឲ្យមានផលប្រយោជន៍ហិរញ្ញវត្ថុដែលមិនរំពឹងទុកពីវិស័យទេសចរណ៍ រួមទាំងការបង្កើតការងារដល់សហគមន៍ក្នុងតំបន់ និងប្រជាជនកម្ពុជា។

ក្នុងខែកុម្ភៈ ឆ្នាំ២០០៦ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន(JICA) បានបញ្ចប់គម្រោងមួយដែលមានឈ្មោះថា ការសិក្សានៅលើផែនការមេ ដែលធ្វើសមាហរណកម្មសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅខេត្តសៀមរាប(ឆ្នាំ២០០៦)។ តាមរយៈវិសាលភាពទូលំទូលាយលើសពីវិស័យទេសចរណ៍ ផែនការនេះជាធាតុផ្សំដ៏សំខាន់សម្រាប់រៀបចំវិស័យទេសចរណ៍នៅអង្គរប្រកបដោយចីរភាព។

នៅក្នុងឆ្នាំ២០០៧ មានរៀបចំ"របាយការណ៍ស្តីពីទិដ្ឋភាពវិស័យទេសចរណ៍" ដោយមានធាតុផ្សំប្រាំ ដើម្បីរួមចំណែកដល់ផែនការគ្រប់គ្រងតំបន់អង្គរ ក្រោមគម្រោងមូលនិធិរបស់ទីភ្នាក់ងារប្រទេសណូវែលសេឡង់សម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ(NZAid)។ របាយការណ៍នេះបានវិភាគទៅលើស្ថានភាពបច្ចុប្បន្ននៃវិស័យទេសចរណ៍នៅអង្គរ ដោយបានតាមដានលើការរៀបចំវិធីសាស្ត្រគ្រប់គ្រងទេសចរណ៍របស់អាជ្ញាធរអប្សរា និងបន្ទាប់មកកំណត់គោល ដៅជាគន្លឹះបី ក្នុងការគ្រប់គ្រងវិស័យទេសចរណ៍នៅអង្គរនោះគឺ ការប្រើប្រាស់វិធីត្រួតពិនិត្យអ្នកទស្សនា ការលើកទឹកចិត្តឲ្យមានការចូលរួមកាន់តែច្រើនពីសំណាក់ប្រជាជនកម្ពុជាក្នុងវិស័យទេសចរណ៍ និងការកសាងជំនាញដើម្បីជំរុញឲ្យមានដំណើរការទេសចរណ៍សហគមន៍។ អ្វីដែលសំខាន់បំផុតនោះគឺ របាយការណ៍នេះបានផ្តល់អនុសាសន៍ថាតើអាជ្ញាធរអប្សរា អាចកែលម្អរចនាសម្ព័ន្ធគ្រប់គ្រងវិស័យទេសចរណ៍របស់ខ្លួនបានដែរឬទេ។

ការសិក្សាទាំងនេះមានគោលបំណងស្ថាបនា ការគ្រប់គ្រងទេសចរណ៍នៅអង្គរ ដោយដាក់ចេញនូវផែនការណែនាំដ៏សំខាន់មួយចំនួន និងបង្កើតនូវគោលការណ៍ស្នូលនានា។ ទោះជាយ៉ាងនេះក្តីក៏ការកើនឡើងនូវសម្ពាធនៃកំណើនអ្នកទស្សនា ដែលចេះតែបន្ត មានន័យថាត្រូវតែរកឲ្យឃើញនូវវិធីសាស្ត្រថ្មី ជាពិសេសគឺស្វែងរកកិច្ចសហប្រតិបត្តិការយ៉ាងសកម្មពីឧស្សាហកម្មទេសចរណ៍ ក្នុងការបង្កើតដំណោះស្រាយដែលអាចធ្វើបានដើម្បីការអភិវឌ្ឍន៍ប្រកបដោយចីរភាព។

ដោយផ្អែកលើការសិក្សាការគ្រប់គ្រងទេសចរណ៍នានាពីមុននិងការផ្តួចផ្តើមគំនិតនាពេលថ្មីៗរបស់អាជ្ញាធរអប្សរានិងក្រសួងទេសចរណ៍ ផែនការគ្រប់គ្រងទេសចរណ៍ថ្មីនេះផ្តល់នូវឱកាសដ៏សំខាន់ ដើម្បីតាក់តែងជាក្របខ័ណ្ឌការងារដែលនឹងផ្តល់ជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាពនៃវិស័យទេសចរណ៍ នាទសវត្សខាងមុខនិងនាពេលអនាគត។ ដោយភ្ជាប់នឹងគម្រោង HMF ផែនការគ្រប់គ្រងទេសចរណ៍បានភ្ជាប់ការគ្រប់គ្រង ទេសចរណ៍ទៅនឹងការទទួលស្គាល់ការការពារ និងការលើកតម្លៃបេតិកភណ្ឌរូបីនិងអរូបីនៅអង្គរ។

TMP ស្គាល់ថា តំបន់បេតិកភណ្ឌពិភពលោកអង្គរគឺជាធាតុស្នូលនៅក្នុងទេសភាពវប្បធម៌ដ៏ធំទូលាយ ដែលរួមបញ្ចូលទាំងក្រុងសៀមរាប បឹងទន្លេសាប និងភ្នំគូលែន ដែលទាំងអស់នេះបង្កើតបានជាផ្នែកមួយ នៃសំណុំរូបវន្តនិងវប្បធម៌សម្រាប់វិស័យទេសចរណ៍នៅអង្គរ(រូបភាពទី២)។ ដូច្នេះ TMP ក៏លើកឡើងផងដែរពីបេតិកភណ្ឌវប្បធម៌ក្រុងសៀមរាប និងតម្រូវការចាំបាច់ក្នុងការទប់ស្កាត់ការកាប់បំផ្លាញព្រៃឈើនៅភ្នំគូលែន។

TMP ផ្តល់នូវការផ្តួចផ្តើមគោលនយោបាយសមាហរណកម្ម ដែលលើកឡើងពីបញ្ហាទេសចរណ៍ចម្បងៗនៅអង្គរ។ អ្វីដែលបានបញ្ចូលក្នុង TMP រួមមានការផ្តួចផ្តើមរបស់អាជ្ញាធរអប្សរា កម្មវិធីនានា ការផ្តួចផ្តើមថ្មីៗ ការផ្តល់យោបល់របស់ឧស្សាហកម្មទេសចរណ៍ និងសហគមន៍ ព្រមទាំងយោបល់និងជំនាញនៃក្រុមគម្រោង HMF។





តម្រូវការក្នុងការរៀបចំTMP ឆ្លើយតបទៅតាមតម្រូវការផ្នែកច្បាប់ កម្រិតអន្តរជាតិ កម្រិតជាតិ និងកម្រិតមូលដ្ឋាន ក៏ដូចជាសេចក្តីថ្លែងការណ៍ពីគោលបំណងសម្រាប់ពេលអនាគត។ វិធីសាស្រ្តរៀបចំ TMP អនុលោមតាមអនុសញ្ញាបេតិកភណ្ឌពិភពលោក គោលការណ៍ណែនាំក្នុងការប្រតិបត្តិ គោលការណ៍សម្រាប់ទេសចរណ៍ប្រកបដោយចីរភាព នៅក្នុងតំបន់បេតិកភណ្ឌពិភពលោក ច្បាប់ជាតិ ផែនការយុទ្ធសាស្រ្តវិស័យទេសចរណ៍ថ្នាក់ជាតិ កាតព្វកិច្ច និងទំនួលខុសត្រូវរបស់អាជ្ញាធរអប្សរា តួនាទីរបស់ICC-Angkor និងផែនការគ្រប់គ្រងអង្គរឆ្នាំ២០០៧។ ការផ្តួចផ្តើមនិងកម្មវិធីដែលបានស្នើឡើង គឺផ្អែកទៅលើបទពិសោធដ៏ទូលំទូលាយដែលទទួលបានពីអ្នកពិគ្រោះយោបល់ បុគ្គលិកអាជ្ញាធរអប្សរា និងអ្នកជំនាញអន្តរជាតិដែលធ្វើការស្រាវជ្រាវទៅលើស្ថានភាព និងការផ្តួចផ្តើមស្រដៀងគ្នានៅក្នុងតំបន់បេតិកភណ្ឌពិភពលោកសំខាន់ៗផ្សេងទៀត ក៏ដូចជាលើគោលនយោបាយគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ដែលបានអនុវត្តល្អបំផុតនៅលើពិភពលោក។

ស្របគ្នានឹងវិធីសាស្រ្តទាំងនេះ TMP ប្រើប្រាស់នូវវិធីសាស្រ្តគ្រប់គ្រងដែលផ្អែកលើគុណតម្លៃធម្មជាតិនិងវប្បធម៌ ដែលជាការអនុវត្តដ៏ល្អបំផុតនៅក្នុងពិភពលោក និងទទួលបានការពេញចិត្តពីសំណាក់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក ចំពោះការគ្រប់គ្រងតំបន់បេតិកភណ្ឌពិភពលោក។ វិធីសាស្រ្តនេះគឺពាក់ព័ន្ធទៅនឹងការយល់ទាំងស្រុងទៅលើគុណតម្លៃធម្មជាតិនិងវប្បធម៌នៃទីកន្លែងមួយ តាមរយៈការវិភាគសារតា ការស្រាវជ្រាវ ការស្ទង់មតិដល់មូលដ្ឋាន ពិសេស ការពិគ្រោះយោបល់ ការវិភាគលើហានិភ័យនិងបញ្ហាដែលអាចជះឥទ្ធិពលដល់គុណតម្លៃទាំងនេះ និងស្វែងរកដំណោះស្រាយសមាហរណកម្មក្នុងការគ្រប់គ្រងបញ្ហានៅក្នុងវិស័យទេសចរណ៍។ ចំណុចទីពីរដែលមានសារៈសំខាន់ផងដែរចំពោះវិធីសាស្រ្តរៀបចំផែនការផ្អែកលើគុណតម្លៃ គឺអ្នកដែលទទួលខុសត្រូវគ្រប់គ្រងរមណីយដ្ឋាន និងអ្នកពាក់ព័ន្ធសំខាន់ៗដទៃទៀត ជាអ្នកធ្វើការសម្រេចចិត្តទាក់ទងនឹងផែនការនេះជាងអ្នកពិគ្រោះយោបល់។

TMP ត្រូវបានបង្កើតឡើងដោយប្រើប្រាស់នូវដំណើរការពិគ្រោះយោបល់ទៅវិញទៅមក ដើម្បីជំរុញឲ្យមានការយល់ដឹងកាន់តែទូលំទូលាយ និងប្តេជ្ញាចិត្តចំពោះការអនុវត្ត TMP។ ការអនុវត្តនេះនឹងតម្រូវឲ្យមានការផ្លាស់ប្តូរយ៉ាងធំធេងមួយចំនួនៈ ការត្រួតពិនិត្យថ្មី ទម្រង់នៃការទស្សនាផ្សេងៗនិងធនធានបន្ថែមមួយចំនួនទៀត។ ចាំបាច់ត្រូវពិនិត្យនិងរៀបចំអនុវត្ត TMP ឲ្យស្របតាមរចនាសម្ព័ន្ធដែលមានស្រាប់នៅតាមទីភ្នាក់ងាររដ្ឋាភិបាល ពិសេសនៅអាជ្ញាធរអប្សរា។ ការអនុវត្ត TMP ឲ្យបានជោគជ័យតម្រូវឲ្យមានការតែងតាំងបុគ្គលិកដែលមានតួនាទីនិងមុខតំណែងយ៉ាងច្បាស់ទាំងនៅក្នុងអាជ្ញាធរអប្សរា និងក្រសួងទេសចរណ៍ ដើម្បីអនុវត្តការងារឲ្យមានប្រសិទ្ធភាពខ្ពស់។ ការអនុវត្ត TMP ក៏តម្រូវឲ្យមានកិច្ចសន្ទនាបើកចំហនិងជាបន្តជាមួយនឹងអ្នកចូលរួមនៅក្នុងឧស្សាហកម្មទេសចរណ៍ នៅអង្គរផងដែរ ដើម្បីរក្សាទំនាក់ទំនងល្អក្នុងការអនុវត្តសកម្មភាពនានា ។




***រូបភាពទី២ :*** *ទំនាក់ទំនងរវាងTMP អង្គរ ទេសភាពវប្បធម៌នៃអង្គរនិងបរិបទជាតិនិងអន្តរជាតិ*

# តួនាទីនៃផែនការគ្រប់គ្រងទេសចរណ៍

TMP ផ្តល់នូវវិធីសាស្រ្តដែលបានទទួលការឯកភាព ក្នុងការគ្រប់គ្រងទេសចរណ៍នៅអង្គរ។ TMP គឺជាផ្នែកដ៏សំខាន់មួយនៃគម្រោងHMF ដែលជាគម្រោងសហការរវាងប្រទេសអូស្រ្តាលី រាជរដ្ឋាភិបាលកម្ពុជា និងអង្គការយូណេស្កូ។ គម្រោង HMF គឺជាមូលដ្ឋានអភិរក្សគុណតម្លៃបេតិកភណ្ឌវប្បធម៌ និងធម្មជាតិនៃតំបន់បេតិកភណ្ឌពិភពលោកអង្គរ ព្រមទាំងពង្រឹងអភិបាលកិច្ចល្អ និងពង្រឹងសមត្ថភាពបុគ្គលិកអាជ្ញាធរអប្សរាតាមរយៈការបណ្តុះបណ្តាលធនធានមនុស្ស។ គម្រោង HMF ត្រូវបានរៀបចំឡើងដោយផ្អែកលើវិធីសាស្រ្ត "គុណតម្លៃបេតិកភណ្ឌ" ដែលមានគោលបំណងកំណត់អត្តសញ្ញាណនៃគុណតម្លៃបេតិកភណ្ឌ ក៏ដូចជាបញ្ហាពាក់ព័ន្ធទាំងឡាយ ដើម្បីរកឲ្យឃើញនូវគោលនយោបាយគ្រប់គ្រងបញ្ហា នៅក្នុងក្របខ័ណ្ឌណាមួយដែលធានាបានថា បេតិកភណ្ឌនិងគុណតម្លៃទាំងអស់ត្រូវបានការពារ។

ការរៀបចំ HMF គួរតែធ្វើឡើងមុនពេលរៀបចំTMP។ ទោះជាយ៉ាងណាក៏ដោយ ក៏រាជរដ្ឋាភិបាលកម្ពុជា និងអាជ្ញាធរអប្សរាបានចាត់ទុកថាការគ្រងគ្រងទេសចរណ៍ជាបញ្ហាសំខាន់និងបន្ទាន់។ ប្រសិនបើយើងគ្រប់គ្រងទេសចរណ៍បានល្អ នោះទេសចរណ៍នឹងមិនត្រឹមតែមិននាំមកនូវការគំរាមកំហែងដល់តំបន់ប្រាសាទនោះទេ ថែមទាំងនាំមកនូវឱកាសសម្រាប់ការអភិរក្សប្រាសាទទៀត។ ការរៀបចំ TMP ដាច់ដោយឡែកពីគម្រោង HMF ជាការស្នើសុំ របស់អាជ្ញាធរអប្សរាព្រោះជាបញ្ហាអាទិភាពមួយ។ ការរៀបចំ TMP ក៏បានបំពេញតាម អនុសាសន៍ជាក់លាក់របស់គណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារ និងអភិរក្ស រមណីយដ្ឋានប្រវត្តិសាស្រ្តអង្គរ (ICC-Angkor) ។ TMP នឹងក្លាយជាឧបករណ៍ជាមូលដ្ឋានសម្រាប់ការអនុវត្ត HMF។

បន្ថែមពីលើ TMP គម្រោង HMF ក៏បានបញ្ចូលការរៀបចំ"ផែនទីហានិភ័យ" ផងដែរ ដោយផ្អែកលើប្រព័ន្ធព័ត៌មានភូមិសាស្រ្តសម្រាប់គុណតម្លៃវប្បធម៌និងធម្មជាតិ ការបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីអាជ្ញាធរអប្សរា និងគម្រោងសាកល្បងចំនួនបួន ដើម្បីអនុវត្តនិងសាកល្បងគោលនយោបាយ និងការផ្តួចផ្តើមនានាដែលមានចែងក្នុងHMF។ TMP អាចនឹងត្រូវរៀបចំកែសម្រួលឡើងវិញ តាមរយៈការអនុវត្តគម្រោងសាកល្បងនៅតាមតំបន់ប្រាសាទនិងជុំវិញតំបន់អង្គរ។





# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍២០១២–២០២០

ការរៀបចំTMP ធ្វើឡើងស្របនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍទេសចរណ៍កម្ពុជាឆ្នាំ ២០១២-២០២០ ដែលដាក់ចេញនូវចក្ខុវិស័យក្នុងការអភិវឌ្ឍន៍វិស័យទេសចរណ៍នៅកម្ពុជានាពេលអនាគត តាមរយៈយុទ្ធសាស្ត្រជាបន្តបន្ទាប់ដូចជា ការអភិវឌ្ឍន៍ផលិតផលទេសចរណ៍ ការធ្វើទីផ្សារ និងការផ្សព្វផ្សាយទេសចរណ៍ ការសម្របសម្រួលដល់ការធ្វើដំណើរនិងការដឹកជញ្ជូន ការគ្រប់គ្រងផលប៉ះពាល់ពីវិស័យទេសចរណ៍ សុវត្ថិភាព វិធាន និងការអភិវឌ្ឍន៍ធនធានមនុស្ស។ ផែនការនេះគ្រោងថា ប្រទេសកម្ពុជានឹងទទួលបានភ្ញៀវទេសចរអន្តរជាតិចំនួន៧លាននាក់ និងភ្ញៀវទេសចរក្នុងស្រុករវាងពី៨ទៅ១០លាននាក់ នៅក្នុងឆ្នាំ ២០២០ ដែលរួមចំណែកយ៉ាងសំខាន់ក្នុងការធ្វើឲ្យមានកំណើនផលិតផលក្នុងស្រុកសរុប (GDP) និងកម្រិតជីវភាពរស់នៅ រួមទាំងបង្កើតការងារប្រមាណ៨00 000។

ការផ្តួចផ្តើមគន្លឹះនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍទេសចរណ៍២០១២-២០២០ រួមមានការអភិវឌ្ឍន៍ផលិតផលទេសចរណ៍ តាមរយៈយុទ្ធសាស្ត្របង្កើតគោលដៅទស្សនាផ្សេងៗ ការពង្រឹងគុណភាពនៃផលិតផលនិងសេវាកម្មទេសចរណ៍ ការពង្រឹងច្បាប់និងវិធានទេសចរណ៍ រួមនឹងការបន្តយុទ្ធនាការ "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ"។ ត្រូវមានការផ្តោតជាសំខាន់ផងដែរលើការបង្កើតសមាគម និងសហគមន៍អ្នកលក់វត្ថុអនុស្សាវរីយ៍ ក៏ដូចជាការអភិវឌ្ឍន៍វិស័យទេសចរណ៍ និងសហគមន៍ទេសចរណ៍ធម្មជាតិ ដើម្បីជាការរួមចំណែកក្នុងការអភិរក្សនិងការពារធនធានធម្មជាតិនិងវប្បធម៌ ដែលរួមមានទំនៀមទម្លាប់

និងប្រពៃណីនៅតាមជនបទ។ តាមរយៈការធ្វើដូចនេះ ប្រជាជនក្នុងតំបន់នឹងទទួលបានផលប្រយោជន៍ស្មើគ្នាពីសកម្មភាពទេសចរណ៍និងសកម្មភាពសេដ្ឋកិច្ចដទៃទៀត។ ត្រូវពង្រឹងកិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជនដើម្បីទាក់ទាញទេសចរនៅក្នុងតំបន់និងពិភពលោកដើម្បីពង្រីកសកម្មភាពនិងដើម្បីផ្សព្វផ្សាយអំពីវិស័យទេសចរណ៍ឲ្យបានកាន់តែទូលំទូលាយបន្ថែមទៀត។ បន្តធ្វើយុទ្ធនាការ "កម្ពុជា ព្រះរាជាណាចក្រអច្ឆរិយៈ" ដើម្បីជំរុញលើកកម្ពស់ម្ហូបអាហារនិងវប្បធម៌ខ្មែរ។





# តំបន់បេតិកភណ្ឌពិភពលោកអង្គរ

អង្គរចែកជាតំបន់ផ្សេងៗគ្នា។ តំបន់បេតិកភណ្ឌពិភពលោកអង្គរត្រូវបានកំណត់ត្រឹមឧទ្យានបុរាណវិទ្យាអង្គរ រលួស និងបន្ទាយស្រី ដែលរួមមាន៤០០គីឡូម៉ែត្រក្រឡានៅក្នុងតំបន់ទំនាបឋិតនៅចន្លោះភ្នំគូលែននៅភាគខាងជើងនិងបឹងទន្លេសាបនៅភាគខាងត្បូង។ យោងតាមផែនការត្រួតពិនិត្យការកំណត់តំបន់ការពារក្នុងរមណីយដ្ឋានអង្គរឆ្នាំ១៩៩៤ គេចែកតំបន់អង្គរជាប្រាំដែលក្នុងនោះរួមមានតំបន់បុរាណវិទ្យា តំបន់នរវិទ្យានិងតំបន់ប្រវត្តិសាស្ត្រមួយចំនួនដែលឋិតនៅខាងក្រៅផ្ទៃដី៤០០គីឡូម៉ែត្រក្រឡា។ ការស្រាវជ្រាវថ្មីៗ បានឲ្យដឹងថា អង្គរមានវិសាលភាពនិងរចនាសម្ព័ន្ធទីក្រុងមជ្ឈិមសម័យមួយដែលគ្របដណ្តប់លើផ្ទៃដីប្រមាណជា១ ០០០គីឡូម៉ែត្រក្រឡា មានទំហំធំជាងតំបន់ស្នូលនិងតំបន់ទ្រនាប់ដែលបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកទៅទៀត។

បច្ចុប្បន្នអាជ្ញាធរអប្សរា មានតួនាទីគ្រប់គ្រងនិងការពាររមណីយដ្ឋានដែលស្ថិតនៅខាងក្រៅតំបន់អង្គរ និងតំបន់ការពារក្នុងរមណីយដ្ឋានអង្គរផងដែរ ក្នុងនោះរួមមានប្រាសាទបេងមាលា កោះកេរ និងភ្នំគូលែន។

ការគ្រប់គ្រងអង្គរក៏ត្រូវភ្ជាប់នឹងក្រុងសៀមរាប ដែលស្ថិតនៅប្រមាណ៧គីឡូម៉ែត្រភាគខាងត្បូងនៃអង្គរ(រូបភាពទី៣)ផងដែរ។ ភ្ញៀវទេសចរនឹងទទួលបាននូវបទពិសោធពីបេតិកភណ្ឌក្រុងសៀមរាប ដែលជាកន្លែងពួកគាត់ស្នាក់នៅនិងបរិភោគអាហារ។ ទំនាក់ទំនងដ៏សំខាន់ផ្សេងទៀតជាមួយនឹងបឹងទន្លេសាប ដែលស្ថិតនៅចម្ងាយ១០គីឡូម៉ែត្រភាគខាងត្បូង បានផ្តល់នូវបទពិសោធនានាបន្ថែមទៀត រួមទាំងភាពទាក់ទាញផ្នែកធម្មជាតិ និងវប្បធម៌ដល់ អ្នកទស្សនា។

TMP មានជាប់ទាក់ទងតែនឹងតំបន់បេតិកភណ្ឌពិភពលោកអង្គរប៉ុណ្ណោះ។ ការពិពណ៌នាពីតំបន់បេតិកភណ្ឌពិភពលោកអង្គរសមស្របនឹងគោលបំណងនៃឯកសារដោយមានបញ្ចូលៈ

- តំបន់ទី១និងទី២ ដែលបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោករួមមានអង្គរ រលួស និងបន្ទាយស្រីដែលគ្របដណ្តប់លើផ្ទៃដីទំហំ៤០០គីឡូម៉ែត្រក្រឡា
- តំបន់ការពារក្នុងរមណីយដ្ឋាន ឆ្នាំ១៩៩៤(រូបភាពទី៤)
- តំបន់ស្នូលនិងតំបន់ទ្រនាប់ បេងមាលា និងកោះកេរ
- តំបន់ដទៃទៀតនៅអង្គរ(រូបភាពទី៥)ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់អាជ្ញាធរអប្សរា។

United Nations Educational, Scientific and Cultural Organization
Australian Government
អាជ្ញាធរអប្សរា APSARA








*រូបភាពទី៣ : អង្គរនិងតំបន់ជុំវិញអង្គរ រួមមានភ្នំគូលែននិងទន្លេសាប*

*(ផែនទី: ដាមែន អ៊ីវេន  (Damian Evan); ទិន្នន័យ SRTM(NASA/JPL) និង JICA/MPWT)*




*រូបភាពទី៤ : តំបន់ការពាររមណីយដ្ឋានអង្គរ*

*(ក្រឹត្យលេខ០០១ នស ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៤)។*




*រូបទី៥ : តំបន់អង្គរ (Pottier និង Evans ឆ្នាំ២០០៧)*

*ផែនទីនេះបង្ហាញពីវិសាលភាពនៃតំបន់អង្គរ។ ចំណុចចតុកោណកែងពណ៌ខៀវ ជាបារាយណ៍ ចំណុចការ៉េនៅចំកណ្ដាលជាអង្គរធំ ចំណុចតូចៗបង្ហាញពីតំបន់ដែលមានមនុស្សតាំងនៅនិង ប្រាសាទ ហើយបន្ទាត់ពណ៌ត្នោតជាហេដ្ឋារចនាសម្ព័ន្ធបុរាណដូចជាផ្លូវថ្នល់ឬប្រឡាយ*

# រចនាសម្ព័ន្ធផែនការគ្រប់គ្រងទេសចរណ៍

HMF ត្រូវបានបង្កើតឡើងតាមរយៈគុណតម្លៃធម្មជាតិនិងវប្បធម៌ ដែលបានឯកភាពគ្នា ហើយការគ្រប់គ្រងតំបន់បេតិតភណ្ឌពិភពលោកអង្គរអាស្រ័យលើគោលនយោបាយ កម្មវិធី សកម្មភាព និងការសម្រេចចិត្តនានា ដើម្បីអភិរក្សគុណតម្លៃទាំងនោះ។ វិធីសាស្ត្រនេះត្រូវបានស្គាល់ថាជា "ការគ្រប់គ្រងដោយផ្អែកលើគុណតម្លៃ"។ ក្នុងគោលបំណងអភិរក្សគុណតម្លៃនានា ចាំបាច់ត្រូវរកឲ្យឃើញនូវបញ្ហាដែលអាចជះឥទ្ធិពលដល់រមណីយដ្ឋាន ដើម្បីរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងសកម្មភាពដ៏សមស្របក្នុងការគ្រប់គ្រងបញ្ហា និងអភិរក្សគុណតម្លៃទាំងអស់។ ដូចគ្នានឹង HMF ការសិក្សា TMP ផ្អែកជាពិសេសលើការវិភាគបញ្ហាក្នុងវិស័យទេសចរណ៍។ គោលនយោបាយ TMP មានរូបភាពជាសេចក្តីថ្លែងការណ៍សង្ខេបច្បាស់ៗនិងយ៉ាងសាមញ្ញ ដោយប្រកាន់យកនូវគោលការណ៍ប្រកបដោយចីរភាពនៅតំបន់បេតិកភណ្ឌពិភពលោក និងមានការផ្តួចផ្តើមគោលការណ៍ជាក់លាក់ចំនួនប្រាំមួយ។ ចំពោះការផ្តួចផ្តើមនីមួយៗ មានថ្លែងពីគោលបំណងនៃការគ្រប់គ្រងនិងសមិទ្ធផលនានាមកដល់ពេលបច្ចុប្បន្ន ការវាយតម្លៃលម្អិតលើបញ្ហា យុទ្ធសាស្ត្រ និងអនុសាសន៍ស្តីពីសកម្មភាពអាទិភាពនានា។

រចនាសម្ព័ន្ធនៃផែនការគ្រប់គ្រងទេសចរណ៍ ត្រូវបានសង្ខេបដូចខាងក្រោម :




## គុណតម្លៃ

គុណតម្លៃបេតិកភណ្ឌអង្គរត្រូវបានទទួលស្គាល់តាមរយៈសេចក្តីថ្លែងការណ៍របស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោកអំពីគុណតម្លៃជាសកល កិច្ចការស្រាវជ្រាវនាពេលថ្មីៗដែលមានដូចជា គម្រោង «រស់នៅជាមួយបេតិកភណ្ឌ» និង គម្រោង «ក្របខ័ណ្ឌគ្រប់គ្រងបេតិកភណ្ឌអង្គរ» និងសេចក្តីថ្លែងការណ៍សង្ខេបដោយICC-Angkor។ គោលបំណងនៃការលើកឡើងពីគុណតម្លៃនៅពេលចាប់ផ្តើមរៀបចំ TMPគឺដើម្បីធ្វើឲ្យអ្នកអនុវត្តទាំងអស់ បានយល់ដឹងពីសារៈសំខាន់នៃគុណតម្លៃទាំងនេះ និងដើម្បីផ្តល់ជូននូវ

បទដ្ឋានក្នុងការកាត់បន្ថយផលប៉ះពាល់ពីវិស័យទេសចរណ៍តាមរយៈគោលនយោបាយ និងសកម្មភាពសមស្របណាមួយ។

## បញ្ហា

មានបញ្ហាជាច្រើនដែលជះឥទ្ធិពលទៅលើវិស័យទេសចរណ៍នៅអង្គរ។ បញ្ហាភាគច្រើនមានបង្ហាញលម្អិតនៅក្នុងផ្នែក «ការផ្តួចផ្តើមគោលនយោបាយ» របស់ TMP។ ទោះជាយ៉ាងណាក៏ដោយ ដើម្បីពណ៌នាពីបរិបទការផ្តួចផ្តើមគោលនយោបាយទាំងមូល យើងអាចសង្ខេបបញ្ហាចម្បងចំនួនប្រាំបីដូចតទៅៈ ការគ្រប់គ្រងនៅអង្គរ ខណៈដែលចំនួនអ្នកទស្សនាកើនឡើង ការយល់ដឹងនិងផ្សព្វផ្សាយពីគុណតម្លៃបេតិកភណ្ឌ ផលប៉ះពាល់ដល់រមណីយដ្ឋាន បទពិសោធ អាកប្បកិរិយានិងសុវត្ថិភាពអ្នកទស្សនា ហេដ្ឋារចនាសម្ព័ន្ធនិងការដឹកជញ្ជូន ប្រជាជនក្នុងតំបន់ ការចូលរួមស្វែងយល់ពីអ្នកពាក់ព័ន្ធ និងអភិបាលកិច្ចល្អ។

## គោលនយោបាយ

TMP ស្ថិតនៅក្នុងរចនាសម្ព័ន្ធរបស់គម្រោង HMF។ ដូចនេះគោលនយោបាយដែលមានចែងនៅក្នុងTMP ត្រូវតែស្របនឹងគម្រោង HMF និងគោលនយោបាយរបស់អាជ្ញាធរអប្សរា និងICC-Angkor ដែលមានពីមុនមក។ TMP ក៏ត្រូវឆ្លើយតបតាមវិធានគ្រប់គ្រងទេសចរណ៍ប្រកបដោយចីរភាព នៅតំបន់បេតិកភណ្ឌពិភពលោកផងដែរ។ ការផ្តួចផ្តើមគោលនយោបាយទាំងនេះ កើតចេញពីគម្រោង HMF និងការវិភាគលើគុណតម្លៃនិងបញ្ហានានា។

## ការផ្តួចផ្តើមគោលនយោបាយគន្លឹះ

TMP ផ្តល់នូវមូលដ្ឋានក្នុងការគ្រប់គ្រង និងសម្របសម្រួលជាមួយឧស្សាហកម្ម

ទេសចរណ៍ ដែលរីកចម្រើនយ៉ាងលឿននៅអង្គរ តាមរយៈការផ្តួចផ្តើមគោលនយោបាយសំខាន់ៗចំនួនប្រាំមួយដូចជា ការលើកកម្ពស់បទពិសោធជាវិជ្ជមានសម្រាប់អ្នកទស្សនា លុបបំបាត់ឬកាត់បន្ថយផលប៉ះពាល់ដល់រមណីយដ្ឋាន ភាពជាដៃគូជាមួយនឹងឧស្សាហកម្មទេសចរណ៍ ការផ្តល់ប្រយោជន៍ដល់ប្រជាជនក្នុងតំបន់ ការប្រើប្រាស់ធនធានដែលមានស្រាប់ឲ្យកាន់តែមានប្រសិទ្ធភាព(អភិបាលកិច្ចល្អ) និងការចូលរួមស្វែងយល់ពីអ្នកពាក់ព័ន្ធ។

## ការផ្តួចផ្តើមចម្បង

អាជ្ញាធរអប្សរា បានបំពេញភារកិច្ចគួរឲ្យកត់សម្គាល់មួយចំនួនទាក់ទងនឹងបញ្ហាដែលបានរៀបរាប់ខាងលើ។ TMP ទទួលស្គាល់ថាការផ្តួចផ្តើមទាំងនេះ ជាអនុសាសន៍សម្រាប់បន្តឲ្យកាន់តែប្រសើរឡើង។ លើសពីនេះទៀត ដើម្បីអនុវត្ត TMP ឲ្យបានជោគជ័យ ចាំបាច់ត្រូវរៀបចំកែលម្អស្ថាប័ន និងការគ្រប់គ្រងនាពេលបច្ចុប្បន្ន។ ការផ្តួចផ្តើមចម្បងដែលមានចែងនៅក្នុងTMP មានសង្ខេបយ៉ាងខ្លីនៅផ្នែកខាងចុងបញ្ចប់នៃឯកសារដែលជាចំណុចសំខាន់សម្រាប់អ្នកធ្វើការសម្រេចចិត្ត។

## សកម្មភាពជាអាទិភាព

ដោយសារការអនុវត្តTMP និងការផ្តួចផ្តើមគោលនយោបាយគន្លឹះ នឹងចំណាយពេលវេលាច្រើន មានសេចក្តីសង្ខេបខ្លីៗស្តីពីសកម្មភាព ដោយរួមបញ្ចូលទាំងសកម្មភាពដែលអាចអនុវត្តភ្លាមៗនិងជាបន្ទាន់ ក៏ដូចជាគម្រោងបន្ថែមទៀតដែលមានសារៈសំខាន់ក្នុងការសម្រេចចិត្តប្រកបដោយព័ត៌មានជាក់លាក់និងគ្រប់គ្រាន់។

## សទ្ទានុក្រម

TMP ក៏រួមបញ្ចូលផងដែរនូវសទ្ទានុក្រមស្តីពីពាក្យដែលបានប្រើជាទូទៅ។




# គុណតម្លៃបេតិកភណ្ឌអង្គរ




ប្រជាជនកម្ពុជានិងប្រជាជននៅលើពិភពលោក ទទួលស្គាល់គុណតម្លៃបេតិកភណ្ឌវប្បធម៌របស់អង្គរគ្រប់កាលៈទេសៈទាំងអស់។ មានការវាយតម្លៃជាច្រើនដែលទទួលស្គាល់គុណតម្លៃបេតិកភណ្ឌនេះ។

<u>សម្រង់សេចក្តីថ្លែងការណ៍ស្តីពីគុណតម្លៃជាសាកលនៃតំបន់បេតិកភណ្ឌពិភពលោកអង្គរ</u>

អង្គរត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៅខែធ្នូ ឆ្នាំ១៩៩២ ដោយឈរលើមូលដ្ឋានថាខ្លួនបានបំពេញនូវលក្ខណៈវិនិច្ឆ័យទាំងបួនស្របតាមអនុសញ្ញាបេតិកភណ្ឌ

ពិភពលោក។ លក្ខណៈវិនិច្ឆ័យទាំងនេះ ត្រូវបានពិពណ៌នានៅក្នុងរបាយការណ៍ក្រុមប្រឹក្សាអន្តរជាតិ (ICOMOS) លេខ៦៦៧ (ខែកញ្ញាឆ្នាំ១៩៩២) ដូចខាងក្រោម៖

*(i)- អង្គរតំណាងឲ្យសិល្បៈខ្មែរទាំងមូល ពីសតវត្សទី៩ដល់សតវត្សទី១៤ និងរួមបញ្ចូលទាំងស្នាដៃសិល្បៈល្អឯកដែលមិនអាចបដិសេធបានជាច្រើនទៀត (ឧទាហរណ៍ អង្គរវត្ត បាយ័ន បន្ទាយស្រី)។*

*(ii)-ឥទ្ធិពលសិល្បៈខ្មែរ ដែលបានវិវឌ្ឍរីកចម្រើនខ្លាំងនៅអង្គរ គឺជាស្នាដៃសិល្បៈដ៏អស្ចារ្យដែលបានជះឥទ្ធិពលលើតំបន់ជាច្រើននៅអាស៊ីអាគ្នេយ៍ និងដើរតួនាទីយ៉ាងសំខាន់ក្នុងការវិវត្តដាច់ដោយឡែករបស់ខ្លួន។*

*(iii)- វិសាលភាពចក្រភពខ្មែរនៅសតវត្សទី៩-១៤ បានគ្រប់ដណ្តប់ស្ទើរពាសពេញតំបន់អាស៊ីអាគ្នេយ៍ និងបានដើរតួនាទីអភិវឌ្ឍនយោបាយនិងវប្បធម៌នៅក្នុងតំបន់។ អ្វីដែលបន្សល់ទុកពីអរិយធម៌នោះគឺបេតិកភណ្ឌដ៏ស្មុគស្មាញនៃរចនាសម្ព័ន្ធវប្បធម៌របស់ខ្លួនដោយការកសាងពីឥដ្ឋនិងថ្ម។*

*(iv)- ស្ថាបត្យកម្មខ្មែរភាគច្រើនបានវិវត្តមកពីឧបទ្វីបឥណ្ឌា ដែលបន្តិចក្រោយមកបានធ្វើឲ្យមានលក្ខណៈប្លែកគ្នាយ៉ាងច្បាស់ នៅពេលដែលស្ថាបត្យកម្មខ្មែរបានវិវឌ្ឍរីកចម្រើនជាលក្ខណៈពិសេសផ្ទាល់របស់ខ្លួន។ ស្ថាបត្យកម្មមួយចំនួនវិវឌ្ឍដាច់ដោយឡែក ហើយស្ថាបត្យកម្មផ្សេងទៀតបានទទួលឥទ្ធិពលពីប្រពៃណីវប្បធម៌ប្រទេសជិតខាង។ ជាលទ្ធផលគឺមានដែនវិសាលភាពសិល្បៈថ្មីមួយនៅក្នុងសិល្បៈ និងស្ថាបត្យកម្មបូព៌ាប្រទេស។*

សេចក្តីថ្លែងការណ៍ខ្លីទាំងនេះ បង្ហាញពីគុណតម្លៃសោភណភាពឆ្នើមខាងសិល្បៈ ស្ថាបត្យកម្ម និងបុរាណវិទ្យានៅតំបន់បេតិកភណ្ឌពិភពលោកអង្គរ ប៉ុន្តែមិនបានសរុបនូវគុណតម្លៃពេញលេញរបស់តំបន់បេតិកភណ្ឌអង្គរនោះទេ។ នៅក្នុងឆ្នាំ ២០១១ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំសេចក្តីថ្លែងការណ៍ស្តីពីគុណតម្លៃជាសកល(RSOUV) របស់អង្គរឡើងវិញ តាមសំណើរបស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក។ បន្ថែមលើលក្ខណវិនិច្ឆ័យទាំងបួននៅពេលចុះបញ្ជី សេចក្តីថ្លែងការណ៍ថ្មីនេះ មានបង្ហាញពីគុណតម្លៃសាសនា ប្រជាជនក្នុងតំបន់ និងបេតិកភណ្ឌអរូបីនៅអង្គរផងដែរ។ សេចក្តីថ្លែងការណ៍ស្តីពីគុណតម្លៃជាសកលឆ្លើយតបតាមលក្ខណៈវិនិច្ឆ័យរបស់បេតិកភណ្ឌពិភពលោកមានសង្ខេបដូចខាងក្រោម៖

# សេចក្តីថ្លែងការណ៍ស្តីពីគុណតម្លៃជាសកលរបស់អង្គរ

## ▪ សេចក្តីសំយោគសង្ខេប

*តាមការចងចាំពីអតីតកាល សំណល់បុរាណវិទ្យាចន្លោះសតវត្សទី៩និងទី១៤ជាច្រើន ក្នុងខេត្តសៀមរាបដែលស្ថិតនៅភាគខាងជើងប្រទេសកម្ពុជាបច្ចុប្បន្ន បានបង្កើតជាអត្តសញ្ញាណខ្មែរ។ អង្គរជាតំបន់ភូមិសាស្ត្រមួយដែលមានប្រាសាទនិងបុរាណវត្ថុដែលគួរឲ្យកត់សម្គាល់ជាច្រើន តំណាងឲ្យគុណតម្លៃសាសនា និងស្នាដៃសិល្បៈតុបតែងលម្អយ៉ាងប៉ិនប្រសប់ ស៊ីចង្វាក់គ្នាជាមួយនឹងការធ្វើផែនការរៀបចំទីក្រុង។ គុណតម្លៃដ៏អស្ចារ្យទាំងនេះបានកកើតឡើងនៅក្នុងសម័យអង្គរ ដោយបង្ហាញពីអំណាចដ៏មហិមា និងជំហរដ៏រឹងមាំ។ ប្រាសាទដ៏ល្អឆើតឆាយត្រូវបានសាងសង់នៅចំចំណុចកណ្តាលនៃរាជធានីនីមួយៗជាបន្តបន្ទាប់ដោយមានកសិន្ធុទឹកព័ន្ធជុំវិញ ហើយ "បារាយណ៍" (អាងស្តុកទឹកដ៏ធំ) និងប្រឡាយទឹកនៅតែបង្ហាញពីភាពលេចធ្លោនៃអារ្យធម៌ខ្មែរកាលពីសម័យបុរាណ។*

*ប្រាសាទស្ថិតនៅជាមួយព្រៃរបោះ វាលស្រែ និងដើមឈើធំៗរប៉េះរប៉ោះ។ ស្ទឹងសៀមរាបដែលជាផ្នែកទាំងមូលនៃប្រព័ន្ធធារាសាស្ត្រតំបន់អង្គរ មានប្រភពពីខ្ពង់រាបភ្នំគូលែន នៅភាគឦសានហូរកាត់តាមតំបន់អង្គរ រួចហូរចាក់ចូលទៅក្នុងបឹងទន្លេសាប។*

*ប្រាសាទនេះមានទីតាំងស្ថិតនៅជាក្រុម ហើយជាទូទៅប្រាសាទទាំងនេះត្រូវបានចាត់ថ្នាក់ទៅតាមទីតាំងភូមិសាស្ត្រដែលខ្លួនស្ថិតនៅ ពីព្រោះមានការលំបាកក្នុងការចាត់ទៅតាមក្រុមដោយផ្អែកទៅលើអ្នកដែលកសាងប្រាសាទទាំងនោះ។*

*ឧទ្យាននេះមានមនុស្សតាំងទីលំនៅ និងមានភូមិជាច្រើនដែលក្នុងនោះ មានអ្នកខ្លះមានដូនតារស់នៅបន្តជំនាន់ជាហូរហែតាំងពីសម័យអង្គរមកម្ល៉េះ ដោយពួកគាត់បានរស់នៅរាយប៉ាយពាសពេញតំបន់អង្គរទាំងមូល។ ប្រជាជនប្រកបរបរកសិកម្ម ពោលគឺធ្វើស្រែចំការ។*

## ▪ លក្ខណៈវិនិច្ឆ័យ

***លក្ខណៈវិនិច្ឆ័យទី១*** *: អង្គរតំណាងឲ្យសិល្បៈខ្មែរទាំងមូល ពីសតវត្សទី៩ដល់សតវត្សទី១៤ និងរួមបញ្ចូលទាំងស្នាដៃសិល្បៈល្អឯកដែលមិនអាចបដិសេធបានជាច្រើនទៀត (ឧទាហរណ៍ អង្គរវត្ត បាយ័ន បន្ទាយស្រី)។*

***លក្ខណៈវិនិច្ឆ័យទី២*** *: ឥទ្ធិពលសិល្បៈខ្មែរដែលបានវិវឌ្ឍរីកចម្រើនខ្លាំងនៅអង្គរ គឺជាស្នាដៃសិល្បៈដ៏អស្ចារ្យដែលបានជះឥទ្ធិពលលើតំបន់ជាច្រើននៅអាស៊ីអាគ្នេយ៍ និងដើរតួនាទីយ៉ាងសំខាន់ក្នុងការវិវត្តដាច់ដោយឡែករបស់ខ្លួន។*

***លក្ខណៈវិនិច្ឆ័យទី៣*** *: វិសាលភាពចក្រភពខ្មែរនៅសតវត្សទី៩-១៤ បានគ្រប់ដណ្តប់ស្ទើរពាសពេញតំបន់អាស៊ីអាគ្នេយ៍ និងបានដើរតួនាទីអភិវឌ្ឍនយោបាយនិងវប្បធម៌នៅក្នុងតំបន់។ អ្វីដែលបន្សល់ទុកពីអរិយធម៌នោះគឺបេតិកភណ្ឌដ៏ស្ដុកស្ដម្ភនៃរចនាសម្ព័ន្ធវប្បធម៌របស់ខ្លួនដោយការកសាងពីឥដ្ឋនិងថ្ម។*

***លក្ខណៈវិនិច្ឆ័យទី៤*** *: ស្ថាបត្យកម្មខ្មែរភាគច្រើនបានវិវត្តមកពីឧបទ្វីបឥណ្ឌា ដែលបន្តិចក្រោយមកបានធ្វើឲ្យមានលក្ខណៈប្លែកគ្នាយ៉ាងច្បាស់ នៅពេលដែលស្ថាបត្យកម្មខ្មែរបានវិវឌ្ឍរីកចម្រើនលក្ខណៈពិសេសផ្ទាល់របស់ខ្លួន។ ស្ថាបត្យកម្មមួយចំនួនវិវឌ្ឍដាច់ដោយឡែក ហើយស្ថាបត្យកម្មផ្សេងទៀតបានទទួលឥទ្ធិពលពីប្រពៃណី វប្បធម៌ប្រទេសជិតខាង។ ជាលទ្ធផលគឺមានដែនវិសាលភាពសិល្បៈថ្មីមួយនៅក្នុងសិល្បៈនិងស្ថាបត្យកម្មបូព៌ាប្រទេស។*





របាយការណ៍ស្តីពីគុណតម្លៃបេតិកភណ្ឌនិងបញ្ហានានា(ខែសីហា ឆ្នាំ២០០៨)

ការស្រាវជ្រាវរបស់ អាជ្ញាធរអប្សរានិងដៃគូអន្តរជាតិ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ បានរកឃើញបន្ថែមទៀតនូវគុណតម្លៃខាងវិទ្យាសាស្ត្រ អត្តសញ្ញាណនិងសង្គម ដែលគុណតម្លៃទាំងនេះជាផ្នែកមួយបង្ហាញពីសារៈសំខាន់និងអត្ថន័យនៃអង្គរ។

ការគ្រប់គ្រងនិងការពារគុណតម្លៃអង្គរ មានសារៈសំខាន់ណាស់ចំពោះការអភិរក្សនិងអភិវឌ្ឍតំបន់អង្គរប្រកបដោយចីរភាព។ ឯកសារ *"អង្គរៈ របាយការណ៍ស្តីពីគុណតម្លៃបេតិកភណ្ឌនិងបញ្ហានានា(ខែសីហា ឆ្នាំ២០០៨)"* ដែលរៀបចំឡើងក្នុងក្របខ័ណ្ឌគម្រោង

ការរស់នៅជាមួយបេតិកភណ្ឌ (២០០៥-២០០៩) បានផ្តល់នូវការវិភាគលម្អិតពីគុណតម្លៃធម្មជាតិនិងវប្បធម៌នៃអង្គរ។ របាយការណ៍នេះ លើកឡើងបន្ថែមពីការអភិរក្ស និងការគ្រប់គ្រងគុណតម្លៃទាំងនេះ។ របាយការណ៍នេះមានដូចខាងក្រោម៖

*អង្គរជាអតីតរាជធានីដ៏អស្ចារ្យ ផ្តុំទៅដោយគុណតម្លៃបេតិកភណ្ឌទាំងរូបីនិងអរូបី។ បញ្ហាប្រឈមចម្បងនៅអង្គរគឺការការពារនិងការគ្រប់គ្រងបេតិកភណ្ឌទាំងនេះ។ ការយល់ដឹងដ៏ទូលំទូលាយពីគុណតម្លៃទាំងនេះមានសារៈសំខាន់ខ្លាំងណាស់ ដើម្បីយល់ដឹងពីការគំរាមកំហែង និងបញ្ហានៅអង្គរកាន់តែច្បាស់។*

*បច្ចុប្បន្នការគ្រប់គ្រងគុណតម្លៃបុរាណវិទ្យានៅអង្គរ ប្រឈមនឹងបញ្ហាជាច្រើន រួមមានតម្រូវការក្នុងការអភិរក្ស និងការបកស្រាយខាងបុរាណវិទ្យា ខណៈដែលប្រជាជនមានសិទ្ធិបន្តជីវភាពប្រចាំថ្ងៃរបស់ខ្លួននៅក្នុងតំបន់អង្គរ។ ការផ្លាស់ប្តូរនៃការប្រើប្រាស់ដី បច្ចេកវិទ្យាថ្មី និងកត្តាសេដ្ឋកិច្ច ដូចជាការប្រែប្រួលប្រជាសាស្ត្រដោយសារនគរូបនីយកម្ម បានគំរាមកំហែងចំពោះភស្តុតាងបុរាណវិទ្យា។*

*តម្លៃសោភណភាពអង្គរបានទាក់ទាញវិស័យទេសចរណ៍នៅអង្គរឲ្យរីកចម្រើនយ៉ាងខ្លាំង។ ចាំបាច់ត្រូវត្រួតពិនិត្យនិងធ្វើអន្តរាគមន៍ ដើម្បីទប់ស្កាត់ការបាត់បង់គុណតម្លៃដោយសារសកម្មភាពមិនសមរម្យ(ឧទាហរណ៍ ដូចជារថយន្តក្រុងតម្រង់ជួរវៀងរាល់ថ្ងៃនៅអង្គរធំ)។*

*តំបន់អង្គរគឺជាទីសក្ការៈដែលតម្រូវឲ្យបន្តផ្តល់ឱកាសដល់ប្រជាជនក្នុងតំបន់ចូលរួមក្នុងការប្រតិបត្តិតាមបែបប្រពៃណី និងតម្រូវឲ្យភ្ញៀវទេសចរមានអាកប្បកិរិយាសមរម្យ។ ការគោរពប្រណិប័តចំពោះអង្គរ ថាជាកន្លែងដ៏ពិសិដ្ឋ តម្រូវឲ្យមានការផ្លាស់ប្តូរការប្រតិបត្តិមួយចំនួនពីសំណាក់ទេសចរ(តាំងពីការស្លៀកពាក់របស់ភ្ញៀវ និងការពន្យល់របស់មគ្គុទ្ទេសក៍ក៏ដូចជាឥរិយាបថក្នុងការបរិយាយរបស់ពួកគាត់)។*

*ប្រជាជននៅតំបន់អង្គរគួរទទួលបានឱកាសប្រតិបត្តិប្រពៃណីខ្លួនទៅតាមស្ថានភាពរស់នៅ និងទិដ្ឋភាពជាក់ស្តែងនៅក្នុងតំបន់។ ស្របពេលជាមួយគ្នានេះ ពួកគាត់ក៏អាចរស់នៅដោយសប្បាយរីករាយជាមួយនឹងការរីកចម្រើននៃសង្គម និងទទួលអត្ថប្រយោជន៍ពីបេតិកភណ្ឌពិភពលោកអង្គរ។*

*ការគ្រប់គ្រងត្រូវតែទទួលស្គាល់ថា ជំនឿអរូបីនិងការប្រតិបត្តិវប្បធម៌ គឺជាផ្នែកមួយនៃគុណតម្លៃបេតិកភណ្ឌអង្គរ។ ប្រជាជន បរិស្ថាន ការប្រតិបត្តិវប្បធម៌ សកម្មភាពនានារបស់ទេសចរ និងសេដ្ឋកិច្ចក្នុងតំបន់ មិនអាចបំបែកចេញពីគ្នានិងត្រូវមានការវិវត្តរួមគ្នា។*

*ដូចនេះ ការគ្រប់គ្រងនាពេលអនាគត តម្រូវឲ្យរក្សាចំណាងទាំងនេះដើម្បីផ្សារភ្ជាប់គុណតម្លៃទាំងនេះ។*

<u>សេចក្តីថ្លែងការណ៍របស់ ICC-Angkorខែឧសភា ឆ្នាំ២០១០ (ឧសភា ២០១០)</u>

គណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍរមណីយដ្ឋានប្រវត្តិសាស្រ្តអង្គរ(ឧសភា ២០១០) បានទទួលស្គាល់លក្ខណសម្បត្តិរមណីយដ្ឋានអង្គរ ដែលបានបញ្ជាក់នៅក្នុងរបាយការណ៍ "អង្គរៈ របាយការណ៍ស្តីពីគុណតម្លៃបេតិកភណ្ឌនិងបញ្ហានានា" ហើយបានគូសបញ្ជាក់ពីលក្ខណៈនៃតំបន់អង្គរដូចតទៅៈ

*១- អង្គរ គឺជាឧទ្យានបុរាណវិទ្យាមួយដែលបង្ហាញពីទម្រង់ប្រាសាទមហាស្ចារ្យរាប់សតវត្សនិងសំណល់រាជធានីដែលកសាងនៅពីលើគ្នា។ តំបន់ប្រាសាទនិងប្រាសាទនានាដែលលាតសន្ធឹងលើទេសភាព មួយដែលអាចសម្គាល់បាន តាមរយៈសមាសធាតុជារចនាសម្ព័ន្ធនៃភាពសំខាន់ខាងប្រវត្តិសាស្ត្រ (ផ្លូវបុរាណសំខាន់ៗ បារាយណ៍ គូទឹក និងប្រឡាយ ស្ពាន) ឬសមាសធាតុបន្ថែមនាពេលថ្មីៗនេះទៀតគឺ (ផ្លូវថ្នល់និងច្រកចូលក្នុងតំបន់បរិវេណប្រាសាទ)។*

*២- អង្គរមានបរិស្ថានធម្មជាតិ ដែលមិនអាចកាត់ផ្តាច់បានពីប្រាសាទ ដោយមានជារចនាសម្ព័ន្ធព្រៃព្រឹក្សា និងគម្របបៃតងជាច្រើនប្រភេទ និងទម្រង់សណ្ឋានដីដែលកំណត់ទេសភាព(ខ្ពង់រាបគូលែន រួមទាំងភ្នំនិងកូនភ្នំដទៃទៀត) និងប្រព័ន្ធធារាសាស្ត្រដែលនៅតែរំលឹកឲ្យឃើញនូវជំនាញខាងវិស្វកម្មធារាសាស្ត្រ។*

*៣- រមណីយដ្ឋានអង្គរមានមនុស្សរស់នៅនិងធ្វើការប្រមាណ១០០ ០០០នាក់ មាន១១២ភូមិលើផ្ទៃដី៤០ ០០០ហិកតា ដែលបានដាក់បញ្ចូលទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។ សកម្មភាពចម្បងគឺវិស័យកសិកម្ម ប៉ុន្តែសហគមន៍ក៏ចូលរួមផងដែរ នៅក្នុងឧស្សាហកម្មទេសចរណ៍ជាលក្ខណៈគ្រួសារ និងសកម្មភាពពាណិជ្ជកម្មនៅតាមកន្លែងផ្សេងៗ។*

*៤- អង្គរជាទីប្រតិបត្តិសាសនា ដែលក្នុងនោះមានវត្តអារាមជាច្រើនកំពុងប្រណិប័តន៍យ៉ាងសកម្ម។*

*៥- អង្គរជាគោលដៅទេសចរណ៍ដ៏ល្បីល្បាញ ដែលកំពុងតែទទួលបានការពេញនិយមកាន់តែខ្លាំងឡើងៗ ខណៈដែលកិច្ចប្រឹងប្រែងក្នុងការស្រាវជ្រាវ អភិរក្ស បង្ហាញ និងជំរុញការផ្សព្វផ្សាយពីតំបន់អង្គរ បានជួយឲ្យមានទីតាំងទស្សនាកាន់តែច្រើន និងបង្ហាញពីសកម្មភាពនានាដែលភ្ញៀវទេសចរអាចចាប់អារម្មណ៍។*

ដើម្បីគ្រប់គ្រងទេសចរណ៍នៅអង្គរប្រកបដោយប្រសិទ្ធភាពនិងចីរភាព យើងទាំងអស់គ្នាត្រូវតែយល់ដឹងនិងការពារគុណតម្លៃបេតិកភណ្ឌ។ ការផ្តួចផ្តើមគោលនយោបាយនៅក្នុង TMP ត្រូវបានតាក់តែងឡើងដើម្បីការពារនិងលើកកម្ពស់គុណតម្លៃបេតិកភណ្ឌអង្គរ។





# បញ្ហាចម្បង




បញ្ហាជាច្រើនបានជះឥទ្ធិពលដល់វិស័យទេសចរណ៍នៅអង្គរ។ ខណៈដែលអាជ្ញាធរអប្សរាខិតខំប្រឹងប្រែងគ្រប់គ្រងវិស័យទេសចរណ៍ កំណើនចំនួនទេសចរយ៉ាងលឿនបានបណ្តាលឲ្យមានផលប៉ះពាល់ដោយផ្ទាល់និងដោយប្រយោលពីទេសចរណ៍ និងគំរាមកំហែងដល់សេចក្តីថ្លៃថ្នូរនៃគុណតម្លៃបេតិកភណ្ឌពិភពលោកអង្គរ។ បញ្ហាទាំងនេះ បានធ្វើឲ្យរាជរដ្ឋាភិបាលកម្ពុជា ICC-Angkor សហគមន៍អភិរក្សអន្តរជាតិ និងភាគីពាក់ព័ន្ធដទៃទៀតមានការចាប់អារម្មណ៍យ៉ាងខ្លាំង។ បើទោះបីជាមានកិច្ចខិតខំប្រឹងប្រែងដើម្បី កាត់បន្ថយផល

ប៉ះពាល់ពីវិស័យទេសចរណ៍ក៏ដោយ ក៏នៅមានបញ្ហាជាច្រើនដែលយើងត្រូវយកចិត្តទុកដាក់ជាបន្ទាន់។ បញ្ហាចម្បងៗទាំងនោះរួមមាន៖

**១- ការគ្រប់គ្រងអ្នកទស្សនានៅអង្គរខណៈដែលចំនួនអ្នកទស្សនាកើនឡើង**

ខណៈដែលចំនួនអ្នកទស្សនានៅប្រាសាទអង្គរបន្តកើនឡើង ចាំបាច់ត្រូវត្រួតពិនិត្យលើវិស័យទេសចរណ៍ឲ្យបានល្អជាងមុន។ ចាំបាច់ត្រូវកំណត់ចំនួនអ្នកទស្សនានិងពេលវេលាទស្សនាប្រាសាទ។ បើគ្មានការត្រួតពិនិត្យនិងការដាក់កំណត់បែបនេះទេ គុណតម្លៃរូបីនិងអរូបីនៃបេតិកភណ្ឌអង្គរអាចនឹងមានហានិភ័យ ហើយគុណភាពនៃបទពិសោធអ្នកទស្សនានឹងធ្លាក់ចុះ ហើយការគ្រប់គ្រងប្រកបដោយគុណភាពនៅអង្គរ និងរូបភាពកម្ពុជានៅលើឆាកអន្តរជាតិនឹងរងផលប៉ះពាល់។

ការគ្រប់គ្រងអ្នកទស្សនានៅអង្គរ ទាមទារឲ្យមានការពិចារណាលើសមត្ថភាពផ្ទុកនៃតំបន់ប្រាសាទនិងប្រាសាទនីមួយៗ ព្រមទាំងការពិនិត្យយ៉ាងល្អិតល្អន់លើការកកស្ទះនិងការបែងចែកភ្ញៀវនៅតាមទីតាំងនិងពេលវេលា។ ការកើនឡើងនៃចំនួនអ្នកទស្សនា បានធ្វើឲ្យមានភាពកកកុញលើសលប់នៅទីតាំងនិងពេលវេលាផ្សេងគ្នា។ ប្រាសាទមួយចំនួនមានភ្ញៀវទស្សនាច្រើន ដែលនាំឲ្យមានការកកស្ទះដោយសារសមត្ថភាពផ្ទុករបស់ប្រាសាទទាំងនោះមានកម្រិតទាប។ ប្រាសាទខ្លះរងផលប៉ះពាល់ខ្លាំងដោយសារមានលំហូរអ្នកទស្សនាច្រើននៅពេលតែមួយ ដូចជានៅពេលថ្ងៃលិចជាដើម។ ចាំបាច់ត្រូវផ្តល់ឱកាសនិងបទពិសោធផ្សេងៗ ដើម្បីបញ្ចៀសភ្ញៀវទេសចរពីប្រាសាទដែលមានភ្ញៀវទស្សនាច្រើន និងដើម្បីបែងចែកភ្ញៀវទេសចរទៅតាមប្រាសាទដទៃទៀត។

**២- ការយល់ដឹងនិងផ្សព្វផ្សាយពីគុណតម្លៃបេតិកភណ្ឌ**

គុណតម្លៃបេតិកភណ្ឌអង្គរ មិនទាន់មានការពណ៌នានិងឯកភាពពេញលេញនៅឡើយទេ។ ឧទាហរណ៍សេចក្តីថ្លែងការណ៍ជាផ្លូវការនៅពេលចុះតំបន់អង្គរក្នុងបញ្ជីបេតិកភណ្ឌពិភពលោក មិនដាក់បញ្ចូលគុណតម្លៃធម្មជាតិ ហើយក៏មិនទទួលស្គាល់តួនាទីរបស់អង្គរថាជាកន្លែងប្រណិប័តសាសនាតាំងពីយូរលង់ណាស់មកហើយនោះទេ។ នៅតំបន់អង្គរ ការបកស្រាយព័ត៌មាននៅមានកម្រិតនិងមិនស៊ីចង្វាក់គ្នានៅឡើយ ដែលប្រការនេះធ្វើឲ្យអ្នកទស្សនា មិនបានយល់ដឹងច្បាស់ពីទីកន្លែង និងគុណតម្លៃបេតិកភណ្ឌ។ ការបកស្រាយព័ត៌មាននៅតំបន់អង្គរគួរតែបង្ហាញពីគុណតម្លៃបរិស្ថាន ធារាសាស្រ្ត និងសង្គមវប្បធម៌ ដល់ភ្ញៀវទេសចរ មគ្គុទ្ទេសក៍ និងប្រតិបត្តិករក្នុងវិស័យទេសចរណ៍ បន្ថែមលើការលើកកម្ពស់បទពិសោធទស្សនាដោយផ្អែកលើគុណតម្លៃបុរាណវិទ្យា សោភណភាព

ស្ថាបត្យកម្ម ឬសិល្បៈតែមួយមុខ។ ដោយឡែក អង្គរគឺជាឋានពិសិដ្ឋមួយ ប៉ុន្តែភ្ញៀវទេសចរ មគ្គុទ្ទេសក៍ និងប្រតិបត្តិករមួយចំនួនមិនបានគោរពគុណតម្លៃសាសនានេះនោះទេ។

## ៣. ផលប៉ះពាល់ដល់រមណីយដ្ឋាន

ដោយសារកិច្ចខំប្រឹងប្រែងរបស់អាជ្ញាធរអប្សរាក្នុងការសម្អាតបរិស្ថាន អង្គរបានក្លាយជារមណីយដ្ឋានដ៏ស្អាតបំផុតមួយនៅលើពិភពលោក។ ទោះជាយ៉ាងណាក៏ដោយ ក៏វិស័យទេសចរណ៍កំពុងបង្កផលប៉ះពាល់ទៅលើរចនាសម្ព័ន្ធប្រាសាទ និងជះឥទ្ធិពលទៅលើសង្គមនិងវប្បធម៌ តាមរយៈអាកប្បកិរិយាមិនសមរម្យធ្វើឲ្យប៉ះពាល់បរិស្ថាន និងការប្រែប្រួលទឹកនៅក្រោមដី។ ខណៈដែលអាជ្ញាធរអប្សរាកំពុងចំណាយប្រាក់៣០ ០០០ដុល្លារក្នុងមួយខែ ដើម្បីយកសំរាមចេញពីតំបន់ប្រាសាទទាំងមូល ការកកស្ទះចរាចរណ៍ ការបោះចោលសំរាម និងការចតរថយន្តមិនត្រឹមត្រូវបានជះឥទ្ធិពលអវិជ្ជមានទៅលើបរិស្ថាន។ ផលប៉ះពាល់ជាក់ស្តែងលើទេសភាព និងប្រាសាទអាចមើលឃើញយ៉ាងងាយ រួមមានការខូចខាតប្រាសាទ ការកើនឡើងនូវស្នាមប្រេះ និងការប្រែប្រួលរចនាសម្ព័ន្ធប្រាសាទ និងការសឹករេចរិលផ្លូវនៅកន្លែងដែលមានភ្ញៀវទស្សនាច្រើន។ ផលប៉ះពាល់បន្ថែមផ្សេងទៀតពាក់ព័ន្ធនឹងសម្ពាធនៃការអភិវឌ្ឍន៍ ដោយសារកំណើនប្រជាជនក្នុងតំបន់អង្គរនិងក្រុងសៀមរាប មានដូចជាការគ្រប់គ្រងកាកសំណល់ ផលប៉ះពាល់លើគុណភាពនិងការផ្គត់ផ្គង់ទឹកសម្រាប់រយៈពេលវែង និងប្រព័ន្ធដឹកជញ្ជូនមិនគ្រប់គ្រាន់ដែលនាំឲ្យបំពុលបរិយាកាសកាន់តែខ្លាំងឡើងៗ។





## ៤- បទពិសោធ អាកប្បកិរិយានិងសុវត្ថិភាពអ្នកទស្សនា

បទពិសោធអ្នកទស្សនាអាស្រ័យលើកត្តាទីផ្សារឧស្សាហកម្មទេសចរណ៍ រួមជាមួយនឹងប្រព័ន្ធគ្រប់គ្រងរបស់អាជ្ញាធរអប្សរា។ បច្ចុប្បន្ននេះ ការគ្រប់គ្រងទេសចរណ៍នៅអង្គរមិនទាន់បានឆ្លើយតបដោយផ្ទាល់ទៅតាមតម្រូវការទីផ្សារផ្សេងៗគ្នានោះទេ ហើយបញ្ហាអាចកើតមានឡើងនៅពេលដែលទីផ្សារខុសគ្នាប្រើប្រាស់ទីតាំងដូចគ្នា ក្នុងពេលតែមួយ ប៉ុន្តែមានការរំពឹងទុកនិងតម្រូវការខុសគ្នា។ ភ្ញៀវមួយចំនួនចូលចិត្តទស្សនាជាក្រុមធំៗ ហើយភ្ញៀវខ្លះទៀតចូលចិត្តធ្វើដំណើរជាលក្ខណៈឯកជននិងស្ងៀមស្ងាត់។ គុណភាពសេវាកម្មដែលផ្តល់ដោយឧស្សាហកម្មទេសចរណ៍ និងអាជ្ញាធរអប្សរាជះឥទ្ធិពលលើអាកប្បកិរិយា អ្នកទស្សនា។ ព័ត៌មាននិងអាកប្បកិរិយារបស់បុគ្គលិកគ្រប់គ្រង មគ្គុទ្ទេសក៍ និងប្រតិបត្តិករជះឥទ្ធិពលលើការគិត អារម្មណ៍ និងការប្រព្រឹត្តរបស់ភ្ញៀវទេសចរ ក៏ដូចជាកម្រិតសេវាកម្ម ដែលកត្តាទាំងនេះអាចបណ្តាលឲ្យប៉ះពាល់ឬជៀសវាងផលប៉ះពាល់ទៅលើតំបន់ប្រាសាទនានា។ ដើម្បីសុវត្ថិភាពនិងសន្តិសុខអ្នកទស្សនានៅអង្គរចាំបាច់ត្រូវពិគ្រោះយោបល់រកបញ្ហានានាមុននឹងរៀបចំផែនការគ្រប់គ្រងឲ្យបានល្អប្រសើរ។ ហានិភ័យចំពោះអ្នកទស្សនារួមមានកង្វះខាតសេវាកម្មសង្គ្រោះបឋម នីតិវិធីសង្គ្រោះបឋម គ្រឹះសំណង់មិនរឹងមាំនិងមានចំណោទខ្ពស់ៗ ការរំខានដោយអ្នកលក់ដូរតាមប្រាសាទនិងភ្ញៀវទេសចរដទៃទៀត។

## ៥- ហេដ្ឋារចនាសម្ព័ន្ធនិងការដឹកជញ្ជូន

ហេដ្ឋារចនាសម្ព័ន្ធបច្ចុប្បន្នមិនបានបំពេញតម្រូវការតាមកំណើនអ្នកទស្សនាឡើយ។ ត្រូវគ្រប់គ្រងលំហូរយានយន្តដឹកជញ្ជូនភ្ញៀវទេសចរបន្ថែមទៀត ដើម្បីកាត់បន្ថយការកកស្ទះចរាចរណ៍នៅក្នុងតំបន់បេតិកភណ្ឌពិភពលោកអង្គរ។ ត្រូវកែលម្អហេដ្ឋារចនាសម្ព័ន្ធចាំបាច់ចំនួននៅក្នុងនិងជុំវិញបរិវេណប្រាសាទបន្ថែមទៀត ដូចជាទីលានមុខប្រាសាទ បង្គន់ ចំណតរថយន្តក្រុង រថយន្ត និងរ៉ឺម៉ក ចិញ្ចើមផ្លូវ និងកន្លែងសម្រាក។

## ៦- ប្រជាជនក្នុងតំបន់

ប្រជាជនក្នុងតំបន់ជាច្រើនមិនទាន់ទទួលបានអត្ថប្រយោជន៍ពីកំណើនទេសចរណ៍នៅឡើយទេ។ អាជ្ញាធរអប្សរា កំពុងជំរុញការបង្កើតសហគមន៍ ដើម្បីឲ្យពួកគាត់ទទួលបានផលប្រយោជន៍សេដ្ឋកិច្ចពីវិស័យទេសចរណ៍។ ទោះជាយ៉ាងនេះក៏ដោយ ក៏នៅមានប្រជាជនជាច្រើនមិនទាន់មានលទ្ធភាពគ្រប់គ្រាន់ ក្នុងការទទួលបានផលប្រយោជន៍សេដ្ឋកិច្ចនិងឱកាសពីការរីកចម្រើននៃវិស័យទេសចរណ៍នៅតំបន់អង្គរនៅឡើយដែរ។ ប្រជាជនក្នុងតំបន់និងវត្តអារាម គឺជាអ្នករក្សាការពារបេតិកភណ្ឌអង្គរតាមរយៈប្រពៃណីវប្បធម៌ និងមានតួនាទីក្នុងវិស័យទេសចរណ៍ ក្នុងការផ្សព្វផ្សាយព័ត៌មានទៅកាន់ភ្ញៀវទេសចរអំពីគុណតម្លៃបេតិកភណ្ឌ។ ប្រជាជនក្នុងតំបន់ មានសេចក្តីរីករាយក្នុងការបង្ហាញពីការប្រតិបត្តិខាងវប្បធម៌របស់ពួកគេទៅភ្ញៀវទេសចរ ហើយការប្រតិបត្តិទាំងនេះ ត្រូវតែទទួលបាននូវការការពារ។ នៅពេលដែលចំនួនអ្នកទស្សនាកើនឡើង ប្រជាជនក្នុងតំបន់មានការព្រួយបារម្ភចំពោះការប្រតិបត្តិអាកប្បកិរិយាមិនសមរម្យ និងគ្មានការគោរពម្ចាស់ស្រុក និងបារម្ភពីការផ្លាស់ទីលំនៅ ខណៈដែលចំនួនអ្នកទស្សនាចេះតែកើនឡើង។






## ៧- ការចូលរួមស្វែងយល់ពីអ្នកពាក់ព័ន្ធ

ត្រូវពង្រឹងទំនាក់ទំនងរវាងអ្នកចូលរួមនៅក្នុងវិស័យទេសចរណ៍នៅអង្គរ ឲ្យបានរឹងមាំ ដើម្បីឲ្យភាគីពាក់ព័ន្ធដូចជា ស្ថាប័នរដ្ឋាភិបាល សហគមន៍ ប្រតិបត្តិករទេសចរណ៍ និងដឹកជញ្ជូន ហើយនិងមគ្គុទ្ទេសក៍ ប្រាស្រ័យទាក់ទងគ្នាកាន់តែប្រសើរឡើង។ មកទល់ពេល

បច្ចុប្បន្ន មិនទាន់មានការប្រាស្រ័យទាក់ទងល្អរវាងឧស្សាហកម្មទេសចរណ៍ និងអាជ្ញាធរអប្សរា ហេតុដូច្នេះហើយបានជាមានការយល់ច្រឡំ ការភាន់ច្រឡំ ឬសកម្មភាពមិនសមរម្យមួយចំនួន។ ចាំបាច់គួរមានការសម្របសម្រួល និងបំភ្លឺពីតួនាទី និងការទទួលខុសរបស់ភាគីពាក់ព័ន្ធនីមួយៗក្នុងការគ្រប់គ្រងវិស័យទេសចរណ៍នៅអង្គរ។

## ៨- អភិបាលកិច្ចល្អ

ដើម្បីគ្រប់គ្រងទេសចរណ៍ប្រកបដោយប្រសិទ្ធភាពនិងអភិបាលកិច្ចល្អ ត្រូវចាត់ចែងប្រើប្រាស់ធនធានមនុស្សនិងសម្ភារៈឲ្យបានត្រឹមត្រូវ និងត្រូវពង្រឹងច្បាប់និងបទដ្ឋាននានា។ មានឱកាសជាច្រើនដែលអាចជួយឲ្យយើងប្រមូលចំណូលពីវិស័យទេសចរណ៍មកប្រើប្រាស់សម្រាប់ការងារការពារ អភិរក្សនិងគ្រប់គ្រងនៅអង្គរបន្ថែមទៀត។ ជាក់ស្តែងអាជ្ញាធរអប្សរាបានប្រើប្រាស់ចំណូលពីទេសចរណ៍មួយផ្នែកធំ សម្រាប់ប្រើប្រាស់ក្នុងការអភិរក្សប្រាសាទនាពេលកន្លងមករួចមកហើយ។





## ដំណោះស្រាយបញ្ហាអ្នកទស្សនានៅប្រាសាទបន្ទាយស្រី

គម្រោងរៀបចំទីលានមុខប្រាសាទបន្ទាយស្រីជាការទទួលខុសត្រូវរបស់អាជ្ញាធរអប្សរា ដោយសហការជាមួយទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍន៍និងសហប្រតិបត្តិការ(SDC) ចន្លោះឆ្នាំ ២០០៧និង២០០៩ ដើម្បីគ្រប់គ្រងអ្នកទស្សនា និងរៀបចំតំបន់ប្រាសាទ ។ ការងារដែលបានធ្វើដោយអាជ្ញាធរអប្សរានៅក្នុងការរៀបចំនេះ អាចប្រើជាគំរូដើម្បីដោះស្រាយបញ្ហាអ្នកទស្សនាដែលមានលក្ខណៈស្រដៀងគ្នានៅទូទាំងតំបន់អង្គរ។

ប្រាសាទបន្ទាយស្រី មានទីតាំងស្ថិតនៅចម្ងាយ៣៧គីឡូម៉ែត្រ ពីក្រុងសៀមរាប ជាប្រាសាទមួយក្នុងចំណោមប្រាសាទនានា ដែលមានអ្នកចូលទស្សនាច្រើនជាងគេបំផុត នៅតំបន់អង្គរ ហើយទទួលរងផលប៉ះពាល់ជាពិសេស ដោយសារសម្ពាធលើសលប់ពីអ្នកទស្សនាទៅលើបរិវេណដ៏តូចចង្អៀតរបស់ប្រាសាទ។ ដោយទំហំប្រាសាទបន្ទាយស្រីនៅកំពែងខាងក្នុង មានផ្ទៃដីត្រឹមតែ២៤ម៉ែត្រក្រឡានិងផ្លូវដើរតូចចង្អៀត ធ្វើឲ្យភ្ញៀវទេសចរអាចចូលបានចំនួនតិចតួចបំផុតប៉ុណ្ណោះក្នុងពេលតែមួយ។ ការសិក្សារបស់អាជ្ញាធរអប្សរាមុនការរៀបចំទីធ្លាមុខប្រាសាទ បានបង្ហាញថាចំនួនភ្ញៀវទេសចរបានកើនលើសសមត្ថភាពផ្ទុកអតិបរមារបស់ប្រាសាទ ជាពិសេសក្នុងរដូវដែលមានទេសចរច្រើន(១៩០០នាក់/ថ្ងៃ) និងនៅថ្ងៃបុណ្យប្រពៃណីជាតិ(៦៥០០នាក់/ថ្ងៃ)។ ការសិក្សានានាក៏បានបង្ហាញផងដែរថា ភ្ញៀវជាងពាក់កណ្ដាលមកទស្សនាប្រាសាទនៅរវាងម៉ោង៩ ដល់១១ព្រឹក។ ចំណុចនេះនាំឲ្យមានការកកស្ទះភ្ញៀវទេសចរ នៅមុខទ្វារចូលនិងមុខចម្លាក់ដ៏ស្រស់ស្អាតនៅពាសពេញប្រាសាទទាំងមូល ធ្វើឲ្យមានបរិយាកាសទ្រហឹង អឺងកងនៅកណ្ដាលប្រាសាទ និងប៉ះពាល់ដល់ការអភិរក្សថ្មនិងចម្លាក់។ មានការគំរាមកំហែងដទៃទៀតផងដែរនៅផ្លូវចូល តំបន់ចំណត និងតូបលក់ដូរជាច្រើនក្បែរប្រាសាទ ដែលបង្កឲ្យមានការបំពុលនិងរេចរិលតំបន់ជុំវិញប្រាសាទ។





*ប្រាសាទបន្ទាយស្រីមុនពេលរៀបចំទីលានមុខប្រាសាទនិងផែនការអភិរក្ស និងប្លង់តំបន់ទីលានមុខប្រាសាទ (SDC ឆ្នាំ2007)*

គម្រោងទីលានមុខប្រាសាទបន្ទាយស្រី លើកឡើងពីផលប៉ះពាល់ពីភ្ញៀវទេសចរ ការដាក់កំណត់ចំនួនអ្នកទស្សនា និងការកែលម្អលំហូរអ្នកទស្សនា ក៏ដូចជាការផ្លាស់ប្តូរហេដ្ឋារចនាសម្ព័ន្ធ ដើម្បីវិថីផ្លូវ ចំណត និងតូបលក់ដូរចេញពីមុខប្រាសាទ។

## ការបង្កើតតំបន់អភិរក្សប្រាសាទ តំបន់ទ្រនាប់និងតំបន់ទទួលភ្ញៀវ

ដើម្បីការពារពីការបំផ្លិចបំផ្លាញតំបន់អភិរក្សប្រាសាទ អាជ្ញាធរអប្សរាបានបង្កើតតំបន់ទ្រនាប់និងតំបន់ទទួលភ្ញៀវថ្មី។ ទីលានមុខប្រាសាទមានទីតាំងស្ថិតនៅចុងខាងកើតនៃប្រាសាទលាតសន្ធឹងលើអ័ក្សកើត-លិច។ ផ្លូវនិងហេដ្ឋារចនាសម្ព័ន្ធដែលជាប់ពាក់ព័ន្ធទាំងអស់ដូចជា ចំណត ភោជនីយដ្ឋាន និងហាងទំនិញនានា ត្រូវបានប្តូរទីតាំងទៅខាងកើត។ បរិវេណជុំវិញជាប់នឹងប្រាសាទនៅក្នុងតំបន់អភិរក្សត្រូវបានការពារនិងដាំដើមឈើឡើងវិញ។

## ការបង្កើតវង់ទស្សនាថ្មី

មានការសាកល្បងជាច្រើនមុននឹងដាក់ដំណើរការវង់ទស្សនា ដើម្បីគ្រប់គ្រងលំហូរភ្ញៀវ។ វិធានការគ្រប់គ្រងលំហូរអ្នកទស្សនាគឺវង់ទស្សនាដែលមានផ្លូវចូលនិងចេញផ្សេងគ្នា ដើម្បីពង្រាយភ្ញៀវទេសចរនៅពាសពេញប្រាសាទ និងបង្ការមិនឲ្យពួកគាត់ដើរសាឡើងវិញ។ មានការដាក់សញ្ញាណែនាំនានាដើម្បីបង្ហាញពីទិសដៅទស្សនា និងបង្កើតច្រកចូលនិងចេញដាច់ដោយឡែកពីគ្នា ព្រមទាំងអាចធានាបាននូវការគ្រប់គ្រងសមត្ថភាពផ្ទុកអតិបរមានៅក្នុងប្រាសាទ។ វិធានការទាំងនេះបានធ្វើឲ្យគុណភាពនៃការទស្សនាប្រសើរឡើង កាត់បន្ថយការកកស្ទះ សំឡេងរំខាន និងភាពអ៊ូអរ។



*វង់ទស្សនានៅប្រាសាទបន្ទាយស្រី*







*ស្លាកសញ្ញានៅបន្ទាយស្រី*

វង់ទស្សនាថ្មីបានលើកទឹកចិត្តអ្នកទស្សនាឲ្យចាកចេញតាមច្រកខាងលិច និងត្រឡប់មកទីលានមុខប្រាសាទតាមផ្លូវខាងជើងនិងខាងត្បូង។ បើចេញតាមផ្លូវខាងជើងអ្នកទស្សនាអាចឃើញធម្មជាតិវាលស្រែ ត្រពាំង និងរានទស្សនាមួយចំនួន។

## សម្ភារៈរូបវន្តទេសចរណ៍

សម្ភារៈរូបវន្តទេសចរណ៍ដែលបានរៀបចំថ្មីរួមមាន បង្គន់ ហាងកាហ្វេ ហាងទំនិញ បន្ទប់សង្គ្រោះបឋម តុព័ត៌មាន/ការកក់ទុក បន្ទប់ផ្លាស់សម្លៀកបំពាក់ និងម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ។ នៅពេលបច្ចុប្បន្ន ម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិនិងបន្ទប់សង្គ្រោះបឋមមិនទាន់ដំណើរការនៅឡើយទេ។ អគារសម្ភារៈរូបវន្តនានាត្រូវបានសាងសង់តាមរចនាបថស្ថាបត្យកម្មនិងប្រពៃណីខ្មែរបច្ចុប្បន្ន។





*កន្លែងគយគន់ទេសភាពនៅជុំវិញប្រាសាទបន្ទាយស្រី*

## មជ្ឈមណ្ឌលស្វាគមន៍និងបកស្រាយព័ត៌មាន

នៅទីលានមុខប្រាសាទ មានកន្លែងណែនាំអ្នកទស្សនាអំពីសេវាកម្មនានារួមមានសម្ភារៈរូបវន្តនិងចំណត។ មជ្ឈមណ្ឌលស្វាគមន៍ភ្ញៀវទេសចរត្រូវបានបង្កើតឡើងដើម្បីផ្តល់ព័ត៌មានបឋមក្នុងការតម្រង់ទិសពីតំបន់ប្រាសាទនិងប្រាសាទ។ មានផ្ទាំងព័ត៌មានបង្ហាញពីប្រាសាទនិងវង់ទស្សនាក្នុងប្រាសាទ និងមានតុព័ត៌មានក៏ដូចជាផ្ទាំងព័ត៌មានដទៃទៀត។





*ផែនទីសម្រាប់ទស្សនាប្រាសាទបន្ទាយស្រីនិងផ្ទាំងព័ត៌មាននៅបន្ទាយស្រី*

មានមជ្ឈមណ្ឌលបកស្រាយព័ត៌មាននៅភាគខាងជើងនៃផ្លូវមុខប្រាសាទ ផ្តល់នូវព័ត៌មានពីប្រវត្តិសាស្ត្រដែលងាយស្រួលយល់ និងមានភាពទាក់ទាញពាក់ព័ន្ធនឹងប្រាសាទបន្ទាយស្រី។ ផ្ទាំងព័ត៌មានធ្វើឡើងជាពីរភាសាៈ ខ្មែរនិងអង់គ្លេស ដោយពន្យល់ពីប្រវត្តិសាស្ត្រ រចនាបថ ស្ថាបត្យកម្ម និងជំនឿសាសនា។

## តួលេខចំនួនភ្ញៀវទេសចរ

ការសិក្សានានារបស់អាជ្ញាធរអប្សរា បង្ហាញថាចំនួនអ្នកទស្សនានៅបន្ទាយស្រីមានស្ថិរភាព ចាប់តាំងពីចាប់ផ្តើមដាក់ឲ្យដំណើរការទីលានមុខប្រាសាទដែលជាមធ្យម មានអ្នកមកទស្សនា២០២២ នាក់ក្នុងមួយថ្ងៃ នៅក្នុងឆ្នាំ២០១០ និងចំនួន២០០២នាក់ក្នុងមួយថ្ងៃនៅក្នុងឆ្នាំ ២០១១ ។

# ការផ្តួចផ្តើមគោលនយោបាយ




គោលនយោបាយមូលដ្ឋាននាពេលអនាគត ក្នុងការគ្រប់គ្រងវិស័យទេសចរណ៍នៅអង្គរផ្អែកលើមូលដ្ឋានចំនួនបី។ ទីមួយ *គោលការណ៍គន្លឹះចេញពីផែនការមេស្តីពីការអភិវឌ្ឍន៍ទេសចរណ៍នៅអង្គរ ឆ្នាំ១៩៩៥*។ ទីពីរ *គោលការណ៍សម្រាប់វិស័យទេសចរណ៍ប្រកបដោយចីរភាពនៅតំបន់បេតិកភណ្ឌពិភពលោក ឆ្នាំ២០០៩* នៅក្នុងសិក្ខាសាលាស្តីពីវិស័យទេសចរណ៍ឈានទៅមុខប្រកបដោយចីរភាពនៅតំបន់បេតិកភណ្ឌវប្បធម៌និងធម្មជាតិនៅម៉ូហ្កាវ(Mogao) ប្រទេសចិន និងបានបង្ហាញជូនគណៈកម្មាធិបេតិកភណ្ឌពិភពលោក

ក្នុងឆ្នាំ២០១០ និងទីបី *គោលនយោបាយនៅក្នុងគម្រោងក្របខ័ណ្ឌគ្រប់គ្រងបេតិកភណ្ឌ*។ អង្គរគឺជាតំបន់បេតិកភណ្ឌពិភពលោក ដូច្នេះហើយ ការគ្រប់គ្រងនៅអង្គរ គួរតែប្រើប្រាស់គោលនយោបាយ និងគោលការណ៍ទាំងអស់ខាងលើ ជាមូលដ្ឋានសម្រាប់ការសម្រេចចិត្ត ការធ្វើផែនការ និងការវាយតម្លៃ។

**គោលការណ៍ចេញពីផែនការមេស្តីពីការអភិវឌ្ឍន៍វិស័យទេសចរណ៍ ឆ្នាំ១៩៩៥**

១. ពង្រឹង "គុណភាព" វិស័យទេសចរណ៍ និងអភិវឌ្ឍខេត្តសៀមរាបឲ្យក្លាយទៅជា "មជ្ឈមណ្ឌលទេសចរណ៍បេតិកភណ្ឌអន្តរជាតិ"

២. គ្រប់គ្រងលំហូរអ្នកទស្សនា បែងចែកភ្ញៀវទេសចរទៅតាមពេលវេលា និងនៅពាសពេញតំបន់ប្រាសាទ

៣. ពន្យារការស្នាក់នៅជាមធ្យម ដោយផ្តល់ជូនជាកញ្ចប់ទស្សនាដែលមានភាពទាក់ទាញ និងសម្បូរបែប

៤. លើកទឹកចិត្តឲ្យមានការទទួលបានផលហិរញ្ញវត្ថុពីវិស័យទេសចរណ៍ ដោយបង្កើតការងារដល់សហគមន៍ក្នុងតំបន់និងប្រជាជនកម្ពុជា

៥. បង្កើតការត្រួតពិនិត្យវិស័យទេសចរណ៍ ដោយមានស្ថាប័នមួយជាអ្នកទទួលខុសត្រូវ។

## គោលការណ៍សម្រាប់វិស័យទេសចរណ៍ប្រកបដោយចីរភាពនៅតំបន់បេតិកភណ្ឌពិភពលោក

### គោលការណ៍ទី១៖ រួមចំណែកក្នុងទិសដៅគ្រប់គ្រងបេតិកភណ្ឌពិភពលោក

ការអភិវឌ្ឍនវិស័យទេសចរណ៍និងសកម្មភាពអ្នកទស្សនានៅតំបន់បេតិកភណ្ឌពិភពលោក ត្រូវតែរួមចំណែកនិងមិនត្រូវធ្វើឲ្យប៉ះពាល់ដល់ការការពារ អភិរក្ស ផ្សព្វផ្សាយ និងផ្តល់ព័ត៌មានពីគុណតម្លៃបេតិកភណ្ឌឡើយ។ វិស័យទេសចរណ៍ក៏ត្រូវតែបង្កើតឲ្យមានការអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ចប្រកបដោយចីរភាព និងរួមចំណែកផ្តល់ផលប្រយោជន៍រូបី ក៏ដូចជាអរូបីប្រកបដោយសមធម៌ដល់មូលដ្ឋាននិងប្រជាជនក្នុងតំបន់ តាមវិធីដែលមានលក្ខណៈស៊ីចង្វាក់គ្នាជាមួយនឹងការអភិរក្សបេតិកភណ្ឌ។

### គោលការណ៍ទី២៖ ភាពជាដៃគូសហការ

តំបន់បេតិកភណ្ឌពិភពលោក គួរតែជាកន្លែងដែលអ្នកពាក់ព័ន្ធទាំងអស់ សហការគ្នាជាដៃគូប្រកបដោយប្រសិទ្ធភាពដើម្បីពង្រីកលទ្ធផលអភិរក្សនិងផ្សព្វផ្សាយ ដើម្បីកាត់បន្ថយការគំរាមកំហែងនិងផលប៉ះពាល់អវិជ្ជមានពីវិស័យទេសចរណ៍។

### គោលការណ៍ទី៣៖ យល់ដឹងជាសាធារណៈនិងបង្កើនការគាំទ្រ

ការផ្សព្វផ្សាយ បង្ហាញ និងបកស្រាយពីសម្បត្តិបេតិកភណ្ឌពិភពលោក គួរតែមាន ប្រសិទ្ធភាព មិនបំផ្លើស ងាយយល់ និងមានការចូលរួមស្វែងយល់។ គួរតែជំរុញការយល់ដឹងនិងគាំទ្រពីថ្នាក់ជាតិនិងអន្តរជាតិ ដល់ការការពារ អភិរក្ស និងប្រើប្រាស់សម្បត្តិបេតិកភណ្ឌប្រកបដោយនិរន្តរភាព។

### គោលការណ៍ទី៤៖ គ្រប់គ្រងវិស័យទេសចរណ៍ដោយមានផែនការបម្រុងទុកជាមុន

ការចូលរួមចំណែកនៃការអភិវឌ្ឍន៍វិស័យទេសចរណ៍និងសកម្មភាពនានារបស់អ្នកទស្សនា ដែលពាក់ព័ន្ធនឹងការការពារ អភិរក្ស និងផ្សព្វផ្សាយពីតំបន់បេតិកភណ្ឌពិភពលោក តម្រូវឲ្យមានការធ្វើផែនការបម្រុងទុកជាមុននឹងបន្តត្រួតពិនិត្យ។ អ្នកគ្រប់គ្រងតំបន់ប្រាសាទត្រូវគោរព

តាមសមត្ថភាពផ្ទុកនៃប្រាសាទនីមួយៗ ដែលអាចទទួលភ្ញៀវទេសចរបាន ក្នុងលក្ខខណ្ឌដែលមិនធ្វើឲ្យរេចរិលឬប៉ះពាល់ដល់គុណតម្លៃបេតិកភណ្ឌ។ ការគ្រប់គ្រងរមណីយដ្ឋានគួរតែយកចិត្តទុកដាក់លើការផ្គត់ផ្គង់ក្នុងវិស័យទេសចរណ៍ និងដោះស្រាយបញ្ហានានាដូចជាការកកស្ទះ និងជីវភាពរស់នៅរបស់ប្រជាជន។ ការធ្វើផែនការទេសចរណ៍និងការគ្រប់គ្រងដោយមានដៃគូសហការ គួរតែគ្របដណ្តប់លើប្រព័ន្ធគ្រប់គ្រងតំបន់ប្រាសាទទាំងមូល។

**គោលការណ៍ទី៥៖ ជំរុញឲ្យមានការចូលរួមពីអ្នកពាក់ព័ន្ធ**

ផែនការអភិវឌ្ឍទេសចរណ៍ និងសកម្មភាពអ្នកទស្សនានៅតំបន់បេតិកភណ្ឌពិភពលោក គួរតែអនុវត្តឡើងដោយមានការចូលរួម គោរព និងផ្តល់សេរីភាពដល់សហគមន៍ម្ចាស់ស្រុក ទៅតាមសមត្ថភាពនិងឆន្ទៈចូលរួមក្នុងសកម្មភាពទេសចរណ៍របស់ពួកគាត់។

**គោលការណ៍ទី៦៖ រៀបចំហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍និងសម្ភារៈរូបវន្ត**

សាងសង់ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍និងសម្ភារៈរូបវន្តនៅតំបន់បេតិកភណ្ឌពិភពលោក ដោយរើសទីតាំង រចនា សាងសង់ និងកែលម្អជាទៀងទាត់តាមតម្រូវការ ដើម្បីឲ្យភ្ញៀវទេសចរពេញចិត្ត និងទទួលបានបទពិសោធទស្សនាល្អ ដោយធានាថាគ្មានផលប៉ះពាល់អវិជ្ជមានដល់គុណតម្លៃបេតិកភណ្ឌ បរិស្ថាននិងវប្បធម៌។

**គោលការណ៍ទី៧៖ សមត្ថភាពគ្រប់គ្រងរមណីយដ្ឋាន**

ចាំបាច់ត្រូវមានប្រព័ន្ធគ្រប់គ្រងដែលមានធនធាន សម្ភារៈរូបវន្ត និងអ្នកជំនាញគ្រប់ផ្នែកចូលរួម ដើម្បីធានាបាននូវការការពារ និងផ្សព្វផ្សាយពីគុណតម្លៃបេតិកភណ្ឌក៏ដូចជាការគោរពសហគមន៍ក្នុងតំបន់។

**គោលការណ៍ទី៨៖ ប្រើប្រាស់ប្រាក់ចំណូលពីវិស័យទេសចរណ៍**

ស្ថាប័នសាធារណៈនិងស្ថាប័នគ្រប់គ្រងរមណីយដ្ឋាន គួរប្រើប្រាស់ចំណូលមួយផ្នែកដែលសមល្មមពីវិស័យទេសចរណ៍ និងសកម្មភាពទស្សនានៅតំបន់បេតិកភណ្ឌពិភពលោកអង្គរ ដើម្បី

ធានាការការពារ អភិរក្ស និងគ្រប់គ្រងគុណតម្លៃបេតិកភណ្ឌ។

**គោលការណ៍ទី៩៖ រួមចំណែកដល់ការអភិវឌ្ឍន៍សហគមន៍ក្នុងតំបន់**

ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ និងសកម្មភាពអ្នកទស្សនានៅតំបន់បេតិកភណ្ឌពិភពលោក គួរតែរួមចំណែកជួយសហគមន៍ និងអភិវឌ្ឍសង្គម-សេដ្ឋកិច្ចប្រកបដោយប្រសិទ្ធភាពនិងសមធម៌។

## គម្រោងក្របខ័ណ្ឌបេតិកភណ្ឌអង្គរ

វិស័យទេសចរណ៍នៅអង្គរ នឹងអនុលោមទៅតាមគោលនយោបាយនៃក្របខ័ណ្ឌគ្រប់គ្រងបេតិកភណ្ឌអង្គរផងដែរ។ គោលដៅរួមនៃHMF រួមមាន៖

- ការគ្រប់គ្រងគុណតម្លៃធម្មជាតិនិងវប្បធម៌ ដោយបំពេញតាមតម្រូវការនៃមនុស្សបច្ចុប្បន្ន ដោយមិនប៉ះពាល់ដល់តម្រូវការមនុស្សជំនាន់ក្រោយ
- ទេសចរណ៍ប្រកបដោយចីរភាព
- ការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ពិសេសបង្កើនកម្រិតជីវភាពប្រជាជនក្រីក្រនៅជនបទ
- អភិបាលកិច្ចល្អនិងពង្រឹងសមត្ថភាពអាជ្ញាធរអប្សរា។





HMFនឹងដាក់បញ្ចូលគោលនយោបាយនិងយុទ្ធសាស្ត្រដោយមានផែនការបម្រុងទុកជាមុន ដើម្បីអភិរក្សគុណតម្លៃទាំងអស់ ដែលទទួលរងផលប៉ះពាល់ពីការអភិវឌ្ឍន៍ដោយគ្មានការគ្រប់គ្រង និងពីការកើនឡើងនៃចំនួនភ្ញៀវទេសចរ។

ធាតុគន្លឹះរបស់ HMF មួយចំនួនរួមមានៈ

- ការទទួលស្គាល់ពេញលេញនិងវិសាលភាពនៃគុណតម្លៃបេតិកភណ្ឌអង្គរ រួមបញ្ចូលទាំងបេតិកភណ្ឌរស់
- ការសហការគ្នាជាមួយនឹងឧស្សាហកម្មទេសចរណ៍ ដើម្បីទប់ស្កាត់រាល់អាកប្បកិរិយា និងសកម្មភាពមិនសមរម្យ និងដើម្បីផ្តល់ព័ត៌មានដល់ភ្ញៀវទេសចរឲ្យបានត្រឹមត្រូវពិតប្រាកដ
- ការទទួលស្គាល់នៃតួនាទីយ៉ាងសំខាន់របស់អ្នកពាក់ព័ន្ធ រួមទាំងប្រជាជនក្នុងតំបន់ ដៃគូអភិរក្សអន្តរជាតិ ឧស្សាហកម្មទេសចរណ៍ សហគមន៍សាសនា អង្គការក្រៅរដ្ឋាភិបាល និងអាជ្ញាធរខេត្ត ក្នុងការអភិរក្សគុណតម្លៃបេតិកភណ្ឌទាំងអស់និងការរៀបចំរចនាសម្ព័ន្ធ ប្រឹក្សាយោបល់ និងបច្ចេកទេសប្រាស្រ័យទាក់ទងដែលបញ្ចូល និងផ្តល់ព័ត៌មានដល់អ្នកពាក់ព័ន្ធ
- ការលើកទឹកចិត្តវិស័យទេសចរណ៍ប្រកបដោយចីរភាព ក្នុងលក្ខណៈមួយដែលចែករំលែកផលប្រយោជន៍សេដ្ឋកិច្ច និងវប្បធម៌ជាមួយប្រជាជនក្នុងតំបន់ និងជួយសម្របសម្រួលក្នុងការប្រារព្ធពិធីសាសនា ការប្រតិបត្តិ និងប្រពៃណី។

ក្របខ័ណ្ឌគោលនយោបាយរបស់HMFផ្តល់នូវគោលនយោបាយ យុទ្ធសាស្ត្រនិងសកម្មភាពជាក់លាក់ ស្របនឹងវិស័យគន្លឹះទាំង៦ ក្នុងការការពារគុណតម្លៃអង្គររបស់នាយកដ្ឋានមួយចំនួននៅក្នុងអាជ្ញាធរអប្សរាដូចជាៈ

- ការអភិរក្សរចនាសម្ពន្ធ័ប្រាសាទនិងទេសភាព
- ការអភិរក្សបរិស្ថាន
- ការអភិរក្សគុណតម្លៃបេតិកភណ្ឌអរូបីនិងសង្គម
- ការអភិវឌ្ឍន៍វិស័យទេសចរណ៍ដែលមានទំនួលខុសត្រូវ
- ការអភិវឌ្ឍន៍ប្រកបដោយចីរភាព និង
- សមត្ថភាពមន្ត្រីនិងបុគ្គលិក។

អភិវឌ្ឍទេសចរណ៍ដោយមានទំនួលខុសត្រូវនៅអង្គរ នឹងរក្សាទំនាក់ទំនងនិងតម្លៃបេតិកភណ្ឌតាមរយៈការគ្រប់គ្រងអាកប្បកិរិយានិងបទពិសោធរបស់អ្នកទស្សនា កិច្ចសហការជាមួយឧស្សាហកម្មទេសចរណ៍ និងការចូលរួមស្វែងយល់ជាមួយប្រជាជនក្នុងតំបន់។ គោលការណ៍សំខាន់គឺថា ការទស្សនាត្រូវតែមានការត្រួតពិនិត្យនិងគ្រប់គ្រងកាន់តែច្រើន និងកាន់តែសកម្មបន្ថែមទៀតនៅអង្គរ។ ចំណុចនេះនឹងត្រូវធ្វើឡើងបានតាមវិធីពីរយ៉ាង៖

- ទី១ ៖ សមត្ថភាពផ្ទុករបស់រមណីយដ្ឋាន ទាមទារឲ្យមានការរៀបចំជាក្រឹត្យក្រម។ ការកំណត់សមត្ថភាពផ្ទុករបស់រមណីយដ្ឋាននិងប្រាសាទ ឬទីតាំងណាមួយ អាចជាព័ត៌មានជួយក្នុងការសម្រេចចិត្តពីចំនួនអតិបរមារបស់ភ្ញៀវទេសចរដែលអាចអនុញ្ញាតឲ្យចូលទស្សនាប្រាសាទ គ្រប់គ្រងលំហូរភ្ញៀវទេសចរនៅក្នុងរមណីយដ្ឋាននិងប្រាសាទ និងកំណត់សម្ភារៈរូបវន្តសម្រាប់ភ្ញៀវទេសចរដូចជាចំណតជាដើម។
- ទី២ ៖ បទពិសោធអ្នកទស្សនា(និងផលប៉ះពាល់) ត្រូវមានលក្ខណៈសម្បូរបែប។ យើងអាចផ្លាស់ប្តូរអាកប្បកិរិយាភ្ញៀវទេសចរ ដោយផ្តល់នូវបទពិសោធទស្សនាកាន់តែប្រសើរនិងកាត់បន្ថយផលប៉ះពាល់លើរមណីយដ្ឋានតាមរយៈការចាត់ថ្នាក់ប្រាសាទ និងផ្តល់ឱកាសដល់ភ្ញៀវទេសចរនៅក្នុងនិងជុំវិញតំបន់អង្គរ ក៏ដូចជាបទពិសោធទស្សនាទៅតាមចំណែកទីផ្សារនីមួយៗ តាមរយៈការផ្សព្វផ្សាយ និងការកំណត់តម្លៃ។

ក្នុងចំណោមការផ្តួចផ្តើមជាច្រើន ដែលមានគោលដៅគ្រប់គ្រងទេសចរណ៍នៅអង្គរ ការសិក្សាសមត្ថភាពផ្ទុកនិងការបែងចែកភ្ញៀវទេសចរទៅតាមចំណែកទីផ្សារផ្សេងៗ ជាមូលដ្ឋានគ្រឹះនៃគោលនយោបាយTMP។

## ការផ្តួចផ្តើមគោលនយោបាយផែនការគ្រប់គ្រងទេសចរណ៍

ការផ្តួចផ្តើមគោលនយោបាយគ្រប់គ្រងទេសចរណ៍មានចំនួនប្រាំមួយ។ គោលនយោបាយទាំងនេះបង្កើតចេញជាមូលដ្ឋានគ្រឹះនៃវិធានផ្សេងៗ ដើម្បីអភិវឌ្ឍទេសចរណ៍ប្រកបដោយចីរភាពនិងទំនួលខុសត្រូវនៅអង្គរ។

### ១- លើកកម្ពស់បទពិសោធជាវិជ្ជមានសម្រាប់អ្នកទស្សនា

អ្នកទស្សនានឹងមានបទពិសោធវិជ្ជមានពីភាពអស្ចារ្យនៃបេតិកភណ្ឌធម្មជាតិនិងវប្បធម៌អង្គរតាមរយៈការផ្តល់ព័ត៌មានប្រកបដោយប្រសិទ្ធភាពពីទីកន្លែងធម្មជាតិដ៏ពិសិដ្ឋនិងប្រពៃណីរស់នៅ ដែលនឹងទទួលបានឱកាសផ្សេងគ្នា និងកម្រិតនៃសេវាកម្មលើសពីការរំពឹងទុករបស់ពួកគេ។

## ២- កាត់បន្ថយផលប៉ះពាល់ដល់រមណីយដ្ឋាន

ផលប៉ះពាល់ដែលកើតឡើងពីកំណើនភ្ញៀវទេសចរនឹងត្រូវបានគ្រប់គ្រងដោយមានផែនការបម្រុងទុកជាមុន ដើម្បីលុបបំបាត់ឬកាត់បន្ថយផលប៉ះពាល់អវិជ្ជមានលើគុណតម្លៃនៃតំបន់បេតិកភណ្ឌពិភពលោកអង្គរតាមរយៈការលើកទឹកចិត្តនិងវិធានផ្សេងៗ។

## ៣- ភាពជាដៃគូជាមួយឧស្សាហកម្មទេសចរណ៍

ឧស្សាហកម្មទេសចរណ៍និងរដ្ឋាភិបាលនឹងសហការគ្នាជាដៃគូ ក្នុងការគ្រប់គ្រងទេសចរណ៍ ប្រកបដោយចីរភាពនៅតំបន់បេតិកភណ្ឌពិភពលោកអង្គរ តាមរយៈការប្រាស្រ័យទាក់ទងដែលច្បាស់លាស់និងស៊ីចង្វាក់គ្នា ព្រមទាំងតម្លាភាព និងការសម្រេចចិត្តបានទាន់ពេលវេលា។

## ៤- ផ្តល់ផលប្រយោជន៍ដល់ប្រជាជនក្នុងតំបន់

គុណតម្លៃសង្គមនិងវប្បធម៌របស់ប្រជាជន នៅក្នុងនិងជុំវិញតំបន់បេតិកភណ្ឌពិភពលោកអង្គរ នឹងត្រូវបានទទួលស្គាល់ អភិរក្សនិងពង្រឹង ហើយសហគមន៍ទាំងនេះនឹងចែករំលែកផលប្រយោជន៍សេដ្ឋកិច្ចនិងផលប្រយោជន៍ផ្សេងទៀតពីវិស័យទេសចរណ៍នៅអង្គរដោយសមធម៌។

## ៥- បង្កើនអភិបាលកិច្ចល្អ

អនុលោមតាមគោលការណ៍ទី៨នៃគោលការណ៍សម្រាប់វិស័យទេសចរណ៍ ប្រកបដោយចីរភាពនូវសម្បត្តិបេតិកភណ្ឌពិភពលោក រាជរដ្ឋាភិបាលនឹងធានាថា នៅពេលប្រាក់ចំណូលពីវិស័យទេសចរណ៍កើនឡើង រចនាសម្ព័ន្ធនិងធនធានស្ថាប័នត្រូវឆ្លុះបញ្ចាំងពីតម្រូវ

ការក្នុងការគ្រប់គ្រងទេសចរណ៍ប្រកបដោយប្រសិទ្ធភាព និងការអនុវត្តគម្រោងគ្រប់គ្រងទេសចរណ៍នេះផងដែរ។

## ៦- ការចូលរួមពីអ្នកពាក់ព័ន្ធ

ការប្រាស្រ័យទាក់ទងដ៏មានប្រសិទ្ធភាព ការប្រឹក្សាយោបល់ និងកិច្ចសហការរវាង និងនៅក្នុងរដ្ឋាភិបាល ឧស្សាហកម្មទេសចរណ៍ អង្គការមិនមែនរដ្ឋាភិបាល និងប្រជាជននៅតំបន់បេតិកភណ្ឌពិភពលោកអង្គរ នឹងបង្កើតឲ្យមានទស្សនៈវិស័យរួមក្នុងការគ្រប់គ្រងទេសចរណ៍នៅអង្គរ។



# ការផ្តួចផ្តើមគោលនយោបាយTMPទី១ គឺការលើកកម្ពស់បទពិសោធជាវិជ្ជមានសម្រាប់អ្នកទស្សនា




## គោលបំណងនៃការគ្រប់គ្រង

អ្នកទស្សនានឹងមានបទពិសោធជាវិជ្ជមានពីបេតិកភណ្ឌធម្មជាតិនិងវប្បធម៌ដ៏អស្ចារ្យរបស់អង្គរតាមរយៈការផ្តល់ព័ត៌មានអំពីទីកន្លែងប្រកបដោយប្រសិទ្ធភាព ធម្មជាតិដ៏ពិសិដ្ឋ និងប្រពៃណីរស់នៅរបស់ប្រជាជន ដោយទទួលបានឱកាស និងកម្រិតសេវាកម្មមួយដែលលើសពីការរំពឹងទុករបស់ពួកគេ។

- ផ្តល់បទពិសោធថ្មីៗដែលរួមបញ្ចូលនូវគុណតម្លៃប្រវត្តិសាស្ត្រនិងប្រពៃណីខ្មែរ
- ផ្តល់ព័ត៌មានដែលសមស្របដល់អ្នកទស្សនាមុននិងអំឡុងពេលទស្សនា
- លើកទឹកចិត្តឲ្យមានអាកប្បកិរិយាសមរម្យ
- ធានាថាភ្ញៀវទេសចរទទួលបាននូវបទពិសោធដែលពេញចិត្ត
- ទទួលយោបល់ពីភ្ញៀវទេសចរក្រោយពេលបញ្ចប់ដំណើរកម្សាន្តរបស់ពួកគេ

## សមិទ្ធផលនានាមកដល់បច្ចុប្បន្ន

អាជ្ញាធរអប្សរា កំពុងទទួលខុសត្រូវក្នុងការគ្រប់គ្រងភ្ញៀវទេសចរដ៏ច្រើនលើសលុប សាងសង់សម្ភារៈរូបវន្តថ្មីសម្រាប់អ្នកទស្សនា ផ្តល់បទពិសោធរបស់អ្នកទស្សនាឲ្យប្រសើរជាងមុន និងបែងចែកលំហូរអ្នកទស្សនានៅក្នុងរមណីយដ្ឋានអង្គរ តាមរយៈការផ្លាស់ប្តូរសុពលភាពសំបុត្រចូលអង្គរនិងសកម្មភាពថ្មីៗ។ អាជ្ញាធរអប្សរាបានដាក់ចេញនូវគោលនយោបាយគ្រប់គ្រងភ្ញៀវទេសចរនៅរួតបាកាណ ប្រាសាទបាភួន ប្រាសាទភ្នំបាខែង និងបានបញ្ចប់ការងាររៀបចំទីលានមុខប្រាសាទបន្ទាយស្រីដោយជោគជ័យ ដែលក្នុងនោះរួមមាន កន្លែងបកស្រាយព័ត៌មានពីតំបន់ប្រាសាទ និងការគ្រប់គ្រងលំហូរអ្នកទស្សនា។ មានការរៀបចំផលិតផលទេសចរណ៍ថ្មីដូចជា ដំណើរកំសាន្តតាមរទេះគោនៅភូមិស្រះស្រង់ និងសកម្មភាពនានានៅខេត្តសៀមរាបដូចជាការទស្សនាវត្តអារាមនៅតាមបណ្តោយស្ទឹងសៀមរាប។ អាជ្ញាធរអប្សរាកំពុងស្វែងរកវិធីដើម្បីធ្វើឲ្យបទពិសោធអ្នកទស្សនាបានប្រសើរឡើងជាលំដាប់ ដោយការកាត់បន្ថយសំឡេងរំខាននៅក្នុងប្រាសាទ តាមរយៈការប្រើប្រាស់ឧបករណ៍ Audio Guide។ ជម្រើសអ្នកទស្សនាមានភាពសម្បូរបែបដោយសារការផ្លាស់ប្តូរសុពលភាពសំបុត្រ ដែលក្នុងនោះសំបុត្របីថ្ងៃមានសុពលភាពមួយសប្តាហ៍ និងសំបុត្រប្រាំពីរថ្ងៃមានសុពលភាពមួយខែក្នុងការទស្សនា ដើម្បីលើកទឹកចិត្តភ្ញៀវទេសចរឲ្យស្នាក់នៅកាន់តែយូរនិងរីករាយជាមួយសកម្មភាពផ្សេងៗទៀត។ មានផ្ទាំងព័ត៌មាននៅមុខប្រាសាទមួយចំនួនដូចជា ប្រាសាទព្រះខ័ន និងផ្ទាំងព័ត៌មានស្តីពីអាកប្បកិរិយាសមរម្យ នៅអង្គរវត្ត បាភួន និងនាគព័ន្ធ។ បច្ចុប្បន្នអាជ្ញាធរអប្សរាកំពុងសាងសង់មជ្ឈមណ្ឌលស្វាគមន៍ភ្ញៀវនិងកន្លែងគយគន់ថ្ងៃលិចថ្មីនៅបារាយណ៍ទឹកថ្លា។ ក្រសួងទេសចរណ៍និងឧស្សាហកម្មទេសចរណ៍ បានសម្តែងការគាំទ្រយ៉ាងខ្លាំងចំពោះការអភិវឌ្ឍន៍ផលិតផលនិងបទពិសោធ

United Nations Educational, Scientific and Cultural Organization | Australian Government | អាជ្ញាធរអប្សរា APSARA

| |
|---|
| ថ្មីៗ បន្ថែមលើការលើកកម្ពស់បទពិសោធអ្នកទស្សនា។ |

## បញ្ហាប្រឈម

បញ្ហាបទពិសោធអ្នកទស្សនាដូចខាងក្រោមនេះ បានមកពីកិច្ចពិភាក្សារវាងរាជរដ្ឋាភិបាល សហគមន៍ ឬភាគីពាក់ព័ន្ធក្នុងឧស្សាហកម្មទេសចរណ៍នៅអង្គរ ក្នុងដំណើរការពិគ្រោះយោបល់ដើម្បីរៀបចំឯកសារផែនការគ្រប់គ្រងទេសចរណ៍នេះ។

| បញ្ហា | យុទ្ធសាស្ត្រ |
|---|---|
| ពុំមានព័ត៌មានគ្រប់គ្រាន់សម្រាប់ផ្ដល់ឲ្យអ្នកទស្សនា ហើយផ្ទាំងព័ត៌មានដែលមានស្រាប់មួយចំនួនខូចខាត។<br><br>អ្នកទស្សនាបានគិតជាមុនថានឹងមកមើលអ្វីនៅអង្គរ ហើយរំពឹងថានឹងទស្សនាតែប្រាសាទសំខាន់ៗដូចជាអង្គរវត្ត បាយ័ន បាខែង តាព្រហ្ម និងបន្ទាយស្រីតែប៉ុណ្ណោះ។<br><br>មគ្គុទ្ទេសក៍ទេសចរណ៍និងអ្នកដឹកនាំក្រុមទេសចរមួយចំនួន ពុំពន្យល់ភ្ញៀវទេសចរដោយសង្ខេបពីរបៀបនៃការទស្សនា និងរបៀបនៃការប្រតិបត្តិនៅក្នុងរមណីយដ្ឋានអង្គរឡើយ។<br><br>មានការខ្វះខាតព័ត៌មាននៅតាមតំបន់ប្រាសាទ។<br><br>មានតែប្រាសាទមួយចំនួនតូចប៉ុណ្ណោះដែលមានភ្ញៀវទស្សនា។<br><br>ភ្ញៀវទេសចរពុំបានដឹងនិងមិនយល់ពីសារៈសំខាន់នៃតួនាទីអាជ្ញាធរអប្សរា។<br><br>ការផ្ដល់ព័ត៌មាននៅលើគេហៈទំព័រអាជ្ញាធរអប្សរាមិនមានលក្ខណៈគ្រប់ | ទី១ ទី២ |

| | |
|---|---|
| គ្រាន់ ដើម្បីឲ្យភ្ញៀវទេសចររៀបចំផែនការស្នាក់នៅរបស់ពួកគេ។ | |
| មានភ្ញៀវទេសចរតិចតួចប៉ុណ្ណោះដែលដឹងពីគុណតម្លៃដ៏សំខាន់ទាំងអស់របស់អង្គរ។<br><br>ពុំសូវមានការផ្តល់ព័ត៌មាននិងផ្សព្វផ្សាយពីគុណតម្លៃអង្គរ។<br><br>អ្នកទស្សនាមិនយល់ពីសាសនាបច្ចុប្បន្ន(ព្រះពុទ្ធសាសនា)និងសារសំខាន់វប្បធម៌(ប្រពៃណីសាសនា)នៅអង្គរដូច្នេះពួកគាត់អាចបង្ហាញអាកប្បកិរិយាឬស្លៀកពាក់មិនសមរម្យ។<br><br>ប្រជាជនក្នុងតំបន់មួយចំនួនមិនយល់ដឹងអំពីគុណតម្លៃនៃបេតិកភណ្ឌពិភពលោក។ | ទី៣<br>[សូមមើលការផ្តួចផ្តើមទី២<br>យុទ្ធសាស្ត្រទី៣] |
| ពេលខ្លះមានសម្លេងរំខាននៅប្រាសាទមួយចំនួន។<br><br>ជួនកាលភ្ញៀវទេសចរដែលធ្វើដំណើរជាក្រុមធំៗ ដោយមានមគ្គុទ្ទេសក៍ទេសចរណ៍(ជាញឹកញាប់មានម៉ាស៊ីនបំពងសំឡេង) បានបង្កសម្លេងរំខានដល់ប្រាសាទ។<br><br>អ្នកលក់មួយចំនួនបានរំខានភ្ញៀវទេសចរនៅខាងក្នុងប្រាសាទនិងតាមទីអារាមនានា។<br><br>ក្មេងលក់ទំនិញនៅតាមតំបន់ប្រាសាទ។<br><br>ខ្វះខាតសម្ភារៈរូបវន្តបន្ថែមទៀត ដើម្បីគ្រប់គ្រងសុវត្ថិភាពនិងអាកប្បកិរិយាអ្នកទស្សនា។<br><br>មានកង្វះខាតជំនួយសង្គ្រោះបឋម និងការសង្គ្រោះបន្ទាន់ ព្រមទាំងនីតិវិធីជម្លៀសអ្នករងគ្រោះចេញ។<br><br>ត្រូវការបុគ្គលិកបន្ថែមទៀត ជាចាំបាច់នៅតាមតំបន់ប្រាសាទដើម្បីធានា | ទី៤<br>[សូមមើលការផ្តួចផ្តើមទី២<br>យុទ្ធសាស្ត្រទី៧] |

| | |
|---|---|
| សុវត្ថិភាពអ្នកទស្សនា។ | |
| មគ្គុទ្ទេសក៍មួយចំនួនមិនមានចំណេះដឹងត្រឹមត្រូវឬគ្រប់គ្រាន់។<br><br>សមត្ថភាពមគ្គុទ្ទេសក៍នៅមានកម្រិតនៅឡើយដូចជាកង្វះខាតផ្នែកភាសា និងចំណេះដឹង ហើយមិនមានមគ្គុទ្ទេសក៍គ្រប់គ្រាន់សម្រាប់ទីផ្សារមួយចំនួន។<br><br>មគ្គុទ្ទេសក៍មួយចំនួនមិនមានចំណេះដឹងគ្រប់គ្រាន់អំពីប្រាសាទនានា។<br><br>មគ្គុទ្ទេសក៍និងប្រតិបត្តិករទេសចរណ៍ មិនបានយកចិត្តទុកដាក់គ្រប់គ្រងភ្ញៀវទេសចរឲ្យបានត្រឹមត្រូវនៅតំបន់អង្គរ។ | ទី៥ |
| ការរៀបចំដំណើរកម្សាន្តនិងសកម្មភាពទេសចរណ៍បច្ចុប្បន្នមិនបានឆ្លើយតបតាមតម្រូវការទីផ្សារផ្សេងគ្នា ដើម្បីធ្វើឲ្យបទពិសោធអ្នកទស្សនាមានភាពសម្បូរបែបនោះទេ។ | ទី៦ |
| មានការលក់វត្ថុអនុស្សាវរីយ៍និងប្រើប្រាស់រូបភាពអង្គរមិនសមស្រប។ | ទី៨ |
| មានតម្រូវការចាំបាច់ដើម្បីបន្តលើកកម្ពស់សេវាកម្មដែលបានផ្តល់ឲ្យភ្ញៀវទេសចរនានានៅតាមតំបន់ប្រាសាទបន្ថែមទៀត។ | ទី៩ |

## យុទ្ធសាស្ត្រ

មានយុទ្ធសាស្ត្រចំនួនដប់ដែលនឹងធានាថាអ្នកទស្សនាមានបទពិសោធជាវិជ្ជមាន នៅតំបន់បេតិកភណ្ឌធម្មជាតិនិងវប្បធម៌អង្គរ៖

១. ផ្តល់ព័ត៌មានដ៏សមស្របនិងមានប្រសិទ្ធភាព

២. តម្រង់ទិសអ្នកទស្សនា

៣. បកស្រាយពីគុណតម្លៃ

៤. គ្រប់គ្រងបទពិសោធរបស់ភ្ញៀវទេសចរនៅរមណីយដ្ឋានអង្គរ

៥. ពង្រឹងអាជីពមគ្គុទ្ទេសក៍

៦. ផ្តល់នូវបទពិសោធសមរម្យទៅតាមទីផ្សារផ្សេងគ្នា

៧.ផ្សារភ្ជាប់អង្គរជាមួយក្រុងសៀមរាបនិងខេត្តសៀមរាប

៨. ជំរុញផ្សព្វផ្សាយអត្តសញ្ញាណអង្គរ

៩. ផ្តល់សេវាកម្មប្រកបដោយគុណភាព

១០. ត្រួតពិនិត្យបទពិសោធអ្នកទស្សនា។

## ១.១ ផ្តល់ព័ត៌មានដ៏សមស្របនិងមានប្រសិទ្ធភាព

***យុទ្ធសាស្ត្រ :*** ភ្ញៀវទេសចរដែលរៀបចំដំណើរកម្សាន្តរបស់ពួកគាត់ជាមុន ត្រូវទទួលបានព័ត៌មានសមស្របនិងចាំបាច់ ដើម្បីសិក្សាស្វែងយល់ពីគុណតម្លៃនិងការអភិរក្សប្រាសាទ និងប្រព្រឹត្តអាកប្បកិរិយាសមរម្យក្នុងអំឡុងពេលទស្សនារមណីយដ្ឋានអង្គរ។

***ហេតុផល :*** ការយល់ដឹងរបស់ភ្ញៀវទេសចរនៅមុននិងក្នុងកំឡុងពេលទស្សនារមណីយដ្ឋានអង្គរ នឹងឆ្លើយតបតាមរំពឹងទុក និងលើកកម្ពស់គុណភាពបទពិសោធទស្សនារបស់ពួកគេ ក៏ដូចជាលើកទឹកចិត្តឲ្យមានអាកប្បកិរិយាសមរម្យ។

| សកម្មភាព | ទំនួលខុសត្រូវ | ពេលវេលា | អាទិភាព |
|---|---|---|---|
| ១.១.១- រៀបចំស្លាកសញ្ញាងាយយល់សម្រាប់តំបន់បេតិកភណ្ឌពិភពលោកអង្គរ | នា-គ្រប់គ្រងលំនៅដ្ឋាន | | ខ្ពស់ |
| ១.១.២- បង្កើនការផ្តល់ព័ត៌មានដល់ភ្ញៀវទេសចរ ពង្រឹងចំណេះដឹងបុគ្គលិក ដាក់ស្លាកសញ្ញានិងផ្ទាំងព័ត៌មានបន្ថែមដោយធ្វើយ៉ាងណាឲ្យខ្លឹមសារទាំងមូលមានភាពស៊ីចង្វាក់គ្នា | នា-ទេសចរណ៍ / គ្រប់គ្រងលំនៅដ្ឋាន/ ផ្សព្វផ្សាយ | | មធ្យម |
| ១.១.៣- រៀបចំនិងចែកចាយព័ត៌មានដល់ភ្ញៀវទេសចរមុនពេលទស្សនា ដើម្បីលើកទឹកចិត្តឲ្យពួកគាត់មានអាកប្បកិរិយាសមរម្យ និងលើកកម្ពស់ការយល់ដឹងពីតម្លៃបេតិកភណ្ឌ | នា-ទេសចរណ៍/ ផ្សព្វផ្សាយ | | ខ្ពស់ |

| | | | |
|---|---|---|---|
| ១.១.៤- ផ្តល់ព័ត៌មានមុនដំណើរទស្សនាបន្ថែមទៀតតាមគេហៈទំព័រអាជ្ញាធរអប្សរា និងបណ្តាញផ្សព្វផ្សាយសង្គម | អ្នកបញ្ចូលទិន្នន័យក្នុងគេហៈទំព័រអាជ្ញាធរអប្សរា | | ខ្ពស់ |
| ១.១.៥- បញ្ចូលព័ត៌មានលើបណ្តាញអ៊ីនធឺណិតដែលផ្តល់ឲ្យដោយភាគីទីបី ដើម្បីលើកទឹកចិត្តឲ្យមានព័ត៌មានត្រឹមត្រូវសម្រាប់ភ្ញៀវទេសចរក្នុងស្រុកនិងអន្តរជាតិ | អ្នកបញ្ចូលទិន្នន័យក្នុងគេហៈទំព័រអាជ្ញាធរអប្សរា | | ខ្ពស់ |
| ១.១.៦- លើកទឹកចិត្តយ៉ាងសកម្មការក្នុងការជំរុញផ្សព្វផ្សាយ "ពីមាត់មួយទៅមាត់មួយ" ដើម្បីឲ្យភ្ញៀវទេសចរស្នាក់នៅកាន់តែយូរនិងត្រឡប់មកវិញ | នា-វប្បធម៌/ផ្សព្វផ្សាយ/ផ្នែកឯកជន | | មធ្យម |
| ១.១.៧- កែលម្អនិងការដាក់សញ្ញាប្រាប់ទិសនិងព័ត៌មានវប្បធម៌នៅក្នុងតំបន់អង្គរ | នា-វប្បធម៌/គ្រប់គ្រងលំនៅដ្ឋាន | | មធ្យម |
| ១.១.៨- លើកកម្ពស់ឲ្យមានការយល់ដឹងពីពិធីបុណ្យនិងប្រតិទិនព្រឹត្តិការណ៍វប្បធម៌ប្រចាំឆ្នាំ | នា-វប្បធម៌/គ្រប់គ្រងលំនៅដ្ឋាន/ផ្សព្វផ្សាយ | | ខ្ពស់ |
| ១.១.៩- ជំរុញផ្សព្វផ្សាយសកម្មភាពនានា ទៅតាមរដូវកាល | នា-ទេសចរណ៍/ផ្សព្វផ្សាយ | | មធ្យម |
| ១.១.១០- ផ្តល់ព័ត៌មានចាំបាច់ និងសមស្របអំពីទីកន្លែងដែលមានលក្ខណៈពិសេសខាងសាសនា ឬសំខាន់ចំពោះសង្គម និងមានអត្ថន័យ ព្រមទាំងផ្តល់ជូននូវគោលការណ៍ណែនាំសមស្របដល់អ្នកទស្សនានៅទីតាំងទាំងនេះ | នា-គ្រប់គ្រងលំនៅដ្ឋាន/វប្បធម៌ | | មធ្យម |

| | | | |
|---|---|---|---|
| ១.១.១១- ផ្តល់ព័ត៌មានបន្ថែមអំពីការអភិរក្សប្រាសាទ រួមទាំងវិធីសាស្ត្រដែលស្ថាប័នអន្តរជាតិប្រើប្រាស់ | នា-ក្នុងឧទ្យាន/ផ្សព្វផ្សាយ | | ទាប |
| ១.១.១២- សហការរៀបចំឬចូលរួមក្នុងពិព័រណ៍ទេសចរណ៍អន្តរជាតិ និងពិព័រណ៍ពាណិជ្ជកម្មជាមួយនឹងក្រសួងទេសចរណ៍ | នា-ទេសចរណ៍/ក្រសួងទេសចរណ៍ | | ខ្ពស់ |
| ១.១.១៣- រៀបចំសន្និសីទទេសចរណ៍អង្គរប្រចាំឆ្នាំ។ | នា-ទេសចរណ៍/ក្រសួងទេសចរណ៍/ផ្នែកឯកជន | | ខ្ពស់ |




## ១.២ តម្រង់ទិសអ្នកទស្សនា

*យុទ្ធសាស្ត្រ* : ភ្ញៀវទេសចរទាំងអស់ត្រូវទទួលបានការតម្រង់ទិសស្តីពីតំបន់បេតិកភណ្ឌពិភពលោកអង្គរ មុននឹងចាប់ផ្តើមការទស្សនា។

*ហេតុផល* : ភ្ញៀវទេសចរត្រូវការព័ត៌មាននៅពេលចាប់ផ្តើមដំណើរទស្សនា ដើម្បីដឹងថាត្រូវប្រព្រឹត្តឥរិយាបថបែបណា និងដើម្បីរៀនសូត្រនិងរីករាយក្នុងអំឡុងពេលទស្សនាអង្គរ។

| សកម្មភាព | ទំនួលខុសត្រូវ | រយៈពេល | អាទិភាព |
|---|---|---|---|
| ១.២.១- តម្រូវឲ្យអ្នកទស្សនាទាំងអស់ដែលមកតំបន់ | នា-ទេសចរណ៍ | | ខ្ពស់ |

| | | | |
|---|---|---|---|
| បេតិកភណ្ឌពិភពលោកអង្គរទទួលបាន ព័ត៌មានតម្រង់ទិស ដោយខានមិនបាន (ការផ្តល់ព័ត៌មានតម្រង់ទិស អាចត្រូវផ្តល់តាមវិធីផ្សេងៗអាស្រ័យលើក្រុមទេសចរ និងចំណែកទីផ្សារនីមួយៗ) | | | |
| ១.២.២- បញ្ចប់ការសាងសង់ច្រកចូល និងហេដ្ឋារចនាសម្ព័ន្ធណែនាំអ្នកទស្សនាដើម្បីលើកកម្ពស់បទពិសោធអ្នកទស្សនា | អគ្គនាយកអាជ្ញាធរអប្សរា | | ខ្ពស់ |
| ១.២.៣- អនុវត្តផែនការសាងសង់មជ្ឈមណ្ឌលស្វាគមន៍សម្រាប់ណែនាំអ្នកទស្សនាអំពីតំបន់បេតិកភណ្ឌពិភពលោកអង្គរ វប្បធម៌និងទេសចរណ៍ | នា-វប្បធម៌/ទេសចរណ៍ | | ខ្ពស់ |
| ១.២.៤- រៀបចំនិងផ្តល់ជាវីដេអូអប់រំនិង/ឬធ្វើសេចក្តីណែនាំសង្ខេបមុនពេលទស្សនា | នា-វប្បធម៌/ផ្សព្វផ្សាយ | | ខ្ពស់ |
| ១.២.៥- កែលម្អការចែកចាយព័ត៌មាននៅព្រលានយន្តហោះខេត្តសៀមរាបនិងតាមតំបន់ព្រំដែន។ គួរតែដាក់សញ្ញានៅព្រលានយន្តហោះសៀមរាប ដែលប្រាប់ព័ត៌មានដល់ភ្ញៀវទេសចរថា ពួកគេកំពុងស្ថិតក្នុងតំបន់ការពាររបស់បេតិកភណ្ឌពិភពលោក | នា-ផ្សព្វផ្សាយ | | ខ្ពស់ |
| ១.២.៦- ផ្តល់ផែនទីនិងសៀវភៅមគ្គុទ្ទេសក៍បន្ថែមនៅទីតាំងសមស្រប ទាំងក្នុងនិងក្រៅតំបន់បេតិកភណ្ឌពិភពលោកអង្គរ។ | នា-វប្បធម៌/ផ្សព្វផ្សាយ | | មធ្យម |




## ១.៣ បកស្រាយពីគុណតម្លៃ

*យុទ្ធសាស្ត្រ :* បង្ហាញពីគុណតម្លៃធម្មជាតិនិងវប្បធម៌នៃតំបន់បេតិកភណ្ឌពិភពលោកអង្គរ (គុណតម្លៃរស់អង្គរផ្ទាល់និងកន្លែងដែលពាក់ព័ន្ធដទៃទៀត) ដល់ភ្ញៀវទេសចរដោយមានភាពស៊ីចង្វាក់គ្នា សមស្របនិងវាយតម្លៃខ្ពស់។

*ហេតុផល :* ការពន្យល់បង្ហាញពីគុណតម្លៃ ជាមូលដ្ឋាននៃការអភិរក្ស។

| សកម្មភាព | ទំនួលខុសត្រូវ | រយៈពេល | អាទិភាព |
|---|---|---|---|
| ១.៣.១- រៀបចំផែនការបកស្រាយព័ត៌មានអំពីតំបន់បេតិកភណ្ឌពិភពលោកអង្គរនិងតំបន់ប្រាសាទនីមួយៗ ដើម្បីបង្កើនការយល់ដឹងអំពីគុណតម្លៃបេតិកភណ្ឌអង្គរ | នា-គ្រប់គ្រងលំនៅដ្ឋាន/វប្បធម៌ | | មធ្យម |
| ១.៣.២- ធានាថាព័ត៌មានស្ដីពីគុណតម្លៃបេតិកភណ្ឌមានបច្ចុប្បន្នភាព | នា-វប្បធម៌ | | ខ្ពស់ |
| ១.៣.៣- រៀបចំគម្រោងដែលផ្ដោតសំខាន់លើបទពិសោធអ្នកទស្សនា ដោយផ្ដល់ព័ត៌មានពីគុណតម្លៃបរិស្ថាន ធារាសាស្ត្រនិងសង្គមវប្បធម៌ | នា-វប្បធម៌/គ្រប់គ្រងលំនៅដ្ឋាន/គ្រប់គ្រងទឹក/គ្រប់គ្រងព្រៃឈើ | | មធ្យម |

| | | | |
|---|---|---|---|
| ១.៣.៤- រៀបចំគោលនយោបាយដើម្បីលើកកម្ពស់ការយល់ដឹងពីគុណតម្លៃបរិស្ថាននិងគុណតម្លៃផ្សេងទៀតដល់ទេសចរក្នុងស្រុក | នា-វប្បធម៌ | | ខ្ពស់ |
| ១.៣.៥- ពង្រឹងការយល់ដឹងរបស់អ្នកទស្សនានិងសង្កត់ធ្ងន់លើគុណតម្លៃបរិស្ថាន និងបេតិកភណ្ឌអរូបីនៃអង្គរដែលមានសារៈសំខាន់ផ្នែកវប្បធម៌និងសាសនានៅអង្គរ | នា-វប្បធម៌/ផ្សព្វផ្សាយ | | ខ្ពស់ |
| ១.៣.៦- ស្វែងរកជម្រើសក្នុងការបង្ហាញព័ត៌មានស្តីពីគុណតម្លៃបេតិកភណ្ឌនៅតាមទីលានមុខប្រាសាទ។ | នា-វប្បធម៌/គ្រប់គ្រងលំនៅដ្ឋាន | | មធ្យម |



## ១.៤ គ្រប់គ្រងបទពិសោធរបស់ភ្ញៀវទេសចរនៅរមណីយដ្ឋានអង្គរ

*យុទ្ធសាស្ត្រ :* គ្រប់គ្រងភ្ញៀវទេសចរនៅក្នុងរមណីយដ្ឋានអង្គរ ដើម្បីធានាថាភ្ញៀវទេសចរទាំងអស់រីករាយនឹងដំណើរកម្សាន្តរបស់ពួកគេ។

*ហេតុផល :* ការលើកកម្ពស់បទពិសោធអ្នកទស្សនាដោយយន្តការរួសរាយរាក់ទាក់ជាមួយភ្ញៀវទេសចរ និងជួយដល់ការគ្រប់គ្រងអាកប្បកិរិយា ការកកស្ទះ លំហូរភ្ញៀវទេសចរ ការតម្រង់ជួរ ចរាចរណ៍ សុវត្ថិភាព និងសំឡេងរំខានជាដើម។

| សកម្មភាព | ទំនួលខុសត្រូវ | រយៈពេល | អាទិភាព |
|---|---|---|---|
| ១.៤.១- ពិនិត្យជម្រើសនានា ដើម្បីគ្រប់គ្រងពេលវេលា និងសម្រួលទំនាក់ទំនងជាមួយនឹងប្រតិបត្តិករដឹកនាំក្រុមទេសចរធំៗ ដើម្បីកាត់បន្ថយការកកស្ទះ និងលើកទឹកចិត្តក្រុមទេសចរជាលក្ខណៈឯកជន និងមានចំនួនតិច | នា-ទេសចរណ៍ | | ខ្ពស់ |
| ១.៤.២- លើកកម្ពស់ការប្រព្រឹត្តអាកប្បកិរិយាសមរម្យនៅតាមទីវត្តអារាម និងប្រាសាទ ដោយប្រមូលនិងផ្តល់ព័ត៌មានពាក់ព័ន្ធ | នា-គ្រប់គ្រងលំនៅដ្ឋាន/ផ្សព្វផ្សាយ | | ខ្ពស់ |
| ១.៤.៣- រៀបចំឲ្យមានសកម្មភាពផ្សេងគ្នានៅក្នុងប្រាសាទដែលស៊ីចង្វាក់គ្នាជាមួយនឹងគុណតម្លៃអង្គរ (ឧទាហរណ៍ គំនូរ ប្រោះទឹកមន្ត បន់ស្រន់ ទស្សន៍ទាយជោគវាសនា) និងរក្សាភាពដើមនិងគោរពការប្រតិបត្តិប្រពៃណីនៅ តំបន់ប្រាសាទ | នា-វប្បធម៌ | | មធ្យម |
| ១.៤.៤- បង្កើតក្រុមសង្គ្រោះបឋម ដើម្បីធានាសុវត្ថិភាពអ្នកទស្សនានៅពេលមានគ្រោះថ្នាក់និងរបួស | នា-ទេសចរណ៍ | | ខ្ពស់ |
| ១.៤.៥- លុបបំបាត់អ្នកលក់ដូរ នៅក្នុងប្រាសាទនិងវត្តអារាមនានា | អគ្គនាយកអាជ្ញាធរអប្សរា/នគរបាលបេតិកភណ្ឌ | | មធ្យម |
| ១.៤.៦- ផ្តល់ព័ត៌មានមូលដ្ឋានជាក់លាក់អំពីការប្រតិបត្តិអនុវត្តនិងប្រើប្រាស់ប្រពៃណី | នា-គ្រប់គ្រងលំនៅដ្ឋាន | | មធ្យម |
| ១.៤.៧- លើកកម្ពស់ការយល់ដឹងអំពីតម្រូវការដើម្បីថែរក្សាបរិយាកាសស្ងប់ស្ងាត់និងគោរពប្រតិបត្តិប្រពៃណីនៅក្នុងនិងជុំវិញប្រាសាទ | នា-គ្រប់គ្រងលំនៅដ្ឋាន/ផ្សព្វផ្សាយ | | ខ្ពស់ |

| | | | |
|---|---|---|---|
| ១.៤.៩- ធ្វើការជាមួយភូមិនិងគ្រួសារ ដើម្បីលើកទឹកចិត្តឲ្យកុមារចូលរៀន និងដើម្បីកាត់បន្ថយចំនួនកុមារលក់របស់របរ និងការដើរតាមភ្ញៀវនៅក្នុងប្រាសាទ។ | នា-គ្រប់គ្រងលំនៅដ្ឋាន | | ទាប |

សកម្មភាពបន្ថែមដទៃទៀតដែលរួមចំណែកធ្វើឲ្យបទពិសោធអ្នកទស្សនាតាមតំបន់ប្រាសាទប្រសើរឡើង មាននៅក្នុងការផ្តួចផ្តើមទី២ យុទ្ធសាស្ត្រទី៣និងទី៤។




### ១.៥ ពង្រឹងអាជីពមគ្គុទ្ទេសក៍

*យុទ្ធសាស្ត្រ :* អង្គរនឹងមានប្រព័ន្ធមគ្គុទ្ទេសក៍ជាលក្ខណៈអាជីព ដែលឆ្លើយតបតាមស្តង់ដារបស់តំបន់បេតិកភណ្ឌពិភពលោក។

**ហេតុផល :** វិធាននៃកម្មវិធីបណ្តុះបណ្តាលមគ្គុទ្ទេសក៍អង្គរនឹងលើកកម្ពស់បទពិសោធអ្នកទស្សនា ក៏ដូចជាកាត់បន្ថយនូវអាកប្បកិរិយាមិនសមរម្យនានា។

| សកម្មភាព | ទំនួលខុសត្រូវ | រយៈពេល | អាទិភាព |
|---|---|---|---|
| ១.៥.១- ត្រួតពិនិត្យនិងកែលម្អការប្រើប្រាស់មគ្គុទ្ទេសក៍ដែលមានអាជ្ញាបណ្ណមគ្គុទ្ទេសក៍ ក្នុងការអនុវត្តច្បាប់និងពង្រឹងការប្រព្រឹត្តអាកប្បកិរិយាសមរម្យ | នា-ទេសចរណ៍ / ក្រសួងទេសចរណ៍/ នគរបាល | | ខ្ពស់ |

| | | | |
|---|---|---|---|
| | ទេសចរណ៍ | | |
| ១.៥.២- ពិនិត្យសក្តានុពលក្នុងការប្រើប្រាស់គោលការណ៍ណែនាំស្តីពីការបណ្តុះបណ្តាលមគ្គុទ្ទេសក៍ប្រកបដោយទំនួលខុសត្រូវ នៅតំបន់បេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ | នា-ទេសចរណ៍ / ក្រសួងទេសចរណ៍ | | ខ្ពស់ |
| ១.៥.៣- ពិនិត្យសក្តានុពលក្នុងការបណ្តុះបណ្តាលមគ្គុទ្ទេសក៍ឯកទេសសម្រាប់ដំណើរទស្សនាតាមប្រធានបទផ្សេងៗនិងមគ្គុទ្ទេសក៍សហគមន៍(ឧទាហរណ៍ធារាសាស្ត្រ ព្រះពុទ្ធសាសនា។ល។) | នា-វប្បធម៌ | | មធ្យម |
| ១.៥.៤- ចាប់ផ្តើមរៀបចំវគ្គបណ្តុះបណ្តាលមគ្គុទ្ទេសក៍ឡើងវិញដោយអាជ្ញាធរអប្សរានិងក្រសួងទេសចរណ៍ ដើម្បីបង្កើនចំណេះដឹងមគ្គុទ្ទេសក៍ ធានានូវអាកប្បកិរិយាសមរម្យ និងជំនាញភាសាច្បាស់លាស់។ វគ្គបណ្តុះបណ្តាលនេះគួរតែមានបញ្ចូលព័ត៌មានតម្រង់ទិសអ្នកទស្សនា ក្រមអ្នកទស្សនាអង្គរ និងព័ត៌មានថ្មីៗអំពីប្រវត្តិសាស្ត្រនិងសារៈសំខាន់នៃតំបន់បេតិកភណ្ឌពិភពលោកអង្គរ | នា-វប្បធម៌/ ទេសចរណ៍/ ក្រសួងទេសចរណ៍ | | ខ្ពស់ |
| ១.៥.៥- រៀបចំនិងចែកជូនក្រមប្រតិបត្តិសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ ដោយមានកិច្ចសហការជាមួយក្រសួងទេសចរណ៍ និងអាជ្ញាធរខេត្តតាមដែលអាចធ្វើទៅបាន | នា-វប្បធម៌/ ទេសចរណ៍ | | ខ្ពស់ |
| ១.៥.៦- លើកទឹកចិត្តឲ្យមានការនាំភ្ញៀវប្រកបដោយការទទួលខុសត្រូវនិងសមស្រប តាមរយៈការផ្សព្វផ្សាយក្រមប្រតិបត្តិសម្រាប់មគ្គុទ្ទេសក៍។ | នា-វប្បធម៌/ ទេសចរណ៍/ ក្រសួងទេសចរណ៍/ | | ខ្ពស់ |

| | | | |
|---|---|---|---|
| | នគរបាល ទេសចរណ៍ | | |






## ១.៦ ផ្តល់នូវបទពិសោធដែលសមរម្យទៅតាមទីផ្សារផ្សេងគ្នា

*យុទ្ធសាស្ត្រ :* អ្នកទស្សនានៅតំបន់បេតិកភណ្ឌពិភពលោកអង្គរ នឹងទទួលបានបទពិសោធជាវិជ្ជមាន ឆ្លើយតបតាមសេចក្តីត្រូវការនិងការរំពឹងទុករបស់ពួកគាត់។

*ហេតុផល :* ជាការសំខាន់ណាស់ ដែលត្រូវផ្តល់នូវបទពិសោធ ផលិតផល និងសេវាកម្មផ្សេងៗគ្នា ស្របតាមគុណតម្លៃរបស់តំបន់បេតិកភណ្ឌពិភពលោកអង្គរ តាមការរំពឹងទុកនិងសេចក្តីត្រូវការរបស់អ្នកទស្សនានៅអង្គរ។

| សកម្មភាព | ទំនួលខុសត្រូវ | រយៈពេល | អាទិភាព |
|---|---|---|---|
| ១.៦.១- យល់និងអនុវត្តបច្ចេកទេសបែងចែកនិងវិភាគទីផ្សារ ដើម្បីជាជំនួយក្នុងការសម្រេចចិត្តឲ្យល្អប្រសើរក្នុងការគ្រប់គ្រងទេសចរណ៍ | នា-ទេសចរណ៍ | | ខ្ពស់ |
| ១.៦.២- ប្រើប្រាស់ការវិភាគចំណែកទីផ្សារដើម្បីធានាបាននូវបទពិសោធស្សនាសម្បូរបែប បង្កើតផលិតផលទេសចរណ៍ថ្មីឲ្យប្រសើរជាងមុន ដោយផ្សារភ្ជាប់ទៅនឹងតម្រូវការទីផ្សារ និងគ្រប់គ្រងទីផ្សារទេសចរណ៍នៅ | នា-ទេសចរណ៍ | | ខ្ពស់ |

| | | | |
|---|---|---|---|
| តាមប្រាសាទឲ្យកាន់តែមានប្រសិទ្ធភាព(ដូចជាតាមរយៈការរៀបចំផ្លូវទស្សនា និងការគ្រប់គ្រងក្រុមប្រកបដោយប្រសិទ្ធភាព) | | | |
| ១.៦.៣- បង្កើតវង់ទស្សនាថ្មីៗនៅតាមប្រាសាទធំៗនិងកន្លែងដែលមានអ្នកទស្សនាតិច ដោយប្រើប្រាស់លទ្ធផលនៃការអង្កេតស្រាវជ្រាវរបស់អាជ្ញាធរអប្សរា ការវិភាគនិងយោបល់របស់ឧស្សាហកម្មទេសចរណ៍ ដែលឆ្លុះបញ្ចាំងពីតម្រូវការរបស់ភ្ញៀវទេសចរជាក្រុម និងជាលក្ខណៈឯកជន | នា-ទេសចរណ៍/ ផ្សព្វផ្សាយ/ វប្បធម៌ | | ខ្ពស់ |
| ១.៦.៤- ពិនិត្យឱកាសក្នុងការផ្តល់បទពិសោធទាក់ទងនឹងវប្បធម៌បន្ថែមទៀត(សហគមន៍រទេះគោ សាសនា) សម្រាប់ទីផ្សារពិសេស | នា-វប្បធម៌/ ទេសចរណ៍/ គ្រប់គ្រងលំនៅដ្ឋាន | | មធ្យម |
| ១.៦.៥- រកឱកាសធ្វើការជាមួយព្រះសង្ឃដែល ជាអ្នកថែរក្សាវប្បធម៌ និងណែនាំឲ្យមានការទស្សនាវត្តអារាមនៅអង្គរទៅតាមបំណងរបស់វត្តទាំងនោះ | នា-វប្បធម៌/ ទេសចរណ៍/ គ្រប់គ្រងលំនៅដ្ឋាន | | មធ្យម |
| ១.៦.៦- រៀបចំនិងជំរុញឲ្យមានសកម្មភាព និងកម្មវិធីទស្សនាបន្ថែមទៀតដោយតភ្ជាប់អង្គរនឹងក្រុងសៀមរាប | នា-ទេសចរណ៍/ បេតិកភណ្ឌក្រុង/ មន្ទីរទេសចរណ៍ខេត្តសៀមរាប | | មធ្យម |
| ១.៦.៧- បន្តបង្កើតបទពិសោធនិងកន្លែងទាក់ទាញដែលមានបរិយាកាសរាក់ទាក់ និងបង្ហាញពីវប្បធម៌ ដើម្បីគាំទ្រសហគមន៍ ក្រៅពីការទស្សនាប្រាសាទ។ | នា-វប្បធម៌/ ទេសចរណ៍/ គ្រប់គ្រង | | មធ្យម |

| | | | |
|---|---|---|---|
| | លំនៅដ្ឋាន | | |




## ១.៧ តភ្ជាប់អង្គរជាមួយក្រុងសៀមរាបនិងខេត្តសៀមរាប

*យុទ្ធសាស្ត្រ* : ធ្វើឲ្យផលិតផលទេសចរណ៍សម្រាប់អ្នកទស្សនានៅអង្គរកាន់តែមានភាពសម្បូរបែប តាមរយៈការអភិវឌ្ឍន៍ទេសចរណ៍ក្រុងនៅខេត្តសៀមរាប និងបទពិសោធដទៃទៀតនៅតំបន់ជុំវិញ ហើយធានាថាមានការគ្រប់គ្រងយ៉ាងត្រឹមត្រូវពីការគំរាមកំហែងពីខាងក្រៅតំបន់អង្គរ។

*ហេតុផល* : តំបន់បេតិកភណ្ឌពិភពលោកអង្គរគឺជាធាតុស្នូលដែលមានទិដ្ឋភាពវប្បធម៌ទូលំទូលាយ ដោយក្តោបបញ្ចូលទាំងក្រុងសៀមរាប បឹងទន្លេសាប និងភ្នំគូលែន ហើយគ្រប់ផ្នែកទាំងអស់ជាចំណែកនៃបណ្តុំរូបវន្ត និងវប្បធម៌សម្រាប់វិស័យទេសចរណ៍នៅអង្គរ។ ការគ្រប់គ្រងទេសចរណ៍នៅអង្គរ មានទាំងសម្ពាធនិងឱកាសនៅក្នុងនិងជុំវិញខេត្តសៀមរាប និងមានការគំរាមកំហែងផ្សេងៗនៅភ្នំគូលែន។

| សកម្មភាព | ទំនួលខុសត្រូវ | រយៈពេល | អាទិភាព |
|---|---|---|---|
| ១.៧.១- គ្រប់គ្រងបេតិកភណ្ឌវប្បធម៌ក្រុងសៀមរាប ដោយភ្ជាប់ជាមួយឧទ្យានអង្គរនិងតំបន់ទ្រនាប់តាមយុទ្ធសាស្ត្រសមស្រប | នា-បេតិកភណ្ឌក្រុង/ អាជ្ញាធរខេត្ត | | ខ្ពស់ |
| ១.៧.២- អភិរក្សនិងផ្សព្វផ្សាយពីទម្រង់វប្បធម៌ក្រុង | នា-បេតិកភណ្ឌ | | មធ្យម |

| | | | |
|---|---|---|---|
| សៀមរាបឲ្យក្លាយជាតំបន់ទាក់ទាញភ្ញៀវទេសចរ | ក្រុង/ អាជ្ញាធរខេត្ត | | |
| ១.៧.៣- កែលម្អហេដ្ឋារចនាសម្ព័ន្ធនិងសម្ភារៈរូបវន្ត នៅក្នុងខេត្តសៀមរាប ដើម្បីផ្តល់សេវាដល់ភ្ញៀវទេសចរដូចជាចំណតជាដើម | នា-បេតិកភណ្ឌក្រុង/ អាជ្ញាធរខេត្ត | | មធ្យម |
| ១.៧.៤- ចាប់ផ្តើមធ្វើនិងគាំទ្រដល់ការផ្តួចផ្តើមទេសចរណ៍ក្នុងតំបន់នៃក្រុងសៀមរាប ដោយរួមបញ្ចូលទាំងគម្រោងខ្សែក្រវ៉ាត់បៃតង (Green Belt Project) និងយុទ្ធនាការដាំដើមឈើ "ទេសចរម្នាក់ដើមឈើមួយដើម" និងយុទ្ធនាការទីក្រុងស្អាត | នា-បេតិកភណ្ឌក្រុង/ អាជ្ញាធរខេត្ត/ មន្ទីរទេសចរណ៍ខេត្ត | | មធ្យម |
| ១.៧.៥- លើកទឹកចិត្តនិងសម្រួលឲ្យមានការទស្សនាតំបន់ដ៏ទាក់ទាញនិងគួរឲ្យចាប់អារម្មណ៍នៅជុំវិញរមណីយដ្ឋានអង្គរដូចជា បឹងទន្លេសាប និងប្រាសាទកោះកេរជាដើម | នា-ទេសចរណ៍/ បេតិកភណ្ឌក្រុង/ មន្ទីរទេសចរណ៍ខេត្ត | | មធ្យម |
| ១.៧.៦- រៀបចំនិងធ្វើឲ្យហេដ្ឋារចនាសម្ព័ន្ធមួយចំនួនប្រសើរឡើង ដើម្បីធានាថាក្រុងសៀមរាបមិនរងការគំរាមកំហែងពីទឹកជំនន់ | នា-បេតិកភណ្ឌក្រុង/ អាជ្ញាធរខេត្ត/ ម្ចាស់ជំនួយ | | ខ្ពស់ |
| ១.៧.៧- គាំទ្រជាសាធារណៈនូវការបញ្ឈប់ការកាប់បំផ្លាញព្រៃឈើ ការរៀបចំនិងអនុវត្តផែនការយុទ្ធសាស្រ្តក្នុងការដាំដើមឈើឡើងវិញ ការការពាររមណីយដ្ឋានប្រវត្តិសាស្រ្ត និងការការពារបរិស្ថាននៅភ្នំគូលែន។ | ប្រធានអាជ្ញាធរអប្សរា/ នា-ក្រៅឧទ្យាន/ អាជ្ញាធរខេត្ត | | ខ្ពស់ |



### ១.៨ ជំរុញផ្សព្វផ្សាយអត្តសញ្ញាណអង្គរ

*យុទ្ធសាស្ត្រ :* ការបង្ហាញពីអង្គរត្រូវស្ថិតនៅក្នុងកម្រិតដែលគោរពវប្បធម៌ គុណតម្លៃ និងសភាពដើមរបស់អង្គរ។

*ហេតុផល :* ការប្រើប្រាស់រូបភាពមិនសមរម្យពាក់ព័ន្ធនឹងអង្គរ អាចបន្ទាបនិងបន្ថយគុណតម្លៃអង្គរ ក៏ដូចជាគុណភាពនៃបទពិសោធអ្នកទស្សនា។

| សកម្មភាព | ទំនួលខុសត្រូវ | រយៈពេល | អាទិភាព |
|---|---|---|---|
| ១.៨.១- ពង្រឹងតម្លៃនិងសេចក្តីថ្លៃថ្នូររបស់ «អត្តសញ្ញាណអង្គរ» តាមរយៈការប្រើប្រាស់ទង់ជាតិកាន់តែច្រើន ដែលគ្រប់គ្នាទទួលស្គាល់ថាជា «សញ្ញានៃអំណាច» គឺតាមរយៈការរៀបចំនិងការអនុវត្តគោលការណ៍ណែនាំ អំពីការប្រើប្រាស់និងការដាក់ទង់ជាតិនៅលើសញ្ញានានា ការងារបោះពុម្ព ទំព័រអ៊ីនធឺណិត និងធ្វើទង់ជាតិតែម្តង | អគ្គនាយក អាជ្ញាធរអប្សរា/ នា- ផ្សព្វផ្សាយ/ ទេសចរណ៍ | | ខ្ពស់ |
| ១.៨.២- ពិនិត្យការប្រើប្រាស់រូបភាពអង្គរ និងធ្វើអន្តរាគមន៍ ដើម្បីបង្ការឬកែតម្រូវការប្រើប្រាស់រូបភាពដែលមិនស្របទៅនឹងគុណតម្លៃអង្គរ | នា-ផ្សព្វផ្សាយ/ ទេសចរណ៍/ សណ្តាប់ធ្នាប់ | | មធ្យម |
| ១.៨.៣-បង្រៀនភ្ញៀវទេសចរអំពីការធ្វើផលិតផលក្នុង | នា-ផ្សព្វផ្សាយ/ | | ទាប |

| | | | |
|---|---|---|---|
| តំបន់ និងតម្លៃនៃការទិញផលិតផលក្នុងតំបន់ តាមរយៈយុទ្ធនាការអប់រំ | ទេសចរណ៍ | | |
| ១.៨.៤-ត្រួតពិនិត្យនិងដោះស្រាយបញ្ហាគុណភាពផលិតផល ដើម្បីជានាការលើកតម្កើងអត្តសញ្ញាណផលិតផលក្នុងតំបន់ដែលល្អ | នា-ផ្សព្វផ្សាយ/ ទេសចរណ៍ | | ទាប |
| ១.៨.៥- ពង្រឹងស្លាកសញ្ញា "បេតិកភណ្ឌ" អង្គរតាមរយៈការផ្សារភ្ជាប់ជាមួយទីផ្សារបេតិកភណ្ឌរបស់ក្រសួងទេសចរណ៍។ | នា-ផ្សព្វផ្សាយ/ វប្បធម៌/ ក្រសួងទេសចរណ៍ | | មធ្យម |




### ១.៩ ផ្តល់សេវាកម្មប្រកបដោយគុណភាព

*យុទ្ធសាស្រ្ត :* តំបន់បេតិកភណ្ឌពិភពលោកអង្គរ នឹងទទួលការវាយតម្លៃខ្ពស់ចំពោះសេវាកម្មអ្នកទស្សនាដែលរាក់ទាក់ ប្រកបដោយព័ត៌មានច្បាស់លាស់ និងមានអត្ថប្រយោជន៍។

*ហេតុផល :* រាល់ទំនាក់ទំនងរវាងអ្នកទស្សនានិងប្រជាជនក្នុងតំបន់បេតិកភណ្ឌពិភពលោកអង្គរ មានឥទ្ធិពលលើគុណភាពនៃបទពិសោធ និងអាកប្បកិរិយារបស់ពួកគេ។

| សកម្មភាព | ទំនួលខុសត្រូវ | រយៈពេល | អាទិភាព |
|---|---|---|---|
| ១.៩.១ លើកទឹកចិត្តបុគ្គលិកអាជ្ញាធរអប្សរា ប៉ូលីស អ្នកលក់និងឆែកសំបុត្រ អ្នកបើករ៉ឺម៉ក អ្នកលក់ | អាជ្ញាធរអប្សរា | | មធ្យម |

| | | | |
|---|---|---|---|
| វត្ថុអនុស្សាវរីយ៍ អ្នកលក់អាហារនិងភេសជ្ជៈ និងសេវាដទៃទៀត ឲ្យផ្តល់សេវាកម្មប្រកបដោយគុណភាពខ្ពស់ | | | |
| ១.៩.២ បង្កើតនូវស្តង់ដាសេវាកម្មបម្រើអតិថិជនជាក់លាក់ ដើម្បីលើកទឹកចិត្តឲ្យបុគ្គលិកចេះស្វាគមន៍ ជួយយកអាសារនិងគួរសមចំពោះភ្ញៀវទេសចរ | អាជ្ញាធរអប្សរា | | ខ្ពស់ |
| ១.៩.៣ រក្សាស្តង់ដាសេវាកម្មតាមរយៈការផ្សព្វផ្សាយឯកសារដែលបានដាក់ចេញនូវស្តង់ដាទាំងនោះជាទៀងទាត់ | នា-ផ្សព្វផ្សាយ | | មធ្យម |
| ១.៩.៤ បន្តថែរក្សាការបង្ហាញពីតំបន់អង្គរ តាមរយៈការគ្រប់គ្រងកាកសំណល់ដ៏មានប្រសិទ្ធភាព បង្កើតសេចក្តីណែនាំ និងស្លាកសញ្ញាដែលស៊ីចង្វាក់គ្នា | អាជ្ញាធរអប្សរា | | ខ្ពស់ |
| ១.៩.៥ ពិនិត្យលើការពេញចិត្តរបស់អ្នកទស្សនាចំពោះសេវាកម្មដែលពួកគេបានទទួល តាមរយៈការស្ទង់មតិ ការអង្កេតនិងការបង្កើតបទដ្ឋានគោលដែលសមស្រប។ | នា-វប្បធម៌/ទេសចរណ៍ | | មធ្យម |

**១.១០ ត្រួតពិនិត្យបទពិសោធអ្នកទស្សនា**

***យុទ្ធសាស្ត្រ*** : បទពិសោធនិងអាកប្បកិរិយាអ្នកទស្សនានៅអង្គរនឹងត្រូវកែល្អជាលំដាប់តាមរយៈការកែតម្រូវដែលឆ្លើយតបទៅនឹងយោបល់របស់ភ្ញៀវទេសចរ និងកម្មវិធីត្រួតពិនិត្យដ៏មានប្រសិទ្ធភាព។

***ហេតុផល :*** ការត្រួតពិនិត្យផ្ទាល់ និងយោបល់របស់ភ្ញៀវទេសចរ បានផ្តល់ជាតឹកតាងសម្រាប់ធ្វើការសម្រេចចិត្ត ដើម្បីធ្វើឲ្យបទពិសោធអ្នកទស្សនានិងការគ្រប់គ្រងតំបន់ប្រាសាទកាន់តែប្រសើរឡើង។

| សកម្មភាព | ទំនួលខុសត្រូវ | រយៈពេល | អាទិភាព |
|---|---|---|---|
| ១.១០.១- បន្តអនុវត្តនូវប្រព័ន្ធត្រួតពិនិត្យបទពិសោធអ្នកទស្សនាឲ្យបានទៀងទាត់ | នា-វប្បធម៌/ទេសចរណ៍ | | មធ្យម |
| ១.១០.២- ធ្វើបច្ចុប្បន្នកម្ម និងកែលម្អការស្ទង់មតិនិងទម្រង់អង្កេតឲ្យសមស្របទៅនឹងលក្ខខណ្ឌនានាដែលបានផ្លាស់ប្តូរ | នា-វប្បធម៌ | | ទាប |
| ១.១០.៣- ស្វែងរកលទ្ធភាពក្នុងការអនុវត្តវិធីសាស្ត្រគ្រប់គ្រងគុណភាព ដើម្បីកែលម្អបទពិសោធទស្សនា | នា-វប្បធម៌ | | ទាប |
| ១.១០.៤-សហការជាមួយវិស័យឯកជនដើម្បីទទួលបានព័ត៌មានស្តីពីបទពិសោធរបស់អ្នកទស្សនា និងយោបល់បន្ទាប់ពីការទស្សនា។ | អាជ្ញាធរអប្សរា/ឧស្សាហកម្មទេសចរណ៍/មន្ត្រីទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍របស់អាជ្ញាធរអប្សរា | | មធ្យម |



# ការផ្តួចផ្តើមគោលនយោបាយTMPទី២ គឺការកាត់បន្ថយផលប៉ះពាល់ដល់រមណីយដ្ឋាន




ឥទ្ធិពលដែលកើតឡើងពីកំណើនវិស័យទេសចរណ៍ ត្រូវមានការគ្រប់គ្រងជាមុនដើម្បីលុបបំបាត់ឬកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានលើគុណតម្លៃតំបន់បេតិកភណ្ឌពិភពលោកអង្គរតាមរយៈការលើកទឹកចិត្តនិងវិធាននានា។

- លើកទឹកចិត្តទេសចរណ៍ប្រកបដោយការទទួលខុសត្រូវខ្ពស់
- កាត់បន្ថយផលប៉ះពាល់លើរមណីយដ្ឋាន
- ការពារសភាពដើមរបស់រមណីយដ្ឋាននិងសហគមន៍

* ធានាបាននូវការអភិរក្សប្រាសាទខណៈដែលមានការអភិវឌ្ឍន៍វិស័យទេសចរណ៍
* ការពារបរិស្ថាន

**សមិទ្ធផលនានាមកដល់បច្ចុប្បន្ន**

អាជ្ញាធរអប្សរាកំពុងអនុវត្តការផ្តួចផ្តើមគំនិតជាច្រើន ដើម្បីកាត់បន្ថយផលប៉ះពាល់រមណីយដ្ឋាន រួមមាន កម្មវិធីគ្រប់គ្រងលំហូរអ្នកទស្សនា ការត្រួតពិនិត្យនិងការថែទាំ និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។ អាជ្ញាធរអប្សរាបានចាប់ផ្តើមការគ្រប់គ្រងលំហូរអ្នកទស្សនានៅរូតបាកាណ(ប៉មកណ្តាលប្រាសាទអង្គរវត្ត) នៅប្រាសាទបាភួន និងនៅលើប្រាសាទភ្នំបាខែង។ មានក្រុមការងារនៅតាមប្រាសាទមួយចំនួន និងមានការរៀបចំផ្លូវដើរ និងសុវត្ថិភាពអ្នកទស្សនាប្រសើរជាងមុននៅប្រាសាទតាព្រហ្ម។ បន្ថែមពីនេះ មានការរៀបចំហេដ្ឋារចនាសម្ព័ន្ធ ដើម្បីឲ្យអ្នកទស្សនាគយគន់ថ្ងៃលិចនៅបារាយណ៍ទឹកថ្លា និងមានការកែលម្អហេដ្ឋារចនា សម្ព័ន្ធផ្សេងទៀត ដូចជា ចំណតនៅភ្នំបាខែង អង្គរវត្ត បន្ទាយស្រី និងតាព្រហ្ម ក៏ដូចបង្កើតចំណតផ្សេងៗទៀត ដើម្បីរួមចំណែកកាត់បន្ថយការកកស្ទះចរាចរណ៍។ ឧស្សាហកម្មទេសចរណ៍ មានគម្រោងមួយចំនួនទាក់ទងនឹងផលប៉ះពាល់ផ្សេងៗពីភ្ញៀវទេសចរ។ អាជ្ញាធរអប្សរាក៏កំពុងបន្តរៀបចំផ្លូវទេសចរណ៍វប្បធម៌មួយចំនួនធំនៅពាសពេញឧទ្យានអង្គរផងដែរដូចជា ផ្លូវទស្សនាធម្មជាតិនៅក្នុងនិងជុំវិញបារាយណ៍ខាងជើង និងនៅតាមតំបន់ផ្សេងទៀតនៅក្នុងខេត្តសៀមរាបឬនៅក្នុងខេត្តផ្សេងៗទៀត។ អាជ្ញាធរអប្សរាបានរៀបចំសេចក្តីណែនាំអ្នកទស្សនាដោយបញ្ជាក់យ៉ាងច្បាស់ពីអាកប្បកិរិយាសមរម្យ និងការត្រួតពិនិត្យនានា ដែលកំពុងអនុវត្តនៅក្នុងឧទ្យានអង្គរ។ អាជ្ញាធរអប្សរាបានរួមចំណែកផងដែរ ក្នុងការកាត់បន្ថយផលប៉ះពាល់តំបន់ប្រាសាទ តាមរយៈការរៀបចំឲ្យប្រជាជនផ្លាស់ប្តូរទីលំនៅទៅភូមិធម្មជាតិរុនតាឯក ស្វែងរកនិងជំរុញផ្សព្វផ្សាយផលិតផលទេសចរណ៍ថ្មីៗ។

## បញ្ហាប្រឈម

បញ្ហាដែលប៉ះពាល់តំបន់ប្រាសាទខាងក្រោម បានមកពីកិច្ចពិភាក្សារវាងរាជរដ្ឋាភិបាល សហគមន៍ ឬអ្នកពាក់ព័ន្ធក្នុងឧស្សាហកម្មទេសចរណ៍នៅអង្គរ ក្នុងដំណើរការពិគ្រោះយោបល់ដើម្បីរៀបចំឯកសារផែនការគ្រប់គ្រងទេសចរណ៍នេះ។

| បញ្ហា | យុទ្ធសាស្ត្រ |
|---|---|
| ចំនួនភ្ញៀវទេសចរដែលចេះតែកើនឡើងនៅតាមប្រាសាទមួយចំនួន គឺគ្មាននិរន្តរភាពនោះទេ។<br><br>មានភ្ញៀវទេសចរច្រើនពេកដែលបង្កឲ្យមានការកកកុញនៅប្រាសាទធំៗមួយចំនួន។<br><br>មានការបារម្ភចំពោះសមត្ថភាពផ្ទុករបស់ប្រាសាទ និងការខូចខាតដោយសារមានភ្ញៀវទេសចរច្រើន។ | ទី១ |
| មានបញ្ហាច្រើនពាក់ព័ន្ធនឹងចរាចរណ៍និងចំណត។<br><br>រថយន្តដឹកទំនិញលើសទម្ងន់ចំណុះអាចបណ្តាលឲ្យខូចខាតដល់ផ្លូវថ្នល់នានា។<br><br>ដោយសារមានភ្ញៀវទេសចរច្រើន ធ្វើឲ្យចំណតនិងចរាចរណ៍នៅក្នុងតំបន់អង្គរគ្មានសណ្តាប់ធ្នាប់។<br><br>ក្នុងពេលដែលមានមនុស្សច្រើន មានបញ្ហាចរាចរណ៍កើតឡើង។<br><br>មានបញ្ហាមួយចំនួនទាក់ទងនឹងគុណភាពខ្យល់។<br><br>នៅកន្លែងមួយចំនួន ចំណតនៅកៀកប្រាសាទ កកកុញនៅច្រកចូល និងធ្វើឲ្យខូចខាតយ៉ាងធ្ងន់ធ្ងរដល់ធនធានធម្មជាតិនិងវប្បធម៌។ | ទី៦ ទី៧ |
| ភ្ញៀវទេសចរភាគច្រើនមកទស្សនាប្រាសាទមួយចំនួនតូចប៉ុណ្ណោះ។ | ទី២ |

| | |
|---|---|
| មានកង្វះខាតការយល់ដឹងអំពីទីកន្លែងទស្សនានានាដែលទាក់ទាញភ្ញៀវទេសចរក្រៅពីប្រាសាទធំៗដោយសារតែកម្មវិធីរបស់ក្រុមហ៊ុនទេសចរណ៍មានលក្ខណៈស្រដៀងគ្នា។ | |
| មានការកកស្ទះគួរឲ្យកត់សម្គាល់នៅក្នុងប្រាសាទមួយចំនួន។ | ទី៤ |
| អ្នកទស្សនាមួយចំនួនបានបង្ហាញអាកប្បកិរិយាមិនសមរម្យ(ការស្លៀកពាក់ ការឡើងលើប្រាសាទ ការដើរលើរូបចម្លាក់ ការចូលតំបន់ហាមឃាត់ ការប៉ះពាល់ចម្លាក់ ការជក់បារី ឆត្រ និងចោលសំរាម ការគូសលើជញ្ជាំង សម្លេងរំខាននៅទីសក្ការៈ)។ | ទី៣ |
| មានផលប៉ះពាល់ផ្នែកបរិស្ថានទៅលើរមណីយដ្ឋានដូចជា ការប្រើទឹកក្រោមដីច្រើនពេក ការកាប់បំផ្លាញព្រៃឈើនៅភាគខាងជើងអង្គរនិង គុណភាពទឹកធ្លាក់ចុះ។ | ទី៨ |
| ត្រូវការនូវហេដ្ឋារចនាសម្ព័ន្ធបន្ថែមទៀត(ចំណត ផ្លូវកង់ បញ្ជរលក់សំបុត្រ) ឲ្យស្របតាមផ្លូវនិងមធ្យោបាយធ្វើដំណើរថ្មី។ | ទី៦ ទី៧ |
| ពុំមានស្លាកសញ្ញាព័ត៌មានគ្រប់គ្រាន់នៅប្រាសាទនានា។ | ទី៧ |
| ចាំបាច់ត្រូវកែលម្អគុណភាពសម្ភារៈរូបវន្ត(បង្គន់ ភោជនីយដ្ឋាន កន្លែងឈប់សម្រាក)។ | ទី៩ |
| ត្រូវគ្រប់គ្រងសម្ពាធពីវិស័យទេសចរណ៍ដែលអាចនាំឲ្យមានការផ្លាស់ប្តូរនិងសម្ពាធលើទេសភាព។ | ទី៨ |
| កំណត់សមត្ថភាពផ្ទុករបស់ប្រាសាទ ក្នុងការគ្រប់គ្រងភ្ញៀវទេសចរឲ្យបានទាន់ពេលវេលា ដើម្បីកាត់បន្ថយផលប៉ះពាល់លើរមណីយដ្ឋាន។ | ទី៥ |



## យុទ្ធសាស្ត្រ

មានយុទ្ធសាស្ត្រចំនួនប្រាំបួន ដែលនឹងកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានពីវិស័យទេសចរណ៍ ទៅលើគុណតម្លៃនៃតំបន់បេតិកភណ្ឌពិភពលោកឲ្យបានទាន់ពេលវេលា៖

១- កំណត់សមត្ថភាពផ្ទុក (ប្រាសាទនិងរមណីយដ្ឋាន)

២- ធ្វើឲ្យបទពិសោធអ្នកទស្សនាសម្បូរបែប

៣- ធានាការប្រព្រឹត្តអាកប្បកិរិយាសមរម្យ

៤- គ្រប់គ្រងលំហូរអ្នកទស្សនា

៥- គ្រប់គ្រងប្រាសាទដោយមានបញ្ចូលគ្រប់ផ្នែកពាក់ព័ន្ធ

៦- ឆ្លើយតបតាមតម្រូវការដឹកជញ្ជូន

៧- ផ្តល់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលចាំបាច់

៨- គ្រប់គ្រងហានិភ័យបរិស្ថាន សង្គម និងប្រាសាទ

៩- ត្រួតពិនិត្យនិងថែទាំ។

### ២.១ កំណត់សមត្ថភាពផ្ទុក

*យុទ្ធសាស្ត្រ* : សមត្ថភាពផ្ទុករបស់តំបន់បេតិកភណ្ឌពិភពលោកអង្គរនិងប្រាសាទធំៗត្រូវកំណត់ ដោយផ្អែកលើការវិភាគទិន្នន័យនៃការចូលមកទស្សនានិងផលប៉ះពាល់នានា។

*ហេតុផល* : ការសម្រេចកំណត់សមត្ថភាពផ្ទុករបស់ប្រាសាទ និងតំបន់បេតិកភណ្ឌពិភពលោកអង្គរ មានសារៈសំខាន់ក្នុងការសម្រេចចិត្តបែងចែកភ្ញៀវទេសចរនៅជុំវិញតំបន់អង្គរនិងក្នុងប្រាសាទនៅតាមកន្លែងចង្អៀតនិងពេលវេលា។

| សកម្មភាព | ទំនួលខុសត្រូវ | រយៈពេល | អាទិភាព |
|---|---|---|---|
| ២.១.១ រៀបចំកែសម្រួលនិងសាកល្បងសមត្ថភាពផ្ទុក (សង្គមនិងបរិស្ថាន) ដែលសមស្របនឹងតំបន់អង្គរ | មន្ត្រីទទួលខុសត្រូវអនុវត្តTMP | | ខ្ពស់ |
| ២.១.២ រកដៃគូសមស្រម ដើម្បីសិក្សាពីសមត្ថភាពផ្ទុកនៅតំបន់អង្គរនិងនៅប្រាសាទនីមួយៗ | អាជ្ញាធរអប្សរា/ម្ចាស់ជំនួយ | | ខ្ពស់ |
| ២.១.៣ កំណត់សមត្ថភាពនៅកន្លែងដែលទ្រុឌទ្រោមបំផុត (ភាពផុយស្រួយ) ក្នុងប្រាសាទនិងកំណត់ចំនួនអ្នកទស្សនាដែលចូលកន្លែងទាំងនេះឲ្យបានតឹងរឹង។ | អាជ្ញាធរអប្សរា/ម្ចាស់ជំនួយ | | ខ្ពស់ |



## ២.២. ធ្វើឲ្យបទពិសោធអ្នកទស្សនាសម្បូរបែប

*យុទ្ធសាស្ត្រ* : ត្រូវបែងចែកភ្ញៀវទេសចរទៅពាសពេញតំបន់បេតិកភណ្ឌពិភពលោកអង្គរ ដើម្បីកាត់បន្ថយផលប៉ះពាល់លើរមណីយដ្ឋានត្រឹមកម្រិតដែលអាចទទួលយកបាន។

*ហេតុផល :* ការផ្សព្វផ្សាយ ការផ្តល់ជូនបទពិសោធទស្សនាផ្សេងគ្នានឹងជួយក្នុងការបែងចែកភ្ញៀវទេសចរនៅពាសពេញតំបន់បេតិកភណ្ឌពិភពលោកអង្គរ ដែលនាំឲ្យភ្ញៀវម្នាក់ៗទទួល

បានបទពិសោធល្អ កាត់បន្ថយការកកស្ទះ និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៅត្រឹមកម្រិតទាប។ ការផ្តល់ជម្រើសទស្សនាអាចការពារនិងលើកតម្កើងវប្បធម៌ខ្មែរ។

| សកម្មភាព | ទំនួលខុសត្រូវ | រយៈពេល | អាទិភាព |
|---|---|---|---|
| ២.២.១- រៀបចំប្រព័ន្ធចាត់ថ្នាក់ប្រាសាទទៅតាមលក្ខណៈ ភ្ញៀវទេសចរ ការទាក់ទាញនិងតម្លៃនៃប្រាសាទនីមួយៗ ដើម្បីជូនដំណឹងដល់អ្នកគ្រប់គ្រងសម្រេចចិត្តក្នុងការបែងចែកភ្ញៀវទេសចរជុំវិញអង្គរ | មន្ត្រីទទួលខុសត្រូវអនុវត្តTMP | | ខ្ពស់ |
| ២.២.២- ចាប់ផ្តើមស្ទង់មតិនិងស្វែងយល់ពីកម្មវិធីនិងបទពិសោធដែលប្រតិបត្តិករទេសចរណ៍ផ្តល់ដល់អតិថិជនរបស់ខ្លួនដោយគិតគូរជាពិសេសចំពោះប្រាសាទដែលមិនសូវមានអ្នកទស្សនាភូមិនិងបេតិកភណ្ឌអរូបី | នា-វប្បធម៌ | | ខ្ពស់ |
| ២.២.៣- ផ្តល់ព័ត៌មានណែនាំពីទីកន្លែងដែលមិនសូវមានការទស្សនា ឬកន្លែងដែលពោរពេញទៅដោយវប្បធម៌និងបរិស្ថាននិងភាពរាក់ទាក់ | នា-ទេសចរណ៍/ផ្សព្វផ្សាយ/វប្បធម៌ | | មធ្យម |
| ២.២.៤- បង្កើតយុទ្ធនាការទីផ្សារ/ជំរុញផ្សព្វផ្សាយពីការទស្សនាដ៏ល្អ | នា-ទេសចរណ៍/ផ្សព្វផ្សាយ | | មធ្យម |
| ២.២.៥- បង្កើតឲ្យមានការលើកទឹកចិត្តការបែងចែកភ្ញៀវទេសចរនៅពាសពេញតំបន់ប្រាសាទ ជាពិសេសទៅកាន់ប្រាសាទដែលមិនសូវមានអ្នកទស្សនា ឲ្យដូចជាកន្លែងល្អឯក | នា-ទេសចរណ៍/វប្បធម៌ | | ទាប |
| ២.២.៦- បង្កើតផលិតផលទេសចរណ៍ផ្សេងក្រៅពីប្រាសាទ ដូចជាផ្លូវដើរជុំវិញប្រាសាទដែលមានទេសភាពល្អ ការដើរ ជិះកង់ ទស្សនាសហគមន៍ ការបង្ហាញវប្បធម៌ និងការទាក់ទាញផ្នែកវប្បធម៌ផ្សេង | នា-វប្បធម៌ | | មធ្យម |

| | | | |
|---|---|---|---|
| ទៀត កន្លែងសម្រាកនិងបរិភោគអាហារ | | | |
| ២.២.៧- រៀបចំផ្លូវថ្មីដោយផ្អែកលើប្រព័ន្ធចាត់ថ្នាក់ប្រាសាទ ដែលជំរុញឲ្យមានទីផ្សារខុសគ្នាក្នុងការទស្សនាប្រាសាទ ទៅតាមទីផ្សារជាក់លាក់និងការរំពឹងទុករបស់ភ្ញៀវទេសចរ ឧទាហរណ៍ ដំណើរកម្សាន្តជាលក្ខណៈគ្រួសារ | នា-វប្បធម៌ | | មធ្យម |
| ២.២.៨- គ្រប់គ្រងលំហូរអ្នកទស្សនាដោយប្រើ "កញ្ចប់" សំបុត្រថ្មី ដើម្បីកាត់បន្ថយចំនួនអ្នកទស្សនានៅតាមប្រាសាទសំខាន់ៗក្នុងមួយថ្ងៃ | នា-វប្បធម៌ | | ខ្ពស់ |
| ២.២.៩- ផ្សព្វផ្សាយព័ត៌មានបន្ថែមទៀតដល់ទីភ្នាក់ងារទេសចរណ៍ពីសក្តានុពលនៃភូមិនានាដែលជាគោលដៅទេសចរណ៍ | នា-គ្រប់គ្រងលំនៅដ្ឋាន/ផ្សព្វផ្សាយ | | មធ្យម |
| ២.២.១០- បង្កើតនិងជំរុញលើកកម្ពស់ឱកាសទទួលបទពិសោធ "ផ្ទះស្នាក់" នៅភូមិធម្មជាតិ រុនតាឯក(ក្រៅឧទ្យានអង្គរ) | នា-គ្រប់គ្រងលំនៅដ្ឋាន/ផ្សព្វផ្សាយ | | ទាប |
| ២.២.១១- ផ្តល់នូវការគាំទ្របន្ថែមទៀតចំពោះការទស្សនាវត្តអារាម | នា-គ្រប់គ្រងលំនៅដ្ឋាន/វប្បធម៌ | | មធ្យម |
| ២.២.១២- លើកទឹកចិត្តឲ្យអ្នកទស្សនារីករាយនឹងបទពិសោធទស្សនាតំបន់ក្រៅឧទ្យានអង្គរ ដូចជាបេតិកភណ្ឌក្រុងសៀមរាប ទន្លេសាប កោះកេរ និងតំបន់ផ្សេងទៀត | នា-ទេសចរណ៍/បេតិកភណ្ឌក្រុង/មន្ទីរទេសចរណ៍ខេត្ត | | មធ្យម |
| ២.២.១៣- បង្កើតនិងជំរុញសកម្មភាពនិងកម្មវិធីទស្សនាដែលភ្ជាប់តំបន់អង្គរនឹងក្រុងសៀមរាប | នា-ទេសចរណ៍/បេតិកភណ្ឌក្រុង/មន្ទីរទេសចរណ៍ | | បន្ត |

| | | | |
|---|---|---|---|
| | ខេត្ត | | |
| ២.២.១៤- រៀបចំដំណើរកម្សាន្តនិងព្រឹត្តិការណ៍ដែលមានភាពស្និទ្ធស្នាលជាមួយឧស្សាហកម្មទេសចរណ៍ ដើម្បីពន្យល់និងបង្ហាញពួកគាត់ពីឱកាសក្នុងទទួលបទពិសោធក្នុងការទស្សនាតំបន់អង្គរ | នា-ទេសចរណ៍/វប្បធម៌ | | មធ្យម |
| ២.២.១៥- កែលម្អព័ត៌មានសម្រាប់ភ្ញៀវទេសចរ នៅលើគេហៈទំព័រអាជ្ញាធរអប្សរា ដើម្បីជួយឲ្យពួកគាត់ងាយស្រួលសម្រេចចិត្តអំពីជម្រើសទស្សនានានា | អ្នកបញ្ចូលទិន្នន័យក្នុងគេហៈទំព័រអាជ្ញាធរអប្សរា | | ខ្ពស់ |
| ២.២.១៦- រៀបចំនិងផ្សព្វផ្សាយប្រតិទិននៃព្រឹត្តិការណ៍វប្បធម៌ប្រចាំឆ្នាំ | នា-វប្បធម៌/គ្រប់គ្រងលំនៅដ្ឋាន | | មធ្យម |
| ២.២.១៧- ស្វែងរកជម្រើសក្នុងការកែប្រែរចនាសម្ព័ន្ធសំបុត្រ ដើម្បីជំរុញការចែកចាយភ្ញៀវទេសចរ នៅពាសពេញតំបន់អង្គរ និងពន្យាការស្នាក់នៅរបស់ភ្ញៀវទេសចរ | អគ្គនាយកអាជ្ញាធរអប្សរា/នា-វប្បធម៌/គណនេយ្យ | | ខ្ពស់ |
| ២.២.១៨- ស្វែងយល់ពីកំណើនភ្ញៀវទេសចរ និងការចំណាយរបស់ពួកគាត់ម្នាក់ៗ ដើម្បីកែលម្អការកំណត់តម្លៃ។ | នា-វប្បធម៌/ទេសចរណ៍/គណនេយ្យ | | មធ្យម |




## ២.៣. ធានាការប្រព្រឹត្តអាកប្បកិរិយាសមរម្យ

*យុទ្ធសាស្ត្រ :* ភ្ញៀវទេសចរនិងបុគ្គលិកបំពេញការងារនៅក្នុងតំបន់បេតិកភណ្ឌពិភពលោកអង្គរទាំងអស់ត្រូវមានអាកប្បកិរិយាសមរម្យ។

*ហេតុផល :* ការបង្ហាញ ប្រាស្រ័យទាក់ទង លើកទឹកចិត្ត និងពង្រឹងអាកប្បកិរិយា សមរម្យនឹងរួមចំណែកការពារគុណតម្លៃបេតិកភណ្ឌអង្គរ។

| សកម្មភាព | ទំនួលខុសត្រូវ | រយៈពេល | អាទិភាព |
|---|---|---|---|
| ២.៣.១- រៀបចំនិងបោះពុម្ពផ្សាយក្រមប្រតិបត្តិរបស់អ្នកទស្សនា មគ្គុទ្ទេសក៍ និងបុគ្គលិកដែលបំពេញការងារនៅក្នុងតំបន់អង្គរ("ក្រមអង្គរ") | នា-វប្បធម៌ | | ខ្ពស់ |
| ២.៣.២- រៀបចំក្រមអ្នកទស្សនានៅតំបន់អង្គរ ដោយយកសេចក្តីណែនាំអ្នកទស្សនាដែលមានស្រាប់ជាមូលដ្ឋាន | នា-វប្បធម៌ | | ខ្ពស់ |
| ២.៣.៣- បោះពុម្ពផ្សាយ "ក្រមអង្គរ" ជាច្រើនភាសា រួមទាំងភាសាខ្មែរផងដែរ | នា-ផ្សព្វផ្សាយ | | ខ្ពស់ |
| ២.៣.៤- ចែកចាយ "ក្រមអង្គរ" នៅក្នុងនិងក្រៅតំបន់ប្រាសាទ និងលើកទឹកចិត្តដល់ការផ្សព្វផ្សាយក្រមនេះ | នា-ផ្សព្វផ្សាយ/ វប្បធម៌/ | | ខ្ពស់ |

| | | | |
|---|---|---|---|
| តាមមធ្យោបាយចម្រុះ តាមរយៈប្រព័ន្ធផ្សព្វផ្សាយផ្សេងៗដូចជាសំបុត្រ ផ្ទាំងផ្សព្វផ្សាយធំៗ បណ្តាញអ៊ីនធឺណិត សៀវភៅមគ្គុទ្ទេសក៍ សណ្ឋាគារ។ល។ ផ្តល់ព័ត៌មានតាមបណ្តាញអ៊ីនធឺណិតដើម្បីផ្សព្វផ្សាយក្រមអ្នកទស្សនានៅតំបន់អង្គរ។ ត្រូវធានាថាភ្ញៀវទេសចរទាំងអស់បានយល់ពីក្រមអ្នកទស្សនាអង្គរមុនពេលមកដល់អង្គរ | ទេសចរណ៍/ក្រសួងទេសចរណ៍/មន្ទីរទេសចរណ៍/អ្នកបញ្ចូលទិន្នន័យក្នុងគេហៈទំព័រអាជ្ញាធរអប្សរា | | |
| ២.៣.៥- សហការជាមួយអ្នកពាក់ព័ន្ធក្នុងវិស័យទេសចរណ៍ទាំងអស់ ក្នុងការជំរុញលើកកម្ពស់ការយល់ដឹងនិងការអនុវត្តក្រមអ្នកទស្សនា ព្រមទាំងស្វែងរកភាពជាដៃគូជាមួយនឹងឧស្សាហកម្មទេសចរណ៍ ដើម្បីឲ្យការផ្សព្វផ្សាយនេះមានភាពទូលំទូលាយ | មន្ត្រីទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍របស់អាជ្ញាធរអប្សរា/ នា-ទេសចរណ៍/ ក្រ. ទេសចរណ៍/មន្ទីរទេសចរណ៍ | | កម្រិតខ្ពស់ |
| ២.៣.៦- រៀបចំនិងពង្រឹងសេចក្តីណែនាំពីការស្លៀកពាក់សមរម្យនៅតំបន់បេតិកភណ្ឌអង្គរ និងដាក់បញ្ចូលសេចក្តីណែនាំនេះទៅក្នុងក្រមអ្នកទស្សនាអង្គរ | នា-វប្បធម៌ | | ខ្ពស់ |
| ២.៣.៧- រៀបចំវគ្គបណ្តុះបណ្តាលបុគ្គលិកអាជ្ញាធរអប្សរាដែលពាក់ព័ន្ធ និងបុគ្គលិកប្រចាំប្រាសាទផ្សេងទៀត ដើម្បីឲ្យពួកគាត់ក្លាយជាគំរូនិងជំរុញលើកកម្ពស់ការប្រតិបត្តិអាកប្បកិរិយាសមរម្យ | អាជ្ញាធរអប្សរា | | ខ្ពស់ |
| ២.៣.៨- កំណត់ភារៈកិច្ចត្រួតពិនិត្យអាកប្បកិរិយាអ្នកទស្សនា នៅតាមទីតាំងប្រាសាទដែលរសើបបំផុត និងដាក់បុគ្គលិកឈរជើងនៅតាមចំណុចយុទ្ធសាស្ត្រ | អគ្គនាយកអាជ្ញាធរអប្សរា/ | | ខ្ពស់ |

| | | | |
|---|---|---|---|
| នានា ដើម្បីអនុវត្តក្រមអ្នកទស្សនាអង្គរ | អាជ្ញាធរអប្សរា | | |
| ២.៣.៩- ត្រួតពិនិត្យនិងគ្រប់គ្រងអាកប្បកិរិយាអ្នកដឹកនាំក្រុមទេសចរនិងមគ្គុទ្ទេសក៍ទាំងអស់ | អាជ្ញាធរអប្សរា/ នគរបាលបេតិកភណ្ឌ | | ខ្ពស់ |
| ២.៣.១០- រៀបចំឲ្យមានសម្ភារៈរូបវន្តតាមតំបន់ប្រាសាទ ដើម្បីឲ្យអ្នកទស្សនាគោរពតាមក្រមអ្នកទស្សនាអង្គរ ឧទាហរណ៍ លក់ក្រមា/សំពត់។ | នា-ទេសចរណ៍ | | មធ្យម |
| ២.៣.១១- ពិនិត្យជម្រើសនៃការពង្រឹងការត្រួតពិនិត្យមគ្គុទ្ទេសក៍ និងភ្ញៀវទេសចរដែលមិនគោរពតាមក្រមប្រតិបត្តិ (ឧទាហរណ៍ ដកហូតសំបុត្រ) | អគ្គនាយកអាជ្ញាធរអប្សរា/ នា-ទេសចរណ៍/ វប្បធម៌/ នគរបាលទេសចរណ៍/ នគរបាលបេតិកភណ្ឌ | | មធ្យម |
| ២.៣.១២- ពង្រឹងនូវការគោរពតាមក្រមប្រតិបត្តិនៅតាមតំបន់ប្រាសាទតាមការចាំបាច់ | អាជ្ញាធរអប្សរា/ នគរបាលទេសចរណ៍/ នគរបាលបេតិកភណ្ឌ | | ខ្ពស់ |
| ២.៣.១៣- ដាក់សញ្ញាបន្ថែមទៀតនៅតាមរមណីយដ្ឋាន ដើម្បីរំលឹកឲ្យភ្ញៀវទេសចររក្សាភាពស្ងប់ស្ងាត់ | នា- គ្រប់គ្រងលំនៅដ្ឋាន/ វប្បធម៌/ ទេសចរណ៍ | | ទាប |
| ២.៣.១៤- សហការជាមួយមគ្គុទ្ទេសក៍ ដើម្បីជូនដំណឹងដល់ភ្ញៀវទេសចរអំពីអាកប្បកិរិយាសមរម្យនៅ | នា-ទេសចរណ៍/ វប្បធម៌/ ក្រសួង | | ខ្ពស់ |

| | | | |
|---|---|---|---|
| ក្នុងវប្បធម៌ខ្មែរ | ទេសចរណ៍ | | |
| ២.៣.១៥- ផ្តល់ព័ត៌មានអំពីក្រមប្រតិបត្តិដល់អ្នកបើកបរ ព្រោះភ្ញៀវទេសចរជាច្រើនមិនមានមគ្គុទ្ទេសក៍ | នា- ផ្សព្វផ្សាយ/ ទេសចរណ៍/ ក្រសួងទេសចរណ៍/ មន្ទីរទេសចរណ៍ | | មធ្យម |
| ២.៣.១៦- ផ្តល់ព័ត៌មានដល់ភ្ញៀវទេសចរអំពីសេចក្តីណែនាំបញ្ហាទាក់ទងនឹងអាកប្បកិរិយា ដូចជាវិធីសមស្របក្នុងការទស្សនា ឬស្ម័គ្រចិត្តនៅឯមណ្ឌលកុមារកំព្រា ការឲ្យលុយដល់ក្មេងៗឬការប្រព្រឹត្តសកម្មភាពដែលពុំមានការទទួលខុសត្រូវ។ | នា- ផ្សព្វផ្សាយ/ ទេសចរណ៍/ ក្រសួងទេសចរណ៍/ មន្ទីរទេសចរណ៍ | | មធ្យម |





## ២.៤ គ្រប់គ្រងលំហូរអ្នកទស្សនា

*យុទ្ធសាស្ត្រ :* ត្រូវគ្រប់គ្រងលំហូរអ្នកទស្សនានៅក្នុងតំបន់បេតិកភណ្ឌពិភពលោកអង្គរ និងនៅតាមប្រាសាទនីមួយៗឲ្យឆ្លើយតបតាមលក្ខខណ្ឌរបស់រមណីយដ្ឋាន និងតម្រូវការទីផ្សារ។

*ហេតុផល :* ការគ្រប់គ្រងលំហូរអ្នកទស្សនានឹងសម្រួលដល់ការបែងចែកអ្នកទស្សនានៅក្នុងតំបន់បេតិកភណ្ឌពិភពលោកអង្គរ និងនៅតាមប្រាសាទនីមួយៗឈានទៅរកការកាត់

បន្ថយការកកស្ទះ ការលើកម្ពស់បទពិសោធទស្សនា និងការកាត់បន្ថយផលប៉ះពាល់នានាទៅលើប្រាសាទ។

| សកម្មភាព | ទំនួលខុសត្រូវ | រយៈពេល | អាទិភាព |
|---|---|---|---|
| ២.៥.១- សិក្សាពីវង់ទស្សនានិងសេចក្តីណែនាំក្នុងការគ្រប់គ្រងលំហូរអ្នកទស្សនានៅតាមប្រាសាទដែលមានភ្ញៀវទេសចរច្រើន ដើម្បីកាត់បន្ថយការកកស្ទះ (ឧទាហរណ៍ ការទស្សនាដោយមានច្រកចេញ ចូលផ្សេងគ្នា) | នា-វប្បធម៌/ ទេសចរណ៍ | | ខ្ពស់ |
| ២.៥.២- ត្រួតពិនិត្យចំនួនអ្នកទស្សនានិងផលប៉ះពាល់នានា ព្រមទាំងវាយតម្លៃប្រសិទ្ធភាពនៃដំណើរការគ្រប់គ្រងលំហូរអ្នកទស្សនា | នា-វប្បធម៌/ ទេសចរណ៍ | | ខ្ពស់ |
| ២.៥.៣- ផ្សព្វផ្សាយនិងដាក់ឲ្យដំណើរការវង់ទស្សនាថ្មីៗដើម្បីគ្រប់គ្រងលំហូរអ្នកទស្សនាឲ្យកាន់តែមានប្រសិទ្ធភាព | នា-ទេសចរណ៍/ ផ្សព្វផ្សាយ | | ខ្ពស់ |
| ២.៥.៤- ពិចារណាលើការដឹកជញ្ជូនដែលមានការត្រួតពិនិត្យច្បាស់លាស់ (ដូចរថយន្តអគ្គិសនីសាធារណៈ) សម្រាប់គ្រប់គ្រងលំហូរអ្នកទស្សនា | នា-ទេសចរណ៍/ វប្បធម៌/ អន្តរវិស័យ | | មធ្យម |
| ២.៥.៥- ពិនិត្យលើការប្រើប្រាស់បច្ចេកវិទ្យា (ឧទាហរណ៍ ម៉ាស៊ីន ថត)ដើម្បីគ្រប់គ្រងចរាចរណ៍និងលំហូរអ្នកទស្សនា | នា-ទេសចរណ៍ | | ទាប |
| ២.៥.៦- ពិនិត្យលើលទ្ធភាពបង្កើតកន្លែងលក់សំបុត្របន្ថែមក៏ដូចជាជម្រើសក្នុងការទិញសំបុត្រដទៃទៀត (ឧទាហរណ៍ ទិញមុនតាមអ៊ីនធឺណិត និងនៅក្នុងក្រុងសៀមរាប) | អគ្គនាយក អាជ្ញាធរអប្សរា/ នា-វប្បធម៌/ ក្រុមហ៊ុនសុខា | | មធ្យម |
| ២.៥.៧-ធ្វើការជាមួយទីភ្នាក់ងារទេសចរណ៍ដើម្បីចាត់ចែងពេលវេលានៃការមកដល់របស់រថយន្តដឹកភ្ញៀវទេសចរ | នា-ទេសចរណ៍ | | មធ្យម |
| ២.៥.៨- គ្រប់គ្រងដោយមានភាពបត់បែនដែលអាចប្រែប្រួលទៅតាមពេលវេលានិងតម្រូវការជាក់ស្តែង | នា-ទេសចរណ៍/ | | មធ្យម |

| | | | |
|---|---|---|---|
| | អាជ្ញាធរអប្សរា | | |
| ២.៤.៩- ពិចារណាជាចម្បងលើបញ្ហាលំហូរអ្នកទស្សនា (រួមមានប្រាសាទតាព្រហ្ម អង្គរវត្ត បេងមាលា និងអង្គរធំ) | នា- វប្បធម៌/ ទេសចរណ៍ | | ខ្ពស់ |
| ២.៤.១០- ផ្សព្វផ្សាយព័ត៌មានអំពីផ្លូវធ្វើដំណើរថ្មីៗទៅដល់មគ្គុទ្ទេសក៍ទេសចរណ៍និងភ្នាក់ងារទេសចរណ៍។ | នា-ទេសចរណ៍/ ផ្សព្វផ្សាយ/ ក្រ. ទេសចរណ៍/ មន្ទីរទេសចរណ៍ | | ខ្ពស់ |

## ២.៥ គ្រប់គ្រងប្រាសាទដោយរួមបញ្ចូលគ្រប់ផ្នែកពាក់ព័ន្ធ

***យុទ្ធសាស្ត្រ*** ***:*** ត្រូវគ្រប់គ្រងប្រាសាទសំខាន់ៗនៅតំបន់បេតិកភណ្ឌពិភពលោកអង្គរដាច់ដោយឡែកច្បាស់លាស់ និងឆ្លើយតបតាមលក្ខខណ្ឌរមណីយដ្ឋាននិងតម្រូវការទីផ្សារ។

***ហេតុផល*** ***:*** ការគ្រប់គ្រងប្រាសាទមួយៗដាច់ដោយឡែក នឹងឆ្លើយតបប្រកបដោយភាពបត់បែនទៅនឹងការប្រែប្រួលលក្ខខណ្ឌនានារបស់រមណីយដ្ឋាននិងអ្នកទស្សនា ក៏ដូចជាការសម្របសម្រួលនិងប្រើប្រាស់ធនធានឲ្យមានប្រសិទ្ធភាព។

| **សកម្មភាព** | **ទំនួលខុសត្រូវ** | **រយៈពេល** | **អាទិភាព** |
|---|---|---|---|
| ២.៥.១- បង្កើតក្រុមគ្រប់គ្រងនៅតាមប្រាសាទនីមួយៗ ដើម្បីពង្រឹងការទទួលខុសត្រូវ និងសមត្ថភាពបុគ្គលិកធ្វើការតាមតំបន់ប្រាសាទ | អគ្គនាយក អាជ្ញាធរអប្សរា | | ខ្ពស់ |
| ២.៥.២- បណ្តុះបណ្តាលបុគ្គលិកគ្រប់គ្រងនៅតាមប្រាសាទ ដែលពួកគាត់អាចគាំទ្រដល់ការសម្រេចចិត្តលើគោលនយោបាយនិងគ្រប់គ្រងការប្រែប្រួលលក្ខខណ្ឌនានានៅក្នុងប្រាសាទដូចជាការផ្លាស់ប្តូរលំហូរអ្នកទស្សនាតាមពេលវេលាផ្សេងៗគ្នា និងទទួលខុសត្រូវលើបញ្ហាដែលអាចកើតឡើងនៅអំឡុងពេលមានភ្ញៀវទស្សនាប្រាសាទ | អាជ្ញាធរអប្សរា/ ក្រុមការងារ HMF | | ខ្ពស់ |
| ២.៥.៣- រៀបចំវគ្គបណ្តុះបណ្តាលបុគ្គលិកអាជ្ញាធរ | អាជ្ញាធរអប្សរា | | ខ្ពស់ |

| | | | |
|---|---|---|---|
| អប្សរា ដើម្បីឲ្យពួកគាត់អាចសម្រេចចិត្តលើការគ្រប់គ្រងរមណីយដ្ឋាន និងពង្រឹងការអនុវត្តច្បាប់និងសេចក្តីណែនាំនានា | | | |
| ២.៥.៤- តែងតាំងអ្នកគ្រប់គ្រងនៅតាមបណ្តាប្រាសាទសំខាន់ៗ ដែលមានអំណាចនិងការទទួលខុសត្រូវក្នុងការសម្របសម្រួលបុគ្គលិកទាំងអស់(អាជ្ញាធរអប្សរា និងមែនមែនអាជ្ញាធរអប្សរា) និងមានសមត្ថភាពបង្កើតបច្ចេកទេសគ្រប់គ្រងនៅតាមរមណីយដ្ឋានប្រកបដោយភាពទន់ភ្លន់និងមានប្រសិទ្ធភាព | អគ្គនាយក អាជ្ញាធរអប្សរា | | ខ្ពស់ |
| ២.៥.៥- ផ្តល់ការបណ្តុះបណ្តាលពិសេសជាបន្តបន្ទាប់ដល់អ្នកគ្រប់គ្រងប្រាសាទ | អាជ្ញាធរអប្សរា/ ម្ចាស់ជំនួយ | | ខ្ពស់ |
| ២.៥.៦- រៀបចំ "សៀវភៅណែនាំស្តីពីការគ្រប់គ្រងរមណីយដ្ឋាន" សម្រាប់អ្នកគ្រប់គ្រងប្រាសាទនិងបុគ្គលិកបម្រើការនៅតាមប្រាសាទទាំងអស់ប្រើប្រាស់ | អាជ្ញាធរអប្សរា/ ក្រុមការងារ HMF | | ខ្ពស់ |
| ២.៥.៧- ត្រួតពិនិត្យចំនួនភ្ញៀវទេសចរ និងអាកប្បកិរិយារបស់អ្នកទស្សនាពិសេស អ្នកដឹកនាំក្រុមទេសចរ និងមគ្គុទ្ទេសក៍។ | នា-វប្បធម៌/ ទេសចរណ៍/ បុគ្គលិកអាជ្ញាធរអប្សរា/ នគរបាលបេតិកភណ្ឌ/ នគរបាលទេសចរណ៍ | | ខ្ពស់ |



## ២.៦ ឆ្លើយតបតាមតម្រូវការដឹកជញ្ជូន

*យុទ្ធសាស្ត្រ :* ការដឹកជញ្ជូននៅអង្គរត្រូវមានសុវត្ថិភាព និរន្តរភាព មានផលប៉ះពាល់តិចតួចទៅលើបេតិកភណ្ឌ និងឆ្លើយតបទៅនឹងលក្ខខណ្ឌរមណីយដ្ឋាន និងតម្រូវការទីផ្សារ។

*ហេតុផល :* តម្រូវការដឹកជញ្ជូន សម្ភារៈរូបវន្ត និងសកម្មភាពនានាគួរឆ្លើយតបតាមតម្រូវការរបស់ប្រជាជនក្នុងតំបន់ និងការអភិរក្សប្រាសាទនិងបរិស្ថាន។

| សកម្មភាព | ទំនួលខុសត្រូវ | រយៈពេល | អាទិភាព |
|---|---|---|---|
| ២.៦.១- រៀបចំផែនការមេតាមដំណាក់កាល សម្រាប់ការដឹកជញ្ជូននៅក្នុងតំបន់បេតិកភណ្ឌពិភពលោកអង្គរ | នា-អន្តរវិស័យ/ មន្ត្រីទទួលខុសត្រូវអនុវត្តTMP | | ខ្ពស់ |
| ២.៦.២- ធ្វើការបន្ថែមទៀតលើច្បាប់ចរាចរ ដើម្បីគ្រប់គ្រងលំហូរភ្ញៀវទេសចរនិងចំណតយានយន្ត | នា-អន្តរវិស័យ/ ទេសចរណ៍/ | | ខ្ពស់ |

| | | | |
|---|---|---|---|
| | អគ្គនាយក អាជ្ញាធរអប្សរា | | |
| ២.៦.៣- លើកទឹកចិត្តឲ្យមានការប្រើប្រាស់រថយន្តអគ្គីសនី និងការដឹកជញ្ជូនក្នុងតំបន់ ហើយកំណត់ទំហំយានយន្តនៅតំបន់អង្គរបន្តិចម្តងៗ | នា-អន្តរវិស័យ/ ទេសចរណ៍/ | | មធ្យម |
| ២.៦.៤- រកជម្រើសប្រព័ន្ធឯកទិសសម្រាប់ចរាចរណ៍នៅតំបន់អង្គរ | នា-អន្តរវិស័យ/ មន្ត្រីទទួលខុសត្រូវអនុវត្តTMP | | ខ្ពស់ |
| ២.៦.៥-លើកទឹកចិត្តឲ្យមានជម្រើសនៃការដឹកជញ្ជូនបែបប្រពៃណីដូចជា ការដើរ ការជិះកង់/រ៉ឺម៉ក និងរទេះគោ | នា-អន្តរវិស័យ/ ទេសចរណ៍/ ផ្សព្វផ្សាយ/ ព្រៃឈើ/ គ្រប់គ្រងលំនៅដ្ឋាន | | មធ្យម |
| ២.៦.៦- ចាត់ថ្នាក់ស្ថានភាព/កំណត់ផ្លូវក្នុងឧទ្យានអង្គរ (សាធារណៈ/ឯកជន) | នា-អន្តរវិស័យ/ អគ្គនាយក អាជ្ញាធរអប្សរា | | មធ្យម |
| ២.៦.៧- ពង្រឹងច្បាប់ចំពោះអ្នកបើកបរដែលប្រព្រឹត្តមិនត្រឹមត្រូវ(ឧទាហរណ៍អ្នកបើកបរទាំងឡាយណាមិនប្រើប្រាស់ចំណត) | នា-អន្តរវិស័យ/ អគ្គនាយក អាជ្ញាធរអប្សរា | | មធ្យម |
| ២.៦.៨- ធ្វើការជាមួយឧស្សាហកម្មទេសចរណ៍ក្នុងការអង្កេតនិងបង្កើតប្រព័ន្ធថ្មីសម្រាប់សេវាកម្មដឹកជញ្ជូននៅក្នុងតំបន់អង្គរ | នា-អន្តរវិស័យ/ មន្ត្រីទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍របស់អាជ្ញាធរ | | ខ្ពស់ |

| | | | |
|---|---|---|---|
| | អប្សរា | | |
| ២.៦.៩- ពិនិត្យលទ្ធភាពក្នុងការដាក់ដំណើរការប្រព័ន្ធដឹកជញ្ជូនថ្មីតាមបែបប្រពៃណី(ជាពិសេសនៅអង្គរធំ) | នា-អន្តរវិស័យ/ ទេសចរណ៍ | | ខ្ពស់ |
| ២.៦.១០- ធ្វើការជិតស្និទ្ធជាមួយនឹងឧស្សាហកម្មទេសចរណ៍ ដើម្បីធានាថាមានរយៈពេលគ្រប់គ្រាន់សម្រាប់ពួកគាត់សម្របខ្លួន មុនការផ្លាស់ប្តូរប្រព័ន្ធដឹកជញ្ជូនណាមួយនៅក្នុងតំបន់អង្គរកើតឡើង។ | នា-អន្តរវិស័យ/ មន្ត្រីទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍របស់អាជ្ញាធរអប្សរា | | ខ្ពស់ |

## ២.៧ ផ្តល់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលចាំបាច់

*យុទ្ធសាស្ត្រ :* ហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅអង្គរ ត្រូវបំពេញតាមតម្រូវការអ្នកទស្សនានិងឧស្សាហកម្មទេសចរណ៍ អភិរក្ស និងលើកកម្ពស់គុណតម្លៃបេតិកភណ្ឌ ព្រមទាំងការពារបរិស្ថាន។

*ហេតុផល :* ហេដ្ឋារចនាសម្ព័ន្ធនៅអង្គរគួរគាំទ្រសកម្មភាពនានានៅក្នុងរមណីយដ្ឋានប្រកបដោយចីរភាព និងសម្របទៅតាមតម្រូវការរបស់ប្រជាជនក្នុងតំបន់ និងការអភិរក្សប្រាសាទនិងបរិស្ថាន។

| សកម្មភាព | ទំនួលខុសត្រូវ | រយៈពេល | អាទិភាព |
|---|---|---|---|
| ២.៧.១- រៀបចំផែនការមេដែលប្រកបដោយទស្សនវិស័យមួយសម្រាប់ហេដ្ឋារចនាសម្ព័ន្ធសេវាកម្មទេសចរណ៍ រួមមានចំណតរថយន្ត បន្ទប់ទឹក កន្លែងសម្រាក តូបលក់ម្ហូបអាហារនិងភេសជ្ជៈនិងហាងផ្សេងៗទៀត | នា-អន្តរវិស័យ/ មន្ត្រីទទួលខុសត្រូវអនុវត្តTMP/ អគ្គនាយកអាជ្ញាធរអប្សរា/ នា-ក្នុងឧទ្យាន/ | | ខ្ពស់ |

| | | | |
|---|---|---|---|
| | ទេសចរណ៍ | | |
| ២.៧.២- បន្តកម្មវិធីស្តារប្រព័ន្ធធារាសាស្ត្របុរាណ | នា-គ្រប់គ្រងទឹក/ អន្តរវិស័យ | | មធ្យម |
| ២.៧.៣- រៀបចំចំណតនៅកន្លែងសំខាន់ៗស្របតាមផែនការមេ និងលើកទឹកចិត្តឲ្យអ្នកបើកបរប្រើប្រាស់ចំណតដែលបានកំណត់ | នា-អន្តរវិស័យ/ ក្នុងឧទ្យាន/ ទេសចរណ៍ | | មធ្យម |
| ២.៧.៤- បន្តធ្វើផ្លូវដើរអំពីឈើនៅកន្លែងដែលទ្រុឌទ្រោមក្នុងប្រាសាទ | នា-ក្នុងឧទ្យាន | | មធ្យម |
| ២.៧.៥- រៀបចំគំរូសមស្របសម្រាប់ហេដ្ឋារចនាសម្ព័ន្ធថ្មីដូចជា ទីលានមុខប្រាសាទ បង្គន់ ចំណត ។ល។ | នា-វប្បធម៌/ គ្រប់គ្រងលំនៅដ្ឋាន | | មធ្យម |
| ២.៧.៦-ផ្តល់អាទិភាពលើការរៀបចំហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងអ្នកទស្សនាបន្ថែមដូចជា ទីលានមុខប្រាសាទនៅប្រាសាទដែលមានភ្ញៀវទេសចរច្រើន | នា-អន្តរវិស័យ/ វប្បធម៌/ ទេសចរណ៍ | | មធ្យម |
| ២.៧.៧- ដំឡើង ផ្ទាំងព័ត៌មានដែលមានច្រើនភាសាបន្ថែមទៀតនៅប្រាសាទនានា | នា-វប្បធម៌/ គ្រប់គ្រងលំនៅដ្ឋាន/ ក្នុងឧទ្យាន | | មធ្យម |
| ២.៧.៨- រៀបចំផែនការនិងសាងសង់កន្លែងសម្រាកនៅក្នុងតំបន់អង្គរ ស្របតាមផែនការមេស្តីពីសេវាកម្មទេសចរណ៍ | នា-អន្តរវិស័យ/ ក្នុងឧទ្យាន/ ទេសចរណ៍ | | ខ្ពស់ |
| ២.៧.៩- បំពាក់ឧបករណ៍ការពាររន្ទះនៅតាមប្រាសាទនានាបន្ថែមទៀត | នា-ក្នុងឧទ្យាន | | ទាប |
| ២.៧.១០- ធ្វើការជាមួយឧស្សាហកម្មទេសចរណ៍ ក្នុងការរៀបចំនិងបង្កើនចំនួនបង្គន់ នៅតាមទីតាំងមួយចំនួន | នា-អន្តរវិស័យ/ មន្ត្រីទំនាក់ទងជាមួយ | | ខ្ពស់ |

| | | | |
|---|---|---|---|
| | ឧស្សាហកម្ម ទេសចរណ៍ របស់អាជ្ញាធរ អប្សរា/ មន្ត្រី ទទួលខុសត្រូវ អនុវត្តTMP | | |
| ២.៧.១១- សិក្សាពីការរៀបចំហាងលក់ម្ហូបអាហារ និង ភេសជ្ជៈដែលមានគុណភាពនៅក្បែរតំបន់ប្រាសាទ | នា-អន្តរវិស័យ/ ទេសចរណ៍ | | ខ្ពស់ |
| ២.៧.១២- តម្លើងភ្លើងនៅតាមបណ្ដោយផ្លូវនៅក្នុង តំបន់អង្គរ | អាជ្ញាធរអប្សរា/ ម្ចាស់ជំនួយ | | ទាប |
| ២.៧.១៣- បន្ថែមធុងសំរាមនិងកន្លែងដែលបាន សម្អាតរួចរាល់ ដើម្បីធ្វើឲ្យមានបរិស្ថានល្អ និងរក្សា អនាម័យ ជាពិសេសនៅជុំវិញកន្លែងលក់ដូរ | នា-ព្រៃឈើ/ ទេសចរណ៍ | | មធ្យម |
| ២.៧.១៤- កែលម្អផ្លូវទៅកាន់ប្រាសាទនិងសហគមន៍ | នា-អន្តរវិស័យ | | មធ្យម |
| ២.៧.១៥- ពិចារណាលើហេដ្ឋារចនាសម្ព័ន្ធបន្ថែម សម្រាប់ភ្ញៀវជាលក្ខណៈគ្រួសារនិងកុមារ | នា-អន្តរវិស័យ | | ទាប |
| ២.៧.១៦- វាយតម្លៃការប្រើប្រាស់ប្រកបដោយ សក្ដានុពលនូវបញ្ជរលក់សំបុត្រចាស់ ក្រោយពេល បើកដំណើរការមណ្ឌលស្វាគមន៍ថ្មី។ ពិចារណាលើការ ប្រើប្រាស់ជាច្រកចូល និងកន្លែងតម្រង់ទិសអ្នក ទស្សនាដែលទិញសំបុត្ររួច។ | នា-ទេសចរណ៍/ អន្តរវិស័យ | | មធ្យម |



## ២.៨ គ្រប់គ្រងហានិភ័យបរិស្ថាន សង្គមនិងប្រាសាទ

*យុទ្ធសាស្ត្រ :* ធ្វើការសម្រេចចិត្តសម្រាប់តំបន់អង្គរត្រូវពឹងផ្អែកលើផែនទីហានិភ័យដែលមានលក្ខណៈច្បាស់លាស់ តាមរយៈព័ត៌មានពីប្រភពផ្សេងៗនិងមានបង្ហាញទិន្នន័យរចនាសម្ព័ន្ធបរិស្ថាននិងសង្គមវប្បធម៌។

*ហេតុផល :* ការគ្រប់គ្រងតំបន់ប្រាសាទនិងការធ្វើការសម្រេចចិត្តបានល្អនៅអង្គរទាមទារនូវឧបករណ៍ប្រកបដោយប្រសិទ្ធភាពដែលកំណត់និងពិចារណាពីគុណតម្លៃ បញ្ហា និងព័ត៌មានដែលមានទំនាក់ទំនងនឹងគ្នា។

| សកម្មភាព | ទំនួលខុសត្រូវ | រយៈពេល | អាទិភាព |
|---|---|---|---|
| ២.៨.១- ទទួលស្គាល់ការផ្សារភ្ជាប់គ្នារវាងទេសចរណ៍ និងការគ្រប់គ្រងបរិស្ថានរួមមាន ភ្លើង ទឹក កាកសំណល់ ការប្រែប្រួលអាកាសធាតុ និងត្រៀមបម្រុងចំពោះគ្រោះមហន្តរាយ | ក្រុមផែនទីហានិភ័យ/ នា-អន្តរវិស័យ/ ក្នុងឧទ្យាន/ គ្រប់គ្រងទឹក/ គ្រប់គ្រងព្រៃឈើ/ ក្រៅឧទ្យាន | | ខ្ពស់ |
| ២.៨.២- ចាប់ផ្តើមប្រមូលទិន្នន័យហានិភ័យ | ក្រុមផែនទី | | ខ្ពស់ |

| | | | |
|---|---|---|---|
| រចនាសម្ព័ន្ធ បរិស្ថាន និងសង្គមវប្បធម៌នៅតាមប្រាសាទក្នុងតំបន់បេតិកភណ្ឌពិភពលោកអង្គរ | ហានិភ័យ/ នា-អន្តរវិស័យ/ ក្នុងឧទ្យាន/ គ្រប់គ្រងទឹក/ គ្រប់គ្រងព្រៃឈើ/ ក្រៅឧទ្យាន | | |
| ២.៨.៣- បន្តការងារផែនទីហានិភ័យ។ | ក្រុមផែនទីហានិភ័យ/ នា-អន្តរវិស័យ/ ក្នុងឧទ្យាន/ គ្រប់គ្រងទឹក/ គ្រប់គ្រងព្រៃឈើ/ ក្រៅឧទ្យាន | | ខ្ពស់ |

## ២.៩ ត្រួតពិនិត្យនិងថែទាំ

*យុទ្ធសាស្ត្រ :* ត្រូវអភិរក្សគុណតម្លៃបេតិកភណ្ឌពិភពលោកតាមរយៈការត្រួតពិនិត្យផលប៉ះពាល់នានាពីទេសចរណ៍ប្រកបដោយប្រសិទ្ធភាព និងការថែទាំដែលឆ្លើយតបទៅនឹងការប្រែប្រួលលក្ខខណ្ឌរមណីយដ្ឋាននិងតម្រូវការទីផ្សារ។

*ហេតុផល :* ការត្រួតពិនិត្យជាបន្តលើផលប៉ះពាល់ពីទេសចរណ៍នៅតំបន់បេតិកភណ្ឌពិភពលោកអង្គរ ទាមទារនូវធនធានតាមពេលវេលាកំណត់ និងសមស្រប ព្រមជាមួយនឹងកម្មវិធីថែទាំដែលកាន់តែមានប្រសិទ្ធភាព។

| សកម្មភាព | ទំនួលខុសត្រូវ | រយៈពេល | អាទិភាព |
|---|---|---|---|
| ២.៩.១- បង្កើតប្រព័ន្ធគោលការណ៍ និងនីតិវិធីសម្រាប់ការត្រួតពិនិត្យនិងថែទាំ ដើម្បីការពារគុណតម្លៃតំបន់ | មន្ត្រីទទួលខុស | | ខ្ពស់ |

| | | | |
|---|---|---|---|
| បេតិកភណ្ឌអង្គរ និងគ្រប់គ្រងបញ្ហាអ្នកទស្សនានិងសុវត្ថិភាពប្រាសាទ | ត្រូវអនុវត្តTMP/ នា-វប្បធម៌/ ទេសចរណ៍ | | |
| ២.៩.២- លើកកម្ពស់ការអនុវត្តការត្រួតពិនិត្យនៅតំបន់បេតិកភណ្ឌពិភពលោកអង្គរ ប្រមូលនិងបញ្ចូលទិន្នន័យ ដើម្បីជាព័ត៌មានសម្រាប់រមណីយដ្ឋាន និងការសម្រេចចិត្តលើការគ្រប់គ្រង | អាជ្ញាធរអប្សរា | | ខ្ពស់ |
| ២.៩.៣- រៀបចំវិធីត្រួតពិនិត្យផលប៉ះពាល់សង្គមតាមទ្រឹស្តីនិងតាមវិធីសាស្ត្រអនុវត្ត (ដើម្បីត្រួតពិនិត្យការប្រែប្រួលឥរិយាបថសង្គមចំពោះទេសចរណ៍ និងផលប៉ះពាល់សង្គមផ្សេងទៀត) ដែលបន្តសាចុះសាឡើង។ ក្នុងពេលយូរអង្វែង។ សិក្សាពីផលប៉ះពាល់សង្គមនិងចាប់ផ្តើមដំណើរការត្រួតពិនិត្យផលប៉ះពាល់សង្គម | នា-គ្រប់គ្រងលំនៅដ្ឋាន | ២ ឆ្នាំ | មធ្យម |
| ២.៩.៤- ថែទាំវត្តអារាម គំនូរ ចម្លាក់ ដើម្បីបង្ហាញ និងពន្យល់ភ្ញៀវទេសចរ ឲ្យយល់ពីប្រពៃណីនិងវប្បធម៌។ | នា-គ្រប់គ្រងលំនៅដ្ឋាន/ ក្នុងឧទ្យាន/ សហាគមន៍ពុទ្ធសាសនា | បន្ត | មធ្យម |



# ការផ្តួចផ្តើមគោលនយោបាយTMPទី៣ គឺភាពជាដៃគូជាមួយឧស្សាហកម្មទេសចរណ៍




## គោលបំណងនៃការគ្រប់គ្រង

ឧស្សាហកម្មទេសចរណ៍និងរាជរដ្ឋាភិបាលនឹងរួមសហការគ្នាជាដៃគូក្នុងការគ្រប់គ្រងវិស័យទេសចរណ៍នៅតំបន់បេតិកភណ្ឌពិភពលោកអង្គរប្រកបដោយចីរភាព តាមរយៈការប្រាស្រ័យទាក់ទងល្អ ឲ្យមានតម្លាភាពនិងស៊ីចង្វាក់គ្នា និងធ្វើការសម្រេចចិត្តទាន់ពេលវេលា។

- ពង្រឹងទំនាក់ទំនងរវាងឧស្សាហម្មទេសចរណ៍និងរាជរដ្ឋាភិបាល ដើម្បីទទួលបានផលប្រយោជន៍ទាំងអស់គ្នា។

- ប្រាស្រ័យទាក់ទងផ្តល់ព័ត៌មានឲ្យច្បាស់លាស់និងស៊ីចង្វាក់គ្នាទៅវិញទៅមករវាងឧស្សាហកម្មទេសចរណ៍និងរាជរដ្ឋាភិបាល។
- ធានាថាការអភិវឌ្ឍន៍និងការលូតលាស់វិស័យទេសចរណ៍ប្រកបដោយចីរភាពនិងទទួលបានការការពារ ព្រមទាំងលើកកម្ពស់គុណតម្លៃបេតិកភណ្ឌ។
- លើកទឹកចិត្តនិងសម្របសម្រួលការផ្តួចផ្តើមវិនិយោគ ក្នុងវិស័យទេសចរណ៍ដែលស្របគ្នាជាមួយគុណតម្លៃបេតិកភណ្ឌ។
- គ្រប់គ្រងដោយឆ្លើយតបទៅនឹងតម្រូវការឧស្សាហកម្មទេសចរណ៍និងបម្រែបម្រួលទីផ្សារ។

**សមិទ្ធផលនានាមកដល់បច្ចុប្បន្ន**

ឧស្សាហកម្មទេសចរណ៍បានបង្ហាញចំណាប់អារម្មណ៍និងចេតនារបស់ខ្លួនក្នុងការចូលរួមអភិរក្សការពារនិងផ្សព្វផ្សាយពីតំបន់បេតិកភណ្ឌពិភពលោកអង្គរ។ អាជ្ញាធរអប្សរាបានរកឃើញនូវបញ្ហាមួយចំនួននិងកំពុងស្វែងរកកិច្ចសហការជាមួយនឹងឧស្សាហកម្មទេសចរណ៍នៅអង្គរ។ សិក្ខាសាលាចំនួនពីរលើកបានធ្វើឡើងដោយជោគជ័យនៅឆ្នាំ២០០៤និង២០០៦ ជាមួយនឹងផ្នែកឯកជននិងមានសិក្ខាសាលាប្រឹក្សាយោបល់ដ៏ធំមួយទៀតនាខែមីនាឆ្នាំ២០១២។ កន្លងមក អាជ្ញាធរអប្សរាបានបង្កើតវគ្គវិក្រឹតការមគ្គុទ្ទេសក៍ទេសចរណ៍ និងកម្មវិធីពង្រឹងសមត្ថភាព ដែលដំណើរការបានរយៈពេលប្រាំឆ្នាំ។ អាជ្ញាធរអប្សរាក៏បានចាប់ផ្តើមវិធានការសម្របសម្រួលប្រតិបត្តិការនានារបស់ឧស្សាហកម្មទេសចរណ៍ផងដែរ។ អាជ្ញាធរអប្សរាបានរៀបចំទីលានមុខប្រាសាទបន្ទាយស្រី ដើម្បីសម្រួលការងារទីភ្នាក់ងារ និងមគ្គុទ្ទេសក៍ទេសចរណ៍និងបានរៀបចំតារាងតម្លៃសម្រាប់ការស្នើសុំលិខិតអនុញ្ញាតរៀបចំព្រឹត្តិការណ៍ពេលយប់នៅក្នុងបរិវេណឧទ្យានអង្គរ។ ការផ្តួចផ្តើមនាពេលថ្មីៗរួមមាន ការបង្កើតក្រុមការងារជាដៃគូជាមួយឧស្សាហកម្មទេសចរណ៍ និងរៀបចំផ្សព្វផ្សាយព័ត៌មានឲ្យបានទៀងទាត់ដល់ឧស្សាហកម្មទេសចរណ៍ តាមរយៈព្រឹត្តិបត្រព័ត៌មានអេឡិចត្រូនិច។

## បញ្ហាប្រឈម

បញ្ហារបស់ឧស្សាហកម្មទេសចរណ៍ខាងក្រោមនេះ បានមកពីកិច្ចពិភាក្សារវាងរាជរដ្ឋាភិបាល សហគមន៍ ឬអ្នកពាក់ព័ន្ធក្នុងវិស័យទេសចរណ៍នៅអង្គរ ក្នុងដំណើរការពិគ្រោះយោបល់ ដើម្បីរៀបចំឯកសារផែនការគ្រប់គ្រងទេសចរណ៍នេះ។

| បញ្ហា | យុទ្ធសាស្ត្រ |
|---|---|
| ខ្វះការសន្ទនា និងការទាក់ទងជាប្រចាំរវាងវិស័យឯកជន និងរាជរដ្ឋាភិបាល។<br><br>ខ្វះប្រឹក្សាយោបល់ជាមួយឧស្សាហកម្មទេសចរណ៍មុននឹងឈានដល់ការអនុវត្តវង់ទស្សនា បទបញ្ញា ឬ សេចក្តីណែនាំនានា។<br><br>ឧស្សាហកម្មទេសចរណ៍បង្ហាញពីក្តីព្រួយបារម្ភយ៉ាងខ្លាំងចំពោះកង្វះខាតការប្រាស្រ័យទាក់ទងនិងទទួលព័ត៌មាន។<br><br>ឧស្សាហកម្មទេសចរណ៍ពិបាកនឹងទទួលព័ត៌មានដែលមានសារៈសំខាន់ថ្មីៗ។<br><br>ខ្វះយន្តការចាំបាច់សម្រាប់បញ្ជូនព័ត៌មានសំខាន់ៗ។<br><br>វិស័យឯកជនត្រូវការឲ្យមានមន្ត្រីអាជ្ញាធរអប្សរាណាម្នាក់ដែលពួកគាត់អាចទំនាក់ទំនងរកព័ត៌មាន។<br><br>ពិបាកក្នុងការទំនាក់ទំនងសួរនាំព័ត៌មានពីសេវាកម្មរបស់អាជ្ញាធរអប្សរា។<br><br>ឧស្សាហកម្មទេសចរណ៍ពុំបានដឹងច្បាស់ថាតើមន្ត្រីរបស់អាជ្ញាធរអប្សរាណាម្នាក់ដែលពួកគាត់អាចទំនាក់ទំនងសុំជំនួយនោះទេ។ | ទី១ |
| ប្រតិបត្តិករមួយចំនួនមិនបានគាំទ្រប្រើមគ្គុទ្ទេសក៍ក្នុងស្រុក ឬអនុវត្តតាមគោលនយោបាយនានារបស់អាជ្ញាធរអប្សរា។<br><br>ពុំទាន់មានស្តង់ដាក្រមប្រត្តិបត្តិស្តីពីការអនុវត្តប្រកបដោយសីលធម៌វិជ្ជាជីវៈរបស់ឧស្សាហកម្មទេសចរណ៍នៅឡើយទេ។<br><br>ទីផ្សារទេសចរណ៍មួយចំនួនប្រើប្រាស់អ្នកដឹកនាំក្រុមភ្ញៀវទេសចរបរទេសច្រើនជាងមគ្គុទ្ទេសក៍ក្នុងស្រុកនៅក្នុងបរិវេណប្រាសាទ។ | ទី២ |
| មានការយល់ដឹងមិនស្របគ្នាឬមិនច្បាស់លាស់ពីការអនុញ្ញាតឲ្យមានសកម្មភាពក្នុងតំបន់អង្គរ ដូចជាការថតរូបធ្វើអាជីវកម្មជាដើម។<br><br>អាជ្ញាធរអប្សរាមានការលំបាកក្នុងការត្រួតពិនិត្យសកម្មភាពរបស់ឧស្សាហកម្មទេសចរណ៍ឲ្យបានត្រឹមត្រូវ។<br><br>ឧស្សាកម្មទេសចរណ៍មិនទាន់យល់ដឹងច្បាស់អំពីសេវាកម្មនានារបស់អាជ្ញាធរ | ទី៦ |

| | |
|---|---|
| អប្សរា។<br><br>ឧស្សាហកម្មទេសចរណ៍មិនទាន់យល់ច្បាស់ពីអាជ្ញាធរអប្សរានៅឡើយ។<br><br>ការអនុញ្ញាតឲ្យបុគ្គលិកឧស្សាហកម្មទេសចរណ៍ ចូលបំពេញការងារនៅតំបន់អង្គរនៅមានកម្រិតនៅឡើយ។<br><br>មានភាពសាំញ៉ាំនៅពេលដែលវិស័យឯកជនស្នើសុំលិខិតអនុញ្ញាតថតរូបភាពសន្លឹកឬវីដេអូ។<br><br>សារធារណជនមិនសូវយល់ដឹងច្បាស់ពីសេវាកម្មនៅមជ្ឈមណ្ឌលសេវាកម្មអាជ្ញាធរអប្សរា។<br><br>វិស័យឯកជនមួយចំនួនមិនដឹងថាត្រូវទាក់ទងនរណា ដើម្បីរៀបចំព្រឹត្តិការណ៍នៅក្នុងតំបន់អង្គរ។<br><br>ការធ្វើសេចក្តីសម្រេចចិត្តនានានៅតំបន់អង្គរមិនមានតម្លាភាពនិងស៊ីចង្វាក់គ្នា។ | |
| ប្រតិបត្តិករមួយចំនួនមិនទាន់យល់ពីគុណតម្លៃនៃបេតិកភណ្ឌអង្គរនិងមិនបានផ្សព្វផ្សាយគុណតម្លៃទាំងនោះទៅដល់ភ្ញៀវទេសចរ។ | ទី៥ |
| ប្រតិបត្តិករមួយចំនួនចង់បង្កើតនិងវិនិយោគលើផលិតផលថ្មីនៅអង្គរ ប៉ុន្តែមិនអាចធ្វើទៅរួច។<br><br>ពុំសូវមានឱកាសរៀបចំព្រឹត្តិការណ៍ឬសកម្មភាពធំៗនៅតំបន់អង្គរ។<br><br>ទីភ្នាក់ងារទេសចរណ៍ចង់ផ្តល់លទ្ធភាពទស្សនាពិសេសដល់អតិថិជនរបស់ខ្លួននៅតាមទីតាំងដែលមិនសូវមានភ្ញៀវទេសចរដទៃទៀត។ | ទី៤ |
| ប្រតិបត្តិករមួយចំនួនមិនដឹង ឬមិនអាចទទួលបានបទបញ្ជានិងសេចក្តីណែនាំនានា។ | ទី២ |
| ឧស្សាហកម្មទេសចរណ៍ត្រូវមានទ្រង់ទ្រាយប្រសើរជាងនេះដើម្បីចូលរួមសកម្មភាពនានានៅតំបន់អង្គរ (ឧទាហរណ៍ សភាពាណិជ្ជកម្ម)។ | ទី៣ |

## យុទ្ធសាស្រ្ត

មានយុទ្ធសាស្រ្តចំនួន៦ដែលអាចជួយឲ្យកិច្ចសហការរវាងឧស្សាហកម្មទេសចរណ៍និងរាជរដ្ឋាភិបាលកាន់តែល្អប្រសើរៈ

១- រៀបចំយន្តការសម្រាប់កិច្ចសហការជាមួយឧស្សាហកម្មទេសចរណ៍

២- កែលម្អឧស្សាហកម្មទេសចរណ៍ឲ្យមានស្តង់ដា

៣- កែលម្អនិងបង្កើនការប្រមូលព័ត៌មានពីឧស្សាហកម្មទេសចរណ៍

៤- រៀបចំកម្មវិធីរួមគ្នា

៥- បង្កើនការយល់ដឹងពីគុណតម្លៃនិងតម្រូវការអភិរក្សនៅអង្គរ

៦- អនុញ្ញាតនិងឯកភាពលើសកម្មភាពសមស្របរបស់ឧស្សាហកម្មទេសចរណ៍។

## ៣.១ រៀបចំយន្តការសម្រាប់កិច្ចសហការជាមួយឧស្សាហកម្មទេសចរណ៍

***យុទ្ធសាស្ត្រ :*** រាជរដ្ឋាភិបាលកម្ពុជានិងឧស្សាហកម្មទេសចរណ៍នឹងរៀបចំប្រព័ន្ធមួយដែលអាចបន្តផ្លាស់ប្តូរព័ត៌មាន សហការការងារ និងពិគ្រោះយោបល់គ្នាទៅវិញទៅមក។

***ហេតុផល :*** ការគ្រប់គ្រងទេសចរណ៍នៅអង្គរតម្រូវឲ្យមានកិច្ចសហប្រតិបត្តិការ ដើម្បីរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងអ្នកទស្សនាប្រកបដោយប្រសិទ្ធភាព ស្របតាមគុណតម្លៃអង្គរ និងផ្តល់ផលប្រយោជន៍ដល់ការអភិវឌ្ឍន៍ទេសចរណ៍ប្រកបដោយចីរភាព។

| សកម្មភាព | ទំនួលខុសត្រូវ | រយៈពេល | អាទិភាព |
|---|---|---|---|
| ៣.១.១-ចែករំលែកព័ត៌មានរវាងឧស្សាហកម្មទេសចរណ៍និងអាជ្ញាធរអប្សរាឲ្យបានទៀតទាត់ តាមរយៈមន្ត្រីជំនាញ គេហៈទំព័រ វេទិកាការប្រជុំប្រចាំត្រីមាស និងព័ត៌មានអេឡិចត្រូនិច | មន្ត្រីទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍/ អ្នកបញ្ចូលទិន្នន័យក្នុងគេហៈទំព័រ/ មជ្ឈមណ្ឌលសេវាកម្មអាជ្ញាធរអប្សរា/ ក្រុមប្រឹក្សា | | ខ្ពស់ |

| | | | |
|---|---|---|---|
| | យោបល់ជាមួយឧស្សាហកម្មទេសចរណ៍ | | |
| ៣.១.២- បង្កើនភាពជឿជាក់លើការទំនាក់ទំនងគ្នារវាងអាជ្ញាធរអប្សរានិងវិស័យឯកជន រួមទាំងឧស្សាហកម្មទេសចរណ៍ | មន្ត្រីទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍/អាជ្ញាធរអប្សរា | | ខ្ពស់ |
| ៣.១.៣- សម្របសម្រួលកិច្ចសហការការងារ ជាបន្តជាប់ជានិច្ចជាមួយក្រុមការងារប្រឹក្សាយោបល់ឧស្សាហកម្មទេសចរណ៍ | មន្ត្រីទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍/ក្រុមប្រឹក្សាយោបល់ជាមួយឧស្សាហកម្មទេសចរណ៍ | | ខ្ពស់ |
| ៣.១.៤- ពិនិត្យវិធានការនានាដែលមានស្រាប់ដើម្បីប្រឹក្សាយោបល់ជាមួយឧស្សាហកម្មទេសចរណ៍រួមមានមន្ត្រីអាជ្ញាធរអប្សរានានាដែលប្រគល់ការងារឲ្យ និងស្វែងរកយោបល់ពីផ្នែកឧស្សាហកម្មទេសចរណ៍លើប្រសិទ្ធភាពនៃការផ្តួចផ្តើមនេះ | មន្ត្រីទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍/អគ្គនាយកអាជ្ញាធរអប្សរា/វិស័យឯកជន/មជ្ឈមណ្ឌលសេវាកម្មអាជ្ញាធរអប្សរា/នា-ទេសចរណ៍ | | ខ្ពស់ |
| ៣.១.៥- លើកទឹកចិត្តឧស្សាហកម្មទេសចរណ៍ឲ្យពិចារណាអំពីយន្តការជ្រើសរើសតំណាងរបស់ខ្លួនមក | មន្ត្រីទំនាក់ទំនង | | មធ្យម |

| | | | |
|---|---|---|---|
| ចូលរួមក្នុងការគ្រប់គ្រងទេសចរណ៍ | ជាមួយឧស្សាហកម្មទេសចរណ៍/ វិស័យឯកជន | | |
| ៣.១.៦- អនុម័តគោលនយោបាយសម្រាប់ប្រឹក្សាយោបល់ជាមួយឧស្សាហកម្មទេសចរណ៍ នៅពេលណាដែលមានសំណើសំខាន់ៗ ឬការប្រែប្រួលផ្សេងៗចំពោះការគ្រប់គ្រងទេសចរណ៍ | អគ្គនាយកអាជ្ញាធរអប្សរា/ អាជ្ញាធរអប្សរា | | ខ្ពស់ |
| ៣.១.៧- ផ្តល់ព័ត៌មាននិងតារាងពេលវេលាអនុវត្តការសម្រេចចិត្តថ្មីក្នុងការគ្រប់គ្រងដល់ឧស្សាហកម្មទេសចរណ៍មុនពេលអនុវត្ត | អាជ្ញាធរអប្សរា | | ខ្ពស់ |
| ៣.១.៨- បង្កើត "ខ្សែទូរស័ព្ទ" សម្រាប់បុគ្គលិកឧស្សាហកម្មទេសចរណ៍ផ្តល់យោបល់ឬសុំជំនួយបន្ទាន់។ | នា-ទេសចរណ៍ | | មធ្យម |



## ៣.២ កែលម្អឧស្សាហកម្មទេសចរណ៍ឲ្យមានស្តង់ដា

*យុទ្ធសាស្ត្រ :* ផ្នែកឧស្សាហកម្មទេសចរណ៍នឹងធ្វើប្រតិបត្តិការនៅអង្គរ ដោយអនុលោមតាមបទដ្ឋានសមស្របដែលបានបង្កើតឡើងតាមតម្រូវការសំខាន់របស់ជាតិនិងស្ថានភាពបេតិកភណ្ឌពិភពលោកនៃតំបន់អង្គរ។

*ហេតុផល* : ការអភិវឌ្ឍន៍ទេសចរណ៍នៅអង្គរប្រកបដោយចីរភាព តម្រូវឲ្យឧស្សាហកម្មទេសចរណ៍ប្រតិបត្តិប្រកបដោយវិជ្ជាជីវៈនិងនិរន្តរភាព និងស្របតាមស្តង់ដា។ ប្រការនេះនឹងលើកកម្ពស់កេរ្តិ៍ឈ្មោះនិងគុណភាពឧស្សាហកម្មទេសចរណ៍ ដែលរួមចំណែកដល់ការអភិរក្សតំបន់បេតិកភណ្ឌពិភពលោកអង្គរ ផ្តល់នូវការទ្រទ្រង់ដ៏រឹងមាំដល់សេដ្ឋកិច្ចកម្ពុជា ព្រមទាំងធានាគុណភាពសេវាកម្មនិងបទពិសោធអ្នកទស្សនា។

| សកម្មភាព | ទំនួលខុសត្រូវ | រយៈពេល | អាទិភាព |
|---|---|---|---|
| ៣.២.១- រៀបចំក្រមប្រតិបត្តិឧស្សាហកម្មទេសចរណ៍មួយដែលរួមបញ្ចូលនូវការបង្កើតស្តង់ដាសេវាកម្មដឹកជញ្ជូនប្រព័ន្ធត្រួតពិនិត្យនានា និងយន្តការផ្តល់យោបល់ត្រឡប់មកវិញ | នា-វប្បធម៌/ ក្រសួងទេសចរណ៍/ នា-ទេសចរណ៍ | | ខ្ពស់ |
| ៣.២.២- រិះរកជម្រើសក្នុងការបង្កើតឡើងនូវយន្តការ "ផ្តល់វិញ្ញាបនបត្រទទួលស្គាល់" មជ្ឈដ្ឋានខាងក្រៅចំពោះប្រតិបត្តិករទេសចរណ៍នានា ដែលអនុវត្តល្អបំផុតមិនបង្កការខូចខាតបេតិកភណ្ឌ | នា-វប្បធម៌/ ក្រសួងទេសចរណ៍/ នា-ទេសចរណ៍ | | មធ្យម |
| ៣.២.៣-លើកទឹកចិត្តទេសចរណ៍ដែលមិនបង្កការខូចខាតបេតិកភណ្ឌ និងគាំទ្របណ្តាញប្រតិបត្តិករដែលផ្តល់ការគាំទ្រជាសាធារណៈឲ្យមានវិធីសាស្ត្រអនុវត្តដ៏ល្អបំផុត។ | មន្ត្រីទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍/ ក្រសួងទេសចរណ៍/ នា-ទេសចរណ៍ | | មធ្យម |





### ៣.៣ កែលម្អនិងការបង្កើនការប្រមូលព័ត៌មានពីឧស្សាហកម្មទេសចរណ៍

*យុទ្ធសាស្ត្រ :* ផ្តល់លទ្ធភាពដល់រដ្ឋាភិបាលនិងឧស្សាហកម្មទេសចរណ៍ទទួលបានព័ត៌មានថ្មីៗទាន់ពេលវេលា អំពីប្រតិបត្តិការរបស់ឧស្សាហកម្មទេសចរណ៍នៅក្នុងតំបន់អង្គរនិងក្រុងសៀមរាប។

*ហេតុផល :* ការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយប្រសិទ្ធភាព និងមានទំនួលខុសត្រូវក្នុងការគ្រប់គ្រងទេសចរណ៍នៅអង្គរ តម្រូវឲ្យមានទិន្នន័យត្រឹមត្រូវនិងទាន់ពេលវេលា។

| សកម្មភាព | ទំនួលខុសត្រូវ | រយៈពេល | អាទិភាព |
|---|---|---|---|
| ៣.៣.១- រៀបចំយន្តការប្រមូលទិន្នន័យកាន់តែប្រសើរឡើងជាមួយឧស្សាហកម្មទេសចរណ៍រួមមាន ចំនួនភ្ញៀវទេសចរ ផ្លូវទស្សនា បញ្ហាប្រឈម អាកប្បកិរិយារដូវទស្សនា និងបញ្ហាផ្សេងៗទៀត។ | នា-ទេសចរណ៍/ មន្ត្រីទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍ | | មធ្យម |

### ៣.៤ រៀបចំកម្មវិធីរួមគ្នា

*យុទ្ធសាស្ត្រ :* កម្មវិធីនិងសកម្មភាពទេសចរណ៍ប្រកបដោយចីរភាពនឹងត្រូវបានធ្វើឡើងតាមរយៈទំនាក់ទំនងការងារប្រកបដោយប្រសិទ្ធភាពរវាងរាជរដ្ឋាភិបាល ឧស្សាហកម្មទេសចរណ៍ អង្គការមិនមែនរដ្ឋាភិបាល និងប្រជាជនក្នុងតំបន់។

*ហេតុផល :* ការផ្តួចផ្តើមថ្មីៗដ៏សំខាន់ចំពោះការគ្រប់គ្រងទេសចរណ៍ អាចសម្រេចជោគជ័យទៅបានលុះត្រាតែពួកគេបានទទួលការគាំទ្រពីអ្នកពាក់ព័ន្ធ។

| សកម្មភាព | ទំនួលខុសត្រូវ | រយៈពេល | អាទិភាព |
|---|---|---|---|
| ៣.៤.១- សហការជាមួយដៃគូឧស្សាហកម្មទេសចរណ៍ ដើម្បីសាកល្បងជាមួយ និងប្រើប្រាស់ផ្លូវធ្វើដំណើរទេសចរណ៍វប្បធម៌មួយថ្មីជាមួយនឹងទីភ្នាក់ងារដំណើរកម្សាន្តនិងមគ្គុទ្ទេសក៍ទេសចរណ៍ | នា- វប្បធម៌/ គ្រប់គ្រង លំនៅដ្ឋាន/ ទេសចរណ៍ | | មធ្យម |
| ៣.៤.២- សហការនិងពិគ្រោះយោបល់ជាមួយនឹងផ្នែកឯកជនពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ "ផលិតផល" ថ្មីនិងកាលានុវត្តភាពថ្មីៗ | មន្ត្រីទំនាក់ទំនងជាមួយ ឧស្សាហកម្ម ទេសចរណ៍/ នា- វប្បធម៌/ គ្រប់គ្រង លំនៅដ្ឋាន/ ទេសចរណ៍ | | ខ្ពស់ |
| ៣.៤.៣- សហការបន្ថែមទៀតជាមួយប្រតិបត្តិករនានាដើម្បីលើកទឹកចិត្តឲ្យមានការប្រើប្រាស់សកម្មភាពដែលនាំមកនូវផលប្រយោជន៍ដល់ប្រជាជនក្នុងតំបន់ និងផលិតផលក្នុងតំបន់ | នា- គ្រប់គ្រង លំនៅដ្ឋាន/ ទេសចរណ៍ | | មធ្យម |
| ៣.៤.៤- រិះរកផលិតផលថ្មីជាមួយនឹងការវិនិយោគពីវិស័យឯកជន | ក្រុមប្រឹក្សា ជាមួយឧស្សាហកម្មទេសចរណ៍ | | មធ្យម |
| ៣.៤.៥-អភិវឌ្ឍកម្មវិធីរួមគ្នាជាមួយនឹងឧស្សាហកម្មទេសចរណ៍ ដើម្បីផ្សព្វផ្សាយពីក្រុមអ្នកទស្សនា | មន្ត្រីទំនាក់ទំនងជាមួយ ឧស្សាហកម្ម ទេសចរណ៍/ | | ខ្ពស់ |

| | | | |
|---|---|---|---|
| | ក្រុមប្រឹក្សាជាមួយឧស្សាហកម្មទេសចរណ៍/ នា-ផ្សព្វផ្សាយ/ ក្រ. ទេសចរណ៍ | | |
| ៣.៤.៦- រិះរកមធ្យោបាយបង្កើតឲ្យមានកម្មវិធីរួមគ្នាដើម្បីអនុញ្ញាត ឲ្យមានការវិនិយោគដែលមានក្រឹត្យក្រមត្រឹមត្រូវ នៅក្នុងរមណីយដ្ឋាននិងសហគមន៍ | ក្រុបប្រឹក្សាជាមួយឧស្សាហកម្មទេសចរណ៍ | | មធ្យម |
| ៣.៤.៧- បង្កើនប្រាក់ចំណូលតាមរយៈការចំណាយរបស់ទេសចរម្នាក់ៗ ជាជាងការបង្កើនចំនួនទេសចរ | នា-គណនេយ្យ/ ទេសចរណ៍/ ក្រ. ទេសចរណ៍ | | ទាប |
| ៣.៤.៨- រិះរកមធ្យោបាយបន្ថែមក្នុងការគ្រប់គ្រងក្រុមភ្ញៀវធំៗឲ្យបានកាន់តែប្រសើរជាងមុន ដូចជាអនុញ្ញាតឲ្យពួកគាត់អាចកក់ទុកជាមុន ឬមានឱកាស "ពិសេស" នានា | មន្ត្រីទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍/ នា-ទេសចរណ៍/ វប្បធម៌ | | មធ្យម |
| ៣.៤.៩- ធ្វើការជាមួយនឹងឧស្សាហកម្មទេសចរណ៍ដើម្បីសិក្សាការផ្តួចផ្តើមផ្សារភ្ជាប់សម្ភារៈរូបវន្តសម្រាប់ភ្ញៀវទេសចរ និងសកម្មភាពក្នុងក្រុងសៀមរាបដូចជាការទស្សនាវត្តអារាមតាមបណ្តោយស្ទឹងសៀមរាប។ | នា-បេតិកភណ្ឌក្រុង/ មន្ត្រីទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍ | | មធ្យម |

## ៣.៥ បង្កើនការយល់ដឹងពីគុណតម្លៃនិងតម្រូវការអភិរក្សនៅអង្គរ

*យុទ្ធសាស្ត្រ :* ប្រតិបត្តិករឧស្សាហកម្មទេសចរណ៍ទាំងអស់នឹងមានការយល់ដឹងកាន់តែច្បាស់ពីគុណតម្លៃនិងតម្រូវការអភិរក្ស។

*ហេតុផល ៖* ការអភិវឌ្ឍន៍ទេសចរណ៍ប្រកបដោយចីរភាពនិងការគ្រប់គ្រងទេសចរណ៍នៅអង្គរ ទាមទារនូវការយល់ដឹងផ្ទាល់ខ្លួនអំពីគុណតម្លៃអង្គរនិងតម្រូវការអភិរក្ស។

| សកម្មភាព | ទំនួលខុសត្រូវ | រយៈពេល | អាទិភាព |
|---|---|---|---|
| ៣.៥.១- ធ្វើផែនការនិងផ្តល់ព័ត៌មានក៏ដូចជាកម្មវិធីអំពីការផ្សព្វផ្សាយគុណតម្លៃអង្គរ | នា-វប្បធម៌/ មន្ត្រីទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍/ ក្រុមប្រឹក្សាជាមួយឧស្សាហកម្មទេសចរណ៍ | | មធ្យម |
| ៣.៥.២- រៀបចំនិងផ្តល់ព័ត៌មានសង្ខេបនិងបណ្តុះបណ្តាលប្រតិបត្តិករទេសចរណ៍ដែលកំពុងធ្វើការនៅតំបន់អង្គរ ដើម្បីឲ្យពួកគេចូលរួមក្នុងការថែរក្សាបេតិកភណ្ឌ។ | អាជ្ញាធរអប្សរា | | មធ្យម |





## ៣.៦ អនុញ្ញាតនិងឯកភាពលើសកម្មភាពសមស្របរបស់ឧស្សាហកម្មទេសចរណ៍

*យុទ្ធសាស្ត្រ ៖* ដំណើរការអនុញ្ញាតនិងឯកភាពលើសកម្មភាពសមស្របរបស់ឧស្សាហកម្មទេសចរណ៍នៅតំបន់បេតិកភណ្ឌពិភពលោកអង្គរនឹងកាន់តែមានប្រសិទ្ធភាព ងាយស្រួល និងមានតម្លាភាព។

*ហេតុផល* : ដំណើរការអនុញ្ញាតនិងឯកភាពលើសំណើសមស្របរបស់ឧស្សាហកម្មទេសចរណ៍ដែលកាន់តែមានប្រសិទ្ធភាពនឹងធ្វើឲ្យឧស្សាហកម្មពេញចិត្តនឹងទទួលយកនិងអនុវត្តតាម។

| សកម្មភាព | ទំនួលខុសត្រូវ | រយៈពេល | អាទិភាព |
|---|---|---|---|
| ៣.៦.១-ធ្វើឲ្យមានស្តង់ដាទាក់ទងនឹងតម្រូវការនិងការគ្រប់គ្រង សម្រាប់សម្បទាននិងព្រឹត្តិការណ៍នានា ដូចជាការថតភាពយន្តនិងថតរូប | អគ្គនាយកអាជ្ញាធរអប្សរា/មជ្ឈមណ្ឌលសេវាកម្មអាជ្ញាធរអប្សរា | | ខ្ពស់ |
| ៣.៦.២- រៀបចំឲ្យមានការស្នើសុំថតរូបនិងភាពយន្តដោយបំពេញបែបបទតាមប្រព័ន្ធអ៊ីនធឺណិត | មជ្ឈមណ្ឌលសេវាកម្មអាជ្ញាធរអប្សរា | | ខ្ពស់ |
| ៣.៦.៣- បង្កើតនីតិវិធីអនុញ្ញាតការថតរូបភាពឲ្យបាន "ឆាប់រហ័ស" សម្រាប់ភ្ញៀវទេសចរដែលមិនបានបំពេញទៅតាមនីតិវិធីសុំអនុញ្ញាតមុនពេលមកទស្សនា | អគ្គនាយកអាជ្ញាធរអប្សរា/មជ្ឈមណ្ឌលសេវាកម្មអាជ្ញាធរអប្សរា | | ខ្ពស់ |
| ៣.៦.៤- កំណត់ពេលវេលាមធ្យមក្នុងការឆ្លើយតបនូវរាល់សំណើដែលបានដាក់មកកាន់មជ្ឈមណ្ឌលសេវាកម្មអាជ្ញាធរអប្សរា | មជ្ឈមណ្ឌលសេវាកម្មអាជ្ញាធរអប្សរា | | ខ្ពស់ |
| ៣.៦.៥- រៀបចំគោលនយោបាយសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តណាមួយឲ្យមានតម្លាភាពនិងដោយគ្មានការផ្លាស់ប្តូរ(លើកលែងតែកាលៈទេសៈខុសពីធម្មតា) | អគ្គនាយកអាជ្ញាធរអប្សរា/មជ្ឈមណ្ឌលសេវាកម្មអាជ្ញាធរអប្សរា | | ខ្ពស់ |

| | | | |
|---|---|---|---|
| ៣.៦.៦- ធ្វើការកំណត់សម្គាល់ច្បាស់ៗថានរណាត្រូវទទួលខុសត្រូវលើសេវាកម្មណា ហើយអ្នកណាដែលអាចទាក់ទង(ឧទាហរណ៍ ព្រឹត្តិការណ៍ រូបថត ការដឹកជញ្ជូន) | អគ្គនាយក អាជ្ញាធរអប្សរា | | ខ្ពស់ |
| ៣.៦.៧- ជូនដំណឹងទៅប្រតិបត្តិករឯកជនថានរណាដែលត្រូវទាក់ទងដើម្បីសុំជំនួយផ្នែកសេវាកម្មផ្សេងៗ | មន្ត្រីទំនាក់ទំនងជាមួយ ឧស្សាហកម្ម ទេសចរណ៍ | | ខ្ពស់ |
| ៣.៦.៨- ពិនិត្យប្រភេទនៃការស្នើសុំឲ្យមានស្តង់ដាត្រឹមត្រូវ ដើម្បីឲ្យដឹងពីតម្លៃដែលអាជ្ញាធរអប្សរាបានកំណត់ | មជ្ឈមណ្ឌល សេវាកម្ម អាជ្ញាធរអប្សរា | | ខ្ពស់ |
| ៣.៦.៩- ពិនិត្យដំណើរការផ្តល់លិខិតអនុញ្ញាតដល់ឧស្សាហកម្មទេសចរណ៍ជារៀងរាល់ឆ្នាំឡើងវិញ។ | អគ្គនាយក អាជ្ញាធរអប្សរា/ មជ្ឈមណ្ឌល សេវាកម្ម អាជ្ញាធរអប្សរា | | មធ្យម |





# ការផ្តួចផ្តើមគោលនយោបាយTMPទី៩ គឺការផ្តល់ផលប្រយោជន៍ដល់ប្រជាជនក្នុងតំបន់




## គោលបំណងនៃការគ្រប់គ្រង

គុណតម្លៃសង្គមនិងវប្បធម៌របស់ប្រជាជននៅក្នុងនិងជុំវិញតំបន់បេតិកភណ្ឌពិភពលោកអង្គរនឹងត្រូវបានទទួលស្គាល់ អភិរក្សនិងលើកកម្ពស់ ហើយប្រជាជនទាំងអស់នឹងទទួលបានការចែករំលែកផលប្រយោជន៍សេដ្ឋកិច្ច ក៏ដូចជាផលប្រយោជន៍ដទៃទៀតពីទេសចរណ៍នៅតំបន់អង្គរដោយយុត្តិធម៌។

- កាត់បន្ថយផលប៉ះពាល់អវិជ្ជមានពីការអភិវឌ្ឍន៍និងវិស័យទេសចរណ៍ដែលជាប់ពាក់ព័ន្ធនឹងតំបន់បេតិកភណ្ឌពិភពលោកអង្គរ
- សហការយ៉ាងសកម្មជាមួយប្រជាជនក្នុងការអភិរក្សគុណតម្លៃ សង្គម និងវប្បធម៌ និងការគ្រប់គ្រងទេសចរណ៍នៅតំបន់អង្គរ
- លើកទឹកចិត្តឲ្យមានការអភិវឌ្ឍន៍ដែលប្រកបដោយចីរភាព ដែលមិនធ្វើឲ្យប៉ះពាល់ដល់គុណតម្លៃបេតិកភណ្ឌ
- លើកទឹកចិត្តប្រជាជនក្នុងតំបន់ឲ្យចូលរួមក្នុងការអភិរក្សបេតិកភណ្ឌ
- បង្កើនផលប្រយោជន៍សេដ្ឋកិច្ចនានាដល់ប្រជាជនក្នុងតំបន់។

**សមិទ្ធផលនានាមកដល់បច្ចុប្បន្ន**

អាជ្ញាធរអប្សរាទទួលស្គាល់ថា អង្គរជាតំបន់ទេសភាពមួយដែលមានប្រជាជនរស់នៅច្រើនជាង ១០០ ០០០នាក់ នៅក្នុង១១២ភូមិ។ អាជ្ញាធរអប្សរាមានកម្មវិធីនិងការផ្តួចផ្តើមនានាដែលត្រូវបានបង្កើតឡើងដើម្បីជាផលប្រយោជន៍ដល់ប្រជាជនក្នុងតំបន់ផងដែរ។ ប្រជាជនក្នុងតំបន់អាចទទួលបានផលប្រយោជន៍សេដ្ឋកិច្ចដូចជា បម្រើការជាភ្នាក់ងារប្រាសាទ លក់ដូរនៅតាមប្រាសាទដូចជានៅប្រាសាទបន្ទាយស្រីជាដើម។ អាជ្ញាធរអប្សរាបានធ្វើការប្រកបដោយជោគជ័យលើគម្រោងសហការទ្វេភាគីជាមួយប្រទេសណូវែលហ្សេឡង់ ដើម្បីពង្រឹងតួនាទីនិងសមត្ថភាពសហគមន៍ក្នុងការចូលរួមអភិវឌ្ឍប្រកបដោយចីរភាព និងការពារឧទ្យានអង្គរ ក៏ដូចជាផ្តល់ឱកាសចិញ្ចឹមជីវិតពួកគាត់ពីធនធានធម្មជាតិនិងវិស័យទេសចរណ៍។ មានយុទ្ធនាការពន្យល់ពីការលើកតម្លៃវប្បធម៌ជាទៀងទាត់នៅតាមភូមិនានា ដើម្បីលើកទឹកចិត្តដល់សហគមន៍ឲ្យការពារបេតិកភណ្ឌ ហើយចាប់ពីឆ្នាំ១៩៩៥ អាជ្ញាធរអប្សរាបានធ្វើការណែនាំឪពុកម្តាយទាំងឡាយណាដែលពេលខ្លះជំរុញឲ្យកូនដើរតាមភ្ញៀវទេសចរ។ នៅឆ្នាំ២០០៥ មានសិក្ខាសាលាស្តីពីការយល់ដឹងនិងប្រឆាំងទេសចរណ៍ផ្លូវភេទ។ អាជ្ញាធរអប្សរាក៏បានស្តារប្រព័ន្ធធារាសាស្ត្របុរាណនានាដែលជំរុញលើកកម្ពស់ការស្រោចស្រពសម្រាប់ការប្រើប្រាស់តាមភូមិផងដែរ។ អាជ្ញាធរអប្សរាបានបង្កើតនូវភូមិធម្មជាតិរុនតាឯក និងមជ្ឈមណ្ឌលលំនៅឋានសម្រាប់សហគមន៍ ដែលផ្តល់ព័ត៌មានអំពីកសិកម្មប្រកបដោយនិរន្តរភាព និងការសាងសង់លំនៅឋាន។

## បញ្ហាប្រឈម

បញ្ហារបស់ប្រជាជនក្នុងតំបន់ខាងក្រោម បានមកពីកិច្ចពិភាក្សារវាងរាជរដ្ឋាភិបាល សហគមន៍និងអ្នកពាក់ព័ន្ធក្នុងវិស័យទេសចរណ៍នៅអង្គរ ក្នុងដំណើរការពិគ្រោះយោបល់ដើម្បីរៀបចំឯកសារគ្រប់គ្រងទេសចរណ៍នេះ។

| បញ្ហា | យុទ្ធសាស្ត្រ |
|---|---|
| ទីផ្សារទេសចរណ៍ដែលកំពុងរីកលូតលាស់យ៉ាងលឿននៅតំបន់អង្គរបានបង្ហាញឲ្យឃើញផលប៉ះពាល់ដោយផ្ទាល់និងប្រយោលដល់សង្គមក្នុងតំបន់អង្គរ។<br><br>ប្រជាជនក្នុងតំបន់មួយចំនួនបានទទួលឥទ្ធិពលពីអាកប្បកិរិយាមិនសមរម្យរបស់ភ្ញៀវទេសចរ។<br><br>មានផលប៉ះពាល់មួយចំនួនប្រជាជនក្នុងតំបន់ដូចជាការមិនគោរពវប្បធម៌ម្ចាស់ស្រុករបស់ភ្ញៀវទេសចរ ព្រោះពួកគាត់មិនបានយល់ដឹងពីវប្បធម៌ខ្មែរ មិនស្គាល់ពីគុណតម្លៃសាសនារបស់ប្រាសាទ ដោយស្លៀកពាក់ និយាយ និងប្រព្រឹត្តនូវសកម្មភាពមិនសមរម្យ។<br><br>អាកប្បកិរិយាមិនសមរម្យនិងកង្វះខាតការគោរពបទដ្ឋានសង្គម អាចនាំឲ្យប្រជាជនក្នុងតំបន់មិនសប្បាយចិត្ត។<br><br>ពេលខ្លះ គេជឿថាការថ្វាយដង្វាយមិនត្រឹមត្រូវ នាំឲ្យមានគ្រោះកាច និងជំងឺដង្កាត់នានាដល់ប្រជាជនក្នុងតំបន់។<br><br>ព្រះសង្ឃកត់សម្គាល់ឃើញថា អ្នកទស្សនាមួយចំនួនបានរំខានដល់ពិធីសាសនា និងពិធីបុណ្យនានា។<br><br>ព្រះសង្ឃចង់ឲ្យភ្ញៀវទេសចរមកទស្សនា សិក្សាស្វែងយល់ និងថ្វាយដង្វាយពុទ្ធបដិមា។ | ទី១ ទី២ |

| | |
|---|---|
| អាកប្បកិរិយាមិនសមរម្យរបស់ភ្ញៀវទេសចរនានាអាចបង្កើតឲ្យមានហានិភ័យដល់កុមារនិងប្រជាជនក្នុងតំបន់ដែលធ្វើការនៅអង្គរ។<br><br>យុវវ័យកម្ពុជាមួយចំនួន មិនចង់បន្តអនុវត្តរបៀបរស់នៅតាមបែបប្រពៃណី បទដ្ឋានសង្គម  ឥរិយាបថ ការស្វាគមន៍ និងអាកប្បកិរិយាសមរម្យឡើយ។ | |
| ចរាចរណ៍ជាច្រើនអាចនាំឲ្យមានផលប៉ះពាល់អវិជ្ជមានលើបរិស្ថានតាមភូមិដោយការបំពុលបរិយាកាស។<br><br>អាចមានការកកស្ទះចរាចរណ៍នៅតាមផ្លូវទៅកាន់ភូមិនានា។ | ទី២ [សូមអានការផ្តួចផ្តើមទី២ យុទ្ធសាស្ត្រទី៦] |
| អ្នកភូមិមួយចំនួនមិនមានសមត្ថភាពទាញយកផលប្រយោជន៍សេដ្ឋកិច្ចពីវិស័យទេសចរណ៍ឡើយ។<br><br>ភាសាអាចជារបាំងមួយរវាងប្រជាជនក្នុងតំបន់និងភ្ញៀវទេសចរ។<br><br>ប្រជាជនក្នុងតំបន់គ្រប់រូបមិនអាចមានឱកាសទទួលបានតូបលក់ដូរនៅជុំវិញប្រាសាទនោះទេ។ | ទី៣ |
| ការបង្ហាញរបាំប្រពៃណីនិងការសម្តែងមួយចំនួនគឺមិនធ្វើតាមទម្រង់ដើម ឬត្រឹមត្រូវតាមបរិបទនិងអត្ថន័យដើម។ | ទី១ |
| មគ្គុទ្ទេសក៍ទេសចរណ៍ និងប្រតិបត្តិករពុំបានផ្តល់នូវឱកាសច្រើនដល់ភ្ញៀវទេសចរក្នុងការទស្សនាទីអារាម និងរៀនសូត្រពីព្រះពុទ្ធសាសនាឡើយ។<br><br>ពុំមានរៀបចំកម្មវិធីដើម្បីជំរុញផ្សព្វផ្សាយពីប្រជាជនក្នុងតំបន់។<br><br>ពុំសូវមានទំនាក់ទំនងរវាងភ្ញៀវទេសចរនិងប្រជាជនក្នុងតំបន់។ | ទី៣ |
| មានតម្រូវការក្នុងការត្រួតពិនិត្យចំនួនអ្នកលក់ដូរ និងគុណភាពផលិតផល។<br><br>ផលិតផលក្នុងតំបន់មួយចំនួនមិនមានគុណភាពខ្ពស់។ | ទី៤ |

| | |
|---|---|
| បើគ្មានកម្រៃជើងសា មគ្គុទ្ទេសក៍មួយចំនួនមិននាំភ្ញៀវទេសចរទៅទិញវត្ថុអនុស្សាវរីយ៍ពីប្រជាជនក្នុងតំបន់នោះទេ។<br><br>ផលិតផលនាំចូលមួយចំនួនបានមកជំនួសផលិតផលក្នុងតំបន់និងមិនបានបង្ហាញវប្បធម៌ពិតប្រាកដរបស់តំបន់នោះទេ។ | |
| ក្មេងៗមួយចំនួនខំប្រឹងប្រែងរកប្រាក់ចិញ្ចឹមគ្រួសារដោយលក់វត្ថុអនុស្សាវរីយ៍តាមប្រាសាទ ហើយមិនចូលសាលារៀន។<br><br>ទីភ្នាក់ងារទេសចរណ៍មួយចំនួនមិននាំភ្ញៀវទេសចរទៅសហគមន៍ដោយសារបញ្ហាអនាម័យដូចជា គ្មានបង្គន់គ្រប់គ្រាន់ខ្វះកន្លែងចោលសំរាម។ | ៥ |
| ខ្វះការប្រាស្រ័យទាក់ទងនិងពិគ្រោះយោបល់រវាងប្រជាជនក្នុងតំបន់និងអាជ្ញាធរគ្រប់គ្រងឲ្យបានល្អប្រសើរ។<br><br>អ្នកភូមិខ្លះយល់ថា មានការលំបាកក្នុងការសុំច្បាប់សាងសង់ផ្ទះ ជួសជុលនិងកែលម្អអគារនានា។<br><br>ប្រជាជនមួយចំនួន មានការភ័យខ្លាចក្នុងការចែករំលែកនូវគំនិតរបស់ពួកគេ។<br><br>ប្រជាជនក្នុងតំបន់មិនយល់ពីវិធាននានានៅក្នុងឧទ្យានអង្គរ។<br><br>ប្រជាជនមិនយល់ពីតួនាទីនិងសិទ្ធិរបស់ពួកគេ។<br><br>ប្រជាជនក្នុងតំបន់ខ្លះមិនធ្លាប់ទទួលបានការអប់រំ/ព័ត៌មាន/ផ្សព្វផ្សាយអំពីគុណតម្លៃបេតិកភណ្ឌអង្គរឡើយ។ | ៦ |




## យុទ្ធសាស្ត្រ

យុទ្ធសាស្ត្រទាំង៦ខាងក្រោមនឹងធ្វើឲ្យមានការរៀបចំ អភិរក្ស និងលើកកម្ពស់គុណតម្លៃសហគមន៍ និងផ្តល់ផលប្រយោជន៍សេដ្ឋកិច្ចនិងផលប្រយោជន៍ដទៃទៀតដល់ប្រជាជនក្នុងតំបន់។

១- ទទួលស្គាល់តម្លៃសាសនារបស់អង្គរ

២- គ្រប់គ្រងតំបន់អង្គរជាតំបន់ទេសភាពដែលមានមនុស្សរស់នៅ

៣- ជំរុញលើកកម្ពស់ផលប្រយោជន៍សេដ្ឋកិច្ច

៤- គាំទ្រសិប្បកម្មក្នុងតំបន់

៥- ផ្តល់ផលប្រយោជន៍ដល់សង្គម

៦- លើកទឹកចិត្តឲ្យមានការចូលរួមពីសហគមន៍

## ៤.១ ទទួលស្គាល់តម្លៃសាសនារបស់អង្គរ

*យុទ្ធសាស្ត្រ :* តំបន់បេតិកភណ្ឌពិភពលោកអង្គរនឹងត្រូវទទួលស្គាល់ សាទរ និងការពារជាតំបន់សាសនាដ៏ពិសិដ្ឋមួយ។

*ហេតុផល :* ការទទួលស្គាល់និងអភិរក្សតម្លៃសាសនានិងជំនឿ ជាមូលដ្ឋានគ្រឹះនៃការអភិរក្សតំបន់បេតិកភណ្ឌពិភពលោកអង្គរ។

| សកម្មភាព | ទំនួលខុសត្រូវ | រយៈពេល | អាទិភាព |
|---|---|---|---|
| ៩.១.១- អប់រំប្រជាជននិងព្រះសង្ឃអំពីគុណតម្លៃបេតិកភណ្ឌពិភពលោកបន្ថែមទៀត | នា-គ្រប់គ្រងលំនៅដ្ឋាន | | មធ្យម |
| ៩.១.២- លើកទឹកចិត្តប្រជាជនឲ្យបន្តប្រតិបត្តិវប្បធម៌នានា ដើម្បីឲ្យភ្ញៀវទេសចរអាចស្វែងយល់ពីប្រពៃណីខ្មែរ។ ត្រូវពិចារណាលើការរួមចំណែករបស់ឧស្សាហកម្មទេសចរណ៍ក្នុងការផ្តល់មូលនិធិដល់សហគមន៍ ដើម្បីគាំទ្រការប្រតិបត្តិវប្បធម៌និងចំណាយក្នុងការរៀបចំពិធីផ្សេងៗ | នា-គ្រប់គ្រងលំនៅដ្ឋាន/ វប្បធម៌/ បុគ្គលិកអាជ្ញាធរអប្សរា | | ខ្ពស់ |
| ៩.១.៣-បង្កើតសារមន្ទីរតូចៗនៅតាមសហគមន៍ ដើម្បីជំរុញផ្សព្វផ្សាយព័ត៌មានដល់ភ្ញៀវអំពីប្រពៃណីរបស់ម្ចាស់ស្រុក | នា-គ្រប់គ្រងលំនៅដ្ឋាន/ វប្បធម៌ | | ទាប |
| ៩.១.៤- ពិនិត្យលើការលើកទឹកចិត្តផ្នែកសេដ្ឋកិច្ច ដើម្បីថែរក្សាប្រពៃណី | នា-គ្រប់គ្រងលំនៅដ្ឋាន | | មធ្យម |
| ៩.១.៥- លើកកម្ពស់ឲ្យមានការគោរពតម្លៃសាសនានៅអង្គរ ដោយពន្យល់ពីតួនាទីវប្បធម៌ ក្បួនគម្ពីរ ជំនឿនិងពិធីនានាដល់បុគ្គលិកអាជ្ញាធរអប្សរា ឧស្សាហកម្មទេសចរណ៍និងភ្ញៀវទេសចរ | នា-គ្រប់គ្រងលំនៅដ្ឋាន/ វប្បធម៌/ ផ្សព្វផ្សាយ/ មន្ត្រីទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍/ ក្រុមប្រឹក្សាជាមួយឧស្សាហកម្មទេសចរណ៍/ អាជ្ញាធរខេត្ត/ ក្រ. | | ខ្ពស់ |

| | | | |
|---|---|---|---|
| | ទេសចរណ៍/ មន្ទីរទេសចរណ៍ | | |
| ៩.១.៦- រៀបចំប្រតិទិនដែលបង្ហាញពីកាលបរិច្ឆេទប្រារព្ធពិធីវប្បធម៌ប្រពៃណីដែលប្រារព្ធធ្វើនៅតាមភូមិនានា | នា-គ្រប់គ្រងលំនៅដ្ឋាន/ វប្បធម៌ | | មធ្យម |
| ៩.១.៧- បន្តចងក្រងឯកសារស្តីពីការប្រតិបត្តិវប្បធម៌និងប្រពៃណីនៅក្នុងតំបន់អង្គរ | នា-គ្រប់គ្រងលំនៅដ្ឋាន | | មធ្យម |
| ៩.១.៨- ផ្សព្វផ្សាយព័ត៌មានពីប្រពៃណីនិងកន្លែងសក្ការៈបូជា(អ្នកតា ទីសក្ការៈព្រះពុទ្ធសាសនា) ដល់ភ្ញៀវទេសចរ។ | នា-គ្រប់គ្រងលំនៅដ្ឋាន/ ផ្សព្វផ្សាយ | | មធ្យម |

## ៩.២ គ្រប់គ្រងតំបន់អង្គរជាកន្លែងទេសភាពដែលមានមនុស្សរស់នៅ

*យុទ្ធសាស្ត្រ* : តំបន់បេតិកភណ្ឌពិភពលោកអង្គរនៅតែជាលំនៅឋានរបស់ប្រជាជនក្នុងតំបន់និងទីវត្តអារាមព្រះពុទ្ធសាសនា។ ពួកគាត់នឹងបន្តជីវភាពរស់នៅ ដោយទាញប្រយោជន៍ចេញពីឱកាសក្នុងសង្គមបច្ចុប្បន្ន ស្របតាមគុណតម្លៃបេតិកភណ្ឌ។

*ហេតុផល* : ប្រជាជននិងវត្តអារាមព្រះពុទ្ធសាសនា បន្តជីវភាពរស់នៅបែបប្រពៃណី រួមចំណែកនិងមានតួនាទីយ៉ាងសកម្មក្នុងការការពារគុណតម្លៃនៃបេតិកភណ្ឌ។ ពួកគាត់មានសិទ្ធិទទួលយកប្រយោជន៍ពីប្រពៃណីនិងសង្គមរបស់ពួកគាត់។

| សកម្មភាព | ទំនួលខុសត្រូវ | រយៈពេល | អាទិភាព |
|---|---|---|---|
| ៩.២.១- គូរផែនទីវប្បធម៌នៃភូមិឋាននៅតំបន់ការពារ ១ និង២។ កំណត់ពីប្រភេទប្រពៃណីនិងទំនៀមទម្លាប់បុរាណដែលមានលក្ខណៈសមរម្យនិងចែករំលែកនិងបកស្រាយជូនភ្ញៀវទេសចរ។ រកឲ្យឃើញថាកន្លែងណាដែលផលិតសម្ភារៈសិប្បកម្មក្នុងតំបន់ | នា-គ្រប់គ្រងលំនៅដ្ឋាន | | ខ្ពស់ |

| | | | |
|---|---|---|---|
| ៥.២.២- បន្តចងក្រងឯកសារស្តីពីជីវភាពនិងរបៀបរស់នៅរបស់ប្រជាជនក្នុងតំបន់ និងរៀបចំផ្តល់ព័ត៌មានទាំងនោះដល់ភ្ញៀវទេសចរ | នា-គ្រប់គ្រងលំនៅដ្ឋាន | | មធ្យម |
| ៥.២.៣- លើកទឹកចិត្តឲ្យមានការគោរពនិងយល់ដឹងថាការរស់នៅរបស់ប្រជាជនក្នុងតំបន់មានលក្ខណៈពិសេសនិងមានប្រពៃណីដូនតាដែលបន្តរហូតដល់ពេលបច្ចុប្បន្ន | នា-គ្រប់គ្រងលំនៅដ្ឋាន/វប្បធម៌/ផ្សព្វផ្សាយ | | មធ្យម |
| ៥.២.៥- រៀបចំផ្តល់ព័ត៌មានដល់ប្រជាជននិងភ្ញៀវទេសចរ ដោយបង្ហាញយ៉ាងច្បាស់ថាតើវិស័យទេសចរណ៍អាចជួយដល់ការប្រតិបត្តិទំនៀមទម្លាប់និងវប្បធម៌ដោយរបៀបណា ដើម្បីឲ្យភ្ញៀវទេសចរគោរពនិងយល់ដឹងកាន់តែច្បាស់ | នា-គ្រប់គ្រងលំនៅដ្ឋាន/ផ្សព្វផ្សាយ | | មធ្យម |
| ៥.២.៥- ការលើកកម្ពស់ការយល់ដឹងដើម្បីពង្រឹងការយល់ដឹងពីវិធាននានានៅអង្គរបស់ប្រជាជនក្នុងតំបន់ | នា-គ្រប់គ្រងលំនៅដ្ឋាន | | ខ្ពស់ |
| ៥.២.៦- ពង្រឹងការយល់ដឹងពីវិធាននានានៅតាមភូមិ | នា-គ្រប់គ្រងលំនៅដ្ឋាន/សណ្តាប់ធ្នាប់ | | ខ្ពស់ |
| ៥.២.៧- បន្តឲ្យមានការផ្តួចផ្តើមនានា ដើម្បីការពារប្រជាជនក្នុងតំបន់ពីផលប៉ះពាល់អវិជ្ជមានពីវិស័យទេសចរណ៍និងភ្ញៀវទេសចរ | នា-គ្រប់គ្រងលំនៅដ្ឋាន | | មធ្យម |
| ៥.២.៨- ត្រួតពិនិត្យនិងគ្រប់គ្រងតួនាទីមជ្ឈមណ្ឌលកុមារកំព្រា និងសាលារៀននានាដែលស្ថិតនៅក្នុងតំបន់អង្គរ។ | នា-គ្រប់គ្រងលំនៅដ្ឋាន/ទេសចរណ៍ | | ទាប |





## ៤.៣ ជំរុញលើកកម្ពស់ផលប្រយោជន៍សេដ្ឋកិច្ច

*យុទ្ធសាស្ត្រ* : ប្រជាជននិងវត្តអារាមព្រះពុទ្ធសាសនានឹងទទួលបានឱកាសសេដ្ឋកិច្ចពីវិស័យទេសចរណ៍នៅតំបន់បេតិកភណ្ឌពិភពលោកអង្គរ។

*ហេតុផល* : ប្រជាជននិងវត្តអារាមជាផ្នែកមួយដ៏សំខាន់នៃគុណតម្លៃបេតិកភណ្ឌវប្បធម៌ពិភពលោក ក្នុងការទាក់ទាញភ្ញៀវទេសចរ ដូច្នេះ ពួកគាត់មានសិទ្ធិស្របច្បាប់ក្នុងការទទួលប្រយោជន៍ពីទេសចរណ៍។

| សកម្មភាព | ទំនួលខុសត្រូវ | រយៈពេល | អាទិភាព |
|---|---|---|---|
| ៤.៣.១- លើកទឹកចិត្តនិងគាំទ្រទេសចរណ៍សហគមន៍ និងសកម្មភាពបង្កើនចំណូលកម្រិតទាប ទាក់ទងនឹងវិស័យទេសចរណ៍ ពិសេសសកម្មភាពទាំងឡាយណាដែលទាក់ទងនឹងម្ហូបអាហារប្រពៃណី សម្ភារៈសិប្បកម្ម និងការប្រតិបត្តិវប្បធម៌។ | នា-គ្រប់គ្រងលំនៅដ្ឋាន | | មធ្យម |
| ៤.៣.២- រៀបចំប្រព័ន្ធនិងទីតាំងសម្រាប់អ្នកលក់ដូរ ហើយផ្តល់ឱកាសភ្ញៀវទេសចរទិញទំនិញផ្ទាល់ពីប្រជាជនក្នុងតំបន់ | នា-អន្តរវិស័យ/ អគ្គនាយកអាជ្ញាធរអប្សរា | | មធ្យម |
| ៤.៣.៣- ជំរុញលើកទឹកចិត្តឲ្យមានការបន្តបណ្តុះបណ្តាលនិងអភិវឌ្ឍជំនាញនានាដល់ប្រជាជនក្នុង | នា-គ្រប់គ្រងលំនៅដ្ឋាន | | មធ្យម |

| | | | |
|---|---|---|---|
| តំបន់ ដូចជាការបង្កើតផលិតផលថ្មី សម្ភារៈសិប្បកម្ម និងប្រតិបត្តិការជំនួញក្នុងវិស័យទេសចរណ៍ | | | |
| ៩.៣.៤- បន្តបណ្តុះបណ្តាលនិងជ្រើសរើសបុគ្គលិកដែលរស់នៅក្នុងតំបន់អង្គរ | អាជ្ញាធរអប្សរា | | ខ្ពស់ |
| ៩.៣.៥- បន្តជំរុញដំណើរការរង់ទស្សនាថ្មី ដើម្បីលើកទឹកចិត្តឲ្យភ្ញៀវទេសចរប្រើប្រាស់ផលិតផលសហគមន៍ | នា-វប្បធម៌ | | មធ្យម |
| ៩.៣.៦- លើកទឹកចិត្តឧស្សាហាកម្មទេសចរណ៍ ឲ្យនាំភ្ញៀវទៅគាំទ្រសហគមន៍នានាក្នុងឧទ្យានអង្គរ តាមរយៈការទិញផលិតផលឬប្រើសេវាកម្មយ៉ាងហោចណាស់បានម្តង | មន្ត្រីទំនាក់ទំនងជាមួយឧស្សាហាកម្មទេសចរណ៍/ នា-ទេសចរណ៍ | | មធ្យម |
| ៩.៣.៧- ផ្តល់ឱកាសឲ្យប្រជាជនដាក់ជួលឬលក់មួក និងសម្លៀកបំពាក់ដល់ភ្ញៀវទេសចរដែលមិនបានស្លៀកពាក់សមរម្យ | នា-គ្រប់គ្រងលំនៅដ្ឋាន | | ទាប |
| ៩.៣.៨- ពិនិត្យរកផលិផលកសិកម្មដែលប្រជាជនអាចដាំដុះដូចជា ស្តៅ បន្លែ | នា-កសិកម្ម | | មធ្យម |
| ៩.៣.៩- អាជ្ញាធរអប្សរាអាចទិញទំនិញរបស់ប្រជាជនដោយផ្ទាល់(ឧទាហរណ៍ អំបោស) | នា-កសិកម្ម/ គ្រប់គ្រងលំនៅដ្ឋាន/ អគ្គនាយកអាជ្ញាធរអប្សរា/ អាជ្ញាធរអប្សរា | | មធ្យម |
| ៩.៣.១០- ចំពោះការផ្តួចផ្តើមសហគមន៍ក្នុងតំបន់ ត្រូវបង្កើតនិងរៀបចំពន្យល់ពីរបៀបទំនាក់ទំនងជាមួយភ្ញៀវទេសចរឲ្យបានសមរម្យដល់ប្រជាជន | នា-គ្រប់គ្រងលំនៅដ្ឋាន/ វប្បធម៌ | | មធ្យម |
| ៩.៣.១១- បង្កើនឲ្យមានការប្រើប្រាស់សេវាកម្ម "ផ្ទះ | នា-គ្រប់គ្រង | | មធ្យម |

| | | | |
|---|---|---|---|
| ស្នាក់" នៅភូមិធម្មជាតិរុនតាឯក | លំនៅដ្ឋាន | | |
| ៤.៣.១២- ទុកកន្លែងលក់ដូរសម្រាប់សហគមន៍នៅពេលមានការកែលម្អសេវាកម្មទេសចរណ៍ដូចជា មជ្ឈមណ្ឌលទទួលស្វាគមន៍ភ្ញៀវនៅតាមប្រាសាទ | អគ្គនាយកអាជ្ញាធរអប្សរា/ នា-គ្រប់គ្រងលំនៅដ្ឋាន/ ទេសចរណ៍ | | មធ្យម |
| ៤.៣.១៣- បង្កើតគម្រោងបណ្តុះបណ្តាលអ្នកភូមិស្តីពីភាពខុសគ្នានៃវប្បធម៌របស់ភូមិនីមួយៗ។ កែលម្អផលិតផលនិងការវេចខ្ចប់ និងជួយជំរុញការលក់ផ្ទាល់ដល់ភ្ញៀវទេសចរ។ | នា-គ្រប់គ្រងលំនៅដ្ឋាន/ ម្ចាស់ជំនួយ | | ទាប |





## ៤.៤. គាំទ្រសិប្បកម្មក្នុងតំបន់

*យុទ្ធសាស្ត្រ :* ប្រជាជនក្នុងតំបន់នឹងទទួលបានចំណូលសេដ្ឋកិច្ចសមរម្យ តាមរយៈការផលិតនិងលក់នូវផលិតផលសិប្បកម្មក្នុងតំបន់។

*ហេតុផល :* ជំរុញលើកទឹកចិត្តនិងគាំទ្រប្រជាជនក្នុងតំបន់ដែលមានចំណេះដឹងក្នុងការផលិតសម្ភារៈសិប្បកម្ម។ ពួកគាត់មានសិទ្ធិស្របច្បាប់ក្នុងការចែករំលែកនូវផលប្រយោជន៍ទាំងឡាយពីវិស័យទេសចរណ៍ តាមរយៈការលក់ផលិតផលសិប្បកម្មក្នុងតំបន់។

| សកម្មភាព | ទំនួលខុសត្រូវ | រយៈពេល | អាទិភាព |
|---|---|---|---|
| ៩.៩.១- ធ្វើជាដៃគូជាមួយសមាគមសិប្បកម្មអង្គរ ក្នុងការណែនាំនូវវិញ្ញាបនបត្រ/អត្តសញ្ញាណគុណភាពសម្រាប់ផលិតផលទេសចរណ៍ក្នុងតំបន់ ដើម្បីជួយសហគមន៍ធ្វើទីផ្សារផលិតផលរបស់ពួកគាត់ | នា-គ្រប់គ្រងលំនៅដ្ឋាន/វប្បធម៌ | | ខ្ពស់ |
| ៩.៩.២- ជួយសម្រួលការធ្វើទីផ្សារនិងផ្សព្វផ្សាយផលិតផលក្នុងតំបន់ តាមរយៈការផ្តួចផ្តើមសាមញ្ញដូចជា "កំណាត់តម្លៃជាក់លាក់" នៅក្នុងឧទ្យានអង្គរជាដើម | នា-គ្រប់គ្រងលំនៅដ្ឋាន/ទេសចរណ៍ | | មធ្យម |
| ៩.៩.៣- បង្កើតឲ្យមាន "ផ្សារលក់តែផលិតផលសិប្បកម្មក្នុងតំបន់" នៅទីតាំងមួយក្នុងឧទ្យានអង្គរ ដែលប្រជាជនក្នុងតំបន់មានសិទ្ធិចូលលក់ផ្ទាល់មុខ ហើយមានការធានាថាទំនិញទាំងអស់សុទ្ធតែជាផលិតផលក្នុងតំបន់ | អគ្គនាយកអាជ្ញាធរអប្សរា/នា-អន្តរវិស័យ/ទេសចរណ៍ | | ខ្ពស់ |
| ៩.៩.៤- លើកទឹកចិត្តនិងគាំទ្រផលិតផលក្នុងតំបន់(អាហារ និងសម្ភារៈសិប្បកម្ម) ដែលទាក់ទងនឹងគុណតម្លៃអង្គរ | អាជ្ញាធរអប្សរា | | មធ្យម |
| ៩.៩.៥- គាំទ្រនិងជំរុញផ្សព្វផ្សាយនូវការប្រើប្រាស់អត្តសញ្ញាណលើទំនិញសិប្បកម្មសុទ្ធនៅខេត្តសៀមរាប ដោយសហការជាមួយនឹងសមាគមសិប្បករអង្គរ។ | អាជ្ញាធរអប្សរា | | មធ្យម |




## ៩.៥ ផ្តល់ផលប្រយោជន៍ដល់សង្គម

*យុទ្ធសាស្ត្រ :* ប្រជាជននិងវត្តអារាមព្រះពុទ្ធសាសនានឹងសប្បាយរីករាយដោយសារទទួលបានផលប្រយោជន៍ពីសង្គមតាមរយៈវិស័យទេសចរណ៍ នៅតំបន់បេតិកភណ្ឌពិភពលោកអង្គរ។

*ហេតុផល:* ប្រជាជននិងវត្តអារាមជាផ្នែកមួយដ៏សំខាន់នៃគុណតម្លៃបេតិកភណ្ឌពិភពលោកដែលទាក់ទាញភ្ញៀវ ដូច្នេះហើយពួកគាត់មានសិទ្ធិស្របច្បាប់ក្នុងការទទួលផលប្រយោជន៍នានា។

| សកម្មភាព | ទំនួលខុសត្រូវ | រយៈពេល | អាទិភាព |
|---|---|---|---|
| ៩.៥.១- ត្រូវធ្វើឲ្យប្រជាជនទទួលបានប្រយោជន៍សង្គមនិងឱកាសបន្ថែមទៀត តាមរយៈក្រុមការងារទំនាក់ទំនងសហគមន៍(CLT) | នា-គ្រប់គ្រងលំនៅដ្ឋាន | | មធ្យម |
| ៩.៥.២- បង្កើតរចនាសម្ព័ន្ធសង្គមដែលជួយដល់វិស័យទេសចរណ៍និងផ្តល់ប្រយោជន៍ដល់សង្គម | នា-គ្រប់គ្រងលំនៅដ្ឋាន | | មធ្យម |
| ៩.៥.៣- បន្តអប់រំដល់ប្រជាជនក្នុងតំបន់ពីគុណតម្លៃបេតិកភណ្ឌនិងទេសចរណ៍ ព្រមទាំងជំនាញអនុវត្តផ្សេងៗ | នា-គ្រប់គ្រងលំនៅដ្ឋាន | បន្ត | មធ្យម |
| ៩.៥.៤- រៀបចំកម្មវិធីសិក្សាអប់រំយុវជនខ្មែរនិងកុមារ | នា-គ្រប់គ្រង | បន្ត | មធ្យម |

| | | | |
|---|---|---|---|
| អំពីគុណតម្លៃបេតិកភណ្ឌនិងទេសចរណ៍ ដូចជា ជំនាញអនុវត្តផ្សេងៗ | លំនៅដ្ឋាន | | |
| ៩.៥.៥- លើកកម្ពស់ការយល់ដឹងពីបរិស្ថាន ដូច្នេះភូមិឋាននានានឹងរក្សាបានភាពស្អាតសម្រាប់ទេសចរណ៍ ហើយអនាម័យតាមភូមិត្រូវបានកែលម្អ | នា-ព្រៃឈើ/ កសិកម្ម | ២ឆ្នាំ | មធ្យម |
| ៩.៥.៦- ស្វែងរកភាពជាដៃគូជាមួយផ្នែកឯកជនដែលធ្វើការផ្នែកអប់រំវិជ្ជាជីវៈ និងជាមួយមជ្ឈមណ្ឌលបណ្តុះបណ្តាលនានា | នា-គ្រប់គ្រងលំនៅដ្ឋាន | | មធ្យម |
| ៩.៥.៧- សម្រួលឲ្យទទួលបានសេវាកម្មសុខភាពប្រសើរជាងមុន | នា-គ្រប់គ្រងលំនៅដ្ឋាន/ កសិកម្ម/ អាជ្ញាធរខេត្ត | | ទាប |
| ៩.៥.៨- លើកទឹកចិត្តអ្នករស់នៅតាមភូមិ ជាពិសេសយុវជនឲ្យប្រើប្រាស់ឱកាសទំនាក់ទំនងជាមួយភ្ញៀវទេសចរដើម្បីរៀនសូត្រ។ | នា-គ្រប់គ្រងលំនៅដ្ឋាន | | ទាប |



## ៩.៦ លើកទឹកចិត្តឲ្យមានការចូលរួមពីសហគមន៍

*យុទ្ធសាស្ត្រ :* ប្រជាជននិងវត្តអារាមព្រះពុទ្ធសាសនានឹងដើរតួនាទីយ៉ាងសកម្មក្នុងការគ្រប់គ្រងទំនាក់ទំនងរបស់ខ្លួនជាមួយវិស័យទេសចរណ៍នៅតំបន់បេតិកភណ្ឌពិភពលោកអង្គរ។

*ហេតុផល :* ភាពជាដៃគូសហការរវាងរាជរដ្ឋាភិបាល ឧស្សាហកម្មទេសចរណ៍ អង្គការមិនមែនរដ្ឋាភិបាល និងប្រជាជនក្នុងតំបន់ ព្រមទាំងវត្តអារាមព្រះពុទ្ធសាសនាមានសារៈសំខាន់ក្នុងការសម្រេចបាននូវការគ្រប់គ្រងនិងអភិវឌ្ឍទេសចរណ៍ប្រកបដោយចីរភាព នៅតំបន់អង្គរ។

| សកម្មភាព | ទំនួលខុសត្រូវ | រយៈពេល | អាទិភាព |
|---|---|---|---|
| ៩.៦.១- គាំទ្រក្រុមការងារទំនាក់ទំនងសហគមន៍នានាដែលមានស្រាប់ | អគ្គនាយកអាជ្ញាធរអប្សរា/ នា-គ្រប់គ្រងលំនៅដ្ឋាន | | ខ្ពស់ |
| ៩.៦.២- បង្កើតក្រុមប្រឹក្សាយោបល់មួយដែលសមាជិកតំណាងអាចបង្ហាញពីការចង់បាននិងបំណងជាទូទៅរបស់ប្រជាជនក្នុងតំបន់ | អគ្គនាយកអាជ្ញាធរអប្សរា/ នា-គ្រប់គ្រងលំនៅដ្ឋាន | | ខ្ពស់ |
| ៩.៦.៣- ពង្រឹងនិងស្វែងរកគម្រោងទ្វេភាគីដែលមានការចូលរួមពីប្រជាជនក្នុងតំបន់និងម្ចាស់ជំនួយអន្តរជាតិ | អគ្គនាយកអាជ្ញាធរអប្សរា/ នា-គ្រប់គ្រងលំនៅដ្ឋាន | | មធ្យម |
| ៩.៦.៤- ពង្រឹងសមត្ថភាពក្រុមទំនាក់ទំនងសហគមន៍ដើម្បីជួយប្រជាជនក្នុងតំបន់បង្កើតផលិតផលថ្មី ផ្សព្វផ្សាយនិងធ្វើទីផ្សារ | អគ្គនាយកអាជ្ញាធរអប្សរា/ នា-គ្រប់គ្រង | | ខ្ពស់ |

| | | | |
|---|---|---|---|
| | លំនៅដ្ឋាន | | |
| ៤.៦.៥- បង្កើនគម្រោងចូលរួមរបស់សហគមន៍នៅក្នុងភូមិទាំងអស់ដែលមានទីតាំងស្ថិតក្នុងឧទ្យានអង្គរ | នា-គ្រប់គ្រងលំនៅដ្ឋាន | | ខ្ពស់ |
| ៤.៦.៦- សម្របសម្រួលតួនាទីនិងសកម្មភាពអង្គការមិនមែនរដ្ឋាភិបាលនានាក្នុងវិស័យទេសចរណ៍នៅអង្គរ។ | នា-ទេសចរណ៍/គ្រប់គ្រងលំនៅដ្ឋាន | | ទាប |





# ការផ្តួចផ្តើមគោលនយោបាយTMPទី៥ គឺការបង្កើនអភិបាលកិច្ចល្អ




## គោលបំណងនៃការគ្រប់គ្រង

យោងតាមគោលការណ៍ទី៨នៃគោលការណ៍ស្តីពីទេសចរណ៍ប្រកបដោយចីរភាពនៅតំបន់បេតិកភណ្ឌពិភពលោក រាជរដ្ឋាភិបាលកម្ពុជាត្រូវធានាថា នៅពេលវិស័យទេសចរណ៍រីកចម្រើននិងផ្តល់ចំណូលកាន់តែខ្ពស់ ត្រូវរៀបចំរចនាសម្ព័ន្ធស្ថាប័ននិងគ្រប់គ្រងធនធានទាំងអស់ឲ្យមានប្រសិទ្ធភាព ក្នុងនោះរួមមានទាំងការអនុវត្តផែនការគ្រប់គ្រងវិស័យទេសចរណ៍ផងដែរ។

| **សមិទ្ធផលនានាមកដល់បច្ចុប្បន្ន** |
|---|
| អាជ្ញាធរអប្សរាបាននឹងកំពុងបន្តទំនាក់ទំនងជាមួយក្រសួងទេសចរណ៍និងអាជ្ញាធរខេត្ត ដើម្បីធ្វើឲ្យមានអភិបាលកិច្ចល្អនៅតំបន់បេតិកភណ្ឌពិភពលោកអង្គរ។ អាជ្ញាធរអប្សរាបានរៀបចំវិធាននានា ដើម្បីការពារធនធានធម្មជាតិ និងបេតិកភណ្ឌវប្បធម៌។ អាជ្ញាធរអប្សរានិងអាជ្ញាធរខេត្តបានផ្លាស់ប្ដូរទីតាំងលំនៅឋាននានាដែលស្ថិតនៅតាមដងស្ទឹងសៀមរាប ដើម្បីធ្វើការកែលម្អទេសភាពស្ទឹងសៀមរាប។ មានយុទ្ធនាការលើកកម្ពស់ការយល់ដឹងជាបន្តបន្ទាប់ដែលពាក់ព័ន្ធនឹងការការពារធនធានធម្មជាតិនិងបេតិកភណ្ឌវប្បធម៌ ហើយអ្នកជំនាញអភិរក្សបានធ្វើការបណ្តុះបណ្តាលបុគ្គលិកបច្ចេកទេសជាទៀងទាត់។ អាយ-ស៊ី-ស៊ី ត្រូវបានបង្កើតឡើងដើម្បីធ្វើការពិភាក្សាជាទៀងទាត់ ផ្តល់អនុសាសន៍និងគាំទ្រជាសាធារណៈដល់សមិទ្ធផលនានាក្នុងការគ្រប់គ្រង។ |

## បញ្ហាប្រឈម

បញ្ហាទាក់ទងនឹងអភិបាលកិច្ចខាងក្រោម បានមកពីកិច្ចពិភាក្សារវាងរាជរដ្ឋាភិបាល សហគមន៍ អ្នកពាក់ព័ន្ធក្នុងឧស្សាហកម្មទេសចរណ៍នៅអង្គរ ក្នុងដំណើរការប្រឹក្សាយោបល់ដើម្បីរៀបចំឯកសារផែនការគ្រប់គ្រងទេសចរណ៍នេះ។

| **បញ្ហា** | **យុទ្ធសាស្ត្រ** |
|---|---|
| ធនធានក្នុងអាជ្ញាធរអប្សរានៅមានកម្រិតនៅឡើយ។<br><br>មានហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍មិនគ្រប់គ្រាន់នៅក្នុងតំបន់បេតិកភណ្ឌពិភពលោកអង្គរ។<br><br>ខ្វះព័ត៌មានវិទ្យាចាំបាច់សម្រាប់ការគ្រប់គ្រងទេសចរណ៍នៅអង្គរ។ | ទី៥ ទី៧ |
| ធនធានមនុស្ស ជំនាញនៅក្នុងអាជ្ញាធរអប្សរានៅមានកម្រិតនៅឡើយ។<br><br>បុគ្គលិកតាមទីតាំងជាច្រើនមិនបានបំពេញភារកិច្ចឲ្យបានខ្ជាប់ខ្ជួន និងពុំបាន | ទី៤ |

| | |
|---|---|
| ហាមឃាត់ភ្ញៀវទេសចរនៅពេលដែលពួកគេមានអាកប្បកិរិយាពុំសមរម្យឬពុំបានអនុវត្តតាមវង់ទស្សនាដែលបានកំណត់។<br><br>បុគ្គលិកតាមប្រាសាទមួយចំនួនពុំមានការទទួលខុសត្រូវការងារនិងឆ្លើយតបតាមការចង់បាន។<br><br>ពុំមានអ្នកសម្របសម្រួលនិងអ្នកគ្រប់គ្រងតែម្នាក់ ដែលទទួលខុសត្រូវក្នុងការសម្រេចចិត្តនានានៅតាមទីតាំងប្រាសាទសំខាន់ៗ។ | |
| មានសម្ពាធរវាងបំណងដែលចង់ពង្រីកចំណូលពីវិស័យទេសចរណ៍និងផលអវិជ្ជមានពីការកើនឡើងចំនួនភ្ញៀវទេសចរ<br><br>ការលក់និងកំណត់ថ្លៃសំបុត្រនាពេលបច្ចុប្បន្ន ពុំបានឆ្លើយតបតាមចំណែកទីផ្សារអ្នកទេសចរ ឬជួយដល់ការគ្រប់គ្រងលំហូរភ្ញៀវនៅក្នុងរមណីយដ្ឋានទេ។ | ទី៥ ទី៦ |
| ខ្វះខាតការពង្រឹងប្រសិទ្ធភាពក្នុងការអនុវត្តបទបញ្ជាឬសេចក្ដីណែនាំនានាសម្រាប់ភ្ញៀវទេសចរនៅតំបន់អង្គរ។<br><br>ខ្វះខាតការពង្រឹងបទបញ្ជាឬសេចក្ដីណែនាំចំពោះអ្នកដើរលក់ និងអ្នកសុំទានក្នុងប្រាសាទ។ | ទី៦ |
| តួនាទីរបស់នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរនិងនាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ សារមន្ទីរ និងបទដ្ឋានបេតិកភណ្ឌនៅក្នុងអាជ្ញាធរអប្សរា ពុំភាពច្បាស់លាស់និងជាន់គ្នា។ | ទី២ |
| ខ្វះខាតការសហការរវាងអង្គភាពដែលធ្វើការងារក្នុងតំបន់អង្គរ។ ស្ថាប័នខ្លះមានតួនាទីនៅក្នុងអភិបាលកិច្ចអង្គរដូចជា អាជ្ញាធរអប្សរា នគរបាលបេតិកភណ្ឌ និងនគរបាលទេសចរ។<br><br>ពុំមានការកំណត់តួនាទីនិងទំនួលខុសត្រូវរបស់បុគ្គលិកអាជ្ញាធរអប្សរា និងភ្នាក់ងារផ្សេងទៀតដែលធ្វើការនៅអង្គរឲ្យបានច្បាស់លាស់ ដែលនាំឲ្យមានការ | ទី៣ |

| | |
|---|---|
| យល់គ្នាមិនច្បាស់លាស់។<br><br>អាជ្ញាធរអប្សរានិងក្រសួងទេសចរណ៍សុទ្ធតែមានតួនាទីនៅក្នុងការគ្រប់គ្រងទេសចរណ៍នៅអង្គរ ដូច្នេះ ត្រូវមានទំនាក់ទំនងនិងការប្រាស្រ័យទាក់ទងល្អជាមួយគ្នា។ | |




## យុទ្ធសាស្ត្រ

មានយុទ្ធសាស្ត្រចំនួន៩ចំណុចដែលនឹងធានាថា រចនាសម្ព័ន្ធស្ថាប័ននិងធនធានដែលមានឆ្លុះបញ្ចាំងពីតម្រូវការនានានៃការគ្រប់គ្រងវិស័យទេសចរណ៍ប្រកបដោយប្រសិទ្ធភាព។

១- អនុម័តនិងត្រួតពិនិត្យដោយ ICC-Angkor

២- សម្របឲ្យត្រូវរវាងTMP និងអាជ្ញាធរអប្សរា

៣- បង្កើតទំនាក់ទំនងរវាងភ្នាក់ងារពាក់ព័ន្ធនិងកម្មវិធីសមាហរណកម្ម

៤- ពង្រឹងសមត្ថភាព

៥- កំណត់បែងចែកធនធាន

៦- ធានាប្រសិទ្ធភាពការគ្រប់គ្រងច្បាប់និងគោលនយោបាយ

៧- គ្រប់គ្រងព័ត៌មាន

៨- ត្រួតពិនិត្យ

៩- ត្រួតពិនិត្យឡើងវិញ

## ៥.១ អនុម័តនិងត្រួតពិនិត្យដោយ ICC-Angkor

*យុទ្ធសាស្ត្រ :* ICC-Angkor នឹងអនុម័តTMP និងសម្រួលដល់កម្មវិធីអន្តរជាតិដែលជាប់ទាក់ទងនឹងម្ចាស់ជំនួយ។

*ហេតុផល :* ICC-Angkor មានតួនាទីក្នុងការការពារនិងអភិវឌ្ឍតំបន់រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ ដូច្នេះ ICC-Angkor ចាំបាច់ត្រូវជួយគាំទ្រTMPនិងការផ្តួចផ្តើមគោលនយោបាយទាំងអស់។

| សកម្មភាព | ទំនួលខុសត្រូវ | រយៈពេល | អាទិភាព |
|---|---|---|---|
| ៥.១.១- គាំទ្រ TMP និងការផ្តួចផ្តើមគោលនយោបាយនានា | ICC-Angkor/ យូណេស្កូ/ ប្រធាននិងអគ្គនាយកអាជ្ញាធរអប្សរា | | ខ្ពស់ |
| ៥.១.២- ស្វែងរកការផ្តល់គំនិតពីអ្នកជំនាញនៅក្នុងការគ្រប់គ្រងវិស័យទេសចរណ៍នៅអង្គរ តាមរយៈការរិះរកឲ្យឃើញការផ្លាស់ប្តូរនិងការកែលម្អដំណើរការ និងដំណាក់កាលគ្រប់គ្រងទៅតាមធនធានដែលមាន | អគ្គនាយកអាជ្ញាធរអប្សរា | | មធ្យម |
| ៥.១.៣- ផ្តល់ព័ត៌មានពីដំណាក់កាលនៃការអនុវត្ត TMP ដល់អ្នកពាក់ព័ន្ធ ដើម្បីឲ្យការរំពឹងទុកទទួលបានលទ្ធផលល្អប្រសើរនិងអាចគ្រប់គ្រងបាន។ | មន្ត្រីអនុវត្តTMP | | ខ្ពស់ |



## ៥.២ សម្របឲ្យត្រូវរវាងTMPនិងអាជ្ញាធរអប្សរា

*យុទ្ធសាស្ត្រ :* អាជ្ញាធរអប្សរានឹងទទួលខុសត្រូវលើការអនុវត្តTMP ដូច្នេះហើយការរៀបចំរចនាសម្ព័ន្ធរបស់អាជ្ញាធរអប្សរា គួរតែឆ្លុះបញ្ចាំងពីតម្រូវការក្នុងការគ្រប់គ្រងទេសចរណ៍។

*ហេតុផល :* តម្រូវការក្នុងការគ្រប់គ្រងទេសចរណ៍នៅអង្គរ ត្រូវស្របគ្នានឹងរចនាសម្ព័ន្ធអាជ្ញាធរអប្សរា ដើម្បីអនុវត្តTMP ឲ្យបានជោគជ័យ ។

| សកម្មភាព | ទំនួលខុសត្រូវ | រយៈពេល | អាទិភាព |
|---|---|---|---|
| ៥.២.១- តែងតាំងមន្ត្រីជាន់ខ្ពស់ម្នាក់ដែលទទួលខុសត្រូវលើការអនុវត្តTMP | អគ្គនាយកអាជ្ញាធរអប្សរា | | ខ្ពស់ |
| ៥.២.២- តែងតាំងមន្ត្រីម្នាក់ដែលទទួលខុសត្រូវលើការអនុវត្តTMP ដែលជាប់ទាក់ទងជាមួយក្រសួងទេសចរណ៍ | ក្រសួងទេសចរណ៍ | | ខ្ពស់ |
| ៥.២.៣- តែងតាំងមន្ត្រីម្នាក់ដែលទទួលខុសត្រូវលើការអនុវត្តTMP ដែលជាប់ទាក់ទងអាជ្ញាធរខេត្តសៀមរាប | អភិបាលខេត្តសៀមរាប | | ខ្ពស់ |
| ៥.២.៤- ប្រគល់តួនាទីនិងទំនួលខុសត្រូវច្បាស់លាស់ក្នុងការអនុវត្តTMP ដល់បុគ្គលិកអាជ្ញាធរអប្សរា | អគ្គនាយកអាជ្ញាធរអប្សរា | | ខ្ពស់ |

| | | | |
|---|---|---|---|
| ៥.២.៥- បង្កើតឲ្យមានយន្តការសហការបន្ថែមទៀត រវាងថ្នាក់ដឹកនាំអាជ្ញាធរអប្សរាដែលបំពេញការងារនៅអង្គរ | អគ្គនាយក អាជ្ញាធរអប្សរា | | ខ្ពស់ |
| ៥.២.៦- អនុវត្តដំណើរការនិងសកម្មភាពអនុវត្តTMP ឲ្យស្របនឹងធនធានដែលអាជ្ញាធរអប្សរាមាន | អគ្គនាយក អាជ្ញាធរអប្សរា | | ខ្ពស់ |
| ៥.២.៧- កំណត់តួនាទីបុគ្គលិកដែលបំពេញការងារនៅតំបន់បេតិកភណ្ឌពិភពលោកអង្គរឲ្យបានច្បាស់លាស់ រួមទាំងការងារទំនាក់ទំនងជាមួយភ្ញៀវទេសចរនិងចំណេះដឹងអំពីការប្រើប្រាស់សេវាកម្មទេសចរណ៍ឲ្យបានល្អ | អគ្គនាយក អាជ្ញាធរអប្សរា | | ខ្ពស់ |
| ៥.២.៨- ផ្តល់អាទិភាពក្នុងការបែងចែកបុគ្គលិកនិងធនធានដែលមាន ដើម្បីឆ្លើយតបទៅតាមការផ្លាស់ប្តូរនានា ក្នុងការគ្រប់គ្រងទេសចរណ៍ ជៀសវាងផលប៉ះពាល់និងឥទ្ធិពលផ្សេងៗនៃបម្រែបម្រួលទាំងនោះ | អគ្គនាយក អាជ្ញាធរអប្សរា | | ខ្ពស់ |
| ៥.២.៩- លើកកម្ពស់រចនាសម្ព័ន្ធចាត់តាំងអាជ្ញាធរអប្សរាបន្ថែមទៀត ដើម្បីឆ្លុះបញ្ចាំងតម្រូវការគ្រប់គ្រងទេសចរណ៍។ | អគ្គនាយក អាជ្ញាធរអប្សរា | | មធ្យម |





## ៥.៣. បង្កើតទំនាក់ទំនងរវាងភ្នាក់ងារពាក់ព័ន្ធនិងកម្មវិធីសមាហរណកម្ម

*យុទ្ធសាស្ត្រ :* អាជ្ញាធរអប្សរា ក្រសួងទេសចរណ៍ និងស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងសហការធានាថា រាល់កម្មវិធីទេសចរណ៍និងការផ្តួចផ្តើមទាំងអស់ដែលជះឥទ្ធិពលដល់តំបន់បេតិកភណ្ឌពិភពលោក ត្រូវមានការចូលរួមចំណែកពីគ្រប់ផ្នែកពាក់ព័ន្ធពិតប្រាកដនិងមិនប៉ះពាល់ដល់គុណតម្លៃអង្គរ។

*ហេតុផល :* តំបន់បេតិកភណ្ឌពិភពលោកអង្គរ រួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ដូច្នេះតម្រូវឲ្យមានការសម្របសម្រួលនិងចូលរួមពីគ្រប់ផ្នែកពាក់ព័ន្ធទាំងអស់របស់រាជរដ្ឋាភិបាល។

| សកម្មភាព | ទំនួលខុសត្រូវ | រយៈពេល | អាទិភាព |
|---|---|---|---|
| ៥.៣.១- ធ្វើការបញ្ជាក់ឲ្យច្បាស់បន្ថែមទៀតនូវតួនាទីនៃក្រសួងទេសចរណ៍ អាជ្ញាធរអប្សរា និងអាជ្ញាធរខេត្តក្នុងការគ្រប់គ្រងទេសចរណ៍នៅអង្គរ | អគ្គនាយក អាជ្ញាធរអប្សរា/ អភិបាលខេត្ត សៀមរាប | | បឋម |
| ៥.៣.២- លើកកម្ពស់កិច្ចសហប្រតិបត្តិការបន្ថែមទៀតរវាងមន្ត្រី បុគ្គលិកអាជ្ញាធរអប្សរា និងនគរបាលទេសចរណ៍ ក៏ដូចជានគរបាលបេតិកភណ្ឌ | អាជ្ញាធរអប្សរា/ នគរបាល ទេសចរ/ នគរបាល បេតិកភណ្ឌ | | មធ្យម |
| ៥.៣.៣- បង្កើតយន្តការសហការរវាងស្ថាប័នពាក់ព័ន្ធដែលបំពេញការងារនៅអង្គរ | អគ្គនាយក អាជ្ញាធរអប្សរា | | មធ្យម |
| ៥.៣.៤- រៀបចំកិច្ចប្រជុំរវាងអាជ្ញាធរអប្សរានិងក្រសួងទេសចរណ៍ឲ្យបានទៀងទាត់។ | ក្រសួង ទេសចរណ៍/ នា-ទេសចរណ៍ | | ខ្ពស់ |

## ៥.៤ ពង្រឹងសមត្ថភាព

*យុទ្ធសាស្ត្រ :* អាជ្ញាធរអប្សរានិងស្ថាប័នពាក់ព័ន្ធដទៃទៀតនឹងទទួលបានរៀនសូត្រនិងប្រើប្រាស់ចំណេះដឹង ជំនាញបច្ចេកទេស និងធនធានមនុស្សដែលចាំបាច់ដើម្បីអនុវត្តTMP។

*ហេតុផល :* ការគ្រប់គ្រងទេសចរណ៍នៅតំបន់បេតិកភណ្ឌពិភពលោកអង្គរ ពឹងផ្អែកទាំងស្រុងលើការប្រើប្រាស់ធនធានមនុស្សដែលមានគ្រប់គ្រាន់និងមានប្រសិទ្ធភាព។

| សកម្មភាព | ទំនួលខុសត្រូវ | រយៈពេល | អាទិភាព |
|---|---|---|---|
| ៥.៤.១- បណ្តុះបណ្តាលក្រុមការងារនៅតាមប្រាសាទដោយកំណត់តួនាទីរបស់ពួកគាត់ឲ្យបានច្បាស់លាស់។ ពួកគាត់ចាំបាច់ត្រូវធ្វើការជាដៃគូនិងសហការជាមួយភ្នាក់ងារដែលពាក់ព័ន្ធដទៃទៀត | អាជ្ញាធរអប្សរា/ អភិបាលខេត្ត/ នគរបាល | | ខ្ពស់ |
| ៥.៤.២- ផ្តល់នូវការបណ្តុះបណ្តាលសកម្មភាពគ្រប់គ្រងដល់អ្នកបណ្តុះបណ្តាលបុគ្គលិក | អាជ្ញាធរអប្សរា/ អភិបាលខេត្ត/ នគរបាល | | មធ្យម |
| ៥.៤.៣- លើកទឹកចិត្តនិងផ្តល់រង្វាន់ដល់បុគ្គលិកដែលមានស្នាដៃ | អាជ្ញាធរអប្សរា | | មធ្យម |
| ៥.៤.៤- រៀបចំការប្រជុំឲ្យបានទៀងទាត់ ដើម្បីផ្តល់ព័ត៌មានត្រួសៗអំពីការអនុវត្តការងាររបស់នាយកដ្ឋាននីមួយៗ ដល់បុគ្គលិកអាជ្ញាធរអប្សរា | អគ្គនាយក អាជ្ញាធរអប្សរា | | ខ្ពស់ |
| ៥.៤.៥- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីសារៈសំខាន់នៃការអភិវឌ្ឍន៍វិស័យទេសចរណ៍ប្រកបដោយចីរភាពនិងបទដ្ឋានបេតិកភណ្ឌដល់បុគ្គលិកទាំងអស់ | នា-វប្បធម៌ | | មធ្យម |
| ៥.៤.៦- តែងតាំងអ្នកគ្រប់គ្រងនៅតាមប្រាសាទដែលមានភ្ញៀវទេសចរច្រើននិងមានគុណតម្លៃខ្ពស់ | អគ្គនាយក អាជ្ញាធរអប្សរា | | ខ្ពស់ |
| ៥.៤.៧- លើកកម្ពស់ការយល់ដឹងនិងការស្គាល់ពី | អាជ្ញាធរអប្សរា/ | | មធ្យម |

| | | | |
|---|---|---|---|
| គុណតម្លៃធម្មជាតិនិងវប្បធម៌របស់អង្គរដល់បុគ្គលិកអាជ្ញាធរអប្សរា | នា-វប្បធម៌ | | |
| ៥.៤.៨- បន្តកសាង ពង្រឹងសមត្ថភាពនៅក្នុងក្រសួងទេសចរណ៍និងអាជ្ញាធរអប្សរា ដើម្បីជួយគាំទ្រផែនការនិងការអនុវត្តការផ្តួចផ្តើមទេសចរណ៍សហគមន៍។ | អាជ្ញាធរអប្សរា/ក្រសួងទេសចរណ៍ | | មធ្យម |




**៥.៥ កំណត់បែងចែកធនធាន**

***យុទ្ធសាស្ត្រ*** **:** ស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធក្នុងការគ្រប់គ្រងទេសចរណ៍នៅតំបន់បេតិកភណ្ឌពិភពលោកអង្គរនឹងប្រើប្រាស់ធនធានមនុស្ស ហិរញ្ញវត្ថុ និងធនធានដទៃទៀតដែលជាតម្រូវការដើម្បីអនុវត្ត TMP ឲ្យមានប្រសិទ្ធភាព។

***ហេតុផល :*** ការគ្រប់គ្រងទេសចរណ៍នៅអង្គរទាមទារឲ្យមានធនធានគ្រប់គ្រាន់ និងដោយបែងចែកធនធានទាំងនោះទៅតាមតម្រូវការអាទិភាព។

| **សកម្មភាព** | **ទំនួលខុសត្រូវ** | **រយៈពេល** | **អាទិភាព** |
|---|---|---|---|
| ៥.៥.១- ធានាថាមានហិរញ្ញវត្ថុនិងធនធានគ្រប់គ្រាន់ដើម្បីអនុវត្តសកម្មភាពអាទិភាពដែលមានចែងនៅក្នុង TMP | អគ្គនាយកអាជ្ញាធរអប្សរា/នា-គណនេយ្យ | | ខ្ពស់ |

| | | | |
|---|---|---|---|
| ៥.៥.២-ផ្តល់ឲ្យនូវមូលនិធិឬធនធានដទៃទៀតដែលត្រូវការក្នុងការបណ្តុះបណ្តាលអ្នកគ្រប់គ្រងប្រាសាទ និងក្រុមការងារគ្រប់គ្រងនៅតាមប្រាសាទសំខាន់ៗ | អាជ្ញាធរអប្សរា/ អគ្គនាយក អាជ្ញាធរអប្សរា/ នា-គណនេយ្យ/ ម្ចាស់ជំនួយ | | ខ្ពស់ |
| ៥.៥.៣- កំណត់និងរៀបចំសេវាកម្មទេសចរណ៍ | នា-អន្តរវិស័យ/ អគ្គនាយក អាជ្ញាធរអប្សរា | | ខ្ពស់ |
| ៥.៥.៤- បញ្ជាក់ពីធនធានចាំបាច់ដែលមានសម្រាប់រៀបចំហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារៈសម្រាប់បម្រើឲ្យភ្ញៀវទេសចរ | នា-អន្តរវិស័យ/ អគ្គនាយក អាជ្ញាធរអប្សរា | | មធ្យម |
| ៥.៥.៥- ប្រើប្រាស់ធនធានចាំបាច់ទៅតាមកាលៈទេសៈផ្សេងគ្នា។ ផ្ទៀងផ្ទាត់និងពិនិត្យកែលម្អប្រព័ន្ធប្រើប្រាស់ធនធានដែលមានស្រាប់ឡើងវិញ។ | អគ្គនាយក អាជ្ញាធរអប្សរា/ នា-គណនេយ្យ | | មធ្យម |






## ៥.៦. ធានាប្រសិទ្ធភាពការគ្រប់គ្រងច្បាប់និងគោលនយោបាយ

*យុទ្ធសាស្ត្រ* : អាជ្ញាធរអប្សរានឹងធ្វើសេចក្តីព្រៀងនិងអនុម័តវិធាននិងគោលនយោបាយចាំបាច់ក្នុងការអនុវត្ត TMP។

*ហេតុផល :* ផ្នែកសំខាន់នៃការអនុវត្តTMP និងការគ្រប់គ្រងទេសចរណ៍នៅក្នុងតំបន់បេតិកភណ្ឌពិភពលោកអង្គរ នឹងក្លាយជាវិធាននិងគោលនយោបាយដ៏រឹងមាំនិងមានប្រសិទ្ធភាព។

| សកម្មភាព | ទំនួលខុសត្រូវ | រយៈពេល | អាទិភាព |
|---|---|---|---|
| ៥.៦.១- ធានាថាTMPត្រូវបានអនុម័តនិងផ្តល់ការគាំទ្រជាសាធារណៈ ដោយរាជរដ្ឋាភិបាលកម្ពុជា ICC-Angkor អង្គការយូណេស្កូ អាជ្ញាធរអប្សរា និងក្រសួងទេសចរណ៍ | ប្រធានអាជ្ញាធរអប្សរា | | ខ្ពស់ |
| ៥.៦.២- កែលម្អវិធាននៅក្នុងប្រាសាទនានា តាមរយៈការប្រើប្រាស់ធនធានមនុស្សឲ្យមានប្រយោជន៍ដោយសមស្រប ដូចជានគរបាលបេតិកភណ្ឌជាដើម | អគ្គនាយកអាជ្ញាធរអប្សរា | | ខ្ពស់ |
| ៥.៦.៣- លើកកម្ពស់ច្បាប់និងវិធានសម្រាប់ទេសចរណ៍បេតិកភណ្ឌបន្ថែមទៀត ដោយអនុវត្តឲ្យបានម៉ឺងម៉ាត់ | អគ្គនាយកអាជ្ញាធរអប្សរា/នា-វប្បធម៌/ទេសចរណ៍ | | មធ្យម |
| ៥.៦.៤- កំណត់តម្លៃទៅតាមប្រភេទទីផ្សារ ដើម្បីទទួលបានចំណូលពីទេសចរម្នាក់ៗខ្ពស់ជាងមុន ក៏ដូចជាបែងចែកភ្ញៀវទេសចរនៅក្នុងតំបន់អង្គរ។ | អគ្គនាយកអាជ្ញាធរអប្សរា/នា-គណនេយ្យ | | ខ្ពស់ |






## ៥.៧. គ្រប់គ្រងព័ត៌មាន

*យុទ្ធសាស្ត្រ* : ត្រូវប្រមូលនិងគ្រប់គ្រងរាល់ព័ត៌មានពាក់ព័ន្ធដែលត្រូវការទាំងអស់ ដើម្បីគ្រប់គ្រងទេសចរណ៍នៅតំបន់អង្គរប្រកបដោយប្រសិទ្ធភាព។ អាជ្ញាធរអប្សរា បុគ្គលិកសំខាន់ៗទាំងអស់និងអ្នកពាក់ព័ន្ធនានា អាចចូលទៅយកព័ត៌មានទាំងនោះបានតាមការចាំបាច់។

*ហេតុផល* : ការទទួលបានព័ត៌មានត្រឹមត្រូវនិងទាន់ពេលវេលារបស់អ្នកពាក់ព័ន្ធ មានសារៈសំខាន់ក្នុងការអនុវត្តTMP និងរួមចំណែកឲ្យមានការសម្រេចចិត្តបានល្អ។

| សកម្មភាព | ទំនួលខុសត្រូវ | រយៈពេល | អាទិភាព |
|---|---|---|---|
| ៥.៧.១- រៀបចំប្រព័ន្ធប្រមូល គ្រប់គ្រង និងចែករំលែកព័ត៌មាននៅក្នុងអាជ្ញាធរអប្សរា(និងនៅក្រៅអាជ្ញាធរអប្សរានៅពេលដែលត្រូវការ)។ | មជ្ឈមណ្ឌលតម្កល់ឯកសារ | | ខ្ពស់ |



## ៥.៨. ត្រួតពិនិត្យ

*យុទ្ធសាស្ត្រ :* ត្រូវត្រួតពិនិត្យការអនុវត្តTMPដោយទៀងទាត់ និងធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពការងារទៅកាន់រាជរដ្ឋាភិបាលកម្ពុជានិង ICC-Angkor។

*ហេតុផល :* ការត្រួតពិនិត្យនឹងជួយវាស់ស្ទង់វឌ្ឍនភាព ក៏ដូចជាកែតម្រូវបញ្ហាជាយថាហេតុដែលអាចកើតមានឡើងនៅពេលអនុវត្តTMP។

| សកម្មភាព | ទំនួលខុសត្រូវ | រយៈពេល | អាទិភាព |
|---|---|---|---|
| ៥.៨.១- រាយការណ៍ពីវឌ្ឍនភាពក្នុងការអនុវត្តTMPទៅដល់កិច្ចប្រជុំបច្ចេកទេស ICC-Angkor | អាជ្ញាធរអប្សរា | | ខ្ពស់ |
| ៥.៨.២- ធ្វើការត្រួតពិនិត្យនិន្នាការទេសចរណ៍និងដំណោះស្រាយក្នុងការគ្រប់គ្រង ដើម្បីឆ្លើយតបតាមបម្រែបម្រួលនៃលក្ខខណ្ឌទេសចរណ៍ | នា-ទេសចរណ៍ | | មធ្យម |
| ៥.៨.៣-បន្តអនុវត្តការត្រួតពិនិត្យនិងស្រាវជ្រាវពីការទស្សនារបស់ភ្ញៀវទេសចរ។ | នា-វប្បធម៌ | | មធ្យម |





## ៥.៩. ត្រួតពិនិត្យឡើងវិញ

*យុទ្ធសាស្ត្រ :* TMPនឹងធ្វើការត្រួតពិនិត្យឡើងវិញជាចម្បងលើគោលនយោបាយនិងយុទ្ធសាស្ត្រជារៀងរាល់៥ឆ្នាំម្តងឬឆាប់ជាងនេះ ទៅតាមកាលៈទេសៈចាំបាច់។

*ហេតុផល* : ការវិវឌ្ឍក្នុងការគ្រប់គ្រងទេសចរណ៍និងកាលៈទេសៈមួយចំនួន តម្រូវឲ្យមានការត្រួតពិនិត្យTMP ឡើងវិញ ហើយនេះជាឱកាសក្នុងការវាយតម្លៃនិងដោះស្រាយបញ្ហា និងការប្រឈមថ្មីៗ។

| សកម្មភាព | ទំនួលខុសត្រូវ | រយៈពេល | អាទិភាព |
|---|---|---|---|
| ៥.៩.១- រៀបចំគោលនយោបាយត្រួតពិនិត្យTMP ឡើងវិញ ព្រោះជាឯកសាររស់និងជាយុទ្ធសាស្ត្រទន់ភ្លន់មួយ ដែលអាចកែតម្រូវនិងផ្លាស់ប្តូរបានឲ្យស្របនឹងកាលៈទេសៈនានាដែលប្រែប្រួល | អគ្គនាយក អាជ្ញាធរអប្សរា | | មធ្យម |
| ៥.៩.២- ធ្វើការត្រួតពិនិត្យTMPឡើងវិញនៅរៀងរាល់៥ឆ្នាំម្តង ដោយមានការពិគ្រោះយោបល់ ជាមួយអ្នកពាក់ព័ន្ធនានា | អាជ្ញាធរអប្សរា/ ក្រសួងទេសចរណ៍/ ក្រុមប្រឹក្សាជាមួយឧស្សាហកម្មទេសចរណ៍/ អភិបាលខេត្ត | | មធ្យម |
| ៥.៩.៣- ត្រួតពិនិត្យនិងកែសម្រួលសកម្មភាពអាទិភាពនានារបស់TMPឡើងវិញ។ | អាជ្ញាធរអប្សរា/ ICC-Angkor | | ខ្ពស់ |





# ការផ្តួចផ្តើមគោលនយោបាយTMPទី៦ គឺការចូលរួមស្វែងយល់ពីអ្នកពាក់ព័ន្ធ




## គោលបំណងនៃការគ្រប់គ្រង

មានចក្ខុវិស័យដែលយល់ស្របគ្នាចំពោះការគ្រប់គ្រងទេសចរណ៍ កើតចេញមកពីការប្រាស្រ័យទាក់ទង ការពិគ្រោះយោបល់និងកិច្ចសហការគ្នារវាងនិងនៅក្នុងរាជរដ្ឋាភិបាល ឧស្សាហកម្មទេសចរណ៍ អង្គការមិនមែនរដ្ឋាភិបាល និងប្រជាជនក្នុងតំបន់បេតិកភណ្ឌពិភពលោកអង្គរ។

- ប្តេជ្ញាឲ្យមានការចូលរួមពីអ្នកពាក់ព័ន្ធទាំងអស់

- ប្រើប្រាស់និងពង្រឹងទំនាក់ទំនងដែលមានស្រាប់
- បង្កើតយន្តការថ្មីសម្រាប់ឲ្យស្ថាប័ននិងអ្នកពាក់ព័ន្ធចូលរួមសហការគ្នា
- គ្រប់គ្រងការប្រែប្រួលតាមរយៈដំណើរការពិគ្រោះយោបល់នានា
- ជំរុញលើកកម្ពស់ភាពជាដៃគូប្រកបដោយប្រសិទ្ធភាពដែលផ្តល់ប្រយោជន៍ទៅវិញទៅមក
- ការប្រាស្រ័យទាក់ទងបើកចំហជាទៀងទាត់។

**សមិទ្ធផលនានាមកដល់បច្ចុប្បន្ន**

អាជ្ញាធរអប្សរាបាននិងបន្តការចូលរួមស្វែងយល់ជាមួយអ្នកពាក់ព័ន្ធជាច្រើននៅក្នុងការគ្រប់គ្រងអង្គរ។ ជាពិសេស អាជ្ញាធរអប្សរាបានចូលរួមជាមួយឧស្សាហកម្មទេសចរណ៍ ក្រសួងទេសចរណ៍ អាជ្ញាធរខេត្ត សហគមន៍ អង្គការមិនមែនរដ្ឋាភិបាល និងព្រះសង្ឃ។ អាជ្ញាធរអប្សរាយល់ថា ការចូលរួមស្វែងយល់ពីអ្នកពាក់ព័ន្ធ គឺជាសមាសធាតុជាមូលដ្ឋានមួយនៃការគ្រប់គ្រងទេសចរណ៍ និងបានជួយសម្រួលការបង្កើតក្រុមការងារជាមួយផ្នែកឧស្សាហកម្ម និងគណៈកម្មការភូមិ។

## បញ្ហានានាដែលត្រូវលើកឡើង

### បញ្ហាប្រឈម

បញ្ហាការប្រាស្រ័យទាក់ទងនានាដែលលើកឡើងខាងក្រោមនេះ បានមកពីកិច្ចពិភាក្សារវាងរាជរដ្ឋាភិបាល សហគមន៍ និងឧស្សាហកម្មទេសចរណ៍នៅអង្គរ ក្នុងដំណើរការពិគ្រោះយោបល់ ដើម្បីរៀបចំឯកសារគ្រប់គ្រងទេសចរណ៍នេះ។

| បញ្ហា | យុទ្ធសាស្ត្រ |
|---|---|
| ខ្វះការផ្តល់ព័ត៌មានដល់អ្នកពាក់ព័ន្ធ ជាពិសេសពីតំបន់ការពារ ភារកិច្ចអាជ្ញាធរអប្សរា បទបញ្ញាផ្ទៃក្នុងនានាសម្រាប់អ្នកទេសចរ។ | ទី៤ |
| អ្នកពាក់ព័ន្ធមួយចំនួននៅក្នុងតំបន់អង្គរ ពុំសហការក្នុងការគ្រប់គ្រង(នៅក្នុងនិងក្រៅរមណីយដ្ឋាន អ្នកលក់ដូរ រំខានភ្ញៀវទេសចរ តម្លៃផលិតផល)។ | ទី២ |

| | |
|---|---|
| ក្រុមហ៊ុនឯកជននិងទីភ្នាក់ងារទេសចរណ៍មួយចំនួនពុំបានគោរពតាមវិធានអភិរក្ស ហើយសកម្មភាពរបស់ពួកគេអាចបង្កបញ្ហាទាញយកប្រៀបពីប្រជាជនក្នុងតំបន់ឬពុំរួមចំណែកឬគោរពការអភិរក្ស។ | ទី៣ |
| មាននូវតម្រូវការមួយក្នុងការតែងតាំងបុគ្គលសម្រាប់ទំនាក់ទំនងនៅអាជ្ញាធរអប្សរា | ទី៤ |
| គួរតែមានការចូលរួមស្វែងយល់បន្ថែមពីអ្នកពាក់ព័ន្ធនិងការប្តេជ្ញាចំពោះការគ្រប់គ្រង ទេសចរណ៍នៅអង្គរ។ | ទី១ |

## យុទ្ធសាស្ត្រ

មានយុទ្ធសាស្ត្រចំនួន៤ ដែលនឹងអាចធ្វើឲ្យការប្រាស្រ័យទាក់ទងគ្នា ការពិគ្រោះយោបល់ និងកិច្ចសហការការរវាងរាជរដ្ឋាភិបាល ឧស្សាហកម្មទេសចរណ៍ អង្គការក្រៅរដ្ឋាភិបាល និងសហគមន៍ក្នុងស្រុកនៅតំបន់បេតិកភណ្ឌពិភពលោកអង្គរមានប្រសិទ្ធភាព។

១- ជំរុញឲ្យមានការចូលរួមពីអ្នកពាក់ព័ន្ធ

២- សម្របសម្រួលនិងចូលរួមពីអ្នកពាក់ព័ន្ធ

៣- សហការជាមួយអ្នកពាក់ព័ន្ធ

៤- ប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធ





## ៦.១. ជំរុញការចូលរួមពីអ្នកពាក់ព័ន្ធ

*យុទ្ធសាស្ត្រ :* ការអនុវត្តTMP ជាប់ទាក់ទងយ៉ាងសកម្មជាមួយអ្នកពាក់ព័ន្ធតាមរយៈការប្រាស្រ័យទាក់ទង ការពិគ្រោះយោបល់ និងកិច្ចសហការជាមួយអ្នកពាក់ព័ន្ធគន្លឹះដទៃទៀត។

*ហេតុផល :* ការគ្រប់គ្រងទេសចរណ៍នៅអង្គរ ទាមទារនូវការប្តេជ្ញាចិត្តពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់ដើម្បីធ្វើការជាមួយគ្នាប្រកបដោយវីរភាព អភិរក្សគុណតម្លៃនៃទីកន្លែងនានា និងជំរុញលើកកម្ពស់ការអភិវឌ្ឍន៍ទេសចរណ៍ប្រកបដោយចីរភាព។

| សកម្មភាព | ទំនួលខុសត្រូវ | រយៈពេល | អាទិភាព |
|---|---|---|---|
| ៦.១.១- លើកកម្ពស់ការយល់ដឹងក្នុងចំណោមបុគ្គលិកអាជ្ញាធរអប្សរា អំពីសារៈសំខាន់និងតម្លាភាពនៃការចូលរួមរបស់អ្នកពាក់ព័ន្ធ | អាជ្ញាធរអប្សរា/ អគ្គនាយក អាជ្ញាធរអប្សរា | | ខ្ពស់ |
| ៦.១.២- បន្តការរៀបចំវេទិកាអ្នកពាក់ព័ន្ធនិងប្រជុំក្រុមការងារ ដើម្បីឲ្យពួកគាត់បានចូលរួមចំណែកក្នុងការគ្រប់គ្រងទេសចរណ៍ | អាជ្ញាធរអប្សរា/ ក្រុមប្រឹក្សាយោបល់ជាមួយឧស្សាហកម្មទេសចរណ៍ | | ខ្ពស់ |
| ៦.១.៣- បង្កើតយន្តការតម្លាភាពសម្រាប់អ្នកពាក់ព័ន្ធ ដើម្បីផ្តល់ព័ត៌មាន សំណូមពរ និងយោបល់ស្តីពីការគ្រប់គ្រងទេសចរណ៍តំបន់អង្គរ។ | អាជ្ញាធរអប្សរា/ អគ្គនាយក អាជ្ញាធរអប្សរា | | ខ្ពស់ |



## ៦.២. សម្របសម្រួលនិងចូលរួមពីអ្នកពាក់ព័ន្ធ

*យុទ្ធសាស្ត្រ :* ត្រូវសម្របសម្រួលនិងចាត់ចែងការចូលរួមពីអ្នកពាក់ព័ន្ធ ដើម្បីសម្រេចទិសដៅនៃTMP។

*ហេតុផល :* ការអនុវត្តTMP ដោយផ្តោតការយកចិត្តទុកដាក់និងសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធជាការចាំបាច់ពុំអាចខ្វះបាន។

| សកម្មភាព | ទំនួលខុសត្រូវ | រយៈពេល | អាទិភាព |
|---|---|---|---|
| ៦.២.១- សម្របសម្រួលទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធនៅក្នុងTMP បង្កើតរបៀបធ្វើការងារដើម្បីសម្រួលដល់ការប្រាស្រ័យទាក់ទងនិងកិច្ចសហប្រតិបត្តិការល្អ | មន្ត្រីអនុវត្តTMP/ មន្ត្រីទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍/ ក្រុមប្រឹក្សាយោបល់ជាមួយឧស្សាហកម្មទេសចរណ៍/ អភិបាលខេត្ត | | ខ្ពស់ |
| ៦.២.២- តែងតាំងមន្ត្រីទំនាក់ទំនង ដើម្បីសម្របសម្រួលនិងទទួលយោបល់ពីអ្នកពាក់ព័ន្ធក្នុង TMP | អគ្គនាយកអាជ្ញាធរអប្សរា | | ខ្ពស់ |

| | | | |
|---|---|---|---|
| ៦.២.៣- ប្រមូលព័ត៌មានពីអ្នកពាក់ព័ន្ធសំខាន់ៗ | មន្ត្រីអនុវត្តTMP/ មន្ត្រីទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍ | | ខ្ពស់ |
| ៦.២.៤- សម្របសម្រួលការផលិតនិងចែកចាយព័ត៌មានអេឡិចត្រូនិច។ | អ្នកបញ្ចូលទិន្នន័យគេហៈទំព័រអាជ្ញាធរអប្សរា | | ខ្ពស់ |

### ៦.៣. សហការជាមួយអ្នកពាក់ព័ន្ធ

*យុទ្ធសាស្ត្រ :* អ្នកពាក់ព័ន្ធនឹងអាចកំណត់និងអនុវត្តគម្រោងនានាដែលគាំទ្រការផ្តួចផ្តើមគោលនយោបាយរបស់ TMP។

*ហេតុផល :* កិច្ចសហការគឺជាគោលការណ៍គ្រឹះជាមូលដ្ឋានមួយសម្រាប់ការគ្រប់គ្រងទេសចរណ៍ដោយជោគជ័យ។

| សកម្មភាព | ទំនួលខុសត្រូវ | រយៈពេល | អាទិភាព |
|---|---|---|---|
| ៦.៣.១- កំណត់គម្រោងទេសចរណ៍ដើម្បីទទួលបានការគាំទ្រពីសហគមន៍អន្តរជាតិ | អគ្គនាយកអាជ្ញាធរអប្សរា/ នា- ទេសចរណ៍ | | មធ្យម |
| ៦.៣.២- បង្កើតឲ្យមានការប្រជុំទៀងទាត់ជាមួយអង្គការក្រៅរដ្ឋាភិបាល នៅក្នុងក្របខ័ណ្ឌការងាររបស់ពួកគាត់ដើម្បីរកឲ្យឃើញឱកាសសហការគ្នា | នា-វប្បធម៌/ ទេសចរណ៍ | | មធ្យម |
| ៦.៣.៣-ជួយឲ្យឧស្សាហកម្មទេសចរណ៍រកឃើញការផ្តួចផ្តើមថ្មីដែលមានការច្នៃប្រឌិត ដើម្បីសហការអនុវត្តTMP ឲ្យបានលទ្ធផលល្អ។ | មន្ត្រីទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍/ | | មធ្យម |

| | | | |
|---|---|---|---|
| | ក្រុមប្រឹក្សាយោបល់ជាមួយឧស្សាហកម្មទេសចរណ៍/ នា-ទេសចរណ៍ | | |



## ៦.៨. ប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធ

*យុទ្ធសាស្ត្រ :* អ្នកពាក់ព័ន្ធនឹងអាចកំណត់និងអនុវត្តគម្រោងនានាដែលគាំទ្រការផ្តួចផ្តើមគោលនយោបាយរបស់ TMP។

*ហេតុផល :* ការប្រាស្រ័យទាក់ទងទៀងទាត់និងច្បាស់លាស់គឺចាំបាច់សម្រាប់ការអនុវត្តគោលនយោបាយគ្រប់គ្រងទេសចរណ៍ដោយជោគជ័យ។

| សកម្មភាព | ទំនួលខុសត្រូវ | រយៈពេល | អាទិភាព |
|---|---|---|---|
| ៦.៨.១- ត្រូវផ្តល់ព័ត៌មានពីដំណាក់កាលអនុវត្តTMP ដល់រាជរដ្ឋាភិបាលកម្ពុជា ICC-Angkor ឧស្សាហកម្មទេសចរណ៍និងអ្នកពាក់ព័ន្ធ ដើម្បីឆ្លើយតបតាមការរំពឹងទុកក្នុងការគ្រប់គ្រង | អគ្គនាយកអាជ្ញាធរអប្សរា/ មន្ត្រីអនុវត្តTMP | | ខ្ពស់ |
| ៦.៨.២- បង្កើតការប្រាស្រ័យទាក់ទងជាលក្ខណៈ | អាជ្ញាធរអប្សរា | | ខ្ពស់ |

| | | | |
|---|---|---|---|
| ប្រព័ន្ធជាមួយអ្នកពាក់ព័ន្ធ រួមមានអង្គការមិនមែនរដ្ឋាភិបាល ផ្នែកឧស្សាហកម្មទេសចរណ៍ មគ្គុទ្ទេសក៍ និងប្រជាជនក្នុងតំបន់ | | | |
| ៦.៩.៣-រៀបចំការប្រជុំកាន់តែឲ្យបានទៀងទាត់ជាមួយវិស័យឯកជន ដើម្បីលើកកម្ពស់ការយល់ដឹងនិងចូលរួមពីប្រជាជនក្នុងតំបន់ ក្នុងការគ្រប់គ្រងតំបន់ប្រាសាទប្រកបដោយប្រសិទ្ធភាព និងកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមាននានា | មន្ត្រីទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍/ក្រុមប្រឹក្សាយោបល់ជាមួយឧស្សាហកម្មទេសចរណ៍ | | ខ្ពស់ |
| ៦.៩.៤- ផ្តល់ព័ត៌មាននិងការប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធអំពីការបិទទីតាំងណាមួយនៃតំបន់បេតិកភណ្ឌអង្គរ ដើម្បីរៀបចំពិធីវប្បធម៌និងព្រឹត្តិការណ៍នានា | មន្ត្រីទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍/អ្នកបញ្ចូលទិន្នន័យក្នុងគេហៈទំព័រអាជ្ញាធរអប្សរា/នា-ផ្សព្វផ្សាយ/ទេសចរណ៍ | | ខ្ពស់ |
| ៦.៩.៥- ប្រើប្រាស់គេហៈទំព័រអាជ្ញាធរអប្សរាដើម្បីផ្តល់ព័ត៌មានថ្មីៗជាប្រចាំដល់អ្នកពាក់ព័ន្ធទាំងអស់នៅឧទ្យានអង្គរ ។ | អ្នកបញ្ចូលទិន្នន័យក្នុងគេហៈទំព័រអាជ្ញាធរអប្សរា | | ខ្ពស់ |





# ការផ្តួចផ្តើមចម្បង




កម្មវិធីការផ្តួចផ្តើមគោលនយោបាយនិងសកម្មភាពជាក់លាក់ដែលបានពិពណ៌នាពីចំណុចសំខាន់ៗខាងលើ ផ្តល់នូវវិធីសាស្រ្តគ្រប់គ្រងទេសចរណ៍នៅអង្គរទាំងមូល។ អនុសាសន៍ជាក់លាក់សំដៅលើការផ្លាស់ប្តូរជាមូលដ្ឋានដែលអាចកើតឡើង តាមរយៈការគាំទ្ររបស់រាជរដ្ឋាភិបាលនិងឧស្សាហកម្មទេសចរណ៍។ ការផ្តួចផ្តើមចម្បងខាងក្រោម មានភាពចាំបាច់ ចំពោះការគ្រប់គ្រងទេសចរណ៍តំបន់អង្គរនាពេលអនាគតដោយអាចផ្តល់បទពិសោធ វិជ្ជមានដល់ភ្ញៀវ កាត់បន្ថយផលប៉ះពាល់រមណីយដ្ឋាន បង្កើតភាពជាដៃគូជាមួយ

ឧស្សាហកម្មទេសចរណ៍ ផ្តល់ផលប្រយោជន៍ដល់ប្រជាជនក្នុងតំបន់ និងសម្រេចបានអភិបាលកិច្ចល្អ។

ទាំងនេះជាមូលដ្ឋានដោះស្រាយបញ្ហានានា។ ការយកចិត្តទុកដាក់អនុវត្តការផ្តួចផ្តើមទាំងនេះ មានភាពចាំបាច់ដើម្បីធ្វើឲ្យTMP ទទួលបានជោគជ័យ ហើយការគ្រប់គ្រងទេសចរណ៍នៅតំបន់អង្គរប្រកបដោយចីរភាព។ បញ្ហាទាំងអស់នេះមានភាពស្មុគ្រស្មាញ ហើយតម្រូវឲ្យមានការចូលរួមពីមន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាលនិងអ្នកពាក់ព័ន្ធចូលរួមស្វែងយល់ ក៏ដូចជាជំនាញដោះស្រាយបញ្ហានិងការផ្លាស់ប្តូរការអនុវត្តមួយចំនួន នាពេលបច្ចុប្បន្ន។

## ក. គ្រប់គ្រងប្រាសាទដោយរួមបញ្ចូលគ្រប់ផ្នែកពាក់ព័ន្ធ

មានបញ្ហានិងការប្រឈមជាច្រើន ទាក់ទងនឹងប្រតិបត្តិប្រចាំថ្ងៃនៅប្រាសាទសំខាន់ៗមួយចំនួន។ មានឱកាសកែលម្អការគ្រប់គ្រងនៅប្រាសាទទាំងនេះ តាមរយៈធនធានដែលមានស្រាប់ ដូច្នេះអាចមានវិធីសាស្ត្រដោះស្រាយដ៏ប្រសើរ អាស្រ័យលើកាលៈទេសៈនៅតាមប្រាសាទនៅពេលវេលាផ្សេងគ្នា។

គួរតែងតាំអ្នកគ្រប់គ្រងនៅតាមប្រាសាទសំខាន់ៗមួយចំនួនដែលមានភ្ញៀវទេសចរច្រើនដូចជាអង្គរវត្ត បាយ័ន តាព្រហ្ម ភ្នំបាខែង អង្គរធំ បេងមាលា និងបន្ទាយស្រី។ នៅពេលតែងតាំងអ្នកគ្រប់គ្រងទាំងនេះត្រូវតែមានសិទ្ធិក្នុងការធ្វើសេចក្តីសម្រេចចិត្តនិងដឹកនាំបុគ្គលិក។ អ្នកគ្រប់គ្រងប្រាសាទទាំងអស់ត្រូវទទួលបានការបណ្តុះបណ្តាលជាបន្តលើការគ្រប់គ្រងប្រាសាទនិងមានជំនួយពី "សៀវភៅណែនាំសម្រាប់អ្នកគ្រប់គ្រងរមណីយដ្ឋាន"។

បុគ្គលិកនៅតាមប្រាសាទទាំងអស់ គួរតែជាផ្នែកនៃក្រុមការងារដែលបានទទួលការបណ្តុះបណ្តាលយ៉ាងត្រឹមត្រូវ និងអាចរួមចំណែកក្នុងការគ្រប់គ្រងប្រាសាទតាមការចង់បាន (ឧទាហរណ៍ គ្រប់មន្ត្រីរដ្ឋាភិបាលទាំងអស់គួរតែទទួលខុសត្រូវក្នុងការណែនាំភ្ញៀវទេសចរ ឬធ្វើអន្តរាគមន៍ចំពោះអាកប្បកិរិយាមិនសមរម្យឬធ្វើឲ្យខូចខាតប្រាសាទ)។





## ខ. ការគ្រប់គ្រងលំហូរអ្នកទស្សនា

បច្ចុប្បន្ន មានព័ត៌មានតិចតួចណាស់ទាក់ទងនឹងកន្លែងដែលភ្ញៀវគួរទៅនិងអ្វីដែលពួកគេអាចធ្វើបាន។ ដោយចំនួនភ្ញៀវទេសចរកើនឡើងយ៉ាងលឿននិងជាលំដាប់ ធ្វើឲ្យវិធីសាស្ត្រនេះមិនមានចីរភាពនោះទេ។ ដូច្នេះ រាជរដ្ឋាភិបាលនិងឧស្សាហកម្មទេសចរណ៍ត្រូវទទួលស្គាល់តម្រូវការក្នុងការដាក់ចេញយន្តការគ្រប់គ្រងលំហូរអ្នកទស្សនា រួមទាំងសមត្ថភាពផ្ទុករបស់ប្រាសាទនីមួយៗ។ ឧទាហរណ៍ នៅពេលអនាគតប្រហែលជាភ្ញៀវទេសចរគ្រប់រូបមិនអាចទស្សនាប្រាសាទណាក៏បាននោះទេ។ ទោះបីយ៉ាងនេះក៏ដោយ យើងប្រហែលជាអាចមានឱកាសកែប្រែស្ថានភាពទាំងនេះតាមរយៈ ការកក់ទុក ចំពោះប្រាសាទខ្លះ ឬរៀបចំឡើងវង់ទស្សនាពិសេស នៅពេលដែលមានភ្ញៀវទេសចរច្រើនលើសលប់។ ត្រូវកំណត់និងគ្រប់គ្រងការធ្វើដំណើរនិងលំហូរអ្នកទស្សនាទាំងនៅក្នុងឧទ្យានអង្គរ និងនៅតាមប្រាសាទដែលមានភ្ញៀវទេសចរច្រើន។

បញ្ហានេះ មានសារៈសំខាន់និងបន្ទាន់ ហើយត្រូវការលើកយកមកដោះស្រាយតាមរយៈការសិក្សាសមត្ថភាពផ្ទុកក្នុងតំបន់អង្គរទាំងមូល និងនៅតាមប្រាសាទសំខាន់ៗដែលមានភ្ញៀវទេសចរច្រើន។ ការសិក្សាសមត្ថភាពផ្ទុក គួរតែមានការយកចិត្តទុកដាក់លើព័ត៌មានស្ដីពីលំហូរភ្ញៀវនិងបែបបទនៃការទស្សនាដែលមានស្រាប់។

## គ. ប្រព័ន្ធដឹកជញ្ជូន

ត្រូវមានប្រព័ន្ធដឹកជញ្ជូនដ៏សមស្របមួយ ដើម្បីឆ្លើយតបទៅនឹងការគ្រប់គ្រងលំហូរអ្នកទស្សនានៅតំបន់អង្គរឲ្យកាន់តែសកម្មឡើង។ ប្រព័ន្ធបែបនេះនឹងតម្រូវឲ្យមានការសង្កេតនិងវិភាគដោយប្រុងប្រយ័ត្ន។ ប្រព័ន្ធដឹកជញ្ជូនគួររៀបចំនិងអនុវត្តដោយមានការពិគ្រោះយោបល់ជាមួយឧស្សាហកម្មទេសចរណ៍ ហើយគួរតែមានពេលវេលាគ្រប់គ្រាន់ដែលអនុញ្ញាតឧស្សាហកម្មទេសចរណ៍អាចសម្របតាមការផ្លាស់ប្តូរនានាបាន។ ប្រព័ន្ធនេះត្រូវគិតបញ្ចូលទាំងការប្រើប្រាស់ផ្លូវសម្រាប់យានយន្តនិងផ្លូវមិនមានយានយន្ត មធ្យោបាយដឹកជញ្ជូន ទិសដៅលំហូរភ្ញៀវ និងសក្តានុពលក្នុងការហាមឃាត់មិនឲ្យភ្ញៀវទេសចរចូលទៅកន្លែងហាមឃាត់ និងចំនួនអ្នកទស្សនានៅតាមទីតាំងនិងពេលវេលាជាក់លាក់។

ការផ្លាស់ប្តូរមធ្យោបាយធ្វើដំណើរដែលមានស្រាប់ គឺជារឿងចាំបាច់ដើម្បីថែរក្សានិងការពារតំបន់បេតិកភណ្ឌពិភពលោកអង្គរ។ ចំនួនយានយន្តត្រូវកាត់បន្ថយ ហើយយានយន្តដែលអនុញ្ញាតឲ្យចូលក្នុងបរិវេណប្រាសាទត្រូវតែតម្រង់ទិសដោយប្រុងប្រយ័ត្ន។ គួរតែលើកទឹកចិត្តការដឹកជញ្ជូនតាមបែបប្រពៃណី (ដូចជា ជិះកង់ រ៉ឺម៉ក ឬរទេះគោ) និងពិចារណាលើវិធីសាស្ត្រថ្មីដូចជា រថយន្តសារធារណៈធុនតូច។ ការបើកសម្ពោធមជ្ឈមណ្ឌលស្វាគមន៍ថ្មីនៅពេលខាងមុខ នឹងផ្តល់នូវឱកាសមួយសម្រាប់គ្រប់គ្រងការដឹកជញ្ជូន ផ្លាស់ប្តូររថយន្តធុនធំនិងជំរុញមធ្យោបាយដឹកជញ្ជូនផ្សេងទៀត។

ទិសដៅរយៈពេលវែងសម្រាប់ប្រពន្ធ័ដឹកជញ្ជូន គឺបញ្ឈប់យានយន្តធុនធ្ងន់រួមមានរថយន្តនិងយានជំនិះធុនធំក្នុងបរិវេណអង្គរ។ ប៉ុន្តែសម្រាប់រយៈពេលខ្លី គឺបញ្ឈប់រថយន្តទាំងនេះនៅក្នុងបរិវេណអង្គរធំជាមុនសិន ឬក៏រៀបចំចរាចរណ៍នៅក្នុងអង្គរធំតាមទិសដៅតែមួយ។

គួរបង្កើតផ្លូវសម្រាប់កង់និងអ្នកថ្មើរជើងបន្ថែមទៀតនៅក្នុងឧទ្យានអង្គរ។

គួររៀបចំចំណតសម្រាប់យានជំនិះឡើងវិញផងដែរ។ រចនាសម្ព័ន្ធរូបវន្តបែបនេះគួរមានទីតាំងឆ្ងាយពីតំបន់ប្រាសាទ ដើម្បីកាត់បន្ថយការប៉ះពាល់និងផ្តល់ឱកាសក្នុងការគ្រប់គ្រងលំហូរអ្នកទស្សនានៅចន្លោះចំណតនិងប្រាសាទផ្ទាល់(ទីធ្លាខាងមុខប្រាសាទបន្ទាយស្រី ជាគំរូដែលបង្ហាញពីអ្វីដែលយើងធ្វើបានតាមរយៈផែនការរៀបចំចំណតដែលមានការពិចារណាច្បាស់លាស់)។

## ឃ. ការតម្រង់ទិសអ្នកទស្សនា

ការគ្រប់គ្រងលំហូរអ្នកទស្សនានិងបទពិសោធដែលទទួលបានពីការទស្សនា ជាស្នូលនៃការតម្រង់ទិស។ ការតម្រង់ទិសបែបនេះអាចបង្ហាញតាមរយៈការពន្យល់សង្ខេបពីអាកប្បកិរិយាសមរម្យរបស់ភ្ញៀវទេសចរ។

ព័ត៌មានមូលដ្ឋានរួមមានប្រវត្តិសាស្ត្រ និងគុណតម្លៃនៃតំបន់បេតិកភណ្ឌពិភពលោក និងជម្រើសសៀគ្វីទស្សនាទៅតាមប្រធានបទនានា។ ល្អបំផុត ព័ត៌មានមូលដ្ឋានគួរតែផ្តល់ជូននៅក្រៅរមណីយដ្ឋាន ដើម្បីកាត់បន្ថយការប៉ះពាល់លើតំបន់ប្រាសាទ។ ការពន្យល់ណែនាំដំបូងអាចធ្វើឡើងនៅមជ្ឈមណ្ឌលស្វាគមន៍ថ្មីនិង/ឬនៅតាមសណ្ឋាគារ ឬរថយន្តក្រុងទៅតាមស្តង់ដាការងារ។

ការបណ្តុះបណ្តាលមគ្គុទ្ទេសក៍ដែលមានស្រាប់និងមគ្គុទ្ទេសក៍ថ្មីស្តីពីការតម្រង់ទិសជារឿងសំខាន់បំផុត។

ព័ត៌មានមូលដ្ឋានគួររួមបញ្ចូលក្រមអ្នកទស្សនា ជាច្រើនភាសាដោយមានដាក់លេខរៀង។ គោលបំណងនៃការដាក់លេខរៀង គឺជួយឲ្យមគ្គុទ្ទេសក៍និងបុគ្គលិកតាមប្រាសាទឲ្យងាយស្រួលទាញចំណាប់អារម្មណ៍អ្នកទស្សនា។ គួរត្រូវរៀបចំក្រមទស្សនានេះ ដោយផ្អែកលើឯកសារ "បទបញ្ញាក្នុងការទស្សនា" ដែលមានស្រាប់។






## ង. បទពិសោធនិងសេវាកម្មសម្រាប់អ្នកទស្សនា

ឧទ្យានអង្គរត្រូវការនូវផែនការប្រកបដោយចក្ខុវិស័យ ដើម្បីរៀបចំហេដ្ឋារចនាសម្ព័ន្ធសេវាកម្មទេសចរណ៍ វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្តទៅតាមផែនការដែលមានការគិតយ៉ាងល្អប្រសើរ និងពោរពេញដោយការត្រិះរិះពិចារណា។ ត្រូវមានបន្ទប់ទឹកដែលមានគុណភាពខ្ពស់នៅក្បែរតំបន់ប្រាសាទ។ ប៉ុន្តែត្រូវស្ថិតនៅទីតាំងដែលមិនប៉ះពាល់ដល់បេតិកភណ្ឌឬបរិស្ថាន(ចំពោះប្រាសាទដែលមានភ្ញៀវទេសចរតិច ត្រូវពន្យល់សង្ខេបពីសម្ភារៈរូបវន្តដែលមានចំនួនកំណត់)។

ដូចគ្នានេះដែរ ត្រូវមានផែនការសម្រាប់តូបអាហារនិងភេសជ្ជៈ ដើម្បីផ្តល់ឱកាសដល់ប្រជាជនក្នុងតំបន់អាចលក់និងភ្ញៀវទេសចរអាចទិញទំនិញ។ ការសាងសង់បន្ទប់ទឹកត្រូវមានការត្រិះរិះពិចារណានិងធានាថាមិនប៉ះពាល់ដល់ប្រាសាទនិងបរិស្ថាន។



## ច. ការបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍

នៅអង្គរមានមគ្គុទ្ទេសក៍ល្អពោរពេញដោយចំណេះដឹង និងមានមគ្គុទ្ទេសក៍ដែលមានចំណេះដឹងមានកម្រិតមួយចំនួនផងដែរ។ កិត្តិសព្ទរបស់អង្គរនិងចំនួនអ្នកទស្សនាពេលបច្ចុប្បន្ន តម្រូវឲ្យមានការយកចិត្តទុកដាក់ជាបន្ទាន់ លើស្តង់ដាមគ្គុទ្ទេសក៍និងការសហការរវាងមគ្គុទ្ទេសក៍ ឧស្សាហកម្មទេសចរណ៍ និងរាជរដ្ឋាភិបាល ឲ្យយល់ស្របលើការបណ្តុះបណ្តាលមគ្គុទ្ទេសក៍ប្រកបដោយបទដ្ឋាននិងការវាយតម្លៃខ្ពស់។

ធាតុសំខាន់មួយនៅក្នុងការកែលម្អការបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍ គឺអាជ្ញាធរអប្សរាត្រូវបណ្តុះបណ្តាលមគ្គុទ្ទេសក៍ដែលមានស្រាប់ឡើងវិញ ដោយផ្តោតជាសំខាន់លើព័ត៌មានតម្រង់ទិសអ្នកទស្សនា ក្រមអ្នកទស្សនា និងព័ត៌មានថ្មីត្រឹមត្រូវអំពីប្រវត្តិសាស្ត្រនិងសារៈសំខាន់នៃតំបន់បេតិកភណ្ឌពិភពលោកអង្គរ។

## ឆ. សិប្បកម្មក្នុងតំបន់

ឱកាសមួយក្នុងចំណោមឱកាសច្រើន សម្រាប់ឲ្យប្រជាជនក្នុងតំបន់ទទួលផលប្រយោជន៍សេដ្ឋកិច្ចពីវិស័យទេសចរណ៍នៅអង្គរ គឺការផលិតផលនិងលក់ផលិតផលសិប្បកម្មក្នុងតំបន់។ ជាទូទៅ ភ្ញៀវទេសចរចាប់អារម្មណ៍និងពេញចិត្តទិញផលិតផលក្នុងតំបន់ជាងផលិតផលពីរោងចក្រ។ បញ្ហាប្រឈមក្នុងការផ្សារភ្ជាប់សិប្បករជាមួយភ្ញៀវទេសចរមានពីរគឺទី១ មានការលំបាកចំពោះអ្នកផលិតក្នុងការបង្ហាញផលិតផលរបស់ពួកគាត់ដល់ភ្ញៀវទេសចរ ជាងការលក់ដុំនិងវាយទៅឈ្មួញកណ្តាល និងទី២ មានការលំបាកសម្រាប់ភ្ញៀវទេសចរក្នុងការបែងចែករវាងផលិតផលសុទ្ធក្នុងតំបន់និងផលិតផលដទៃទៀត។

TMP មានគោលដៅផ្តល់ផលប្រយោជន៍ដល់ប្រជាជនក្នុងតំបន់ ដោយមានការសម្រួលដោយរដ្ឋាភិបាលនិងផ្នែកឧស្សាហកម្មទេសចរណ៍។

រដ្ឋាភិបាលអាចរៀបចំវិធានឬលើកទឹកចិត្តដោយចេញវិញ្ញាបនបត្រផលិតផល"សុទ្ធ" របស់ប្រជាជនក្នុងតំបន់។ រដ្ឋាភិបាលអាចបង្កើតកម្មវិធីបណ្តុះបណ្តាលឬរៀបចំឲ្យមាន

ឱកាសធ្វើពាណិជ្ជកម្មក្នុងតំបន់ ដូចដែលនាយកដ្ឋានរៀបចំដែនដីនិងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរកំពុងអនុវត្ត។ គួរបង្កើតផ្សារលក់ផលិតផលសិប្បកម្មក្នុងតំបន់នៅចំណុចកណ្តាលតំបន់អង្គរ ដែលជាកន្លែងសម្រាប់សិប្បករដែលមានលំនៅឋាននៅតំបន់អង្គរអាចធ្វើអាជីវកម្ម(ដោយគ្មានការបង់ប្រាក់) ហើយអ្នកទស្សនាអាចប្រាកដថាពួកគេកំពុងទិញសម្ភារៈសិប្បកម្មក្នុងតំបន់សុទ្ធដោយផ្ទាល់ពីអ្នកផលិត។ គួររៀបចំ "ផែនទីវប្បធម៌" ដើម្បីបង្ហាញពីទីតាំងផលិតសម្ភារៈសិប្បកម្មនៅក្នុងតំបន់អង្គរនាពេលបច្ចុប្បន្ន។ ការបណ្តុះបណ្តាលប្រជាជនក្នុងតំបន់អំពីការផលិតសម្ភារៈសិប្បកម្មប្រពៃណី និងការធ្វើអាជីវកម្មសិប្បកម្ម ជាតម្រូវការដែលត្រូវធ្វើជាបន្ត។ អាជ្ញាធរអប្សរាក៏អាចជួយទិញផលិតផលដែលបានផលិតនៅក្នុងតំបន់តាមដែលអាចធ្វើទៅបាន (ដូចជាអំបោស)។

ឧស្សាហកម្មទេសចរណ៍ ជាកន្លែងល្អបំផុតដើម្បីធានាថា ភ្ញៀវទេសចរពិតជាត្រូវបានផ្សារភ្ជាប់ជាមួយប្រជាជនក្នុងតំបន់និងមានឱកាសទិញអាហារនិងភេសជ្ជៈឬផលិតផលសិប្បកម្មក្នុងតំបន់។ ខណៈពេលដែលគំនិតផ្តួចផ្តើមទាំងនេះមានលក្ខណៈសាមញ្ញ និងកំពុងអនុវត្តរួចហើយក៏ដោយ ក៏គោលការណ៍នៅពីក្រោយគំនិតទាំងនេះត្រូវធានាពីសារៈសំខាន់ដែលប្រជាជនក្នុងតំបន់បានលក់ដូរផលិតផលដោយផ្ទាល់ទៅឲ្យភ្ញៀវទេសចរ។ ដំណោះស្រាយមួយទៀត គឺការចេញវិញ្ញាបនបត្រសម្រាប់ប្រតិបត្តិទេសចរណ៍ដែលបានប្តេជ្ញាថានឹងផ្តល់ឱកាសឲ្យភ្ញៀវទេសចរទិញផលិតផលសិប្បកម្មក្នុងតំបន់ ដោយផ្ទាល់ពីអ្នកផលិតយ៉ាងហោចណាស់បានម្តង ស្រដៀងគ្នានឹងការចេញវិញ្ញាបនបត្រផលិតផល "សីលធម៌ពាណិជ្ជកិច្ច"។

## ជ. ការលក់សំបុត្រ

ដំណើរការលក់សំបុត្រនៅអង្គរ មិនបានដើរស្របជាមួយនឹងកំណើនយ៉ាងលឿនរបស់ទីផ្សារទេសចរណ៍ទេ ហើយក៏មិនស្របនឹងបច្ចេកវិទ្យាដែលមាន ព្រមទាំងមិនស្របទៅនឹងការអនុវត្តល្អបំផុតនៅតំបន់បេតិកភណ្ឌពិភពលោកសំខាន់ៗដទៃទៀត។ មានបញ្ហាចំនួនបីគឺ ការកំណត់តម្លៃសំបុត្រ ការទិញសំបុត្រ និងរបៀបទិញសំបុត្រ។

តម្លៃសំបុត្រនៅអង្គរគឺនៅក្រោមកម្រិតទីផ្សារបើប្រៀបធៀបជាមួយតំបន់បេតិកភណ្ឌពិភពលោកជាច្រើនទៀត។ ជាការជៀសមិនរួចទេដែលតម្លៃសំបុត្រនឹងឡើងនៅពេលខាងមុខ ដែលនេះបង្ហាញពីឱកាសក្នុងការធ្វើឲ្យប្រាក់ចំណូលកើនឡើង និងឱកាសក្នុងការណែនាំប្រភេទសំបុត្រផ្សេងៗ ដែលផ្តល់នូវបទពិសោធក្នុងការទស្សនាផ្សេងគ្នា និងតម្លៃផ្សេងគ្នា។

ប្រភេទសំបុត្រនៅក្នុងតំបន់អង្គរនាពេលបច្ចុប្បន្នមិនបានឆ្លុះបញ្ចាំងពីតម្រូវការទីផ្សារ និងការកាត់បន្ថយផលប៉ះពាល់ ក៏ដូចជាគោលបំណងក្នុងការកែលម្អបទពិសោធអ្នកទស្សនាដែរ។ ការកំណត់តម្លៃសំបុត្រគឺជាឧបករណ៍ដែលមានសក្តានុពលមួយក្នុងការផ្លាស់ប្តូរអាកប្បកិរិយារបស់អ្នកទស្សនា។ ដោយផ្សារភ្ជាប់សំបុត្រជាមួយនឹងចំណែកទីផ្សារភ្ញៀវទេសចរអាចទទួលបានអត្ថប្រយោជន៍ពីការទិញសំបុត្រ ដែលឆ្លើយតបទៅនឹងតម្រូវផ្ទាល់របស់ពួកគេ។ ផលប៉ះពាល់ពីការកកស្ទះ អាចត្រូវបានកាត់បន្ថយតាមរយៈតម្លៃសំបុត្រខុសគ្នា ហើយប្រាក់ចំណូលពិតជាអាចកើនឡើងយ៉ាងពិតប្រាកដ។ (ឧទាហរណ៍ គួរពិចារណាលើការប្រើប្រាស់សំបុត្រទស្សនាមួយថ្ងៃដែលភ្ញៀវទេសចរគ្រាន់តែអាចទស្សនាតែប្រាសាទសំខាន់ណាមួយក្នុងចំណោមប្រាសាទសំខាន់បីគឺ អង្គរវត្ត បាយ័ន និងតាព្រហ្ម)។

បន្ថែមលើការយកចិត្តទុកដាក់លើកំណើនភ្ញៀវទេសចរអង្គរ រាជរដ្ឋាភិបាលនិងឧស្សាហកម្មទេសចរណ៍ គួរតែពិចារណាលើប្រាក់ចំណូល និងកម្រៃដែលបានទទួលពីភ្ញៀវម្នាក់ៗ។ ដោយពិចារណាលើលក្ខខណ្ឌប្រាក់ចំណូលនិងបទពិសោធអ្នកទស្សនាដែលមានសក្តានុពល ក្នុងការបង្កើនប្រាក់ចំណូល ធ្វើឲ្យបទពិសោធក្នុងការទស្សនាកាន់តែប្រសើរឡើង និងកាត់បន្ថយផលប៉ះពាល់នានា ដោយការណែនាំនូវការកំណត់តម្លៃតាមរដូវកាល។ ទន្ទឹមនឹងនេះ ក៏មានឱកាសផងដែរក្នុងការណែនាំបង្ហាញពីបទពិសោធ"ពិសេស" នៅអង្គរកម្រិតខ្ពស់នៅក្នុងទីផ្សារទេសចរណ៍តាមរយៈតម្លៃដ៏ថ្លៃ។ ឧទាហរណ៍ ការកក់ប្រាសាទណាមួយផ្តាច់មុខសម្រាប់ក្រុមណាមួយ ឬលទ្ធភាពក្នុងការកក់ដើម្បីចូលទស្សនាប្រាសាទដែលមានប្រជាប្រិយភាពណាមួយនៅពេលពិសេសណាមួយ។

មានការមិនពេញចិត្តច្រើនអំពីការទិញសំបុត្រនិងការពន្យាពេល ការឈរតម្រង់ជួរ និងការភ័ន្តច្រឡំនៅក្នុងទីធ្លាច្រកចូលមជ្ឈមណ្ឌលលក់សំបុត្រនៅពេលព្រឹកដែលមានភាពមមាញឹក។ អាចមានបច្ចេកវិទ្យាដែលអនុញ្ញាតឲ្យមានការទិញសំបុត្រតាមប្រព័ន្ធអ៊ីនធឺណិត ឬយ៉ាងហោចណាស់នៅតាមសណ្ឋាគារឬក៏នៅលើរថយន្តក្រុង។

ការផ្លាស់ប្តូរតម្លៃឬការលក់សំបុត្រនៅអង្គរ គួរតែប្រឹក្សាពិគ្រោះយោបល់ជាមួយឧស្សាហកម្មទេសចរណ៍ជាមុន ដើម្បីផ្តល់ពេលវេលាគ្រប់គ្រាន់ឲ្យឧស្សាហកម្មទេសចរណ៍អាចសម្របតាម។

## ឈ. ទំនាក់ទំនង និងការប្រាស្រ័យទាក់ទងជាមួយឧស្សាហកម្មទេសចរណ៍

វិស័យទេសចរណ៍នៅអង្គរ គឺជាភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងឧស្សាហកម្មទេសចរណ៍។ ឧស្សាហកម្មទេសចរណ៍បានបង្ហាញបំណងចូលរួមស្វែងយល់ជាមួយរាជរដ្ឋាភិបាល រៀនសូត្របន្ថែម ផ្តល់យោបល់ និងចាប់យកឱកាសក្នុងការវិនិយោគលើផលិតផលទេសចរណ៍ថ្មីៗនៅអង្គរ។ វិធីសាស្ត្រសហការ តម្រូវឲ្យរាជរដ្ឋាភិបាលមានឆន្ទៈ និងមានការប្រាស្រ័យទាក់ទងដ៏ប្រសើរសម្រាប់ភាពជាដៃគូប្រកបដោយប្រសិទ្ធភាព។

មានការផ្តួចផ្តើមសាមញ្ញតែមានប្រសិទ្ធភាព ដែលអាចត្រូវបានអនុវត្តយ៉ាងងាយស្រួលនិងឆាប់រហ័ស ដើម្បីបង្កើតទំនាក់ទំនងដ៏មានផ្លែផ្កា កែលម្អការផ្សព្វផ្សាយដល់បុគ្គលក្នុងឧស្សាហកម្មទេសចរណ៍នៅអង្គរ។

គួរកោះប្រជុំក្រុមពិគ្រោះយោបល់ឧស្សាហកម្មទេសចរណ៍ រួមមានតំណាងមកពីឧស្សាហកម្មទេសចរណ៍ និងស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធរៀងរាល់បីខែម្តង ដើម្បីរកឲ្យឃើញនិងពិភាក្សាអំពីការផ្តួចផ្តើមថ្មីៗលើបញ្ហានិងឱកាសនានា។

អាជ្ញាធរអប្សរា ក្រសួងទេសចរណ៍ និងសមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជាគួរតែចាត់ចែងឲ្យមានការប្រជុំសម្រួលទំនាក់ទំនងក្នុងតំបន់ឲ្យបានទៀងទាត់។

អាជ្ញាធរអប្សរាគួរតែចូលរួមយ៉ាងសកម្មក្នុងពិព័រណ៍ពាណិជ្ជកម្មឧស្សាហកម្មទេសចរណ៍ដែលជាប់ពាក់ព័ន្ធ ព្រមទាំងជំរុញផ្សព្វផ្សាយផងដែរ។

អាជ្ញាធរអប្សរាគួរតែងតាំងមន្ត្រីសម្រួលទំនាក់ទំនងឧស្សាហកម្មទេសចរណ៍០១រូបដែលអាចជាចំណុចចាប់ផ្តើមជួបប្រាស្រ័យទាក់ទង និងដោះស្រាយបញ្ហាសម្រាប់ឧស្សាហកម្មទេសចរណ៍។ មន្ត្រីនេះគួរតែមានលេខទូរស័ព្ទ "ខ្សែពិសេស" ដែលអ្នកទស្សនាឬប្រតិបត្តិករទេសចរណ៍អាចហៅនៅពេលដែលត្រូវការជំនួយ។

អាជ្ញាធរអប្សរាគួរតែអនុវត្តជាបន្ទាន់នូវការផ្ញើព្រឹត្តិបត្រព័ត៌មានអេឡិចត្រូនិចប្រចាំខែទៀងទាត់ ដើម្បីរក្សាការផ្តល់ព័ត៌មានទៅកាន់ឧស្សាហកម្មទេសចរណ៍។ បុគ្គលិកអាជ្ញាធរអប្សរាដែលពាក់ព័ន្ធនឹងត្រូវមានសិទ្ធិក្នុងការប្រមូល និងចែកចាយព័ត៌មានដែលពាក់ព័ន្ធ។

គួរធ្វើបច្ចុប្បន្នកម្មគេហៈទំព័រអាជ្ញាធរអប្សរា ដោយមានបុគ្គលិកអចិន្ត្រៃយ៍០១រូបជាអ្នកទទួលខុសត្រូវ។ គេហៈទំព័រនេះ គួរតែត្រូវបានតភ្ជាប់ទៅនឹងទំព័របណ្តាញដែលពាក់ព័ន្ធ ឲ្យច្រើនតាមដែលអាចធ្វើទៅបាន។ ធាតុសំខាន់ក្នុងទំព័របណ្តាញអ៊ីនធឺណិតនេះគួរតែធ្វើឡើងជាច្រើនភាសា។




## ៣. សៀមរាប ទន្លេសាប និងភ្នំគូលែន

តំបន់បេតិកភណ្ឌពិភពលោកអង្គរ គឺជាធាតុស្នូលដែលមានទិដ្ឋភាពវប្បធម៌ដ៏ធំទូលំទូលាយដោយក្តោបទាំងក្រុងសៀមរាប បឹងទន្លេសាប និងភ្នំគូលែន ហើយគ្រប់ផ្នែកពាក់ព័ន្ធទាំងអស់ ជាចំណែកនៃបណ្តុំរូបវន្តនិងវប្បធម៌សម្រាប់វិស័យទេសចរណ៍នៅអង្គរ។ ដូច្នេះ ចាំបាច់ត្រូវគិតគូរពីការគ្រប់គ្រងវិស័យទេសចរណ៍នៅអង្គរ និងបញ្ចូលនូវការអភិរក្សនិងវិស័យទេសចរណ៍នៅទីតាំងទាំងអស់នេះ។

បេតិកភណ្ឌវប្បធម៌ក្រុងសៀមរាប គួរតែជាផ្នែកមួយនៃបទពិសោធសម្រាប់ភ្ញៀវទេសចរ ដោយមានយុទ្ធសាស្ត្រគ្រប់គ្រងផ្សារភ្ជាប់យ៉ាងស្អិតរមួតជាមួយតំបន់អង្គរ និងតំបន់ទ្រនាប់។ ការគ្រប់គ្រងនេះគួរតែរួមបញ្ចូលទាំងការអភិរក្ស និងការបកស្រាយពីទម្រង់នានានៃវប្បធម៌ ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ការកែលម្អសម្ភារៈរូបវន្ត ដើម្បីធានាថាខេត្តសៀមរាបមិនរងការគំរាមកំហែងពីទឹកជំនន់ ផ្តល់សេវាកម្មទេសចរណ៍ដូចជាចំណតនិងបង្ហាញឱកាសទាក់ទាញដល់អ្នកទស្សនា។

ការបន្តកាប់បំផ្លាញព្រៃឈើនៅភ្នំគូលែន បានគំរាមកំហែងដល់រមណីយដ្ឋានអង្គរនិងក្រុងសៀមរាប ពីទឹកជំនន់ដែលអាចជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ការអភិរក្សនិងវិស័យទេសចរណ៍។ ដំណោះស្រាយបន្ទាន់ដើម្បីបញ្ឈប់ការកាប់បំផ្លាញព្រៃឈើ គឺការរៀបចំនិង

អនុវត្តផែនការយុទ្ធសាស្ត្រក្នុងការដាំដើមឈើឡើងវិញ ការការពាររមណីយដ្ឋានប្រវត្តិសាស្ត្រ និងការការពារបរិស្ថាន។





## ដ. ការត្រួតពិនិត្យវឌ្ឍនភាព ដោយ ICC-Angkor

ការអនុវត្តផែនការគ្រប់គ្រងទេសចរណ៍ គឺជាមូលដ្ឋានអភិរក្ស និងគ្រប់គ្រងតំបន់បេតិកភណ្ឌពិភពលោកអង្គរសម្រាប់រយៈពេលវែង។ ស្ថាប័នជំនាញឯករាជ្យដែលសមស្របក្នុងការត្រួតពិនិត្យវឌ្ឍនភាព អនុម័ត TMP គឺជាគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារនិងអភិរក្សរមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ(ICC-Angkor) ។ ជាការប្រសើរផងដែរ ដែល ICC-Angkor ធ្វើការជាមួយអាជ្ញាធរអប្សរាក្នុងការពិនិត្យឡើងវិញជាទៀងទាត់នូវរាល់ការអនុវត្តសកម្មភាព "អាទិភាព" របស់ TMP។

អាជ្ញាធរអប្សរាគួរផ្តល់នូវរបាយការណ៍ការអនុវត្តលម្អិត ស្តីពីវឌ្ឍនភាពTMP ទាំងមូល និងសមិទ្ធផលជាក់លាក់លើ "សកម្មភាពអាទិភាពនានា" ដែលរកឃើញសម្រាប់កិច្ចប្រជុំបច្ចេកទេសនៃ ICC-Angkor ។

អាជ្ញាធរអប្សរានិង ICC-Angkor គួរតែពិនិត្យនិងកំណត់សកម្មភាពអាទិភាពសម្រាប់ TMP ឡើងវិញ នៅចន្លោះពេលមិនតិចជាង៥ឆ្នាំម្តង។

# សកម្មភាពអាទិភាព




ការកែលម្អការគ្រប់គ្រងទេសចរណ៍នៅអង្គរ ជាដំណើរការរយៈពេលវែង ហើយ "ការផ្តួចផ្តើមចម្បង"មួយចំនួន នឹងត្រូវចំណាយពេលវេលាច្រើន។ ទោះជាយ៉ាងណាក៏ដោយ ក៏មានឱកាសក្នុងការកែលម្អភ្លាមៗនិងមានតម្រូវការក្នុងការចាប់ផ្តើមគម្រោងសំខាន់ៗមួយចំនួនដែលនឹងជះឥទ្ធិពលទៅលើការសម្រេចចិត្តដ៏ល្អសម្រាប់រយៈពេលយូរអង្វែង។ ខាងក្រោមជា "សកម្មភាពអាទិភាព" ដែលគួរត្រូវអនុវត្តឲ្យបានឆាប់តាមដែលអាចធ្វើបាន បន្ទាប់ពីរាជរដ្ឋាភិបាលឯកភាពនិងផ្តល់នូវធនធានចាំបាច់៖

## តែងតាំងបុគ្គលិកឲ្យទទួលខុសត្រូវក្នុងការអនុវត្តផែនការគ្រប់គ្រងទេសចរណ៍

១. អាជ្ញាធរអប្សរា ក្រសួងទេសចរណ៍ និងអាជ្ញាធរខេត្តសៀមរាប គួរតែផ្តល់អាទិភាពខ្ពស់ចំពោះការតែងតាំងបុគ្គលិកអនុវត្តTMPនេះ និងត្រូវធានាថា បុគ្គលិកទាំងនេះអាចលះបង់ពេលវេលា និងទទួលបានធនធានដែលចាំបាច់។

- អាជ្ញាធរអប្សរា គួរតែងតាំងមន្ត្រីជាន់ខ្ពស់០១រូប ឲ្យទទួលខុសត្រូវក្នុងការគ្រប់គ្រងវិស័យទេសចរណ៍នៅអង្គរ ដោយអនុលោមទៅតាមTMP។
- ក្រសួងទេសចរណ៍គួរតែងតាំងមន្ត្រី០១រូប ឲ្យទទួលខុសត្រូវការអនុវត្តTMP ដែលជាប់ទាក់ទងនឹងក្រសួងទេសចរណ៍។
- អភិបាលខេត្តសៀមរាប គួរតែងតាំងមន្ត្រី០១រូប ឲ្យទទួលខុសត្រូវក្នុងការអនុវត្ត TMP ដែលជាប់ទាក់ទងនឹងរដ្ឋបាលខេត្តសៀមរាប។

- បុគ្គលិកអាជ្ញាធរអប្សរាទូទាំងស្ថាប័ន ត្រូវមានតួនាទីនិងការទទួលខុសត្រូវជាក់លាក់ក្នុងការអនុវត្ត TMP។

## សិក្សាពីសមត្ថភាពផ្ទុកនៅតំបន់អង្គរ

២. អាជ្ញាធរអប្សរាគួរកំណត់វិធីសាស្ត្រ រៀបចំការងារលម្អិត និងសិក្សាពីសមត្ថភាពផ្ទុករបស់ប្រាសាទសំខាន់ៗមួយចំនួន ក្នុងតំបន់បេតិកភណ្ឌពិភពលោកអង្គរជាបន្ទាន់។ វិធីសាស្ត្រនិងផែនការការងារនេះ គួរតែផ្អែកលើព័ត៌មានស្តីអំពីការអនុវត្តដ៏ល្អបំផុតនៅតាមតំបន់បេតិកភណ្ឌពិភពលោកនានា និង "ផែនទីហានិភ័យ" ដែលជាផ្នែកមួយនៃ HMF។ យើងអាចស្វែងរកម្ចាស់ជំនួយអន្តរជាតិដែលសក្តិសម ដើម្បីជំរុញការសិក្សានេះ។

## អនុវត្តការគ្រប់គ្រងប្រាសាទដោយរួមបញ្ចូលគ្រប់ផ្នែកពាក់ព័ន្ធ

៣. ប្រតិបត្តិការមួយថ្ងៃៗនៃប្រាសាទសំខាន់ៗដែលមានភ្ញៀវទេសចរច្រើន (ដូចជា អង្គរវត្ត បាយ័ន តាព្រហ្ម ភ្នំបាខែង អង្គរធំ បេងមាលា និងបន្ទាយស្រី) គួរតែអនុវត្តការគ្រប់គ្រងដោយរួមបញ្ចូលគ្រប់ផ្នែកពាក់ព័ន្ធ ហើយអ្នកគ្រប់គ្រងប្រាសាទនីមួយៗគួរតែមានសិទ្ធិក្នុងការធ្វើការសម្រេចចិត្តនិងដឹកនាំបុគ្គលិកប្រចាំការនៅទីនោះ។ អ្នកគ្រប់គ្រងប្រាសាទ ត្រូវទទួលបានការបណ្តុះបណ្តាលលើការគ្រប់គ្រងរមណីយដ្ឋាន និងមានជំនួយពី "សៀវភៅណែនាំសម្រាប់អ្នកគ្រប់គ្រងរមណីយដ្ឋាន"។ បុគ្គលិកទាំងអស់នៅតាមប្រាសាទ គួរតែជាផ្នែកមួយនៃក្រុមគ្រប់គ្រង ដែលទទួលបានការបណ្តុះ

បណ្តាលសមស្រប និងអាចរួមចំណែកដល់ការគ្រប់គ្រងប្រាសាទតាមការចង់បាន។ គួរតែអនុវត្តប្រព័ន្ធនេះតាមដំណាក់កាល ដោយចាប់ផ្តើមពីបេងមាលានិងប្រាសាទណាមួយនៅក្នុងឧទ្យានអង្គរ។

## រៀបចំនិងអនុវត្តប្រព័ន្ធចាត់ថ្នាក់ប្រាសាទ

៤. គួររៀបចំ"ប្រព័ន្ធចាត់ថ្នាក់ប្រាសាទ" ដោយប្រើប្រាស់លទ្ធផលពី "ការសិក្សាសមត្ថភាពផ្ទុករបស់ប្រាសាទ" ការពិគ្រោះយោបល់និងសហការជាមួយឧស្សាហកម្មទេសចរណ៍និងអាជ្ញាធរអប្សរា។ ប្រព័ន្ធចាត់ថ្នាក់ប្រាសាទ គួរតែអាចជួយឲ្យរកឃើញចំណែកទីផ្សារទេសចរណ៍នៅតាមប្រាសាទផ្សេងៗគ្នា និងផ្តល់នូវបទពិសោធទាក់ទងនឹងចំណែកទីផ្សារទាំងនោះ។

## ចាប់ផ្តើមនូវប្រព័ន្ធដឹកជញ្ជូនថ្មី

៥. មុននឹងអនុវត្តប្រព័ន្ធដឹកជញ្ជូនថ្មីដែលសមស្របសម្រាប់តំបន់អង្គរ អាជ្ញាធរអប្សរាគួរតែទទួលខុសត្រូវរៀបចំឯកសារចាំបាច់ ស្រាវជ្រាវ និងវិភាគ ដើម្បីរៀបចំប្រព័ន្ធដឹកជញ្ជូនសម្រាប់ឧទ្យានអង្គរ ក្រុងសៀមរាបនិងតំបន់ជុំវិញ ។ ការសិក្សានេះត្រូវតែមានការចូលរួមគាំទ្រពីអន្តរជាតិ និងចាត់ទុកជាការអនុវត្តដ៏ប្រសើរបំផុតនៅក្នុងតំបន់បេតិកភណ្ឌពិភពលោក។ ប្រព័ន្ធថ្មីនេះគួរតែឆ្លើយតបនឹងបញ្ហាយានជំនិះ និងផ្លូវដែលគ្មានយានយន្ត មធ្យោបាយដឹកជញ្ជូន ទិសដៅលំហូរយានជំនិះ និងទីតាំងសក្តានុពលដែលត្រូវហាមឃាត់។ ប្រព័ន្ធនេះគួរតែឆ្លើយតបទៅនឹងការកាត់បន្ថយការប្រើប្រាស់រថយន្តធំ និងផ្តោតលើការដឹកជញ្ជូនធនតូចនិងតាមបែបប្រពៃណី។

## រៀបចំផែនការសេវាកម្មទេសចរណ៍

៦. អាជ្ញាធរអប្សរា គួរតែរៀបចំផែនការនិងហេដ្ឋារចនាសម្ព័ន្ធ សម្រាប់បម្រើឲ្យសេវាកម្មទេសចរណ៍ ដោយផ្តោតជាពិសេសទៅលើចំណតរថយន្ត បន្ទប់ទឹក និងកន្លែងលក់ម្ហូបអាហារនិងភេសជ្ជៈ។






## រៀបចំផែនការសេវាកម្មទេសចរណ៍

៦. អាជ្ញាធរអប្សរា គួរតែរៀបចំផែនការនិងហេដ្ឋារចនាសម្ព័ន្ធ សម្រាប់បម្រើឲ្យសេវាកម្មទេសចរណ៍ ដោយផ្តោតជាពិសេសទៅលើចំណតរថយន្ត បន្ទប់ទឹក និងកន្លែងលក់ម្ហូបអាហារនិងភេសជ្ជៈ។

## បណ្តុះបណ្តាល មគ្គុទ្ទេសក៍ទេសចរណ៍ឡើងវិញ

៧. អាជ្ញាធរអប្សរា គួរអនុវត្តកម្មវិធីបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍ឡើងវិញ កែលម្អនិងពង្រឹងកម្មវិធីបណ្តុះបណ្តាលដោយបញ្ចូលព័ត៌មានគន្លឹះ និងតម្រង់ទិសអ្នកទស្សនារួមមានក្រុមអ្នកទស្សនា និងការរកឃើញថ្មីៗស្តីពីប្រវត្តិសាស្ត្រនិងគុណតម្លៃនៃតំបន់បេតិកភណ្ឌពិភពលោកអង្គរ។ ការបណ្តុះបណ្តាលនេះគួរតែត្រូវផ្អែកលើវិធីសាស្ត្រសហការរវាងសមាគមមគ្គុទ្ទេសក៍ ឧស្សាហកម្មទេសចរណ៍ និងរាជ រដ្ឋាភិបាល។

## ការរៀបចំក្រុមអ្នកទស្សនា

៨. គួររៀបចំក្រមប្រតិបត្តិ សម្រាប់អ្នកមកទស្សនា មគ្គុទ្ទេសក៍ និងប្រតិបត្តិករនៅអង្គរ ដោយផ្តល់អាទិភាពដល់ការរៀបចំក្រុមអ្នកទស្សនា។ ក្រមនេះត្រូវធ្វើជាច្រើនភាសា មានលក្ខណៈច្នៃប្រឌិតដើម្បីងាយស្រួលក្នុងការប្រាស្រ័យទាក់ទងនិងចែកចាយឲ្យបានទូលំទូលាយទៅកាន់វិស័យទេសចរណ៍នៅអង្គរ។

## អនុវត្តការផ្តួចផ្តើមពិគ្រោះយោបល់និងប្រាស្រ័យទាក់ទងជាមួយឧស្សាហកម្មទេសចរណ៍

៩. ដើម្បីសម្រេចភាពជាដៃគូរវាងក្រុមហ៊ុនឯកជននិងរដ្ឋាភិបាលប្រកបដោយជោគជ័យ គួរតែកោះប្រជុំក្រុមពិគ្រោះយោបល់ឧស្សាហកម្មទេសចរណ៍រៀងរាល់បីខែម្តង ដោយ

មានការចូលរួមពីតំណាងមកពីគ្រប់ឧស្សាហកម្មទេសចរណ៍ និងស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធទាំងអស់ ដើម្បីពិភាក្សារកឲ្យឃើញការផ្តួចផ្តើមថ្មីៗ បញ្ហានិងឱកាសនានា។ សមាជិកដែលចូលរួមក្នុងក្រុមពិគ្រោះយោបល់ ត្រូវតែផ្តល់ព័ត៌មានត្រឡប់ទៅសហការីរបស់ខ្លួន និងផ្សារភ្ជាប់ទំនាក់ទំនងជាមួយរដ្ឋាភិបាល។

១០. អាជ្ញាធរអប្សរា ក្រសួងទេសចរណ៍ និងសមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា(CATA) សមាគមដឹកជញ្ជូន សមាគមមគ្គុទ្ទេសក៍ និងទីភ្នាក់ងារទេសចរណ៍នៅអង្គរ គួរតែរៀបចំការប្រជុំសម្រួលទំនាក់ទំនងក្នុងតំបន់ឲ្យបានទៀងទាត់។

១១. អាជ្ញាធរអប្សរាគួរតែងតាំងមន្ត្រីសម្រួលទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍ម្នាក់ (ឬមន្ត្រីច្រើននាក់) ដែលជាមនុស្សចម្បងសម្រាប់ទំនាក់ទំនង និងដោះស្រាយបញ្ហាមួយចំនួនសម្រាប់ឧស្សាហកម្មទេសចរណ៍។

១២. មន្ត្រីសម្រួលទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍របស់អាជ្ញាធរអប្សរា គួរតែមានលេខទូរស័ព្ទ "ខ្សែពិសេស" ជាមធ្យោបាយសម្រួលការងារ នៅពេលដែលអ្នកទស្សនាឬប្រតិបត្តិករក្នុងវិស័យទេសចរណ៍ត្រូវការជំនួយ។





## ដាក់បញ្ចូលព័ត៌មានថ្មីៗក្នុងគេហ:ទំព័រអាជ្ញាធរអប្សរា

១៣. បញ្ចូលព័ត៌មានថ្មីៗទៅក្នុងគេហ:ទំព័រអាជ្ញាធរអប្សរា និងតែងតាំងអ្នកបញ្ចូលទិន្នន័យក្នុងបណ្តាញអ៊ីនធឺណិតម្នាក់ ដោយបុគ្គលិកម្នាក់នោះមានសិទ្ធិបញ្ចូលព័ត៌មានថ្មីៗជាបន្តបន្ទាប់ក្នុងទំព័របណ្តាញអ៊ីនធឺណិត។ អ្នកបញ្ចូលទិន្នន័យគួរជាអ្នកផ្ញើព្រឹត្តិបត្រព័ត៌មានអេឡិចត្រូនិចជារៀងរាល់ខែទៀងទាត់ទៅឧស្សាហកម្មទេសចរណ៍ ដើម្បីឲ្យពួកគាត់ទទួលបានព័ត៌មានទាន់ពេលវេលា។ អ្នកបញ្ចូលទិន្នន័យក្នុងអ៊ីនធឺណិត គួរតែ

មានសិទ្ធិក្នុងការប្រមូលព័ត៌មានពីទីកន្លែងផ្សេងៗ និងចែកចាយព័ត៌មានដែលពាក់ព័ន្ធ។

## គាំទ្រការចេញវិញ្ញាបនបត្រ សម្ភារៈសិប្បកម្មសុទ្ធក្នុងតំបន់និងការលក់ដូរ

១៤. រដ្ឋាភិបាលគួរតែមានផែនការបម្រុងទុកជាមុន ក្នុងការផ្តួចផ្តើម ដើម្បីសម្រួលដល់ការផលិតនិងលក់សម្ភារៈសិប្បកម្មរបស់ប្រជាជនក្នុងតំបន់ដោយផ្ទាល់ទៅឲ្យភ្ញៀវទេសចរនៅអង្គរ។ អាជ្ញាធរអប្សរា ក្រសួងទេសចរណ៍ នាយកដ្ឋានសិប្បកម្មនៅក្រសួងឧស្សាហកម្មរ៉ែនិងថាមពល និងស្ថាប័នរដ្ឋាភិបាលផ្សេងទៀត គួរគាំទ្រយ៉ាងសកម្មចំពោះដំណើរការនេះ តាមរយៈការចេញវិញ្ញាបនបត្រសមាគមសិប្បកម្មអង្គរ និងតាមរយៈការបណ្តុះបណ្តាលសិប្បកម្មក្នុងតំបន់ជាបន្តបន្ទាប់។

១៥. អាជ្ញាធរអប្សរា គួរតែបង្កើត "ផ្សារសម្រាប់លក់សម្ភារៈសិប្បកម្មក្នុងតំបន់" នៅទីតាំងកណ្តាលតំបន់អង្គរ ដែលប្រជាជនក្នុងតំបន់អាចចូលទៅលក់ផលិតផលសុទ្ធឥតក្លែងក្លាយដល់ភ្ញៀវទេសចរ។ គួរពិចារណាលើការកំណត់ "តម្លៃជាក់លាក់" របស់ផលិតផលក្នុងផ្សារនេះ។

## អភិរក្សនិងបង្ហាញពីបេតិកភណ្ឌក្រុងសៀមរាប

១៦. អាជ្ញាធរអប្សរានិងអាជ្ញាធរខេត្តសៀមរាប គួរតែសហការគ្នាដើម្បីអភិរក្សនិងផ្សព្វផ្សាយពីបេតិកភណ្ឌក្រុងសៀមរាប ដែលជាផ្នែកមួយនៃបទពិសោធអ្នកទស្សនានៅតំបន់អង្គរ។ ការគ្រប់គ្រងនេះគួរតែរួមបញ្ចូលទាំងការអភិរក្ស និងការបកស្រាយទម្រង់នៃវប្បធម៌នានា ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងការកែលម្អសម្ភារៈរូបវន្តដើម្បីធានាថាសៀមរាបមិនរងការគំរាមកំហែងពីទឹកជំនន់ ផ្តល់សេវាកម្មទេសចរណ៍ដែលមានសារៈសំខាន់ដូចជាចំណត និងបង្ហាញពីឱកាសកម្សាន្តសម្រាប់ភ្ញៀវទេសចរ។

## រៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ភ្នំគូលែន

១៧. ដោយទទួលស្គាល់ពីទំនាក់ទំនងរវាងភ្នំគូលែននិងប្រាសាទអង្គរ រាជរដ្ឋាភិបាលកម្ពុជាគួរតែរៀបចំនិងអនុវត្តផែនការយុទ្ធសាស្ត្រក្នុងការបញ្ឈប់ការកាប់បំផ្លាញព្រៃឈើ បង្កើតឲ្យមានការដាំដើមឈើឡើងវិញ ការពាររមណីយដ្ឋានប្រវត្តិសាស្ត្រនិងការពារបរិស្ថានភ្នំគូលែន។





# ផែនការអនុវត្ត

សម្រាប់សកម្មភាពអាទិភាពនីមួយៗ មាន"ផែនការអនុវត្ត" នៅទំព័របន្ទាប់ ដែលមានដំណើរការច្បាស់លាស់និងភារកិច្ចនានាដែលត្រូវចាប់ផ្តើមអនុវត្ត។

ផែនការអនុវត្តន៍ទាំង១៧ បានទទួលការឯកភាពនៅក្នុងសិក្ខាសាលាការអនុវត្តពិសេសមួយដែលមានការចូលរួមពីអាជ្ញាធរអប្សរា ក្រសួងទេសចរណ៍ និងអង្គការយូណេស្កូ នៅអាជ្ញាធរអប្សរា ក្នុងខេត្តសៀមរាប នាខែធ្នូ ឆ្នាំ២០១២។

## ការតែងតាំងមន្ត្រីទទួលខុសត្រូវ

**សកម្មភាពអាទិភាព ១**

### សេចក្តីសង្ខេប

អាជ្ញាធរអប្សរា ក្រសួងទេសចរណ៍ និងរដ្ឋបាលខេត្តសៀមរាប គួរផ្តល់អាទិភាពតែងតាំងបុគ្គលិកអនុវត្តផែនការគ្រប់គ្រងទេសចរណ៍ឲ្យបានឆាប់រហ័ស និងធានាថាបុគ្គលិកទាំងនេះអាចលះបង់ពេលវេលានិងទទួលបានធនធានចាំបាច់។

### គោលបំណង

- ធានាសម្រេចបាននូវរាល់តម្រូវការក្នុងការអនុវត្តផែនការគ្រប់គ្រងទេសចរណ៍
- សម្រួលដល់ការប្រគល់ភារកិច្ចសម្រាប់អនុវត្តផែនការគ្រប់គ្រងទេសចរណ៍
- ធានាថាការអនុវត្តផែនការគ្រប់គ្រងទេសចរណ៍ស្របទៅតាមពេលវេលាដែលរាជរដ្ឋាភិបាលកម្ពុជាបានកំណត់
- កំណត់តួនាទី និងការទទួលខុសត្រូវនៅក្នុងរចនាសម្ព័ន្ធស្ថាប័នរដ្ឋាភិបាល ក្នុងការអនុវត្តផែនការគ្រប់គ្រងទេសចរណ៍ឲ្យបានច្បាស់លាស់
- ជួយសម្រួលដល់ការផ្សារភ្ជាប់អន្តរស្ថាប័នរបស់រាជរដ្ឋាភិបាល និងកម្មវិធីសមាហរណកម្មដើម្បីធ្វើឲ្យការអនុវត្តផែនការគ្រប់គ្រងទេសចរណ៍បានល្អប្រសើរ។

### ការផ្សារភ្ជាប់ទៅនឹងការផ្តួចផ្តើមចម្បង

ការអនុវត្តសកម្មភាពអាទិភាព១ ជាការចាប់ផ្តើមការផ្តួចផ្តើមចម្បងចំនុច **៨** ទំព័រទី គឺការត្រួតពិនិត្យដំណើរការវិវត្តនៃការអនុវត្តផែនការគ្រប់គ្រងទេសចរណ៍

| ដំណោះស្រាយ<br>គ្មាន | | | |
|---|---|---|---|
| **ភារកិច្ច** | **រយៈពេល** | **ទំនួលខុសត្រូវ** | **ធនធានស្នើឡើង** |
| ១- តែងតាំងមន្ត្រី០១រូបមកពីអាជ្ញាធរអប្សរា ដើម្បីទទួលខុសត្រូវគ្រប់គ្រងការអនុវត្តផែនការគ្រប់គ្រងទេសចរណ៍ | | អគ្គនាយកអាជ្ញាធរអប្សរា | បុគ្គលិកពេញម៉ោង |
| ២- តែងតាំងមន្ត្រី០១រូបមកពីក្រសួងទេសចរណ៍ដែលទទួលខុសត្រូវអនុវត្តផែនការគ្រប់គ្រងទេសចរណ៍ដែលជាប់ទាក់ទងនឹងក្រសួងទេសចរណ៍ | | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | បុគ្គលិកពេញម៉ោង |
| ៣- តែងតាំងមន្ត្រី០១រូបមកពីអាជ្ញាធរខេត្តសៀមរាបដែលទទួលខុសត្រូវក្នុងការអនុវត្តផែនការគ្រប់គ្រងទេសចរណ៍ដែលជាប់ពាក់ព័ន្ធនឹងរដ្ឋបាលខេត្តសៀមរាប | | អភិបាលខេត្ត | បុគ្គលិកក្រៅម៉ោង |
| ៤- តែងតាំងបុគ្គលិកនៅក្នុងអាជ្ញាធរអប្សរាដោយកំណត់តួនាទីនិងការទទួលខុសត្រូវជាក់លាក់ក្នុងការអនុវត្តផែនការគ្រប់គ្រងទេសចរណ៍ | | អគ្គនាយកអាជ្ញាធរអប្សរា | ~ ២០ម៉ោង |
| ៥- កំណត់ឲ្យបានច្បាស់ពីបែបបទដែលមន្ត្រី បុគ្គលិកដែលមានតួនាទីច្បាស់លាស់ខាងលើ ទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយមន្ត្រីអាជ្ញាធរអប្សរាដែលទទួលខុសត្រូវក្នុងការគ្រប់គ្រង | | អគ្គនាយកអាជ្ញាធរអប្សរា | ~ ២០ម៉ោង |

<table>
<tr><td>ការអនុវត្តផែនការគ្រប់គ្រងទេសចរណ៍</td><td></td><td></td><td></td></tr>
<tr><td>៦- បង្កើតឲ្យមានយន្តការសហការបន្ថែមទៀតរវាងនាយកដ្ឋានជំនាញក្នុងអគ្គនាយកដ្ឋានអាជ្ញាធរអប្សរាដែលកំពុងធ្វើការនៅក្នុងតំបន់អង្គរ ដើម្បីអនុវត្តសកម្មភាពអាទិភាពរបស់TMP ដូចជាការជួបប្រជុំជាទៀងទាត់រវាងនាយកដ្ឋានជំនាញស្ដីពីការបន្តអនុវត្តTMP</td><td></td><td>អគ្គនាយកអាជ្ញាធរអប្សរា</td><td>~ ២០ម៉ោង</td></tr>
<tr><td>៧- បង្កើតយន្តការសហការមួយរវាងអាជ្ញាធរអប្សរាជាមួយនឹងស្ថាប័នរដ្ឋាភិបាលផ្សេងទៀតដែលជាប់ទាក់ទងនឹងការអនុវត្តTMPដូចជាការជួបប្រជុំជាទៀងទាត់មួយរវាងស្ថាប័នទាំងនេះ។</td><td></td><td>អគ្គនាយកអាជ្ញាធរអប្សរា និងស្ថាប័នរដ្ឋាភិបាលផ្សេងៗ</td><td>~ ២០ម៉ោង</td></tr>
<tr><td>បុគ្គលិកអាជ្ញាធរអប្សរា</td><td colspan="3">បុគ្គលិកផ្សេងទៀត</td></tr>
<tr><td>- មន្ត្រីអាជ្ញាធរអប្សរាទទួលខុសត្រូវក្នុងការអនុវត្តTMP<br>- អគ្គនាយកអាជ្ញាធរអប្សរា<br>- បុគ្គលិកអាជ្ញាធរអប្សរាដែលមានភារកិច្ច តួនាទីនិងការទទួលខុសត្រូវច្បាស់លាស់</td><td colspan="3">- ក្រសួងទេសចរណ៍<br>- អាជ្ញាធរខេត្តសៀមរាប</td></tr>
<tr><td>តម្រូវការបណ្ដុះបណ្ដាល</td><td colspan="3">កំណត់ចំណាំ</td></tr>
<tr><td>គ្មាន</td><td colspan="3">គ្មាន</td></tr>
</table>

**ការសិក្សាសមត្ថភាពផ្ទុក** | **សកម្មភាពអាទិភាព ២**

**សេចក្តីសង្ខេប**

អាជ្ញាធរអប្សរាគួរកំណត់នូវវិធីសាស្ត្ររៀបចំផែនការការងារលម្អិត និងរៀបចំគណៈកម្មការ «សិក្សាសមត្ថភាពផ្ទុក» សម្រាប់តំបន់បេតិកភណ្ឌវប្បធម៌ពិភពលោកអង្គរ និងប្រាសាទសំខាន់ផ្សេងទៀតឲ្យបានជាបន្ទាន់។ វិធីសាស្ត្រនិងផែនការការងារនេះ គួរតែផ្អែកលើព័ត៌មានស្តីពីការអនុវត្តល្អបំផុតនៅតំបន់បេតិកភណ្ឌពិភពលោកដទៃទៀត និង"ផែនទីហានិភ័យ" ដែលជាផ្នែកមួយនៃគម្រោងHMF។ អាជ្ញាធរអប្សរាអាចស្នើសុំមូលនិធិសម្រាប់ការសិក្សាពីម្ចាស់ជំនួយអន្តរជាតិដែលសមស្របណាមួយ។



**គោលបំណង**

- ជំរុញការអភិវឌ្ឍន៍ទេសចរណ៍ប្រកបដោយចីរភាពតាមរយៈការយល់ដឹងពីកត្តាទាំងឡាយដែលនាំឲ្យវិស័យទេសចរណ៍លូតលាស់ ដោយរួមបញ្ចូលទាំងចំនួនភ្ញៀវទេសចរដែលសមស្រប
- អនុវត្តនូវវិធីសាស្ត្រប្រតិបត្តិដែលល្អបំផុត ដើម្បីយល់ដឹងនិងកំណត់កត្តាវាស់វែងសម្រាប់កំណត់សមត្ថភាពផ្ទុករបស់ប្រាសាទឬរមណីយដ្ឋាន
- យល់ដឹងពីកត្តាវាស់វែងសម្រាប់បន្តត្រួតពិនិត្យប្រាសាទនៅក្នុងរមណីយដ្ឋានអង្គរ
- យល់ដឹងពីសមត្ថភាពផ្ទុករបស់រមណីយដ្ឋាន ក៏ដូចជាសមត្ថភាពផ្ទុករបស់ប្រាសាទនីមួយៗ
- យល់ដឹងពីសមត្ថភាពផ្ទុករបស់ប្រាសាទ ដើម្បីផ្តល់ព័ត៌មានពីការរៀបចំប្រព័ន្ធចាត់ថ្នាក់ប្រាសាទ វង់ទស្សនា និងចាត់ចែងប្រភពធនធានក្នុងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ

**ការផ្សារភ្ជាប់ទៅនឹងការផ្តួចផ្តើមចម្បង**

ការអនុវត្តសកម្មភាពអាទិភាព២ នឹងរួមចំណែកក្នុងការផ្តួចផ្តើមចម្បងចំនុច **ខ** ទំព័រទី១៣ គឺការគ្រប់គ្រងលំហូរអ្នកទស្សនា

**ដំណោះស្រាយ**

កិច្ចប្រជុំការងារផែនការគ្រប់គ្រងទេសចរណ៍នៅថ្ងៃទី១៨-១៩ ខែកញ្ញា ឆ្នាំ២០១២ រវាងអាជ្ញាធរអប្សរា ក្រសួងទេសចរណ៍ អង្គការយូណេស្កូ អ្នកពិគ្រោះយោបល់ Godden Mackay Logan(GML) និងអ្នកតំណាងមកពីវិស័យឯកជនបានអនុម័តនូវដំណោះស្រាយដូចខាងក្រោម៖

- គណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារនិងអភិវឌ្ឍរមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ(ICC-Angkor) គួរផ្តល់អនុសាសន៍ស្តីពីការសិក្សាពីសមត្ថភាពផ្ទុក
- ការសិក្សាពីសមត្ថភាពផ្ទុក គួរត្រូវបានធ្វើឡើងមុនការចាត់ថ្នាក់ប្រាសាទនិងរៀបចំវង់ទស្សនាតាមប្រាសាទ

| ភារកិច្ច | រយៈពេល | ទំនួលខុសត្រូវ | ធនធានស្នើឡើង |
|---|---|---|---|
| ១- តែងតាំងអ្នកទំនាក់ទំនងរបស់អាជ្ញាធរអប្សរា | | អាជ្ញាធរអប្សរា | |
| ២- បង្ហាញអនុសាសន៍ដល់ការប្រជុំគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារនិងអភិវឌ្ឍរមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ | | អាជ្ញាធរអប្សរា | |
| ៣- រៀបចំគម្រោងសិក្សាសមត្ថភាពផ្ទុកដោយប្រើវិធីសាស្ត្រ "LAC: Limit of Acceptable Change: ការផ្លាស់ប្តូរដែលអាចទទួលយកបាន" | | អាជ្ញាធរអប្សរា និងជំនួយខាងក្រៅ និង/ឬ GML | ~ ៦០ម៉ោង |
| ៤- អនុម័តក្របខ័ណ្ឌគម្រោង | | អាជ្ញាធរអប្សរា | |

| | | | |
|---|---|---|---|
| ៥- បង្ហាញក្របខ័ណ្ឌគម្រោងដល់កិច្ចប្រជុំគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារនិងអភិវឌ្ឍរមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ | | អាជ្ញាធរអប្សរា | |
| ៦- តែងតាំងមន្ត្រីគម្រោងរបស់អាជ្ញាធរអប្សរា | | អាជ្ញាធរអប្សរា | បុគ្គលិក២ឆ្នាំ |
| ៧- ស្នើសុំម្ចាស់ជំនួយដែលមានសក្តានុពល | | អាជ្ញាធរអប្សរា/ អង្គការយូណេស្កូ | ~៥០ម៉ោង |
| ៨- អំពាវនាវរកដៃគូដែលចាប់អារម្មណ៍ | | អង្គការយូណេស្កូ | ~៥០ម៉ោង |
| ៩- ស្នើសុំឲ្យធ្វើការងារវាយតម្លៃសមត្ថភាពផ្ទុក(សិក្សានិងដំណាក់កាលរៀបចំប្រព័ន្ធចាត់ថ្នាក់ប្រាសាទ) | | អាជ្ញាធរអប្សរា/ អង្គការយូណេស្កូ | |
| ១០- ចូលរួមក្នុងដំណាក់កាលសិក្សាវាយតម្លៃសមត្ថភាពផ្ទុក | | អាជ្ញាធរអប្សរា/ ជំនួយខាងក្រៅ | ~២០០០០០ដុល្លារ/ ~១៥០ម៉ោង |
| ១១- ទទួលរបាយការណ៍សមត្ថភាពផ្ទុកដែលចេញពីលទ្ធផលនៃការសិក្សា | | អាជ្ញាធរអប្សរា/ អង្គការយូណេស្កូ | TBD(នឹងត្រូវប្រកាស) |
| ១២- អនុវត្តលទ្ធផលនៃការសិក្សាសមត្ថភាពផ្ទុក និងដាក់ចេញនូវការត្រួតពិនិត្យជាបន្តដោយផ្អែកលើដែនកំណត់សមត្ថភាពផ្ទុក | | អាជ្ញាធរអប្សរា | TBD(នឹងត្រូវប្រកាស) |
| ១៣- ចាប់ផ្តើមរៀបចំប្រព័ន្ធចាត់ថ្នាក់ប្រាសាទដោយផ្អែកលើលទ្ធផលស្តីពីសមត្ថភាពផ្ទុក។ | | អាជ្ញាធរអប្សរា/ ជំនួយខាងក្រៅ | |

| បុគ្គលិកអាជ្ញាធរអប្សរា | បុគ្គលិកផ្សេងទៀត |
| --- | --- |
| - មន្ត្រីអាជ្ញាធរអប្សរាទទួលខុសត្រូវក្នុងការអនុវត្តTMP<br><br>- គណៈកម្មាធិការបច្ចេកទេស(ក្រុមគម្រោង៣នាក់)<br>- ICC-Angkor និងអ្នកជំនាញចំពោះកិច្ច ដើម្បីសុំយោបល់<br>- អគ្គនាយកអាជ្ញាធរអប្សរា<br>- នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ<br>- នាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្ការ<br>- នាយកដ្ឋានរៀបចំដែនដីនិងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរ | អ្នកជំនាញចំពោះកិច្ច<br>អ្នកជំនាញប្រឹក្សាយោបល់ខាងក្រៅ<br>ម្ចាស់ជំនួយ |
| **តម្រូវការបណ្តុះបណ្តាល** | **កំណត់ចំណាំ** |
| - គណៈកម្មាធិការបច្ចេកទេសស្តីពីវិធីសាស្ត្រ LAC<br>- សិក្ខាសាលានៅក្នុងអាជ្ញាធរអប្សរា<br>- សិក្ខាសាលានៅក្នុងអាជ្ញាធរអប្សរានាពេលបន្ទាប់ | ស្នើសុំយោបល់ពីវិទ្យាស្ថានអភិរក្សហ្គេធី(Getty Conservation Institute) អំពីក្របខ័ណ្ឌគម្រោង ថវិកា និងសក្តានុពលចូលរួមជាអ្នកជំនាញ ពិគ្រោះយោបល់និងម្ចាស់ជំនួយ |

| ការគ្រប់គ្រងប្រាសាទដោយរួមបញ្ចូលគ្រប់ផ្នែកពាក់ព័ន្ធ | សកម្មភាពអាទិភាព ៣ |
|---|---|
| **សេចក្តីសង្ខេប**<br>ប្រតិបត្តិការប្រចាំថ្ងៃនៅប្រាសាទសំខាន់ៗដែលមានការភ្ញៀវទេសចរច្រើន(ដូចជា អង្គរវត្ត បាយ័ន តាព្រហ្ម ភ្នំបាខែង អង្គរធំ បេងមាលា និងបន្ទាយស្រី) គួរអនុវត្តការគ្រប់គ្រងដោយរួមបញ្ចូលគ្រប់ផ្នែកពាក់ព័ន្ធ ហើយអ្នកគ្រប់គ្រងប្រាសាទនីមួយៗ គួរមានសិទ្ធិក្នុងការសម្រេចចិត្ត និងដឹកនាំបុគ្គលិកប្រចាំការនៅទីនោះ។ អ្នកគ្រប់គ្រងប្រាសាទត្រូវទទួលបានការបណ្តុះបណ្តាលលើផ្នែកគ្រប់គ្រងរមណីយដ្ឋាន និងមានជំនួយពី "សៀវភៅណែនាំសម្រាប់អ្នកគ្រប់គ្រងរមណីយដ្ឋាន"។ បុគ្គលិកទាំងអស់នៅតាមប្រាសាទនានាគួរតែជាផ្នែកនៃការងារគ្រប់គ្រង ដែលទទួលបានការបណ្តុះបណ្តាលសមស្របនិងអាចរួមចំណែកក្នុងការគ្រប់គ្រងប្រាសាទតាមការចង់បាន។ គួរអនុវត្តប្រព័ន្ធនេះទៅតាមដំណាក់កាល ដោយចាប់ផ្តើមពីប្រាសាទបេងមាលា និងជ្រើសរើសយកប្រាសាទណាមួយនៅក្នុងឧទ្យានអង្គរមកអនុវត្តក្នុងជំហានបន្ទាប់។ |  |

**គោលបំណង**

- ធ្វើឲ្យការគ្រប់គ្រងទេសចរណ៍នៅតាមប្រាសាទសំខាន់ៗក្នុងឧទ្យានអង្គរកាន់តែប្រសើរឡើង
- បង្កើនសមត្ថភាពបុគ្គលិកនៅតាមរមណីយដ្ឋានពីគ្រប់ផ្នែកពាក់ព័ន្ធ(ប៉ូលីស ឆ្មាំ បុគ្គលិកបច្ចេកទេស និងអ្នកសម្អាត) ដើម្បីការពារប្រាសាទនិងគ្រប់គ្រងភ្ញៀវទេសចរ ដោយការសហការគ្នា
- តែងតាំងអ្នកគ្រប់គ្រងរមណីយដ្ឋានដែលអាចដឹកនាំបុគ្គលិកនិងបែងចែកធនធានមនុស្សឲ្យកាន់តែប្រសើរ ក៏ដូចជាកិច្ចប្រឹងប្រែង

ប្រកបដោយការទទួលខុសត្រូវ និងមានជំនាញ

- តែងតាំងអ្នកគ្រប់គ្រងមណីយដ្ឋាននៅតាមប្រាសាទចម្បងៗ ដែលអាចផ្តល់ព័ត៌មានអំពីទិសដៅទស្សនា និងតម្រូវការគ្រប់គ្រង ដើម្បីឆ្លើយតបទៅនឹងលក្ខខណ្ឌដែលអាចកើតមាន
- បង្កើតប្រព័ន្ធគ្រប់គ្រងដោយរួមបញ្ចូលគ្រប់ផ្នែកពាក់ព័ន្ធ ដើម្បីបន្តត្រួតពិនិត្យនិងគ្រប់គ្រងមណីយដ្ឋានដោយមានផែនការបម្រុងទុកជាមុន
- តែងតាំងអ្នកគ្រប់គ្រងរមណីយដ្ឋានដែលអាចសហការជាមួយអ្នកគ្រប់គ្រងប្រាសាទផ្សេងទៀត ដើម្បីគ្រប់គ្រងលំហូរអ្នកទស្សនានៅក្នុងតំបន់អង្គរ។

**ការផ្សារភ្ជាប់ទៅនឹងការផ្តួចផ្តើមចម្បង**

ការអនុវត្តសកម្មភាពអាទិភាព៣ ជាការចាប់ផ្តើមនូវការផ្តួចផ្តើមចម្បងចំនុច ៥ ទំព័រទី១៣ គឺការគ្រប់គ្រងដោយរួមបញ្ចូលគ្រប់ផ្នែកពាក់ព័ន្ធនៅប្រាសាទនីមួយៗ

**ដំណោះស្រាយ**

កិច្ចប្រជុំការងារផែនការគ្រប់គ្រងវិស័យទេសចរណ៍នៅថ្ងៃទី១៨-១៩ ខែកញ្ញា ឆ្នាំ២០១២ រវាងអាជ្ញាធរអប្សរា ក្រសួងទេសចរណ៍ អង្គការយូណេស្កូ អ្នកពិគ្រោះយោបល់ Godden Mackay Logan(GML) និងអ្នកតំណាងមកពីវិស័យឯកជនបានអនុម័តនូវដំណោះស្រាយដូចខាងក្រោម៖

- គ្រប់គ្រងប្រាសាទដោយរួមបញ្ចូលគ្រប់ផ្នែកពាក់ព័ន្ធ(អ្នកគ្រប់គ្រងរមណីយដ្ឋាន)
- គ្រប់គ្រងលំហូរអ្នកទស្សនា

| ភារកិច្ច | រយៈពេល | ទំនួលខុសត្រូវ | ធនធានស្នើឡើង |
|---|---|---|---|
| ១- ព្រាងសៀវភៅណែនាំសម្រាប់អ្នកគ្រប់គ្រងរមណីយដ្ឋាន | | គណៈកម្មាធិការបច្ចេកទេស/ GML | ~៥០ម៉ោង |
| ២- បកប្រែនិងបោះពុម្ពសៀវភៅណែនាំសម្រាប់អ្នកគ្រប់គ្រងរមណីយដ្ឋាន | | អង្គការយូណេស្កូ | ២០០០ដុល្លារអាមេរិក ~២០ម៉ោង |
| ៣- បង្កើតលក្ខខណ្ឌក្នុងការតែងតាំងអ្នកគ្រប់គ្រងរមណីយដ្ឋាន | | អគ្គនាយកអាជ្ញាធរអប្សរា | ក្នុងគម្រោងHMF |
| ៤- បណ្តុះបណ្តាលគណៈកម្មាធិការបច្ចេកទេសក្នុងក្របខ័ណ្ឌHMF របស់អាជ្ញាធរអប្សរា ដើម្បីឲ្យពួកគេមានជំនាញគ្រប់គ្រងរមណីយដ្ឋាន និងប្រើប្រាស់សៀវភៅណែនាំសម្រាប់អ្នកគ្រប់គ្រងរមណីយដ្ឋាន | | GML | |
| ៥- រកជម្រើសក្នុងការបណ្តុះបណ្តាលអ្នកគ្រប់គ្រងរមណីយដ្ឋាន | | GML/ អាជ្ញាធរអប្សរា/ អង្គការយូណេស្កូ | ក្នុងគម្រោងHMF |
| ៦- ផ្តល់ការបណ្តុះបណ្តាលលើការគ្រប់គ្រងរមណីយដ្ឋានដល់អ្នកគ្រប់គ្រងរមណីយដ្ឋាន | | GML/ អាជ្ញាធរអប្សរា | គម្រោងHMF និងបន្ត |
| ៧- ផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិកនៅតាមរមណីយដ្ឋានអំពីការគ្រប់គ្រងរមណីយដ្ឋានដោយ | | អាជ្ញាធរអប្សរា | TBD(នឹងត្រូវប្រកាស) |

<table>
<tr><td>រួមបញ្ចូលគ្រប់ផ្នែកពាក់ព័ន្ធ តាមតួនាទីនិងការទទួលខុសត្រូវរៀងៗខ្លួន<br><br>៨- អនុវត្តការគ្រប់គ្រងប្រាសាទបេងមាលា និងនៅប្រាសាទណាមួយនៅក្នុងឧទ្យានអង្គរ<br>៩- អនុវត្តការគ្រប់គ្រងរមណីយដ្ឋានដោយរួមបញ្ចូលគ្រប់ផ្នែកពាក់ព័ន្ធបន្តិចម្តងៗ នៅទីតាំងផ្សេងក្នុងឧទ្យានអង្គរ។</td><td></td><td>អ្នកគ្រប់គ្រងរមណីយដ្ឋាន និងបុគ្គលិក<br><br>អាជ្ញាធរអប្សរា</td><td>TBD(នឹងត្រូវប្រកាស)<br><br>TBD(នឹងត្រូវប្រកាស)</td></tr>
<tr><td>បុគ្គលិកអាជ្ញាធរអប្សរា</td><td colspan="3">បុគ្គលិកផ្សេងទៀត</td></tr>
<tr><td>- អគ្គនាយកអាជ្ញាធរអប្សរា<br>- អ្នកគ្រប់គ្រងរមណីយដ្ឋាន<br>- គណៈកម្មាធិការបច្ចេកទេស<br>- បុគ្គលិកធ្វើការនៅតាមរមណីយដ្ឋាន</td><td colspan="3">GML នគរបាលបេតិកភណ្ឌ<br>អង្គការយូណេស្កូ នគរបាលទេសចរណ៍<br>អ្នកជំនាញខាងក្រៅ បុគ្គលិកសម្អាត</td></tr>
<tr><td>តម្រូវការបណ្តុះបណ្តាល</td><td colspan="3">កំណត់ចំណាំ</td></tr>
<tr><td>- បណ្តុះបណ្តាលស្តីពីការគ្រប់គ្រងរមណីយដ្ឋានសម្រាប់អ្នកគ្រប់គ្រងប្រាសាទ<br>- វគ្គបណ្តុះបណ្តាលបុគ្គលិកអាជ្ញាធរអប្សរា និងបុគ្គលិក</td><td colspan="3">អ្នកគ្រប់គ្រងរមណីយដ្ឋាន គួរមានសិទ្ធិនិងការទទួលខុសត្រូវសម្របសម្រួលបុគ្គលិកនៅតាមរមណីយដ្ឋានពីគ្រប់ផ្នែកផ្សេងៗ</td></tr>
</table>

| | |
|---|---|
| តាមរមណីយដ្ឋានដទៃទៀតស្តីពីការគ្រប់គ្រង<br>រមណីយដ្ឋាន | |

| ប្រព័ន្ធចាត់ថ្នាក់ប្រាសាទ | សកម្មភាពអាទិភាព ៤ |
|---|---|
| **សេចក្តីសង្ខេប**<br>រៀបចំ"ប្រព័ន្ធចាត់ថ្នាក់ប្រាសាទ" ដោយប្រើប្រាស់លទ្ធផលពីការសិក្សា"សមត្ថភាពផ្ទុក" ក៏ដូចជាការផ្តល់គំនិត ពិគ្រោះយោបល់ និងកិច្ចសហការជាមួយឧស្សាហកម្មទេសចរណ៍និងអាជ្ញាធរអប្សរា។ ប្រព័ន្ធចាត់ថ្នាក់ប្រាសាទ គួរតែជួយឲ្យរកឃើញចំណែកទីផ្សារទេសចរណ៍ផ្សេងៗគ្នា និងអាចបែងចែកប្រាសាទទៅតាមបទពិសោធទស្សនានៃចំណែកទីផ្សារទាំងនោះ។ |  |

**គោលបំណង**

- ធ្វើឲ្យបទពិសោធអ្នកទស្សនាប្រសើរឡើង ដោយកំណត់ប្រាសាទដែលសមស្រប ក៏ដូចជារមណីយដ្ឋានផ្សេងទៀតដែលឆ្លើយតបតាមតម្រូវការអ្នកទស្សនា និងផ្សារភ្ជាប់អ្នកទស្សនាជាមួយប្រាសាទទាំងនោះ
- កាត់បន្ថយផលប៉ះពាល់រមណីយដ្ឋានដោយធ្វើឲ្យបទពិសោធអ្នកទស្សនាសម្បូរបែប តាមរយៈការចាត់ថ្នាក់ប្រាសាទនិងបង្ហាញពីគុណតម្លៃប្រាសាទដល់ភ្ញៀវទេសចរ
- យល់ដឹងពីលក្ខណៈប្រាសាទនៅក្នុងនិងជុំវិញតំបន់អង្គរ ដើម្បីគ្រប់គ្រងអ្នកទស្សនាកាន់តែប្រសើរ និងផ្តល់នូវព័ត៌មានសម្រាប់ការអភិរក្ស
- លើកឡើងនូវព័ត៌មានពិសេសរបស់ប្រាសាទដែលមានភ្ញៀវទេសចរតិច ឬកន្លែងដែលមានតែមួយប្រកបដោយគុណតម្លៃពិសេសផ្នែកវប្បធម៌និងបរិស្ថាន
- ប្រើប្រាស់លក្ខណៈរបស់ប្រាសាទ ដើម្បីរៀបចំវង់ទស្សនាថ្មីសម្រាប់ភ្ញៀវទេសចរ។

**ការផ្សារភ្ជាប់ទៅនឹងការផ្តួចផ្តើមចម្បង**

ការអនុវត្តសកម្មភាពអាទិភាព៤ ជាការចាប់ផ្តើមនៃការផ្តួចផ្តើមចម្បងចំនុច **ភ** ទំព័រទ១៣ គឺការគ្រប់គ្រងលំហូរអ្នកទស្សនា

## ដំណោះស្រាយ

កិច្ចប្រជុំការងារផែនការគ្រប់គ្រងវិស័យទេសចរណ៍នៅថ្ងៃទី១៨-១៩ ខែកញ្ញា ឆ្នាំ២០១២ រវាងអាជ្ញាធរអប្សរា ក្រសួងទេសចរណ៍ អង្គការយូណេស្កូ អ្នកពិគ្រោះយោបល់ Godden Mackay Logan(GML) និងអ្នកតំណាងមកពីវិស័យឯកជនបានអនុម័តនូវដំណោះស្រាយដូចខាងក្រោម៖

- គ្រប់គ្រងលំហូរអ្នកទស្សនា
- តម្រូវការក្នុងការលុបបំបាត់ "វង់ធំ-វង់តូច" ដោយមិនត្រឹមតែចាត់ថ្នាក់ប្រាសាទទេ ប៉ុន្តែថែមទាំងបង្ហាញពីគុណតម្លៃរបស់ប្រាសាទដើម្បីទាក់ទាញភ្ញៀវទេសចរ។

| ភារកិច្ច | រយៈពេល | ទំនួលខុសត្រូវ | ធនធានស្មើឡើង |
|---|---|---|---|
| ១- តែងតាំងបុគ្គលិកអាជ្ញាធរអប្សរាឲ្យរៀបចំបង្កើតប្រព័ន្ធចាត់ថ្នាក់ប្រាសាទ | | អគ្គនាយកអាជ្ញាធរអប្សរា | ~២០ម៉ោង |
| ២- ប្រើប្រាស់នូវលទ្ធផលពីការសិក្សាសមត្ថភាពផ្ទុកដោយកំណត់ចំនួនភ្ញៀវទេសចរក្នុងប្រាសាទនីមួយៗទៅតាមលក្ខណៈនិងគុណតម្លៃប្រាសាទនិងរមណីយដ្ឋាន | | បុគ្គលិកដែលពាក់ព័ន្ធ | ~១០០ម៉ោង |
| ៣- រៀបចំប្រព័ន្ធចាត់ថ្នាក់ប្រាសាទតាមលក្ខណៈពិសេសនិងគុណតម្លៃ | | បុគ្គលិកដែលពាក់ព័ន្ធ/អ្នកជំនាញខាងក្រៅ | ~៣០០០០ដុល្លារ |

| | | | |
|---|---|---|---|
| ៤- បញ្ចូលទិន្នន័យក្នុងប្រព័ន្ធចាត់ថ្នាក់ប្រាសាទនូវព័ត៌មានពីប្រាសាទនិងរមណីយដ្ឋាន | | បុគ្គលិកដែលពាក់ព័ន្ធ | ~២០០ម៉ោង |
| ៥- ប្រើប្រាស់នូវទិន្នន័យដែលមាននៅក្នុងប្រព័ន្ធចាត់ថ្នាក់ប្រាសាទ ដើម្បីកំណត់ឱកាសរៀបចំវង់ទស្សនាថ្មីដែលពោរពេញទៅដោយបទពិសោធទស្សនា | | បុគ្គលិកដែលពាក់ព័ន្ធ | ~៤០០ម៉ោង |
| ៦- ធ្វើទីផ្សារទេសចរណ៍ឲ្យបានសមស្របសម្រាប់រមណីយដ្ឋាននិងប្រាសាទ ដោយផ្អែកលើប្រព័ន្ធចាត់ថ្នាក់ប្រាសាទនិងដោយមានការប្រឹក្សាយោបល់ជាមួយវិស័យឯកជន | | បុគ្គលិកដែលពាក់ព័ន្ធ/ អ្នកតំណាងវិស័យឯកជន | ~៦០ម៉ោង |
| ៧- រកឲ្យឃើញប្រាសាទដែលមានភ្ញៀវទេសចរតិចនិងមិនសូវស្គាល់ ដើម្បីបង្ហាញដល់ទីផ្សារអ្នកទស្សនាមួយចំនួន | | បុគ្គលិកដែលពាក់ព័ន្ធ/ ក្រសួងទេសចរណ៍ | ~១០០ម៉ោង |
| ៨- ជំរុញផ្សព្វផ្សាយពីជម្រើសក្នុងការទស្សនាប្រាសាទនិងរមណីយដ្ឋានដល់ទីផ្សារទេសចរណ៍ ក្នុងគោលបំណងបែងចែកភ្ញៀវទេសចរពាសពេញតំបន់អង្គរ និងធ្វើឲ្យបទពិសោធអ្នកទស្សនាប្រសើរឡើង | | បុគ្គលិកដែលពាក់ព័ន្ធ | បន្តទៅតាមប្រភពធនធានដែលមាន |
| ៩- ផ្តល់ព័ត៌មានដល់ភ្ញៀវទេសចរឲ្យបានប្រសើរជាងមុន | | បុគ្គលិកដែលពាក់ព័ន្ធ | ~១០០ម៉ោងបំពេញ |

| | | | |
|---|---|---|---|
| ស្តីពីលក្ខណៈ និងគុណតម្លៃដើម្បីឲ្យពួកគាត់អាចធ្វើ សេចក្តីសម្រេចចិត្តដោយទទួលបានព័ត៌មាន។ គ្រប់គ្រាន់។ | | | ការងារ និងបន្ត |
| **បុគ្គលិកអាជ្ញាធរអប្សរា** | **បុគ្គលិកផ្សេងទៀត** | | |
| - អគ្គនាយកអាជ្ញាធរអប្សរា<br>- បុគ្គលិកអាជ្ញាធរអប្សរាដែលមានភារកិច្ចក្នុងការងារនេះ | - GML<br>- អ្នកជំនាញខាងក្រៅ<br>- វិស័យឯកជន<br>- ក្រសួងទេសចរណ៍ | | |
| **តម្រូវការបណ្តុះបណ្តាល** | **កំណត់ចំណាំ** | | |
| ការបណ្តុះបណ្តាលបុគ្គលិកអាជ្ញាធរអប្សរាដែលបាន ទទួលការតែងតាំង | អ្នកជំនាញខាងក្រៅនិងអ្នកជំនាញចំពោះកិច្ចរបស់ICC-Angkor អាចមានលទ្ធភាពផ្តល់យោបល់តាមការស្នើសុំ | | |

## ប្រព័ន្ធដឹកជញ្ជូនថ្មី

## សកម្មភាពអាទិភាព ៥

### សេចក្តីសង្ខេប

អាជ្ញាធរអប្សរាគួរតែចាប់ផ្តើមរៀបចំឯកសារ ស្រាវជ្រាវ និងវិភាគ ដើម្បីរៀបចំប្រព័ន្ធដឹកជញ្ជូនថ្មីមួយសម្រាប់ឧទ្យានអង្គរ។ ប្រព័ន្ធនេះគួរគិតបញ្ចូលទាំងផ្លូវសម្រាប់យានយន្ត និងផ្លូវគ្មានយានយន្ត មធ្យោបាយដឹកជញ្ជូន ទិសដៅលំហូរទេសចរ ការធ្វើដំណើរ និងការហាមឃាត់នានា។ ប្រព័ន្ធនេះគួរតែកាត់បន្ថយការប្រើប្រាស់យានយន្តធុនធំនាពេលអនាគត និងផ្តោតសំខាន់លើការដឹកជញ្ជូនតាមបែបប្រពៃណី។



### គោលបំណង

- ជំរុញឲ្យប្រើប្រាស់មធ្យោបាយដឹកជញ្ជូនផ្សេងនិងតាមបែបប្រពៃណីតាមដែលអាចធ្វើបានរួមមានកង់ សេះ និងរទេះគោ
- ជួយសម្រួលដល់អ្នកទស្សនាដោយថ្មើរជើងនិងបង្កើតផ្លូវសម្រាប់ជិះកង់
- កាត់បន្ថយការប្រើប្រាស់រថយន្តធុនធំនៅក្នុងតំបន់អង្គរ
- កាត់បន្ថយការកកស្ទះយានយន្ត និងធ្វើឲ្យលំហូរអ្នកទស្សនានៅជុំវិញឧទ្យានអង្គរនិងក្រុងសៀមរាបប្រសើរឡើង
- ធ្វើឲ្យស្តង់ដាសុវត្ថិភាពមធ្យោបាយដឹកជញ្ជូនប្រសើរឡើង តាមរយៈវិធាននិងការគ្រប់គ្រងចរាចរណ៍ដ៏សមស្រប
- រៀបចំប្រព័ន្ធដឹកជញ្ជូនថ្មីដោយប្រឹក្សាយោបល់ជាមួយវិស័យឯកជនដើម្បីកាត់បន្ថយនូវការប៉ះពាល់ដល់គុណតម្លៃ វប្បធម៌ និងធម្មជាតិ។

### ការផ្សារភ្ជាប់ទៅនឹងការផ្តួចផ្តើមចម្បង

ការអនុវត្តសកម្មភាពអាទិភាព៥ ជាការចាប់ផ្តើមនៃការផ្តួចផ្តើមចម្បងចំនុច **ឆ** ទំព័រទី១៣ គឺប្រព័ន្ធដឹកជញ្ជូន

## ដំណោះស្រាយ

កិច្ចប្រជុំការងារផែនការគ្រប់គ្រងវិស័យទេសចរណ៍នៅថ្ងៃទី១៨-១៩ ខែកញ្ញា ឆ្នាំ២០១២ រវាងអាជ្ញាធរអប្សរា ក្រសួងទេសចរណ៍ អង្គការយូណេស្កូ អ្នកពិគ្រោះយោបល់ Godden Mackay Logan(GML) និងអ្នកតំណាងមកពីវិស័យឯកជនបានអនុម័តនូវដំណោះស្រាយដូចខាងក្រោម៖

- ប្រព័ន្ធដឹកជញ្ជូន

| ភារកិច្ច | រយៈពេល | ទំនួលខុសត្រូវ | ធនធានស្នើឡើង |
|---|---|---|---|
| ១- តែងតាំងបុគ្គលិកអាជ្ញាធរអប្សរាឲ្យទទួលខុសត្រូវរៀបចំផែនការប្រព័ន្ធដឹកជញ្ជូនថ្មី | | អគ្គនាយកអាជ្ញាធរអប្សរា | ~១០ម៉ោង |
| ២- ស្វែងរកម្ចាស់ជំនួយនិងដៃគូសហការ | | អាជ្ញាធរអប្សរា/ អង្គការយូណេស្កូ | ~៥០ម៉ោង |
| ៣- ពិនិត្យមើលកិច្ចការទាំងឡាយដែលបានធ្វើមកដល់សព្វថ្ងៃ ទាក់ទងនឹងប្រព័ន្ធដឹកជញ្ជូនក្នុងឧទ្យានអង្គរ | | បុគ្គលិកដែលពាក់ព័ន្ធ | ~៤០០ម៉ោង |
| ៤- ស្វែងរកការពិគ្រោះយោបល់ជាមួយឧស្សាហកម្មទេសចរណ៍ ដើម្បីធ្វើឲ្យប្រព័ន្ធដឹកជញ្ជូននៅក្នុងតំបន់អង្គរកាន់តែប្រសើរឡើង | | បុគ្គលិកដែលពាក់ព័ន្ធ/ ឧស្សាហកម្មទេសចរណ៍/ អ្នកពាក់ព័ន្ធដទៃទៀត | ៣០០០ដុល្លារ |

| | | | |
|---|---|---|---|
| ៥- បញ្ជាក់ឲ្យច្បាស់ពីស្ថានភាពផ្លូវនៅក្នុងឧទ្យានអង្គរ និងបុគ្គល/យានយន្តដែលអាចប្រើប្រាស់ផ្លូវទាំងនោះបាន | | អគ្គនាយកអាជ្ញាធរអប្សរា | ~៤០ម៉ោង |
| ៦- រកមធ្យោបាយដើម្បីដករថយន្តក្រុងនិងរថយន្តនានាៗចេញពីឧទ្យានអង្គរ និងរៀបចំប្រព័ន្ធចរាចរណ៍ឯកទិស | | បុគ្គលិកដែលពាក់ព័ន្ធ | ~៦០ម៉ោង |
| ៧- រកមធ្យោបាយដើម្បីដកយានយន្តធុនធំចេញពីអង្គរធំ និងមធ្យោបាយផ្សេងទៀតដូចជាការប្រើប្រាស់សេវារថយន្តក្រុងអគ្គិសនីសារធារណៈ ឬបង្កើតផ្លូវសម្រាប់ថ្មើរជើងនិងទោចក្រយានយន្ត | | បុគ្គលិកដែលពាក់ព័ន្ធ | ~១០០ម៉ោង |
| ៨- កំណត់ហេដ្ឋារចនាសម្ព័ន្ធដែលពាក់ព័ន្ធចាំបាច់ដូចជាចំណត កន្លែងសម្រាកនិងបន្ទប់ទឹក នៅពេលរៀបចំផែនការសាងសង់សេវាកម្មទេសចរណ៍ | | បុគ្គលិកដែលពាក់ព័ន្ធ | ~៧០ម៉ោង |
| ៩- បង្ហាញពីប្រព័ន្ធផ្លូវធ្វើដំណើរដោយថ្មើរជើងនិងដោយជិះកង់នៅក្នុងរមណីយដ្ឋានអង្គរ | | បុគ្គលិកដែលពាក់ព័ន្ធ | ~៧០ម៉ោង |
| ១០- ព្រៀងផែនការមេសម្រាប់ប្រព័ន្ធដឹកជញ្ជូននៅក្នុងនិងជុំវិញរមណីយដ្ឋានអង្គរដោយមានការ | | បុគ្គលិកដែលពាក់ព័ន្ធ | ~២០០ម៉ោង |

| | | | |
|---|---|---|---|
| ចូលរួមពីអ្នកពាក់ព័ន្ធ ដើម្បីកាត់បន្ថយផលប៉ះពាល់ និងគ្រប់គ្រងលំហូរភ្ញៀវទេសចរ និង ការចតយានយន្ត | | | |
| ១១- បញ្ចប់ផែនការមេសម្រាប់ប្រព័ន្ធដឹកជញ្ជូន និងធ្វើការងារជាមួយអ្នកពាក់ព័ន្ធ ដើម្បីរកឲ្យឃើញការផ្លាស់ប្តូរជាអាទិភាព | | បុគ្គលិកដែលពាក់ព័ន្ធ/ អ្នកពាក់ព័ន្ធដទៃទៀត | ~១០០ម៉ោង |
| ១២- ស្វែងរកការគាំទ្រពីគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារនិងអភិរក្សរមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ(ICC-Angkor) និងរាជរដ្ឋាភិបាលកម្ពុជា | | ICC-Angkor / ប្រធានអាជ្ញាធរអប្សរា | |
| ១៣- រៀបចំហេដ្ឋារចនាសម្ព័ន្ធតាមផ្លូវធ្វើដំណើរសម្រាប់អ្នកដំណើរដោយថ្មើរជើងនិងទោចក្រយានយន្ត | | អាជ្ញាធរអប្សរា/ ម្ចាស់ជំនួយ | TBD(នឹងត្រូវប្រកាស) |
| ១៤- លើកទឹកចិត្តឲ្យប្រើប្រាស់ការដឹកជញ្ជូនផ្សេងដែលមានការប៉ះពាល់តិចតួចនិងតាមបែបប្រពៃណី(កង់ ស៊ីក្លូ រទេះគោ)។ | | អាជ្ញាធរអប្សរា/ វិស័យឯកជន | បន្ត |

| បុគ្គលិកអាជ្ញាធរអប្សរា | បុគ្គលិកផ្សេងទៀត |
|---|---|
| - អគ្គនាយកអាជ្ញាធរអប្សរា<br>- បុគ្គលិកអាជ្ញាធរអប្សរាដែលមានភារកិច្ចក្នុងការងារនេះ | - ម្ចាស់ជំនួយខាងក្រៅ<br>- វិស័យឯកជន<br>- ICC-Angkor |
| **តម្រូវការបណ្តុះបណ្តាល** | **កំណត់ចំណាំ** |
| បុគ្គលិកអាជ្ញាធរអប្សរា នៅពេលដែលរៀបចំផែនការមេសម្រាប់ប្រព័ន្ធដឹកជញ្ជូនរួចរាល់ | អ្នកជំនាញខាងក្រៅ និងអ្នកជំនាញចំពោះកិច្ចរបស់ ICC-Angkor អាចផ្តល់យោបល់តាមការស្នើសុំ |

| **ផែនការសេវាកម្មទេសចរណ៍** | **សកម្មភាពអាទិភាព ៦** |
|---|---|
| **សេចក្ដីសង្ខេប**<br>អាជ្ញាធរអប្សរាគួររៀបចំផែនការថ្មីសម្រាប់ហេដ្ឋារចនាសម្ព័ន្ធសេវាកម្មទេសចរណ៍ ដោយផ្ដោតជាពិសេសលើចំណតរថយន្ត បន្ទប់ទឹកនិងតូបលក់ចំណីអាហារនិងភេសជ្ជៈ ។ |  |

**គោលបំណង**

- ធ្វើឲ្យហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅក្នុងឧទ្យានអង្គរប្រសើរឡើង
- រៀបចំនិងអនុវត្តផែនការសេវាកម្មទេសចរណ៍ដោយរួមបញ្ចូលទាំងចំណត កន្លែងសម្រាក បង្គន់អនាម័យ តូបលក់វត្ថុអនុស្សាវរីយ៍ ចំណីអាហារនិងភេសជ្ជៈ
- ជៀសវាងនិង/ឬកាត់បន្ថយផលប៉ះពាល់លើបេតិកភណ្ឌនិងបរិស្ថានផ្សេងទៀត តាមរយៈការរៀបចំហេដ្ឋារចនាសម្ព័ន្ធសេវាកម្មទេសចរណ៍ឲ្យបានល្អ
- ផ្ដល់ឱកាសបន្ថែមឲ្យប្រជាជនក្នុងតំបន់ក្នុងការលក់ដូរ និងឲ្យភ្ញៀវទេសចរទិញទំនិញតាមរយៈផែនការផ្ដល់ឱកាសដល់ប្រជាជនក្នុងតំបន់ផ្ដល់សេវាដល់ភ្ញៀវទេសចរដូចជាវត្ថុអនុស្សាវរីយ៍ ឬចំណីអាហារនិងភេសជ្ជៈ
- ឆ្លើយតបតាមតម្រូវការរបស់អ្នកទស្សនា និងគាំទ្រដំណើរការប្រតិបត្តិនៅរមណីយដ្ឋានប្រកបដោយចីរភាព

**ការផ្សារភ្ជាប់ទៅនឹងការផ្ដួចផ្ដើមចម្បង**

ការអនុវត្តសកម្មភាពអាទិភាព៦ ជាការចាប់ផ្ដើមនៃការផ្ដួចផ្ដើមចម្បងចំនុច **ខ** ទំព័រទី១៤ គឺសេវាកម្ម និងបទពិសោធអ្នកទស្សនា

## ដំណោះស្រាយ

កិច្ចប្រជុំការងារផែនការគ្រប់គ្រងវិស័យទេសចរណ៍នៅថ្ងៃទី១៨-១៩ ខែកញ្ញា ឆ្នាំ២០១២ រវាងអាជ្ញាធរអប្សរា ក្រសួងទេសចរណ៍ អង្គការយូណេស្កូ អ្នកពិគ្រោះយោបល់ Godden Mackay Logan(GML) និងអ្នកតំណាងមកពីវិស័យឯកជនបានអនុម័តនូវដំណោះស្រាយដូចខាងក្រោមៈ

- តាមច្បាប់ មិនមានផ្ទះសំណាក់និងភោជនីយដ្ឋានថ្មីក្នុងឧទ្យានអង្គរ និងមិនមានការទស្សនាប្រាសាទនៅពេលយប់
- អ្នកធ្វើដំណើរផ្លូវអាកាសគួរទទួលបានព័ត៌មានថា ពួកគេបានចុះយន្តហោះមកក្នុងតំបន់ការពារនៃតំបន់បេតិកភណ្ឌពិភពលោក

| ភារកិច្ច | រយៈពេល | ទំនួលខុសត្រូវ | ធនធានស្នើឡើង |
|---|---|---|---|
| ១- ប្រគល់កិច្ចការឲ្យបុគ្គលិកអាជ្ញាធរអប្សរាទទួលខុសត្រូវក្នុងការរៀបចំផែនការសេវាកម្មទេសចរណ៍ | | អគ្គនាយកអាជ្ញាធរអប្សរា<br>បុគ្គលិកដែលពាក់ព័ន្ធ | ~២០ម៉ោង<br>~២០ម៉ោង |
| ២- កំណត់វិធីល្អបំផុតដើម្បីផ្តល់ព័ត៌មានដល់អ្នកធ្វើដំណើរតាមផ្លូវអាកាសថា ពួកគេបានចុះយន្តហោះនៅក្នុងតំបន់ការពារនៃតំបន់បេតិកភណ្ឌពិភពលោក | | បុគ្គលិកដែលពាក់ព័ន្ធ | ~២០០ម៉ោង |
| ៣- ពិនិត្យមើលនិងរៀបចំផែនទីហេដ្ឋារចនាសម្ព័ន្ធបច្ចុប្បន្នទាំងអស់ | | បុគ្គលិកដែលពាក់ព័ន្ធ/ | ~៣០០០ដុល្លារ |
| ៤- ពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធដើម្បីទទួល | | ឧស្សាហកម្មទេសចរណ៍/ | |

| | | | |
|---|---|---|---|
| បានព័ត៌មានទាក់ទងនឹងផែនការសេវាកម្មទេសចរណ៍ និងហេដ្ឋារចនាសម្ព័ន្ធរមណីយដ្ឋានដែលត្រូវការ | | អ្នកពាក់ព័ន្ធដទៃទៀត<br><br>បុគ្គលិកដែលពាក់ព័ន្ធ | <br><br>~៤០ម៉ោង |
| ៥- រកជម្រើសក្នុងការផ្តល់ឱកាសបន្ថែមទៀតដល់ប្រជាជនក្នុងតំបន់ផ្តល់សេវាកម្មដល់ភ្ញៀវទេសចរ | | <br>បុគ្គលិកដែលពាក់ព័ន្ធ | <br>~២០ម៉ោង |
| ៦- សហការជាមួយបុគ្គលិកតែងតាំងដើម្បីពិនិត្យជម្រើសទីផ្សារលក់សិប្បកម្មរបស់ប្រជាជនក្នុងតំបន់ | | <br><br>បុគ្គលិកដែលពាក់ព័ន្ធ | <br><br>~២០ម៉ោង |
| ៧- សហការជាមួយបុគ្គលិកអាជ្ញាធរអប្សរាដែលពាក់ព័ន្ធនឹងការងារប្រព័ន្ធដឹកជញ្ជូនដើម្បីរៀបចំផែនទីសេវាកម្មទេសចរណ៍ដូចជា ចំណត កន្លែងសម្រាក និងបង្គន់អនាម័យ | | | |
| ៨- ព្រាងផែនការសេវាកម្មទេសចរណ៍ដែលឆ្លើយតបនឹងតម្រូវការអ្នកទស្សនានិងកាត់បន្ថយការប៉ះពាល់ដល់គុណតម្លៃបេតិកភណ្ឌនិងបរិស្ថាន | | បុគ្គលិកដែលពាក់ព័ន្ធ | ~ ៤០០ម៉ោង |
| ៩- កំណត់សកម្មភាពអាទិភាពនិងធ្វើការជាមួយអ្នកពាក់ព័ន្ធដើម្បីបញ្ចប់ផែនការសេវាកម្មទេសចរណ៍ | | បុគ្គលិកដែលពាក់ព័ន្ធ/<br>អ្នកពាក់ព័ន្ធដទៃទៀត | ~ ១០០ម៉ោង |
| ១០- ស្វែងរកការគាំទ្រផែនការសេវាកម្មទេសចរណ៍ | | ប្រធានអាជ្ញាធរអប្សរា/ | |

| | | | |
|---|---|---|---|
| ពីរាជរដ្ឋាភិបាលកម្ពុជា និងគណៈកម្មាធិការសម្របសម្រួលអន្តរជាតិសម្រាប់ការការពារ និងអភិវឌ្ឍតំបន់ប្រវត្តិសាស្ត្រអង្គរ( ICC-Angkor)<br>១១- រៀបចំសេចក្តីណែនាំដែលសមស្របសម្រាប់ហេដ្ឋារចនាសម្ព័ន្ធថ្មី<br>១២- អនុវត្តផែនការសេវាកម្មទេសចរណ៍និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធអាទិភាពថ្មី។ | | ICC-Angkor<br><br>បុគ្គលិកដែលពាក់ព័ន្ធ<br><br>អាជ្ញាធរអប្សរា | <br><br>~ ១០០ម៉ោង<br><br>TBD(នឹងត្រូវប្រកាស) |

| **បុគ្គលិកអាជ្ញាធរអប្សរា** | **បុគ្គលិកផ្សេងទៀត** |
|---|---|
| - អគ្គនាយកអាជ្ញាធរអប្សរា<br>- បុគ្គលិកអាជ្ញាធរអប្សរាដែលមានភារកិច្ចក្នុងការងារនេះ | - វិស័យឯកជន/អ្នកពាក់ព័ន្ធដទៃទៀត<br>- ICC-Angkor |
| **តម្រូវការបណ្តុះបណ្តាល** | **កំណត់ចំណាំ** |
| គ្មាន | អ្នកជំនាញខាងក្រៅ និងអ្នកជំនាញចំពោះកិច្ច របស់ ICC-Angkor អាចផ្តល់យោបល់តាមការស្នើសុំ |

**បណ្ដុះបណ្ដាលមគ្គុទ្ទេសក៍ទេសចរណ៍ឡើងវិញ** | **សកម្មភាពអាទិភាព ៧**

**សេចក្ដីសង្ខេប**

អាជ្ញាធរអប្សរាគួររៀបចំកម្មវិធីបណ្ដុះបណ្ដាលមគ្គុទ្ទេសក៍ទេសចរណ៍ឡើងវិញ ទាក់ទងនឹងព័ត៌មានតម្រង់ទិសអ្នកទស្សនា ក្រុមអ្នកទស្សនានៅអង្គរ និងព័ត៌មានថ្មីៗអំពីប្រវត្តិសាស្ត្រនិងសារៈសំខាន់នៃតំបន់បេតិកភណ្ឌពិភពលោកអង្គរឲ្យបានត្រឹមត្រូវ។ ការបណ្ដុះបណ្ដាលនេះគួរផ្អែកលើវិធីសាស្ត្រសហការគ្នារវាងសមាគមមគ្គុទ្ទេសក៍ទេសចរណ៍ ឧស្សាហកម្មទេសចរណ៍និងរាជរដ្ឋាភិបាល។



**គោលបំណង**

- ធានាគុណភាពសេវាកម្មមគ្គុទ្ទេសក៍ទេសចរណ៍អង្គរដែលជាបុគ្គលសំខាន់ក្នុងការគ្រប់គ្រងទេសចរណ៍
- ធានាថាមគ្គុទ្ទេសក៍ជាអ្នកពាក់ព័ន្ធ និងគាំទ្រការផ្លាស់ប្ដូរដ៏សំខាន់ក្នុងប្រព័ន្ធគ្រប់គ្រងទេសចរណ៍នៅអង្គរ ដូចជាក្រុមអ្នកទស្សនា និងព័ត៌មានតម្រង់ទិសដែលសមស្រប
- ធានាថាប្រព័ន្ធបណ្ដុះបណ្ដាលមគ្គុទ្ទេសក៍ មានបញ្ចូលព័ត៌មានត្រឹមត្រូវ និងទិន្នន័យថ្មីៗអំពីគុណតម្លៃនៃតំបន់បេតិកភណ្ឌពិភពលោកអង្គរ

**ការផ្សារភ្ជាប់ទៅនឹងការផ្ដួចផ្ដើមចម្បង**

ការអនុវត្តសកម្មភាពអាទិភាព៧ នឹងធ្វើការអនុវត្តតាមការផ្ដួចផ្ដើមចម្បងចំនុច ១ ទំព័រទី១៤ គឺការបណ្ដុះបណ្ដាលមគ្គុទ្ទេសក៍ទេសចរណ៍

**ដំណោះស្រាយ**

កិច្ចប្រជុំការងារផែនការគ្រប់គ្រងវិស័យទេសចរណ៍នៅថ្ងៃទី១៨-១៩ ខែកញ្ញា ឆ្នាំ២០១២ រវាងអាជ្ញាធរអប្សរា ក្រសួងទេសចរណ៍ អង្គការ

| យុទ្ធសាស្ត្រ | | | |
|---|---|---|---|
| យុទ្ធសាស្ត្រ អ្នកពិគ្រោះយោបល់ Godden Mackay Logan(GML) និងអ្នកតំណាងមកពីវិស័យឯកជនបានអនុម័តនូវដំណោះស្រាយដូចខាងក្រោម៖<br>• អនុវត្តការបណ្តុះបណ្តាលមគ្គុទ្ទេសក៍ដោយអាជ្ញាធរអប្សរា(ការអនុវត្តអនុក្រឹត្យថ្មីស្តីពីបញ្ហាខាងដើម)<br>• ប្រជាជនក្នុងតំបន់ស្គាល់យ៉ាងច្បាស់ពីភូមិឋាន រួមទាំងប្រពៃណីទំនៀមទម្លាប់នៅក្នុងតំបន់ ដូច្នេះពួកគេអាចធ្វើជាមគ្គុទ្ទេសក៍ដោយប្រើប្រាស់ចំណេះដឹងទាំងនោះ<br>• តម្រូវការក្នុងការបែងចែកមគ្គុទ្ទេសក៍និងអ្នកបកប្រែឲ្យដាច់ពីគ្នាតាមរយៈឯកសណ្ឋានមគ្គុទ្ទេសក៍ | | | |
| **ភារកិច្ច** | **រយៈពេល** | **ទំនួលខុសត្រូវ** | **ធនធានស្នើឡើង** |
| ១- បង្កើតក្រុមការងារដែលមានការចូលរួមពីបុគ្គលិកអាជ្ញាធរអប្សរា និងក្រសួងទេសចរណ៍ ដើម្បីចាប់ផ្តើមរៀបចំផែនការការផ្តួចផ្តើមបណ្តុះបណ្តាលមគ្គុទ្ទេសក៍ឡើងវិញ | | អគ្គនាយកអាជ្ញាធរអប្សរា | ~១០ម៉ោង |
| ២- ពិចារណាតែងតាំងតំណាងឧស្សាហកម្មទេសចរណ៍ក្នុងក្រុមការងារ | | អគ្គនាយកអាជ្ញាធរអប្សរា/ ក្រ. ទេសចរណ៍ | ~១០០ម៉ោង |
| ៣- តាមរយៈយន្តការពិគ្រោះយោបល់ជាមួយឧស្សាហកម្មទេសចរណ៍(សូមមើលសកម្មភាពអាទិភាព៩-១២) ត្រូវរកឲ្យឃើញបញ្ហាដែលត្រូវពិចារណាបន្ថែមក្នុងការរៀបចំកម្មវិធីបណ្តុះ | | | |

| | | | |
|---|---|---|---|
| បណ្តាលមគ្គុទ្ទេសក៍ឡើងវិញ និងពិភាក្សាពីវិធីសាស្រ្តដែលអាចប្រើក្នុងការអនុវត្តកម្មវិធីបណ្តុះបណ្តាលនេះ<br>៤- រៀបចំមាតិកានិងកម្មវិធីសម្រាប់ការបណ្តុះបណ្តាល<br>៥- រៀបចំកម្មវិធី "បណ្តុះបណ្តាលអ្នកបណ្តុះបណ្តាល" ដល់អ្នកបណ្តុះបណ្តាលមគ្គុទ្ទេសក៍<br>៦- ណែនាំអ្នកបណ្តុះបណ្តាលឲ្យអនុវត្តការបណ្តុះបណ្តាល<br>៧- វាយតម្លៃកម្មវិធីបណ្តុះបណ្តាលនិងផ្តល់អនុសាសន៍ស្តីពីការបណ្តុះបណ្តាលមគ្គុទ្ទេសក៍បន្តទៀត<br>៨- បន្តត្រួតពិនិត្យនិងពង្រឹងស្តង់ដាគុណភាពមគ្គុទ្ទេសក៍។ | | ក្រុមការងារបណ្តុះបណ្តាលមគ្គុទ្ទេសក៍<br>អ្នកបណ្តុះបណ្តាលមគ្គុទ្ទេសក៍<br>អ្នកបណ្តុះបណ្តាលមគ្គុទ្ទេសក៍<br>អ្នកវាយតម្លៃការបណ្តុះបណ្តាល<br>អាជ្ញាធរអប្សរានិងក្រសួងទេសចរណ៍ | ~២០០ម៉ោង<br>TBD(នឹងត្រូវប្រកាស)<br>TBD(នឹងត្រូវប្រកាស)<br>TBD(នឹងត្រូវប្រកាស)<br>បន្ត |

| **បុគ្គលិកអាជ្ញាធរអប្សរា** | **បុគ្គលិកផ្សេងទៀត** |
|---|---|
| - អគ្គនាយកអាជ្ញាធរអប្សរា<br>- មន្រ្តីអាជ្ញាធរអប្សរាដែលទទួលខុសត្រូវក្នុងការអនុវត្ត | - តំណាងក្រសួងទេសចរណ៍<br>- តំណាងឧស្សាហកម្មទេសចរណ៍ |

| | |
|---|---|
| ផែនការគ្រប់គ្រងទេសចរណ៍<br>- បុគ្គលិកអាជ្ញាធរអប្សរាមួយចំនួន | - ម្ចាស់ជំនួយ |
| **តម្រូវការបណ្តុះបណ្តាល** | **កំណត់ចំណាំ** |
| សកម្មភាពអាទិភាព មានទិសដៅសម្រេចលទ្ធផលតាមរយៈការបណ្តុះបណ្តាល។ ដើម្បីឲ្យកម្មវិធី "បណ្តុះបណ្តាលអ្នកបណ្តុះបណ្តាល" មានប្រសិទ្ធភាព ត្រូវមានផែនការនិងអ្នកបណ្តុះបណ្តាលមគ្គុទ្ទេសក៍មុននឹងដំណើរការកម្មវិធីបណ្តុះបណ្តាល។ | មាត្រា២២នៃអនុក្រឹត្យស្តីពីមគ្គុទ្ទេសក៍ទេសចរណ៍(១៩១អនក្រ.បក) ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ តម្រូវឲ្យអាជ្ញាធរអប្សរាផ្តល់នូវការបណ្តុះបណ្តាលដល់មគ្គុទ្ទេសក៍ទេសចរណ៍ពិសេសដែលធ្វើការងារក្នុងតំបន់អង្គរ ដោយសហការជាមួយក្រសួងទេសចរណ៍។ |

## រៀបចំបង្កើតក្រមប្រតិបត្តិ

**សកម្មភាពអាទិភាព ៨**

### សេចក្តីសង្ខេប

គួររៀបចំក្រមប្រតិបត្តិសម្រាប់អ្នកទស្សនា មគ្គុទ្ទេសក៍ និងប្រតិបត្តិករក្នុងឧស្សាហកម្មទេសចរណ៍នៅអង្គរជាអាទិភាពដំបូងបំផុតក្នុងការរៀបចំក្រមអ្នកទស្សនានៅអង្គរ។ គួរផ្សព្វផ្សាយក្រមនេះឲ្យបានទូលំទូលាយនិងច្រើនភាសា និងមានលក្ខណៈច្នៃប្រឌិតដើម្បីធានាការប្រាស្រ័យទាក់ទងល្អជាមួយវិស័យទេសចរណ៍នៅអង្គរ។ គួរប្រើប្រាស់សេចក្តីណែនាំដែលមានស្រាប់ ជាចំណុចចាប់ផ្តើមក្នុងការរៀបចំក្រមទាំងនេះ។



### គោលបំណង

- រៀបចំក្រមអ្នកទស្សនាអង្គរដើម្បីផ្តល់សារដល់ភ្ញៀវទេសចរដោយពណ៌នាពីអាកប្បកិរិយាដែលភ្ញៀវទេសចរត្រូវអនុវត្តតាមការចង់បាន និងដើម្បីចែកចាយនិងផ្សព្វផ្សាយដល់ទីផ្សារទេសចរណ៍ឲ្យបានទូលំទូលាយនិងមានប្រសិទ្ធភាព
- រៀបចំក្រមអ្នកទស្សនាដែលជាការអនុវត្តល្អបំផុតនៅក្នុងពិភពលោកដើម្បីផ្តល់ព័ត៌មានដល់ភ្ញៀវទេសចរអំពីការរួមចំណែករបស់ពួកគេក្នុងការការពារគុណតម្លៃបេតិកភណ្ឌអង្គរ
- នាពេលអនាគត រៀបចំក្រមប្រតិបត្តិសម្រាប់ឧស្សាហកម្មទេសចរណ៍រួមមាន ប្រតិបត្តិករទេសចរណ៍ មគ្គុទ្ទេសក៍ និងអ្នកផ្តល់សេវាកន្លែងស្នាក់នៅ។

### ការផ្សារភ្ជាប់ទៅនឹងការផ្តួចផ្តើមចម្បង

ការអនុវត្តសកម្មភាពអាទិភាព៨ ជាធាតុមួយនៅក្នុងការផ្តួចផ្តើមចម្បងចំនុច ឃ ទំព័រទី១៣ គឺការតម្រង់ទិសអ្នកទស្សនា និងការផ្តួចផ្តើមចម្បង

| ចំនុច ៦ ទំព័រទី១៤ គឺការបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍ | | | |
|---|---|---|---|
| **ដំណោះស្រាយ**<br>កិច្ចប្រជុំការងារផែនការគ្រប់គ្រងវិស័យទេសចរណ៍នៅថ្ងៃទី១៨-១៩ ខែកញ្ញា ឆ្នាំ២០១២ រវាងអាជ្ញាធរអប្សរា ក្រសួងទេសចរណ៍ អង្គការយូណេស្កូ អ្នកពិគ្រោះយោបល់ Godden Mackay Logan(GML) និងអ្នកតំណាងមកពីវិស័យឯកជនបានអនុម័តនូវដំណោះស្រាយដូចខាងក្រោម៖<br>• ពិនិត្យឡើងវិញនូវសេចក្តីព្រាងស្តីពីវិធានអ្នកទស្សនាពីដំបូង និងបកប្រែជាភាសាខ្មែរ អង់គ្លេស បារាំង | | | |
| **ភារកិច្ច** | **រយៈពេល** | **ទំនួលខុសត្រូវ** | **ធនធានស្នើឡើង** |
| ១- បង្កើតក្រុមការងាររៀបចំក្រមប្រតិបត្តិដែលទទួលខុសត្រូវបង្កើតក្រមអ្នកទស្សនា ក្រមប្រតិបត្តិសម្រាប់ឧស្សាហកម្មទេសចរណ៍ និងក្រមប្រតិបត្តិសម្រាប់មគ្គុទ្ទេសក៍ | | អគ្គនាយកអាជ្ញាធរអប្សរា/ក្រសួងទេសចរណ៍ | ~៤០ម៉ោង |
| ២- កំណត់គោលបំណងនិងវិសាលភាពនៃក្រមប្រតិបត្តិ | | ក្រុមការងាររៀបចំក្រមប្រតិបត្តិ | ~ ២០ម៉ោង |
| ៣- ពិចារណាលើវិធាននានានិងការអនុវត្តការងារដែលមានស្រាប់ក្នុងការរៀបចំក្រមប្រតិបត្តិ | | | ~ ២០ម៉ោង |
| ៤- ធ្វើការសិក្សាស្រាវជ្រាវពីការប្រើប្រាស់ក្រមប្រតិបត្តិនៅតំបន់បេតិកភណ្ឌផ្សេងទៀត ដោយ | | មន្ត្រីស្រាវជ្រាវ | ~ ១០០ម៉ោង |

| | | | |
|---|---|---|---|
| ផ្តោតការយកចិត្តទុកដាក់លើក្រមប្រតិបត្តិសម្រាប់អ្នកទស្សនា | | | |
| ៥- រៀបចំយុទ្ធសាស្ត្រអនុវត្តលម្អិត និងស្នើសុំថវិកាសម្រាប់បោះពុម្ពក្រមអ្នកទស្សនាជាអាទិភាព | | ក្រុមការងាររៀបចំក្រមប្រតិបត្តិ | ~ ១០០ម៉ោង |
| ៦- ស្វែងរកថវិកានិងការគាំទ្រក្នុងការរៀបចំនិងអនុវត្តក្រមអ្នកទស្សនា ដោយសហការជាមួយឧស្សាហកម្មទេសចរណ៍ | | អគ្គនាយកអាជ្ញាធរអប្សរា/ ក្រសួងទេសចរណ៍ | ស្នើសុំថវិកាម្ចាស់ជំនួយ |
| ៧- រៀបចំសម្ភារៈនិងប្រព័ន្ធគាំទ្រការប្រើប្រាស់ក្រមអ្នកទស្សនា ដោយប្រើប្រាស់បណ្តាញព័ត៌មានផ្សេងៗនិងយន្តការផ្សព្វផ្សាយជាសាធារណៈ(រួមបញ្ចូលទាំងបណ្តាញអ៊ីនធឺណិត) និងមធ្យោបាយប្រើប្រាស់ក្រមនេះឲ្យមានប្រសិទ្ធភាពនិងចីរភាព។ ចំណុចនេះអាចសម្រេចតាមរយៈអ្នកចុះកិច្ចសន្យានិង/ឬក្រុមអនុវត្តដែលមានជំនាញសមស្រប | | ក្រុមអនុវត្តក្រមប្រតិបត្តិ | ថវិកាម្ចាស់ជំនួយ |
| ៨- ដាក់ឲ្យប្រើប្រាស់ក្រមអ្នកទស្សនា ដោយប្រើបណ្តាញផ្សព្វផ្សាយ | | TBD(នឹងត្រូវប្រកាស) | ~ ៥០ម៉ោង និង ២០០០ដុល្លារ |

| | | | |
|---|---|---|---|
| ៩- រៀបចំយុទ្ធសាស្ត្រអនុវត្តលម្អិតស្តីពីក្រមប្រតិបត្តិសម្រាប់ឧស្សាហកម្មទេសចរណ៍ និងក្រមប្រតិបត្តិសម្រាប់មគ្គុទ្ទេសក៍<br>១០- ដាក់ឲ្យប្រើប្រាស់ក្រមប្រតិបត្តិសម្រាប់ឧស្សាហកម្មទេសចរណ៍ និងក្រមប្រតិបត្តិសម្រាប់មគ្គុទ្ទេសក៍ដោយប្រើប្រាស់បណ្តាញផ្សព្វផ្សាយប្រកបដោយនិរន្តរភាព<br>១១- កំណត់ដំណើរការនិងការទទួលខុសត្រូវក្នុងការត្រួតពិនិត្យ វាយតម្លៃ និងពិនិត្យក្រមប្រតិបត្តិ។ | | ក្រុមការងាររៀបចំក្រមប្រតិបត្តិ<br>TBD(នឹងត្រូវប្រកាស)<br>ក្រុមការងាររៀបចំក្រមប្រតិបត្តិ | TBD(នឹងត្រូវប្រកាស)<br>~ ៥០ម៉ោង និង ២០០០ដុល្លារ<br>TBD(នឹងត្រូវប្រកាស) |
| **បុគ្គលិកអាជ្ញាធរអប្សរា** | **បុគ្គលិកផ្សេងទៀត** | | |
| - អគ្គនាយកអាជ្ញាធរអប្សរា<br>- មន្ត្រីអាជ្ញាធរអប្សរាដែលទទួលខុសត្រូវក្នុងការអនុវត្តផែនការគ្រប់គ្រងទេសចរណ៍<br>- បុគ្គលិកអាជ្ញាធរអប្សរាមួយចំនួន | - តំណាងក្រសួងទេសចរណ៍<br>- តំណាងឧស្សាហកម្មទេសចរណ៍<br>- ម្ចាស់ជំនួយ<br>- ICC-Angkor និងអ្នកជំនាញការចំពោះកិច្ច ក្នុងការផ្តល់យោបល់ | | |
| **តម្រូវការបណ្តុះបណ្តាល** | **កំណត់ចំណាំ** | | |
| យុទ្ធសាស្ត្រអនុវត្តក្រមប្រតិបត្តិនឹងត្រូវការដាក់បញ្ចូល | ការស្រាវជ្រាវ ដើម្បីកំណត់កម្មវិធីអនុវត្តដែលមានប្រយោជន៍ ក្នុងការផ្តល់ព័ត៌មានពេល | | |

| | |
|---|---|
| ក្នុងកម្មវិធីបណ្តុះបណ្តាលនិងស្វែងយល់ ដើម្បីធ្វើឲ្យអ្នកជាប់ពាក់ព័ន្ធទាំងអស់យល់ដឹងនិងពិចារណាពីរបៀបដាក់បញ្ចូលក្រមនេះទៅក្នុងការងាររបស់ពួកគេ។ | រៀបចំក្រមប្រតិបត្តិ។ ចាំបាច់ត្រូវមានផែនការយុទ្ធសាស្ត្រដែលរៀបចំដោយប្រុងប្រយ័ត្ននិងតាមវិធីសាស្ត្រជំនាញ ដើម្បីជាឧបករណ៍និងប្រព័ន្ធគាំទ្រការអនុវត្តក្រមប្រតិបត្តិ។ ការរៀបចំក្រមប្រតិបត្តិដែលមានការសហការមួយជាមួយឧស្សាហកម្មទេសចរណ៍និងអ្នកពាក់ព័ន្ធផ្សេងទៀត នឹងជួយធ្វើឲ្យក្រមនេះមានប្រសិទ្ធភាពនិងនិរន្តរភាព។ |

| ក្រុមពិគ្រោះយោបល់ទេសចរណ៍ | សកម្មភាពអាទិភាព ៩ |
|---|---|
| **សេចក្តីសង្ខេប**<br>ដើម្បីធានានូវភាពជាដៃគូប្រកបដោយប្រសិទ្ធភាព វិស័យឯកជននិងរាជរដ្ឋាភិបាលកម្ពុជា គួរកោះប្រជុំក្រុមពិគ្រោះយោបល់ទេសចរណ៍ដែលមានតំណាងពីវិស័យទេសចរណ៍ទាំងអស់ តំណាងស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធរៀងរាល់បីខែម្តង ដើម្បីរកឲ្យឃើញនិងពិភាក្សាពីគំនិតផ្តួចផ្តើមថ្មី បញ្ហានិងឱកាសនានា។ សមាជិកទាំងឡាយក្នុងក្រុមនឹងប្រឹក្សាយោបល់ជាមួយគ្នានិងរាយការណ៍ត្រឡប់ទៅសហការីរបស់ពួកគេ និងទៅអ្នករួមការងារក្នុងស្ថាប័នរាជរដ្ឋាភិបាលនិងឧស្សាហកម្មទេសចរណ៍។ |  |

**គោលបំណង**

- ផ្តល់នូវយន្តការទំនាក់ទំនងនិងប្រឹក្សាយោបល់ប្រកបដោយប្រសិទ្ធភាព ដោយបង្កើតភាពជាដៃគូរវាងវិស័យឯកជន អាជ្ញាធរអប្សរា និងក្រសួងទេសចរណ៍អំពីការគ្រប់គ្រងនិងអភិវឌ្ឍន៍ទេសចរណ៍អង្គរ
- ផ្តល់នូវមធ្យោបាយទំនាក់ទំនងដោយផ្ទាល់រវាងអាជ្ញាធរអប្សរានិងឧស្សាហកម្មទេសចរណ៍ ព្រមទាំងធ្វើឲ្យការផ្សព្វផ្សាយនិងចែកចាយព័ត៌មានកាន់តែប្រសើរឡើង
- រៀបចំវេទិកាពិភាក្សាលើបញ្ហានិងក្តីបារម្ភរបស់រាជរដ្ឋាភិបាលនិងឧស្សាហកម្មទេសចរណ៍ ប្រកបដោយការគោរព មានប្រសិទ្ធភាព និងជាផ្លូវការ
- រៀបចំវេទិកាពិភាក្សាលើការផ្តួចផ្តើមចម្បងទាំងឡាយដើម្បីបង្កើនប្រសិទ្ធភាព និងបណ្តុះនូវភាពជាដៃគូនិងកិច្ចសហការពិតប្រាកដនៅក្នុងការរៀបចំនិងអនុវត្តការផ្តួចផ្តើមទាំងនោះ

| ការផ្សារភ្ជាប់ទៅនឹងការផ្ដួចផ្ដើមចម្បង<br>ការអនុវត្តសកម្មភាពអាទិភាព៩ នឹងក្លាយជាសកម្មភាពរួមចំណែកក្នុងការផ្ដួចផ្ដើមចម្បងចំនុច ញ ទំព័រទី១៥ គឺទំនាក់ទំនងនិងប្រាស្រ័យទាក់ទង ឧស្សាហកម្ម ទេសចរណ៍ | | | |
|---|---|---|---|
| **ដំណោះស្រាយ**<br>កិច្ចប្រជុំការងារផែនការគ្រប់គ្រងវិស័យទេសចរណ៍នៅថ្ងៃទី១៨-១៩ ខែកញ្ញា ឆ្នាំ២០១២ រវាងអាជ្ញាធរអប្សរា ក្រសួងទេសចរណ៍ អង្គការយូណេស្កូ អ្នកពិគ្រោះយោបល់ Godden Mackay Logan(GML) និងអ្នកតំណាងមកពីវិស័យឯកជនបានអនុម័តនូវដំណោះស្រាយដូចខាងក្រោម៖<br>• ទទួលរ៉ាប់រងការជំរុញវិស័យទេសចរណ៍រួម(ជាមួយក្រសួងទេសចរណ៍និងវិស័យឯកជន)<br>• ជំរុញការតភ្ជាប់ទៅបណ្តាញគេហៈទំព័រអាជ្ញាធរអប្សរា | | | |
| **ភារកិច្ច** | **រយៈពេល** | **ទំនួលខុសត្រូវ** | **ធនធានស្នើឡើង** |
| ១- យោងសេចក្ដីសម្រេចរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ប្រធានអាជ្ញាធរអប្សរា នៅក្នុងសិក្ខាសាលាស្ដីពីឧស្សាហកម្មទេសចរណ៍ ដែលបានធ្វើឡើងនៅសៀមរាប ក្នុងខែមីនា ឆ្នាំ ២០១២ ត្រូវបង្កើត "ក្រុមពិគ្រោះយោបល់ទេសចរណ៍ រាជរដ្ឋាភិបាល និងឯកជន" ដើម្បីជួបប្រជុំបីខែម្តង | | ឯកឧត្តមប្រធានអាជ្ញាធរអប្សរា/ អគ្គនាយកអាជ្ញាធរអប្សរា/ គណៈកម្មការគម្រោងHMF | ការសម្រេចរបស់គណៈកម្មការគម្រោងHMF |

| | | | |
|---|---|---|---|
| ២- លើកសំណើសមាជិកភាពនិងលក្ខខណ្ឌយោង សម្រាប់ក្រុមពិគ្រោះយោបល់ទេសចរណ៍។ ស្វែងរកយោបល់ពីសមាគមឧស្សាហកម្ម ទេសចរណ៍ដែលពាក់ព័ន្ធ<br>៣- សេចក្តីសម្រេចស្តីពីសមាជិកភាពនិងលក្ខខណ្ឌ យោងសម្រាប់ក្រុម ប្រធាន និងអ្នកសម្រប សម្រួលត្រូវធ្វើការសម្រេចជាផ្លូវការដោយ ឯកឧត្តមប្រធានអាជ្ញាធរអប្សរា និងឯកឧត្តម រដ្ឋមន្ត្រីក្រសួងទេសចរណ៍<br>៤- រៀបចំការប្រជុំក្រុមពិគ្រោះយោបល់ឧស្សាហកម្ម ទេសចរណ៍ជាលើកដំបូងនៅទីស្នាក់ការ កណ្តាលអាជ្ញាធរអប្សរាខេត្តសៀមរាប<br>៥- រៀបចំការប្រជុំបីខែម្តងនៅតាមទីតាំងនិងពេល វេលាដែលសម្រេចដោយក្រុមពិគ្រោះយោបល់។ | | ឯ.ឧទាហរណ៍រដ្ឋមន្ត្រី ក្រសួង ទេសចរណ៍/ មន្ត្រីទំនាក់ ទំនងជាមួយឧស្សាហកម្ម ទេសចរណ៍<br>មន្ត្រីទំនាក់ទំនងជាមួយ ឧស្សាហកម្មទេសចរណ៍<br>មន្ត្រីទំនាក់ទំនងជាមួយ ឧស្សាហកម្មទេសចរណ៍<br>មន្ត្រីទំនាក់ទំនងជាមួយ ឧស្សាហកម្មទេសចរណ៍ | ~ ២០ម៉ោង<br>~២០ម៉ោង<br>~៣០០០ដុល្លារ<br>TBD(នឹងត្រូវប្រកាស) |
| **បុគ្គលិកអាជ្ញាធរអប្សរា** | **បុគ្គលិកផ្សេងទៀត** | | |
| - អគ្គនាយកអាជ្ញាធរអប្សរា<br>- មន្ត្រីអាជ្ញាធរអប្សរាដែលទទួលខុសត្រូវក្នុងការអនុវត្ត | - ឯ.ឧទាហរណ៍ រដ្ឋមន្ត្រីក្រសួងទេសចរណ៍<br>- តំណាងក្រសួងទេសចរណ៍ | | |

| | |
|---|---|
| ផែនការគ្រប់គ្រងទេសចរណ៍ | - គណៈកម្មការគម្រោងHMF<br>- អ្នកដែលបានទទួលការតែងតាំងពីអភិបាលខេត្តសៀមរាប<br>- តំណាងឧស្សាហកម្មទេសចរណ៍<br>- ប្រធាននិងអ្នកសម្របសម្រួល |
| **តម្រូវការបណ្តុះបណ្តាល** | **កំណត់ចំណាំ** |
| គ្មាន | គ្មាន |

| **កិច្ចប្រជុំជាប្រចាំស្តីពីការសម្របសម្រួលទំនាក់ទំនងជាមួយវិស័យឯកជន** | **សកម្មភាពអាទិភាព ១០** |
|---|---|

**សេចក្តីសង្ខេប**

អាជ្ញាធរអប្សរា ក្រសួងទេសចរណ៍ អាជ្ញាធរខេត្តសៀមរាប និងសមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា (CATA) សមាគមដឹកជញ្ជូនភ្ញៀវទេសចរ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ និងទីភ្នាក់ងារផ្តល់សេវាកម្មទេសចរណ៍ដទៃទៀត គួររៀបចំកិច្ចប្រជុំពង្រឹងទំនាក់ទំនងក្នុងតំបន់ឲ្យបានទៀងទាត់។

**គោលបំណង**

- ជំរុញលើកទឹកចិត្តឲ្យមានការចាត់ចែងនិងរៀបចំកិច្ចសហការយ៉ាងសកម្មរវាងទីភ្នាក់ងារទេសចរណ៍និងអាជ្ញាធរអប្សរា ព្រមទាំងក្រសួងទេសចរណ៍
- ផ្តល់នូវមធ្យោបាយទំនាក់ទំនងដោយផ្ទាល់រវាងអាជ្ញាធរអប្សរានិងទីភ្នាក់ងារទេសចរណ៍ដែលជួយឲ្យរៀបចំផែនការរយៈពេលវែងកាន់តែប្រសើរសម្រាប់ការគ្រប់គ្រងទេសចរណ៍ និងសម្រាប់ឲ្យប្រតិបត្តិករទេសចរណ៍ក្នុងស្រុកមានពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើការផ្សព្វផ្សាយផលិតផលរបស់ខ្លួនទៅកាន់អន្តរជាតិ

**ការផ្សារភ្ជាប់ទៅនឹងការផ្តួចផ្តើមចម្បង**

ការអនុវត្តសកម្មភាពអាទិភាព១០ នឹងក្លាយជាសកម្មភាពរួមចំណែកក្នុងការផ្តួចផ្តើមចម្បងចំនុច **ឈ** ទំព័រទី១៤ គឺទំនាក់ទំនង និងការប្រាស្រ័យទាក់ទងជាមួយឧស្សាហកម្មទេសចរណ៍

**ដំណោះស្រាយ**

កិច្ចប្រជុំការងារផែនការគ្រប់គ្រងវិស័យទេសចរណ៍នៅថ្ងៃទី១៨-១៩ ខែកញ្ញា ឆ្នាំ២០១២ រវាងអាជ្ញាធរអប្សរា ក្រសួងទេសចរណ៍ អង្គការ

យូណេស្កូ អ្នកពិគ្រោះយោបល់ Godden Mackay Logan(GML) និងអ្នកតំណាងមកពីវិស័យឯកជនបានអនុម័តនូវដំណោះស្រាយដូចខាងក្រោម៖

- ជំរុញការជួបប្រជុំរវាងអាជ្ញាធរអប្សរានិងសមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា អំពីការគាំទ្រប្រជាជនក្នុងតំបន់ដោយគ្មានការកេងប្រយោជន៍

| ភារកិច្ច | រយៈពេល | ទំនួលខុសត្រូវ | ធនធានស្នើឡើង |
|---|---|---|---|
| ១- បង្កើតឲ្យមានកិច្ចប្រជុំការសម្រួលទំនាក់ទំនងតាមការសម្រេចជាផ្លូវការ/សេចក្តីណែនាំរបស់អាជ្ញាធរអប្សរានិងក្រសួងទេសចរណ៍ | | អគ្គនាយកអាជ្ញាធរអប្សរា | ~ ១០ម៉ោង |
| ២- តែងតាំងអ្នកសម្របសម្រួលនិងប្រធានអង្គប្រជុំ | | អគ្គនាយកអាជ្ញាធរអប្សរា | ~ ១០ម៉ោង |
| ៣- បញ្ជូនលិខិតអញ្ជើញឲ្យមកចូលរួមក្នុងកិច្ចប្រជុំការសម្រួលទំនាក់ទំនងជាលើកដំបូង | | មន្ត្រីសម្របសម្រួលជាមួយឧស្សាហកម្មទេសចរណ៍ | ~ ៥០ម៉ោង |
| ៤- រៀបចំកិច្ចប្រជុំការសម្រួលទំនាក់ទំនងដំបូងនិងសម្រេចកាលបរិច្ឆេទប្រជុំលើកក្រោយ | | មន្ត្រីសម្របសម្រួលជាមួយឧស្សាហកម្មទេសចរណ៍ | ~ ៣០០០ ដុល្លារ |
| ៥- រៀបចំកិច្ចប្រជុំការសម្រួលទំនាក់ទំនងទៀងទាត់ស្របទៅតាមពេលវេលាដែលបានឯកភាព។ | | មន្ត្រីសម្របសម្រួលជាមួយឧស្សាហកម្មទេសចរណ៍ | TBD(នឹងត្រូវប្រកាស) |
| **បុគ្គលិកអាជ្ញាធរអប្សរា** | **បុគ្គលិកផ្សេងទៀត** | | |

| | |
|---|---|
| - អគ្គនាយកអាជ្ញាធរអប្សរា<br>- មន្ត្រីអាជ្ញាធរអប្សរាដែលទទួលខុសត្រូវក្នុងការអនុវត្តផែនការគ្រប់គ្រងទេសចរណ៍ | - តំណាងក្រសួងទេសចរណ៍<br>- តំណាងឧស្សាហកម្មទេសចរណ៍ |
| **តម្រូវការបណ្ដុះបណ្ដាល** | **កំណត់ចំណាំ** |
| គ្មាន | គ្មាន |

| មន្ត្រីសម្របសម្រួលទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍ | សកម្មភាពអាទិភាព ១១ |
|---|---|
| **សេចក្ដីសង្ខេប**<br>អាជ្ញាធរអប្សរា គួរតែងតាំងមន្ត្រីសម្របសម្រួលទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍ម្នាក់(ឬច្រើននាក់) ដើម្បីងាយស្រួលទំនាក់ទំនងនិងដោះស្រាយបញ្ហាជាមួយឧស្សាហកម្មទេសចរណ៍។ | <br> |

**គោលបំណង**

- ផ្ដល់នូវចំណុចទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍ដើម្បីពិភាក្សាពីបញ្ហាដែលពាក់ព័ន្ធនឹងប្រតិបត្តិការទេសចរណ៍នៅអង្គរ
- តែងតាំងមន្ត្រីសម្របសម្រួលទំនាក់ទំនង ដើម្បីធានាប្រសិទ្ធភាពនិងការប្រាស្រ័យទាក់ទងប្រកបដោយតម្លាភាពរវាងប្រតិបត្តិករទេសចរណ៍និងអាជ្ញាធរអប្សរា
- បង្កើតនូវលក្ខខណ្ឌក្នុងការតែងតែងមន្ត្រីសម្រួលទំនាក់ទំនង ដោយមានការផ្លាស់ប្ដូរជាទៀងទាត់ ដើម្បីឆ្លើយតបតាមតម្រូវការរបស់អាជ្ញាធរអប្សរានិងឧស្សាហកម្មទេសចរណ៍
- អាជ្ញាធរអប្សរានឹងមានមន្ត្រីទទួលខុសត្រូវម្នាក់ឬច្រើននាក់ ដើម្បីត្រួតពិនិត្យទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍ និងទិន្នន័យផ្សេងៗដែលទទួលបានឧស្សាហកម្មទេសចរណ៍ អាជ្ញាធរអប្សរា និងក្រសួងទេសចរណ៍ ពាក់ព័ន្ធនឹងបញ្ហាទេសចរណ៍ កិច្ចសហប្រតិបត្តិការនិងកិច្ចសហការជាមួយឧស្សាហកម្មទេសចរណ៍។
- អាជ្ញាធរអប្សរានឹងមានមន្ត្រីទទួលខុសត្រូវការងាររៀបចំ ចងក្រងឯកសារ និងរាយការណ៍ពីទំនាក់ទំនងនិងការសហការជាមួយឧស្សាហកម្មទេសចរណ៍
- មានមន្ត្រីសម្រួលទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍ដែលមានភាពចាស់ទុំក្នុងការទំនាក់ទំនងដោយផ្ទាល់ជាមួយឧស្សាហកម្មទេសចរណ៍ និងធ្វើជាលេខាធិការដ្ឋានសម្របសម្រួលក្រុមពិគ្រោះយោបល់ជាមួយឧស្សាហកម្មទេសចរណ៍(ផែនការគ្រប់គ្រងទេសចរណ៍

សកម្មភាពអាទិភាព ៩) និងសកម្មភាពសម្របសម្រួលទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍ដទៃទៀត

**ការផ្សារភ្ជាប់ទៅនឹងការផ្តួចផ្តើមចម្បង**

ការអនុវត្តសកម្មភាពអាទិភាព១១ នឹងក្លាយជាសកម្មភាពរួមចំណែកក្នុងការផ្តួចផ្តើមចម្បងចំនុច **ឈ** ទំព័រទី១៩គឺទំនាក់ទំនង និងការប្រាស្រ័យទាក់ទងឧស្សាហកម្មទេសចរណ៍

**ដំណោះស្រាយ**

កិច្ចប្រជុំការងារផែនការគ្រប់គ្រងវិស័យទេសចរណ៍នៅថ្ងៃទី១៨-១៩ ខែកញ្ញា ឆ្នាំ២០១២ រវាងអាជ្ញាធរអប្សរា ក្រសួងទេសចរណ៍ អង្គការយូណេស្កូ អ្នកពិគ្រោះយោបល់ Godden Mackay Logan(GML) និងអ្នកតំណាងមកពីវិស័យឯកជនបានអនុម័តនូវដំណោះស្រាយដូចខាងក្រោម៖

- តែងតាំងមន្ត្រីទំនាក់ទំនងជាមួយវិស័យឯកជនឲ្យមានប្រសិទ្ធភាពនិងតម្លាភាព។ គួរតែមិនមែនជាមនុស្សនៅជាចិន្ត្រៃយ៍ម្នាក់ តែអាចមានការផ្លាស់ប្តូរជាទៀងទាត់

| **ភារកិច្ច** | **រយៈពេល** | **ទំនួលខុសត្រូវ** | **ធនធានស្នើឡើង** |
|---|---|---|---|
| ១- ដើម្បីធ្វើឲ្យសេចក្តីសម្រេចរបស់ ឯ.ឧ បណ្ឌិតសភាចារ្យ **សុខ អាន** ប្រធានអាជ្ញាធរអប្សរា ក្នុងការបង្កើត "ក្រុមពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាលនិងឧស្សាហកម្មទេសចរណ៍" ទទួលបានជោគជ័យ ត្រូវតែងតាំងមន្ត្រីសម្រប | | អគ្គនាយកអាជ្ញាធរអប្សរា/ក្រសួងទេសចរណ៍ | ប្រាក់បៀវត្សពេញម៉ោង |

| | | | |
|---|---|---|---|
| សម្រួលទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍ ឲ្យទទួលខុសត្រូវក្នុងការអនុវត្តការផ្តួចផ្តើមនេះ រួមមានសកម្មភាពសម្របសម្រួលទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍ | | | |
| ២- បង្កើតលក្ខខណ្ឌក្នុងការតែងតាំងមន្ត្រីសម្របសម្រួលទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍ | | អគ្គនាយកអាជ្ញាធរអប្សរា | ~៥០ម៉ោង |
| ៣- តែងតាំងមន្ត្រីទទួលបន្ទុកសម្របសម្រួលទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍ | | អគ្គនាយកអាជ្ញាធរអប្សរា | ~២០ម៉ោង |
| ៤- រៀបចំការប្រជុំពិគ្រោះយោបល់បឋមជាមួយឧស្សាហកម្មទេសចរណ៍ ដើម្បីផ្តល់ព័ត៌មានដល់ពួកគេអំពីការតែងតាំងនិងតួនាទីមន្ត្រីសម្របសម្រួលទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍ | | មន្ត្រីសម្របសម្រួលទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍/វិស័យឯកជន | ~១០០ម៉ោង |
| ៥- ស្វែងរកយោបល់ពីឧស្សាហកម្មទេសចរណ៍ស្តីពីតួនាទីបន្តនៃមន្ត្រីសម្របសម្រួលទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍ | | មន្ត្រីសម្របសម្រួលទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍ | ~៤០ម៉ោង |

| | | | |
|---|---|---|---|
| ៦- ធ្វើឲ្យយន្តការទំនាក់ទំនងនិងប្រឹក្សាយោបល់ជាមួយឧស្សាហកម្មទេសចរណ៍កាន់តែប្រសើរឡើង។ | | មន្ត្រីសម្របសម្រួលទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍ | បន្ត |
| **បុគ្គលិកអាជ្ញាធរអប្សរា** | **បុគ្គលិកផ្សេងទៀត** | | |
| អគ្គនាយកអាជ្ញាធរអប្សរា | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | | |
| **តម្រូវការបណ្តុះបណ្តាល** | **កំណត់ចំណាំ** | | |
| មន្ត្រីសម្របសម្រួលទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍គួរមានចំណេះដឹងឬបទពិសោធមួយចំនួនលើវិស័យទេសចរណ៍។ ទោះជាយ៉ាងនេះក៏ដោយ ក៏មន្ត្រីរូបនេះត្រូវចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលជាបន្តលើបញ្ហាឧស្សាហកម្មទេសចរណ៍ ឬមានវត្តមាននៅក្នុងវេទិកាឧស្សាហកម្មទេសចរណ៍ផងដែរ។ | គ្មាន | | |

| “ទូរស័ព្ទខ្សែពិសេស” សម្រាប់ទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍ | សកម្មភាពអាទិភាព ១២ |
|---|---|
| **សេចក្តីសង្ខេប**<br>មន្ត្រីសម្របសម្រួលទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍របស់អាជ្ញាធរអប្សរា គួរមានលេខទូរស័ព្ទ “ខ្សែពិសេស” ដើម្បីឲ្យភ្ញៀវទេសចរនិងឧស្សាហកម្មទេសចរណ៍ អាចទំនាក់ទំនងនៅពេលត្រូវការជំនួយ។ | <br> |

## គោលបំណង

- ផ្តល់នូវសេវាកម្មមួយដែលជួយឲ្យឧស្សាហកម្មទេសចរណ៍ និងអ្នកពាក់ព័ន្ធដទៃអាចទំនាក់ទំនងជាមួយអាជ្ញាធរអប្សរាដោយងាយស្រួល
- ផ្តល់នូវសេវាកម្មជំនួយនិងគាំទ្រដែលមានស្តង់ដាសម្រាប់ឧស្សាហកម្មទេសចរណ៍ឲ្យបានទាន់ពេលវេលា
- ផ្តល់នូវសេវាកម្មដ៏មានសារៈសំខាន់ដើម្បីបង្កើនជំនាញនិងប្រសិទ្ធភាពប្រព័ន្ធគ្រប់គ្រងទេសចរណ៍ និងដើម្បីណែនាំពីវិធីទំនាក់ទំនងការងារថ្មីជាមួយឧស្សាហកម្មទេសចរណ៍
- រៀបចំយន្តការចែកចាយព័ត៌មានអំពីក្រមប្រតិបត្តិនិងសេចក្តីណែនាំផ្សេងៗរបស់អាជ្ញាធរអប្សរា

## ការផ្សារភ្ជាប់ទៅនឹងការផ្តួចផ្តើមចម្បង

ការអនុវត្តសកម្មភាពអាទិភាព១២ នឹងក្លាយជាសកម្មភាពរួមចំណែកក្នុងការផ្តួចផ្តើមចម្បងចំនុច **ឈ** ទំព័រទី១៩គឺទំនាក់ទំនង និងប្រាស្រ័យទាក់ទងជាមួយឧស្សាហកម្មទេសចរណ៍

**ដំណោះស្រាយ ៖**

កិច្ចប្រជុំការងារផែនការគ្រប់គ្រងវិស័យទេសចរណ៍នៅថ្ងៃទី១៨-១៩ ខែកញ្ញា ឆ្នាំ២០១២ រវាងអាជ្ញាធរអប្សរា ក្រសួងទេសចរណ៍ អង្គការយូណេស្កូ អ្នកពិគ្រោះយោបល់ Godden Mackay Logan(GML) និងអ្នកតំណាងមកពីវិស័យឯកជនបានអនុម័តនូវដំណោះស្រាយដូចខាងក្រោម៖

- ចែកចាយព័ត៌មានក្រមប្រតិបត្តិដល់អ្នកពាក់ព័ន្ធទាំងឡាយជាច្រើនភាសាតាមដែលអាចធ្វើបាន

| ភារកិច្ច | រយៈពេល | ទំនួលខុសត្រូវ | ធនធានស្នើឡើង |
|---|---|---|---|
| ១- បន្ទាប់ពីការតែងតាំងមន្ត្រីសម្របសម្រួលទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍ ត្រូវរៀបចំសំណើជាក់លាក់ដោយមានតម្លៃលម្អិតដើម្បីបង្កើតទូរស័ព្ទខ្សែពិសេសសម្រាប់សម្របសម្រួលទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍ | | មន្ត្រីសម្របសម្រួលទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍ | ~៨០ម៉ោង |
| ២- សម្រេចលើឧបករណ៍និងការទទួលខុសត្រូវរបស់អ្នកប្រើប្រាស់ទូរស័ព្ទខ្សែពិសេស | | | |
| ៣- ប្រកាសពីការប្រើប្រាស់ទូរស័ព្ទខ្សែពិសេសនៅក្នុងការប្រជុំក្រុមពិគ្រោះយោបល់ជាមួយ | | អគ្គនាយកអាជ្ញាធរអប្សរា | ~៨០០០ដុល្លារអាមេរិក |

| | | | |
|---|---|---|---|
| ឧស្សាហកម្មទេសចរណ៍ជាលើកដំបូង<br>៤- ដំឡើងទូរស័ព្ទខ្សែពិសេសនិងផ្សព្វផ្សាយលេខទូរស័ព្ទដោយមានជំនួយពីក្រុមពិគ្រោះយោបល់ជាមួយឧស្សាហកម្មទេសចរណ៍ | | អគ្គនាយកអាជ្ញាធរអប្សរា | TBD(នឹងត្រូវប្រកាស) |
| ៥- បង្កើតសៀវភៅកត់ត្រារាល់សំណួរនិងចម្លើយឆ្លើយតបនឹងសំណួរទាំងនេះ | | មន្ត្រីសម្របសម្រួលទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍ | បន្ត |
| ៦- វាយតម្លៃថាតើទូរស័ព្ទខ្សែពិសេសអាចប្រើដើម្បីបង្កើនការយល់ដឹងពីសំណាក់ភ្ញៀវទេសចរនិងឧស្សាហកម្មទេសចរណ៍ អំពីវិធាន និងក្រមប្រតិបត្តិរបស់អាជ្ញាអប្សរាដោយរបៀបណា | | មន្ត្រីអាជ្ញាធរអប្សរាដែលទទួលបានការតែងតាំង | ~៦០ម៉ោង |
| ៧- វាយតម្លៃការប្រើប្រាស់និងដំណើរការរបស់ទូរស័ព្ទខ្សែពិសេសបន្ទាប់ពី៦ខែដំបូង និងឆ្នាំដំបូងនៃប្រតិបត្តិការដោយមានជំនួយពីក្រុមពិគ្រោះយោបល់ឧស្សាហកម្មទេសចរណ៍។ | | មន្ត្រីសម្របសម្រួលទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍/ ក្រុមពិគ្រោះយោបល់ទំនងជាមួយឧស្សាហកម្មទេសចរណ៍ | ~៣០ម៉ោង |

| **បុគ្គលិកអាជ្ញាធរអប្សរា** | **បុគ្គលិកផ្សេងទៀត** |
| --- | --- |
| - អគ្គនាយកអាជ្ញាធរអប្សរា<br>- មន្ត្រីអាជ្ញាធរអប្សរាដែលទទួលខុសត្រូវក្នុងការអនុវត្តផែនការគ្រប់គ្រងទេសចរណ៍ | សមាជិកក្រុមប្រឹក្សាយោបល់ជាមួយឧស្សាហកម្មទេសចរណ៍ |
| **តម្រូវការបណ្តុះបណ្តាល** | **កំណត់ចំណាំ** |
| ការបណ្តុះបណ្តាលលើការប្រើប្រាស់ឧបករណ៍គោលនយោបាយ និងដំណើរការកឆ្លើយសំណួរជាតម្រូវការក្នុងការបណ្តុះបណ្តាលបុគ្គលិកនៅកន្លែងធ្វើការនិងអនុវត្តការងារ | គ្មាន |

| ដាក់បញ្ចូលព័ត៌មានថ្មីៗក្នុងគេហៈទំព័រអាជ្ញាធរអប្សរា | សកម្មភាពអាទិភាព ១៣ |
|---|---|
| **សេចក្តីសង្ខេប**<br>គួរដាក់បញ្ចូលព័ត៌មានថ្មីៗក្នុងគេហៈទំព័ររបស់អាជ្ញាធរអប្សរា និងតែងតាំងអ្នកបញ្ចូលទិន្នន័យក្នុងគេហៈទំព័រជាប្រចាំមួយរូប ដែលទទួលបានធនធានសម្ភារៈនិងសិទ្ធិក្នុងការបញ្ចូលព័ត៌មានក្នុងគេហៈទំព័រនេះ។ អ្នកបញ្ចូលទិន្នន័យគួរផ្ញើព័ត៌មានអេឡិចត្រូនិចជាប្រចាំទៅកាន់ឧស្សាហកម្មទេសចរណ៍។ អគ្គនាយកអាជ្ញាធរអប្សរាគួរអនុញ្ញាតឲ្យអ្នកបញ្ចូលទិន្នន័យប្រមូលព័ត៌មានពីប្រភពផ្សេងៗ និងចែកចាយព័ត៌មានដែលចាំបាច់។ |  |



**គោលបំណង ៖**

- ផ្តល់នូវព័ត៌មានឲ្យទាន់ពេលវេលានិងជាក់លាក់ដល់ឧស្សាហកម្មទេសចរណ៍ និងភ្ញៀវទេសចរ
- ធ្វើការប្រាស្រ័យទាក់ទងព័ត៌មាន បទពិសោធ និងឱកាសក្នុងការទស្សនា
- ធ្វើការប្រាស្រ័យទាក់ទងព័ត៌មានពាក់ព័ន្ធនឹងការផ្លាស់ប្តូរលក្ខខណ្ឌ ហានិភ័យ ការបិទប្រាសាទ ឬកត្តាដទៃដែលជះឥទ្ធិពលដល់ភ្ញៀវទេសចរ
- ផ្តល់ព័ត៌មានដល់ប្រជាជនក្នុងតំបន់ ជាតិ និងអន្តរជាតិ អំពីអាជ្ញាធរអប្សរានិងកិច្ចការរបស់អាជ្ញាធរអប្សរា
- ផ្តល់ព័ត៌មានទាក់ទងនឹងការអនុញ្ញាត វិធាន និងដំណើរការផ្សេងទៀតដែលជះឥទ្ធិពលដល់វិស័យទេសចរណ៍នៅអង្គរ
- ផ្តល់នូវយន្តការសម្រាប់ឲ្យសាធារណៈជនទំនាក់ទំនងជាមួយអាជ្ញាធរអប្សរា
- ធានាថាគេហៈទំព័រអាជ្ញាធរអប្សរាមានបញ្ចូលព័ត៌មានថ្មីៗទាន់ពេលវេលានិងជាប្រចាំ

**ការផ្សារភ្ជាប់ទៅនឹងការផ្តួចផ្តើមចម្បង ៖**

ការអនុវត្តសកម្មភាពអាទិភាព១៣ នឹងក្លាយជាសកម្មភាពរួមចំណែកក្នុងការផ្តួចផ្តើមចម្បងចំនុច**ឈ** ទំព័រទី១៩គឺទំនាក់ទំនង និងការប្រាស្រ័យទាក់ទងជាមួយឧស្សាហកម្មទេសចរណ៍

**ដំណោះស្រាយ ៖**

កិច្ចប្រជុំការងារផែនការគ្រប់គ្រងវិស័យទេសចរណ៍នៅថ្ងៃទី១៨-១៩ ខែកញ្ញា ឆ្នាំ២០១២ រវាងអាជ្ញាធរអប្សរា ក្រសួងទេសចរណ៍ អង្គការយូណេស្កូ អ្នកពិគ្រោះយោបល់ Godden Mackay Logan(GML) និងអ្នកតំណាងមកពីវិស័យឯកជនបានអនុម័តនូវដំណោះស្រាយដូចខាងក្រោម៖

- ទំនាក់ទំនងនិងប្រាស្រ័យទាក់ទងជាមួយឧស្សាហកម្មទេសចរណ៍
- តែងតាំងអ្នកបញ្ចូលទិន្នន័យក្នុងគេហៈទំព័ររបស់អាជ្ញាធរអប្សរា ដើម្បីលើកកម្ពស់និងពង្រឹងគេហៈទំព័ររបស់អាជ្ញាធរអប្សរា

| ភារកិច្ច | រយៈពេល | ទំនួលខុសត្រូវ | ធនធានស្នើឡើង |
|---|---|---|---|
| ១- បង្កើតការងារពេញម៉ោងសម្រាប់អ្នកបញ្ចូលទិន្នន័យក្នុងគេហៈទំព័ររបស់អាជ្ញាធរអប្សរា | | ប្រធានអាជ្ញាធរអប្សរា/ អគ្គនាយកអាជ្ញាធរអប្សរា | បៀវត្សពេញម៉ោង |
| ២- ជ្រើសរើសអ្នកបញ្ចូលទិន្នន័យក្នុងគេហៈទំព័ររបស់អាជ្ញាធរអប្សរា | | អគ្គនាយកអាជ្ញាធរអប្សរា | ~២០ម៉ោង |
| ៣- ពិនិត្យលើគេហៈទំព័រដែលមានស្រាប់ជាលក្ខណៈផ្ទៃក្នុងដើម្បីរកឲ្យឃើញកង្វះខាត | | អ្នកបញ្ចូលទិន្នន័យក្នុងគេហៈទំព័រ | ~៧០ម៉ោង |

| | | | |
|---|---|---|---|
| និងឱកាស<br>៤- បង្កើតគំរូសារព័ត៌មានអេឡិចត្រូនិច | | GML/ អ្នកបញ្ចូលទិន្នន័យក្នុងគេហៈទំព័រ | ~២០ម៉ោង |
| ៥- ចាប់ផ្តើមការប្រមូលព័ត៌មាននិងសកម្មភាពពីនាយកដ្ឋាននានា និងចែកចាយរបាយការណ៍សកម្មភាពតាមប្រព័ន្ធអេឡិចត្រូនិចប្រចាំខែដល់ឧស្សាហកម្មទេសចរណ៍និងអ្នកពាក់ព័ន្ធផ្សេងទៀត | | អ្នកបញ្ចូលទិន្នន័យក្នុងគេហៈទំព័រ | ~៣០ម៉ោង -បន្ត |
| ៦- ពិគ្រោះយោបល់ជាមួយអ្នកតំណាងឧស្សាហកម្មទេសចរណ៍ដែលពាក់ព័ន្ធនឹងតម្រូវការព័ត៌មានក្នុងគេហៈទំព័ររបស់អាជ្ញាធរអប្សរា | | អ្នកបញ្ចូលទិន្នន័យក្នុងគេហៈទំព័រ | ~២០ម៉ោង |
| ៧- វិភាគគេហៈទំព័រនៃរមណីយដ្ឋានបេតិកភណ្ឌវប្បធម៌ផ្សេងទៀត ដើម្បីទទួលបានគំនិតល្អៗ និង "ការអនុវត្តល្អបំផុត" | | អ្នកបញ្ចូលទិន្នន័យក្នុងគេហៈទំព័រ | ~៤០ម៉ោង |
| ៨- រៀបចំផែនការដាក់បញ្ចូលព័ត៌មានថ្មីៗក្នុងគេហៈទំព័រ ដើម្បីផ្តល់ព័ត៌មានដល់ភ្ញៀវទេសចរមុនពេលទស្សនា ដល់ឧស្សាហកម្ម | | អ្នកបញ្ចូលទិន្នន័យក្នុងគេហៈទំព័រ | ~១០០ម៉ោង |

| | | | |
|---|---|---|---|
| ទេសចរណ៍ និងដល់អ្នកពាក់ព័ន្ធផ្សេងទៀត | | | |
| ៩- អនុម័តផែនការដាក់បញ្ចូលព័ត៌មានថ្មីៗក្នុងគេហៈទំព័រ | | អគ្គនាយកអាជ្ញាធរអប្សរា | |
| ១០- អនុវត្តផែនការដាក់បញ្ចូលព័ត៌មានថ្មីៗក្នុងគេហៈទំព័រ | | អ្នកបញ្ចូលទិន្នន័យក្នុងគេហៈទំព័រ | TBD(នឹងត្រូវប្រកាស) |
| ១១- ស្នើសុំបញ្ចូលព័ត៌មានបន្ថែមជាផ្លូវការណាមួយក្នុងគេហៈទំព័រដូចជា ការរចនាក្រាហ្វិកថ្មី ទំព័រទំនាក់ទំនង ឬលទ្ធភាពសុំការអនុញ្ញាតតាមបណ្តាញអ៊ីនធឺណិត | | អ្នកបញ្ចូលទិន្នន័យក្នុងគេហៈទំព័រ | ~២០០០០០ដុល្លារ |
| ១២- បន្ថែមទំព័រ "បទពិសោធក្នុងការទស្សនាថ្ងៃលិច" ក្នុងគេហៈទំព័រអាជ្ញាធរអប្សរា | | GML/ អ្នកបញ្ចូលទិន្នន័យក្នុងគេហៈទំព័រ | បញ្ចូលទាំងគម្រោង "ទស្សនាថ្ងៃលិច" |
| ១៣- ពិនិត្យមាតិកាទំព័រគេហៈទំព័រឡើងវិញជារៀងរាល់ឆ្នាំ និងកិច្ចដំណើរការដោយមានការប្រឹក្សាយោបល់ជាមួយបុគ្គលិកអាជ្ញាធរអប្សរា និងឧស្សាហកម្មទេសចរណ៍ | | អ្នកបញ្ចូលទិន្នន័យក្នុងគេហៈទំព័រ/ ឧស្សាហកម្មទេសចរណ៍ | ~១០០ម៉ោង |
| ១៤- ធ្វើបច្ចុប្បន្នកម្មមាតិកាក្នុងគេហៈទំព័រប្រចាំខែឲ្យបានទៀងទាត់និងទាន់ពេលវេលា។ | | អ្នកបញ្ចូលទិន្នន័យក្នុងគេហៈទំព័រ | ~៦០ម៉ោង |

| បុគ្គលិកអាជ្ញាធរអប្សរា | បុគ្គលិកផ្សេងទៀត |
|---|---|
| - ប្រធានអាជ្ញាធរអប្សរា<br>- អគ្គនាយកអាជ្ញាធរអប្សរា<br>- គណៈកម្មាធិការបច្ចេកទេស(មន្ត្រីសម្របសម្រួលទំនាក់ទំនងដែលទទួលបានការតែងតាំង)<br>- អ្នកបញ្ចូលទិន្នន័យក្នុងគេហៈទំព័រ<br>- នាយកដ្ឋានទាំងអស់របស់អាជ្ញាធរអប្សរា(ក្នុងការផ្តល់ព័ត៌មាន) | - GML<br>- អ្នកជំនាញប្រឹក្សាយោបល់ពីខាងក្រៅ ស្តីពីការធ្វើនិងរចនាគេហៈទំព័រ<br>- អ្នកជំនាញចំពោះកិច្ចក្នុងការត្រួតពិនិត្យដំណើរជឿនលឿន |
| **តម្រូវការបណ្តុះបណ្តាល** | **កំណត់ចំណាំ** |
| គ្មាន | ការកែលម្អនិងពង្រឹងគេហៈទំព័ររបស់អាជ្ញាធរអប្សរាឲ្យបានប្រសើរឡើង គឺជាអាទិភាពខ្ពស់បំផុត។ នាយកដ្ឋាននៃអាជ្ញាធរអប្សរាទាំងអស់មានតួនាទីផ្តល់ព័ត៌មានត្រឹមត្រូវដល់អ្នកបញ្ចូលទិន្នន័យក្នុងគេហៈទំព័រឲ្យបានតាមពេលកំណត់ |

## គាំទ្រការផ្តល់វិញ្ញាបនបត្រសម្ភារៈសិប្បកម្មសុទ្ធនិងការលក់ដូរ

**សកម្មភាពអាទិភាព ៖ ១៤**

### សេចក្តីសង្ខេប

រដ្ឋាភិបាលគួរតែត្រៀមលក្ខណៈជាមុនក្នុងការផ្តួចផ្តើមគំនិត ដើម្បីជួយសម្រួលដល់ការផលិត និងលក់ផលិតផលសិប្បកម្មរបស់ប្រជាជនក្នុងតំបន់ដោយផ្ទាល់ទៅដល់ភ្ញៀវទេសចរនៅអង្គរ។ អាជ្ញាធរអប្សរា ក្រសួងទេសចរណ៍ នាយកដ្ឋានសិប្បកម្ម នៅក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល និងស្ថាប័ន រាជរដ្ឋាភិបាលដទៃទៀតគួរតែគាំទ្រដំណើរការនេះយ៉ាងសកម្ម តាមរយៈការផ្តល់វិញ្ញាបនបត្រ សមាគមសិប្បកម្មអង្គរនិងតាមរយៈការបណ្តុះបណ្តាលសិប្បករក្នុងតំបន់។



### គោលបំណង

- ជួយប្រជាជនក្នុងតំបន់ឧទ្យានអង្គរឲ្យទទួលបានផលចំណេញសេដ្ឋកិច្ចពីការអភិវឌ្ឍន៍ទេសចរណ៍
- ជួយសម្រួលការផលិតនិងលក់ផលិតផលក្នុងតំបន់សុទ្ធ
- ផ្តល់ជំនួយដល់ប្រជាជនក្នុងតំបន់តាមរយៈការបណ្តុះបណ្តាលស្តីពីការផលិតសម្ភារៈសិប្បកម្ម និងគ្រប់គ្រងមុខជំនួញ
- អប់រំ និងផ្តល់គ្រឿងទាក់ទាញដល់ប្រតិបត្តិករទេសចរណ៍ឲ្យនាំភ្ញៀវទេសចរទៅកន្លែងដែលពួកគេអាចទិញផលិតផលសិប្បកម្មប្រចាំតំបន់

### ការផ្សារភ្ជាប់ទៅនឹងការផ្តួចផ្តើមចម្បង

ការអនុវត្តសកម្មភាពអាទិភាព១៤ នឹងរួមចំណែកដល់ការផ្តួចផ្តើមចម្បងចំនុច **ឆ** ទំព័រទី១៤គឺសម្ភារៈសិប្បកម្មប្រចាំតំបន់

### ដំណោះស្រាយ

កិច្ចប្រជុំការងារផែនការគ្រប់គ្រងវិស័យទេសចរណ៍នៅថ្ងៃទី១៨-១៩ ខែកញ្ញា ឆ្នាំ២០១២ រវាងអាជ្ញាធរអប្សរា ក្រសួងទេសចរណ៍ អង្គការយូណេស្កូ

អ្នកពិគ្រោះយោបល់ Godden Mackay Logan(GML) និងអ្នកតំណាងមកពីវិស័យឯកជនបានអនុម័តនូវដំណោះស្រាយដូចខាងក្រោម៖

- សម្ភារៈសិប្បកម្មប្រចាំតំបន់
  ក. រាជរដ្ឋាភិបាលត្រូវដើរតួនាំទីដឹកនាំ
  ខ. អាជ្ញាធរអប្សរាគួរផ្តល់និងរៀបចំកន្លែងទំនេរដើម្បីលក់ផលិតផលសិប្បកម្មប្រចាំតំបន់ដែលផលិតដោយអ្នករស់នៅក្នុងឧទ្យានអង្គរ
  គ. ពិនិត្យមើលច្បាប់ហាមឃាត់ការលក់ផលិតផលនាំចូលថាជាផលិតផលតំបន់សុទ្ធ(ក្លែងក្លាយ)(យោងក្រសួងវប្បធមិនិងវិចិត្រសិល្បៈ)
  ឃ. បណ្តុះបណ្តាលប្រជាជនក្នុងតំបន់ស្តីពីគុណភាពផលិតផល ចំណេះដឹងហិរញ្ញវត្ថុ ទីផ្សារជនបទ ថ្លៃដើម ការកំណត់តម្លៃ ការគ្រប់គ្រងប្រាក់សន្សំ សហាគមន៍ ជំនាញចរចា ការស្វាគមន៍ភ្ញៀវទេសចរ ការលើកតម្លៃបេតិកភណ្ឌក្នុងតំបន់
  ង. តម្រូវការបណ្តុះបណ្តាលជាបន្តរយៈពេលវែងដើម្បីសម្រេចបានលទ្ធផលគាប់ប្រសើរ
  ច. ប្រតិបត្តិករទេសចរណ៍គួរបញ្ចូលភូមិដែលផលិតសម្ភារៈសិប្បកម្មនៅក្នុងកញ្ចប់ទេសចរណ៍របស់ពួកគេ
  ឆ. ជំរុញប្រព័ន្ធផ្តល់វិញ្ញាបនបត្រសម្រាប់ផលិតផលអង្គរ(ឧទាហរណ៍ ត្រាសម្ភារៈសុទ្ធដែលមានស្រាប់)

| ភារកិច្ច | រយៈពេល | ទំនួលខុសត្រូវ | ធនធានស្មើឡើង |
|---|---|---|---|
| ១- ប្រគល់កិច្ចការឲ្យមន្ត្រីអាជ្ញាធរអប្សរាទទួលខុសត្រូវលើសិប្បកម្មប្រចាំតំបន់ | | អគ្គនាយកអាជ្ញាធរអប្សរា | ~ ១០ម៉ោង |
| ២- ពិនិត្យមើលច្បាប់ដើម្បីធានាបង្កាការលក់ផលិតផលនាំចូលថាជាផលិតផលសិប្បកម្មសុទ្ធប្រចាំតំបន់ | | អាជ្ញាធរអប្សរា/ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | ~៤០ម៉ោង |

| | | | |
|---|---|---|---|
| ៣- សិក្សាពីផលិតផលសិប្បកម្មក្នុងតំបន់ ដើម្បីរៀបចំធនធាន ឱកាសនិងតម្រូវការនានា<br><br>៤- ផ្តល់កន្លែងទំនេរនៅតាមកន្លែងនានាក្នុងឧទ្យានអង្គរ(ឧទាហរណ៍ នៅទីធ្លាមុខប្រាសាទ) ដើម្បីលក់សម្ភារៈសិប្បកម្មដែលផលិតដោយអ្នករស់នៅឧទ្យានអង្គរផ្ទាល់ | | មន្រ្តីអាជ្ញាធរអប្សរាទទួលខុសត្រូវលើសិប្បកម្មប្រចាំតំបន់<br>មន្ត្រីដែលទទួលបានការតែងតាំង | ~៤០ម៉ោង<br><br>~៦០ម៉ោង |
| ៥- យកចិត្តទុកដាក់បណ្តុះបណ្តាលសិប្បករក្នុងតំបន់អំពីការផលិតនិងគុណភាពផលិតផល | | អាជ្ញាធរអប្សរា/ អ្នកបណ្តុះបណ្តាលពីខាងក្រៅ | ~៣០០ម៉ោង និងបន្ត |
| ៦- បណ្តុះបណ្តាលផលិតករតំបន់អំពីជំនាញជំនួញមូលដ្ឋានរួមមានចំណេះដឹងហិរញ្ញវត្ថុ ការធ្វើទីផ្សារជនបទ ថ្លៃដើម ការកំណត់តម្លៃ ការគ្រប់គ្រងប្រាក់សន្សំសហគមន៍ ជំនាញចរចា ការស្វាគមន៍ភ្ញៀវទេសចរ ការលើកតម្លៃបេតិកភណ្ឌក្នុងតំបន់ | | អាជ្ញាធរអប្សរា/ អ្នកបណ្តុះបណ្តាលពីខាងក្រៅ | ~៣០០ម៉ោង និងបន្ត |
| ៧- តម្រូវឲ្យប្រតិបត្តិករទេសចរណ៍ឲ្យដាក់បញ្ចូលភូមិដែលផលិតសម្ភារៈសិប្បកម្មក្នុងកញ្ចប់ទេសចរណ៍របស់ពួកគេ | | អាជ្ញាធរអប្សរា/ ក្រសួងទេសចរណ៍ | |

<table>
<tr><td>៨- ជំរុញនិងពង្រីកប្រព័ន្ធផ្តល់វិញ្ញាបនបត្រសម្រាប់ផលិតផលអង្គរ(ប្រើប្រាស់ឬពង្រីកត្រាសមាគមសិប្បកម្មអង្គរដែលមានស្រាប់ដើម្បីបញ្ជាក់អត្តសញ្ញាណផលិតផលសុទ្ធឬពីក្រសួងទេសចរណ៍)។</td><td></td><td>អាជ្ញាធរអប្សរា/ ក្រសួងទេសចរណ៍/ សមាគមសិប្បកម្ម</td><td>~២០០ម៉ោង និងបន្ត បូក ២០០០ដុល្លារ ប្រចាំឆ្នាំ សម្រាប់ការផ្សព្វផ្សាយ</td></tr>
<tr><td>បុគ្គលិកអាជ្ញាធរអប្សរា</td><td colspan="3">បុគ្គលិកផ្សេងទៀត</td></tr>
<tr><td>- មន្ត្រីអាជ្ញាធរអប្សរាទទួលខុសត្រូវសម្ភារៈសិប្បកម្មតំបន់<br>- នាយកដ្ឋានរៀបចំដែនដីនិងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរ<br>- អគ្គនាយកអាជ្ញាធរអប្សរាដើម្បីសុំការឯកភាព</td><td colspan="3">- ICC-Angkor និងអ្នកជំនាញចំពោះកិច្ច ដើម្បីស្នើសុំយោបល់និងត្រួតពិនិត្យ<br>- សមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា(CATA)<br>- ប្រតិបត្តិករទេសចរណ៍</td></tr>
<tr><td>តម្រូវការបណ្តុះបណ្តាល</td><td colspan="3">កំណត់ចំណាំ</td></tr>
<tr><td>• ការផលិតសម្ភារៈសិប្បកម្មសម្រាប់ប្រជាជនក្នុងតំបន់<br>• ប្រតិបត្តិការជំនួញខ្នាតតូចសម្រាប់ប្រជាជនក្នុងតំបន់<br>• ទស្សនកិច្ចបង្កើនទំនាក់ទំនងល្អ</td><td colspan="3">គ្មាន</td></tr>
</table>

| បង្កើត "ផ្សារលក់សម្ភារៈសិប្បកម្មក្នុងតំបន់" | សកម្មភាពអាទិភាព ១៥ |
| --- | --- |
| **សេចក្តីសង្ខេប**<br>អាជ្ញាធរអប្សរាគួរបង្កើត "ផ្សារលក់ផលិតផលសិប្បកម្មក្នុងតំបន់" នៅទីតាំងកណ្តាលក្នុងឧទ្យានអង្គរណាមួយដែលមានតែប្រជាជនក្នុងតំបន់ប៉ុណ្ណោះដែលអាចចូលទៅលក់ដូរ និងដោយធានាបាននូវផលិតផលសុទ្ធក្នុងតំបន់ដល់ភ្ញៀវទេសចរ។ ត្រូវពិចារណាលើ "ការកំណត់តម្លៃដាក់លាក់" ចំពោះផលិតផលដាក់លក់នៅផ្សារនេះ។ |  |
| **គោលបំណង**<br><br>• ជួយប្រជាជនក្នុងតំបន់ឧទ្យានអង្គរឲ្យទទួលបានផលចំណេញសេដ្ឋកិច្ចពីការអភិវឌ្ឍន៍ទេសចរណ៍<br>• ជួយសម្រួលដល់ការផលិតនិងលក់ផលិតផលសុទ្ធរបស់ប្រជាជនក្នុងតំបន់<br>• បង្កើនបទពិសោធអ្នកទស្សនាតាមរយៈការជួបអ្នកផលិត និងអ្នកលក់ផលិតផលក្នុងតំបន់ដោយផ្ទាល់<br>• លើកទឹកចិត្តដល់ប្រតិបត្តិករទេសចរណ៍ឲ្យនាំភ្ញៀវទេសចរទៅកន្លែងដែលពួកគេអាចទិញផលិតផលសិប្បកម្មប្រចាំតំបន់<br>• បង្កើតការទាក់ទាញទេសចរ "ថ្មី" ដើម្បីបែងចែកភ្ញៀវទេសចរនៅក្នុងតំបន់អង្គរ | |
| **ការផ្សារភ្ជាប់ទៅនឹងការផ្តួចផ្តើមចម្បង**<br>ការអនុវត្តសកម្មភាពអាទិភាព១៤ នឹងរួមចំណែកដល់ការផ្តួចផ្តើមចម្បងចំនុច **ខ** ទំព័រទី១៣គឺការគ្រប់គ្រងលំហូរអ្នកទស្សនា ចំនុច **ង** ទំព័រទី១៤គឺសេវាកម្មនិងបទពិសោធអ្នកទស្សនា និងចំនុច **ឆ** ទំព័រទី១៤គឺសម្ភារៈសិប្បកម្មប្រចាំតំបន់ | |

**ដំណោះស្រាយ**

កិច្ចប្រជុំការងារផែនការគ្រប់គ្រងវិស័យទេសចរណ៍នៅថ្ងៃទី១៨-១៩ ខែកញ្ញា ឆ្នាំ២០១២ រវាងអាជ្ញាធរអប្សរា ក្រសួងទេសចរណ៍ អង្គការយូណេស្កូ អ្នកពិគ្រោះយោបល់ Godden Mackay Logan(GML) និងអ្នកតំណាងមកពីវិស័យឯកជនបានអនុម័តនូវដំណោះស្រាយដូចខាងក្រោម៖

- សម្ភារៈសិប្បកម្មប្រចាំតំបន់
  ក. រដ្ឋាភិបាលត្រូវដើរតួនាំទីដឹកនាំ
  ខ. អាជ្ញាធរអប្សរាគួរផ្តល់និងរៀបចំកន្លែងលក់ផលិតផលសិប្បកម្មក្នុងតំបន់ដែលផលិតដោយអ្នករស់នៅឧទ្យានអង្គរ
  គ. ប្រតិបត្តិករទេសចរណ៍គួរបញ្ចូលការទស្សនាភូមិដែលមានសិប្បកម្មនៅក្នុងកញ្ចប់ទេសចរណ៍របស់ពួកគេ
  ឃ. ជំរុញប្រព័ន្ធផ្តល់វិញ្ញាបនបត្រសម្រាប់ផលិតផលអង្គរ(ឧទាហរណ៍ ត្រាសម្ភារៈសុទ្ធដែលមានស្រាប់)

| ភារកិច្ច | រយៈពេល | ទំនួលខុសត្រូវ | ធនធានស្នើឡើង |
|---|---|---|---|
| ១- ប្រគល់ការងារឲ្យមន្ត្រីអាជ្ញាធរអប្សរាទទួលខុសត្រូវលើសិប្បកម្មក្នុងតំបន់ ជាអ្នកសម្របសម្រួលផ្សារសម្ភារៈសិប្បកម្មក្នុងតំបន់ | | អគ្គនាយកអាជ្ញាធរអប្សរា | ~១០ម៉ោង និងពេញម៉ោង |
| ២- បង្កើតក្រុមការងាររៀបចំគម្រោងផ្សារសម្ភារៈសិប្បកម្មក្នុងតំបន់ ដោយមានការចូលរួមពីនាយកដ្ឋានជំនាញរបស់អាជ្ញាធរអប្សរា ភូមិក្នុងតំបន់និងអ្នកពាក់ព័ន្ធផ្សេងទៀត | | អាជ្ញាធរអប្សរា | ~២០ម៉ោង |

| | | | |
|---|---|---|---|
| ៣- ស្ទាបស្ទង់និងវាយតម្លៃបឋមពីទីតាំងផ្សារលក់សម្ភារៈសិប្បកម្មដែលមានសក្តានុពល | | អ្នកសម្របសម្រួលផ្សារសម្ភារៈសិប្បកម្មក្នុងតំបន់ | ~៦០ម៉ោង |
| ៤- អង្កេតពីតំបន់ដែលមានសក្តានុពលសម្រាប់សម្ភារៈសិប្បកម្ម | | អ្នកសម្របសម្រួលផ្សារសម្ភារៈសិប្បកម្មក្នុងតំបន់ | ~៦០ម៉ោង |
| ៥- រៀបចំសិក្ខាសាលាផ្ទៃក្នុងអាជ្ញាធរអប្សរាស្តីពីលទ្ធភាពដែលអាចសម្រេចបាន | | អ្នកសម្របសម្រួលផ្សារសម្ភារៈសិប្បកម្មក្នុងតំបន់ | ~៤០ម៉ោង |
| ៦- ពិគ្រោះយោបល់ជាមួយសមាគមសិប្បកម្មអង្គរ | | អ្នកសម្របសម្រួលផ្សារសម្ភារៈសិប្បកម្មក្នុងតំបន់ | ~២០ម៉ោង |
| ៧- ពិគ្រោះយោបល់ជាមួយតំណាងឧស្សាហកម្មទេសចរណ៍និងក្រសួងទេសចរណ៍ | | អ្នកសម្របសម្រួលផ្សារសម្ភារៈសិប្បកម្មក្នុងតំបន់/ ក្រុមការងារ | ~២០ម៉ោង |
| ៨- កំណត់ទីតាំងផ្សារ | | អាជ្ញាធរអប្សរា / អ្នកសម្របសម្រួលផ្សារសម្ភារៈសិប្បកម្មក្នុងតំបន់ | ~៦០ម៉ោង |
| ៩- រៀបចំឲ្យមានការសាកល្បង | | អ្នកសម្របសម្រួលផ្សារសម្ភារៈសិប្បកម្មក្នុងតំបន់ | ~៦០ម៉ោង |
| ១០- ផ្ទៀងផ្ទាត់លទ្ធផលនៃការដាក់ដំណើរការសាកល្បង ដោយពិគ្រោះយោបល់ជាមួយអ្នក | | អាជ្ញាធរអប្សរា / អ្នកសម្របសម្រួលផ្សារ | ~៧០ម៉ោង |

| | | | |
|---|---|---|---|
| ចូលរួម ក្រសួងទេសចរណ៍និងអាជ្ញាធរអប្សរា | | សម្ភារៈសិប្បកម្មក្នុងតំបន់ / ក្រុមការងារ | |
| ១១- សម្រេចលើចំណាត់ការប្រតិបត្តិការ ទីកន្លែងសម្ភារៈរូបវន្ត ម៉ោងបើក ការកំណត់ទីតាំងលក់ដូរ។ល។ | | អ្នកសម្របសម្រួលផ្សារសម្ភារៈសិប្បកម្មក្នុងតំបន់/ ក្រុមការងារ | ~១០០ម៉ោង |
| ១២- រៀបចំផែនការគម្រោងលម្អិត | | អ្នកសម្របសម្រួលផ្សារសម្ភារៈសិប្បកម្មក្នុងតំបន់/ ក្រុមការងារ | ~១០០ម៉ោង |
| ១៣- សាងសង់ហេដ្ឋារចនាសម្ព័ន្ធដែលចាំបាច់ | | មន្ត្រីដែលទទួលបានការតែងតាំង | ~២០០០០០ដុល្លារ |
| ១៤- រៀបចំច្បាប់និងវិធាននានា | | អ្នកសម្របសម្រួលផ្សារសម្ភារៈសិប្បកម្មក្នុងតំបន់ | ~ ៥០ម៉ោង |
| ១៥- កំណត់ទីតាំងកន្លែងលក់ដូរ | | អ្នកសម្របសម្រួលផ្សារសម្ភារៈសិប្បកម្មក្នុងតំបន់ | ~ ៥០ម៉ោង |
| ១៦- ជួយផ្សព្វផ្សាយផលិតផលជាមួយប្រតិបត្តិករទេសចរណ៍ តាមបណ្តាញព័ត៌មានក្នុងតំបន់ថ្នាក់ជាតិ និងអន្តរជាតិ។ | | អាជ្ញាធរអប្សរា / អ្នកសម្របសម្រួលផ្សារសម្ភារៈសិប្បកម្មក្នុងតំបន់/ ក្រុមការងារ | ~ ៧០ម៉ោង និង ប្រហែល ៣០០០ដុល្លារ ក្នុងមួយឆ្នាំ |

| | | | |
|---|---|---|---|
| | | | |
| **បុគ្គលិកអាជ្ញាធរអប្សរា** | **បុគ្គលិកផ្សេងទៀត** | | |
| - មន្ត្រីអាជ្ញាធរអប្សរាទទួលខុសត្រូវសម្ភារៈសិប្បកម្មក្នុងតំបន់<br>- នាយកដ្ឋានរៀបចំដែនដីនិងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរ<br>- អគ្គនាយកអាជ្ញាធរអប្សរា ដើម្បីសុំការឯកភាព<br>- នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ<br>- មន្ត្រីអាជ្ញាធរអប្សរាដែលពាក់ព័ន្ធផ្សេងទៀត | - ICC-Angkor និងអ្នកជំនាញចំពោះកិច្ច ដើម្បីស្នើសុំយោបល់និងត្រួតពិនិត្យ<br>- ក្រសួងទេសចរណ៍<br>- ប្រតិបត្តិករទេសចរណ៍<br>- សិប្បករក្នុងតំបន់ឧទ្យានអង្គរ | | |
| **តម្រូវការបណ្ដុះបណ្ដាល** | **កំណត់ចំណាំ** | | |
| • ប្រតិបត្តិការជំនួញខ្នាតតូចសម្រាប់ប្រជាជនក្នុងតំបន់ | ត្រូវរៀបចំវិធីសាស្ត្រនិងអនុវត្តផែនការគម្រោង នៅពេលគម្រោងនេះដំណើរការទៅមុខ | | |

| ការអភិរក្សនិងការបង្ហាញបេតិកភណ្ឌក្រុងសៀមរាប | សកម្មភាពអាទិភាព ១៦ |
|---|---|
| **សេចក្ដីសង្ខេប**<br>អាជ្ញាធរអប្សរានិងអាជ្ញាធរខេត្តសៀមរាបគួរតែសហការគ្នាក្នុងការអភិរក្សនិងបង្ហាញពីបេតិកភណ្ឌវប្បធម៌ក្រុងសៀមរាប ដែលជាផ្នែកមួយនៃបទពិសោធរបស់អ្នកទស្សនាអង្គរផងដែរ។ ការគ្រប់គ្រងនេះគួរតែរួមបញ្ចូលការអភិរក្ស ការបកស្រាយពីទម្រង់វប្បធម៌ ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ការកែលម្អសម្ភារៈរូបវន្តដើម្បីធានាថាក្រុងសៀមរាបមិនទទួលរងការគំរាមកំហែងពីទឹកជំនន់ ការផ្ដល់សេវាកម្មទេសចរណ៍ចាំបាច់ដូចជាចំណត និងការបង្ហាញឱកាសគួរឲ្យទាក់ទាញសម្រាប់អ្នកទស្សនា។ |  |

**គោលបំណង**

ដើម្បីអភិរក្សបេតិកភណ្ឌវប្បធម៌ក្រុងសៀមរាប ពង្រីកបទពិសោធអ្នកទស្សនា និងបន្ថយសម្ពាធនៅតាមផ្លូវបច្ចុប្បន្នដោយ

- បន្តកំណត់អត្តសញ្ញាណនិងអភិរក្សទម្រង់ធម្មជាតិនិងវប្បធម៌ក្រុងសៀមរាប ដោយបញ្ចូលទាំងអគារសល់ពីសម័យអាណានិគមបារាំង សំណង់ប្រពៃណីខ្មែរ និងហេដ្ឋារចនាសម្ព័ន្ធនៅក្នុងទីក្រុង
- ផ្ដល់នូវការការពារផ្នែកច្បាប់សម្រាប់ទម្រង់ទាំងនេះ
- រៀបចំផែនការបកស្រាយព័ត៌មានដើម្បីពន្យល់និងបង្ហាញពីទម្រង់ទាំងនេះដល់ភ្ញៀវទេសចរនិងប្រជាជនក្នុងតំបន់
- ដាក់បញ្ចូលការបកស្រាយពីទម្រង់ធម្មជាតិនិងវប្បធម៌ក្រុងសៀមរាប ជាចំណែកមួយនៃបទពិសោធអ្នកទស្សនានៅអង្គរ ដោយរួមមានការផ្ដល់ឱកាសទាក់ទាញភ្ញៀវទេសចរដូចជារង់ទស្សនានិងដំណើរកម្សាន្ត
- ផ្សព្វផ្សាយពីទម្រង់ធម្មជាតិនិងវប្បធម៌ក្រុងសៀមរាប ជាចំណែកមួយនៃបទពិសោធអ្នកទស្សនានៅអង្គរ

- បង្កើនសេវាកម្មទេសចរណ៍សំខាន់ៗ តាមរយៈការសាងសង់និងកែលម្អហេដ្ឋារចនាសម្ព័ន្ធ
- បន្តកម្មវិធីការពារបរិស្ថាន និងធានាថាសៀមរាបមិនទទួលការគំរាមកំហែងពីទឹកជំនន់

**ការផ្សារភ្ជាប់ទៅនឹងការផ្តួចផ្តើមចម្បង**

ការអនុវត្តសកម្មភាពអាទិភាព១៦ នឹងរួមចំណែកដល់ការផ្តួចផ្តើមចម្បងចំនុច **ញ** ទំព័រទី១៥ គឺសៀមរាប ទន្លេសាប និងភ្នំគូលែន

**ដំណោះស្រាយ**

កិច្ចប្រជុំការងារផែនការគ្រប់គ្រងវិស័យទេសចរណ៍នៅថ្ងៃទី១៨-១៩ ខែកញ្ញា ឆ្នាំ២០១២ រវាងអាជ្ញាធរអប្សរា ក្រសួងទេសចរណ៍ អង្គការយូណេស្កូ អ្នកពិគ្រោះយោបល់ Godden Mackay Logan(GML) និងអ្នកតំណាងមកពីវិស័យឯកជនបានអនុម័តនូវដំណោះស្រាយដូចខាងក្រោម៖

- ដាក់បញ្ចូលបេតិកភណ្ឌវប្បធម៌ក្រុងសៀមរាបទៅក្នុងគោលនយោបាយយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងទេសចរណ៍នៅតំបន់អង្គរនិងតំបន់ទ្រនាប់
- ពង្រឹងលទ្ធភាពអាជ្ញាធរអប្សរាក្នុងការការពារពីការបំផ្លាញនិងអភិវឌ្ឍន៍បេតិកភណ្ឌវប្បធម៌ក្រុងសៀមរាប ក៏ដូចជាបេតិកភណ្ឌធម្មជាតិរបស់ក្រុង(ប្រឡាយទឹក)
- ធ្វើឲ្យសម្ភារៈរូបវន្តនៃក្រុងសៀមរាបដែលជាក្រុងវប្បធម៌មានភាពប្រសើរឡើង ដើម្បីបង្កើតនិងអនុវត្តផែនការទាំងមូលរួមមានវង់ទស្សនាហេដ្ឋារចនាសម្ព័ន្ធ ចំណត សេវាកម្មទេសចរណ៍។ល។

| ភារកិច្ច | រយៈពេល | ទំនួលខុសត្រូវ | ធនធានស្នើឡើង |
|---|---|---|---|
| ១- តែងតាំងបុគ្គលិកអាជ្ញាធរអប្សរាដើម្បីទទួល | | អគ្គនាយកអាជ្ញាធរ | ~១០ម៉ោង |

| | | | |
|---|---|---|---|
| ខុសត្រូវលើការងារនេះ | | អប្សរា | |
| ២- បន្តការងារ កំណត់ និងអភិរក្សទម្រង់ធម្មជាតិ និងវប្បធម៌ក្រុងសៀមរាប | | អាជ្ញាធរអប្សរា/ អាជ្ញាធរខេត្ត | គ្មានធនធានបន្ថែម |
| ៣- ដាក់បញ្ចូលការងារក្នុងផែនការអភិរក្សនិង បកស្រាយព័ត៌មានអំពីក្រុងសៀមរាប | | អាជ្ញាធរអប្សរា/ អាជ្ញាធរខេត្ត/ អ្នកពិគ្រោះយោបល់ | ~៧០០០០ដុល្លារ |
| ៤- ពិនិត្យនិងបង្កើនចំនួនសម្ភារៈរូបវន្តនៅក្នុង ក្រុងសៀមរាប រួមបញ្ចូលទាំងការរៀបចំ មជ្ឈមណ្ឌលសម្រាប់ភ្ញៀវទេសចរ | | អាជ្ញាធរអប្សរា/ អាជ្ញាធរខេត្ត | TBD(នឹងត្រូវប្រកាស) |
| ៥ បញ្ចូលក្រុងសៀមរាបទៅក្នុងសំណើរៀបចំ ប្រព័ន្ធដឹកជញ្ជូនថ្មីនៅក្នុងតំបន់អង្គរ | | អាជ្ញាធរអប្សរា | បញ្ចូលក្នុងសកម្មភាព អាទិភាព ៥ |
| ៦- សហការជាមួយអាជ្ញាធរខេត្តនិងអ្នកពាក់ព័ន្ធ ផ្សេងដើម្បីរៀបចំផែនការសេវាកម្ម ទេសចរណ៍នៅក្នុងក្រុងសៀមរាប | | អាជ្ញាធរអប្សរា/ អាជ្ញាធរ ខេត្ត/ អ្នកជំនាញ | ~៥០០០០ដុល្លារ |
| ៧- រៀបចំយុទ្ធសាស្ត្ររយៈពេលវែងដើម្បីការពារ បេតិកភណ្ឌក្រុងតាមផ្លូវច្បាប់ក្នុងតំបន់ទីបីនៃ តំបន់បេតិកភណ្ឌពិភពលោកអង្គរ | | អាជ្ញាធរអប្សរា/ រាជរដ្ឋាភិបាលកម្ពុជា | ~២០០០០ដុល្លារ |
| ៨- ស្វែងរកការអនុម័តលើផែនការបកស្រាយ | | រាជរដ្ឋាភិបាលកម្ពុជា/ | |

| | | | |
|---|---|---|---|
| ព័ត៌មានស្តីពីបេតិកភណ្ឌក្រុងសៀមរាបពី រាជរដ្ឋាភិបាលកម្ពុជានិង ICC-Angkor | | ICC-Angkor | |
| ៩- រៀបចំកម្មវិធីបង្ហាញពីសារៈសំខាន់នៃវប្បធម៌ក្រុងសៀមរាបនិងការទាក់ទាញពីតំបន់ជុំវិញ ព្រមទាំងគាំទ្រការផ្តួចផ្តើមទេសចរណ៍ក្នុងតំបន់ជាចំណែកមួយនៃបទពិសោធអ្នកទស្សនានៅអង្គរ | | អាជ្ញាធរអប្សរា/ក្រសួងទេសចរណ៍/ ឧស្សាហកម្មទេសចរណ៍/អ្នកពាក់ព័ន្ធផ្សេងទៀត | TBD(នឹងត្រូវប្រកាស) |
| ១០- បញ្ចប់គម្រោងបង់លេខផ្លូវនិងរៀបចំវង់ទស្សនានិងដំណើរកម្សាន្តក្នុងក្រុងសៀមរាប | | អាជ្ញាធរអប្សរា/ រាជរដ្ឋាភិបាលកម្ពុជា/ ICC-Angkor | កម្មវិធីដែលមានស្រាប់ |
| ១១- បន្តការងារការពារទឹកជំនន់នៅសៀមរាប និងសមាសធាតុវប្បធម៌សំខាន់របស់គេ។ | | អាជ្ញាធរអប្សរា/ អាជ្ញាធរខេត្ត | កម្មវិធីដែលមានស្រាប់ |

| **បុគ្គលិកអាជ្ញាធរអប្សរា** | **បុគ្គលិកផ្សេងទៀត** |
|---|---|
| - អគ្គនាយកអាជ្ញាធរអប្សរា<br>- ប្រធាននាយកដ្ឋានអភិវឌ្ឍន៍បេតិកភណ្ឌក្រុងក្នុងតំបន់សៀមរាប<br>- អគ្គនាយករងអាជ្ញាធរអប្សរានិងប្រធាននាយកដ្ឋាន | - អ្នកជំនាញចំពោះកិច្ច<br>- អ្នកជំនាញពិគ្រោះយោបល់ខាងក្រៅ អំពីការបកស្រាយគម្រោង<br>- ម្ចាស់ជំនួយ<br>- ក្រសួងទេសចរណ៍ |

| | |
|---|---|
| គ្រប់គ្រងទឹក | - អាជ្ញាធរខេត្តសៀមរាប |
| **តម្រូវការបណ្តុះបណ្តាល** | **កំណត់ចំណាំ** |
| មគ្គុទ្ទេសក៍ទេសចរណ៍នឹងត្រូវការនូវការបណ្តុះបណ្តាលអំពីការបកស្រាយពីក្រុងសៀមរាប | ដាក់បញ្ចូលជាផ្នែកមួយនៃកម្មវិធីបណ្តុះបណ្តាលមគ្គុទ្ទេសក៍ |

## រៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ភ្នំគូលែន

**សកម្មភាពអាទិភាព ១៧**

### សេចក្តីសង្ខេប

ដោយទទួលស្គាល់ថាការផ្សារភ្ជាប់រវាងភ្នំគូលែននិងអង្គរមានសារៈសំខាន់ រាជរដ្ឋាភិបាលកម្ពុជាគួររៀបចំនិងអនុវត្តផែនការយុទ្ធសាស្ត្រទាំងស្រុងមួយដើម្បីបញ្ឈប់ការកាប់បំផ្លាញព្រៃឈើ ការបង្កើតឲ្យមានការដាំដើមឈើឡើងវិញ ការការពារ ការបំផ្លាញរមណីយដ្ឋានប្រវត្តិសាស្ត្រនិងការការពារបរិស្ថានភ្នំគូលែន។



### គោលបំណង

ធានាការថែរក្សា អភិរក្សរយៈពេលវែង និងកែលម្អបរិស្ថានធម្មជាតិនិងវប្បធម៌ភ្នំគូលែនឲ្យបានប្រសើរឡើងជាពិសេសព្រៃឈើ ប្រាសាទនិងទម្រង់បេតិកភណ្ឌផ្សេងទៀត ដោយរៀបចំនិងអនុវត្តផែនការយុទ្ធសាស្ត្រសម្រាប់ភ្នំគូលែនដើម្បី

- បង្ការការកាប់បំផ្លាញព្រៃឈើ
- បង្កើតកម្មវិធីដាំដើមឈើឡើងវិញ
- កំណត់និងអភិរក្សគុណតម្លៃនៃរមណីយដ្ឋានរួមមានប្រាសាទ ចម្លាក់ថ្ម តំបន់ជុំវិញអង្គរ និងទម្រង់ផ្សេងទៀត
- អភិរក្សសមាសធាតុផ្សេងទៀតនៃបរិស្ថានធម្មជាតិភ្នំគូលែន
- ផ្តល់មូលដ្ឋានសេដ្ឋកិច្ចប្រកបដោយចីរភាព ដើម្បីធ្វើឲ្យជីវភាពរស់នៅរបស់ប្រជាជនបានប្រសើរឡើងមួយកម្រិតនិងអភិរក្សបរិស្ថាន
- បង្កើនឱកាសដល់វិស័យទេសចរណ៍ប្រកបដោយទំនួលខុសត្រូវ
- ថែរក្សាប្រព័ន្ធទឹកនៃតំបន់អង្គរនិងក្រុងសៀមរាប
- ជំរុញទេសចរណ៍វប្បធម៌និងធម្មជាតិនៅភ្នំគូលែននិងតំបន់ជុំវិញ

| ការផ្សារភ្ជាប់ទៅនឹងការផ្តួចផ្តើមចម្បង<br>ការអនុវត្តសកម្មភាពអាទិភាព១៧ ជាការចាប់ផ្តើមនៃការផ្តួចផ្តើមចម្បងចំនុច ៣ ទំព័រទី១៥ គឺសៀមរាប ទន្លេសាប និងភ្នំគូលែន | | | |
|---|---|---|---|
| **ដំណោះស្រាយ**<br>កិច្ចប្រជុំការងារផែនការគ្រប់គ្រងវិស័យទេសចរណ៍នៅថ្ងៃទី១៨-១៩ ខែកញ្ញា ឆ្នាំ២០១២ រវាងអាជ្ញាធរអប្សរា ក្រសួងទេសចរណ៍ អង្គការយូណេស្កូ អ្នកពិគ្រោះយោបល់ Godden Mackay Logan(GML) និងអ្នកតំណាងមកពីវិស័យឯកជនបានអនុម័តនូវដំណោះស្រាយដូចខាងក្រោម៖<br>• ការបន្តកាប់បំផ្លាញព្រៃឈើនៅភ្នំគូលែនគំរាមកំហែងដល់រមណីយដ្ឋានអង្គរ និងក្រុងសៀមរាបដោយទឹកជំនន់ គ្រោះធម្មជាតិ ដែលអាចជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់វិស័យទេសចរណ៍។ ដូច្នេះ សកម្មភាពជាបន្ទាន់ គឺបញ្ឈប់នូវការកាប់បំផ្លាញព្រៃឈើឲ្យបានឆាប់តាមដែលអាចធ្វើទៅបាននិងជំរុញការអនុវត្តផែនការយុទ្ធសាស្រ្តរួមមាន៖<br>ក- ការដាំដើមឈើឡើងវិញ<br>ខ- ការការពារពីការបំផ្លាញរមណីយដ្ឋានប្រវត្តិសាស្រ្ត<br>គ- ការការពារបរិស្ថាន | | | |
| **ភារកិច្ច** | **រយៈពេល** | **ទំនួលខុសត្រូវ** | **ធនធានស្នើឡើង** |
| ១- បំភ្លឺពីសមត្ថកិច្ចនិងការទទួលខុសត្រូវរបស់អាជ្ញាធរអប្សរានិងស្ថាប័នរដ្ឋាភិបាលដទៃទៀតក្នុងការគ្រប់គ្រងភ្នំគូលែននិងតំបន់ជុំវិញ | | នាយករដ្ឋមន្ត្រី | |
| ២- តែងតាំងបុគ្គលិកអាជ្ញាធរអប្សរាឲ្យទទួលខុសត្រូវលើការងារនេះ | | អគ្គនាយកអាជ្ញាធរអប្សរា | ~២០ម៉ោង |

| | | | |
|---|---|---|---|
| ៣- បង្ហាញអនុសាសន៍របស់ ICC-Angkor ក្នុងការរៀបចំផែនការគម្រោងយុទ្ធសាស្ត្រ | | បុគ្គលិកដែលទទួលបានការតែងតាំង | |
| ៤- សហការជាមួយគម្រោងមូលនិធិបុរាណវិទ្យានិងការអភិវឌ្ឍន៍ភ្នំគូលែន(ADF: Archaeology & Development Foundation) ក្រសួងបរិស្ថាន និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីរៀបចំសិក្សាផែនការយុទ្ធសាស្ត្រ | | បុគ្គលិកដែលទទួលបានការតែងតាំង/ ADF/ ក្រសួងបរិស្ថាន/ អ្នកពាក់ព័ន្ធផ្សេងទៀត | ~២០ម៉ោង |
| ៥- ស្វែងរកម្ចាស់ជំនួយ/ដៃគូ/អ្នកពិគ្រោះយោបល់ ដើម្បីធ្វើការជាមួយអាជ្ញាធរអប្សរាក្នុងការរៀបចំផែនការនេះ | | បុគ្គលិកដែលទទួលបានការតែងតាំង | TBD(នឹងត្រូវប្រកាស) |
| ៦- រៀបចំសេចក្តីសង្ខេបស្តីផែនការយុទ្ធសាស្ត្រ ដោយពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ | | បុគ្គលិកដែលទទួលបានការតែងតាំង/ ADF/ ក្រសួងបរិស្ថាន/ អ្នកពាក់ព័ន្ធផ្សេងទៀត | ~២០០ម៉ោង |
| ៧- រៀបចំផែនការយុទ្ធសាស្ត្រដែលផ្តល់ការការពារគុណតម្លៃធម្មជាតិ និងវប្បធម៌ និងការអភិវឌ្ឍន៍ភ្នំគូលែនប្រកបដោយចីរភាព | | បុគ្គលិកដែលទទួលបានការតែងតាំង/ អ្នកពិគ្រោះយោបល់ | ~១៩ខែ/~៤០០០០០ដុល្លារ |
| ៨- ជំរុញទេសចរណ៍ធម្មជាតិនិងវប្បធម៌ប្រកបដោយ | | អាជ្ញាធរអប្សរា | |

| | | | |
|---|---|---|---|
| ចីរភាព<br>៩- កំណត់អាទិភាពក្នុងការអនុវត្តនិងបញ្ចប់ផែនការយុទ្ធសាស្ត្រ<br>១០- ស្វែងរកការគាំទ្រផែនការយុទ្ធសាស្ត្រពីរាជរដ្ឋាភិបាលកម្ពុជានិង ICC-Angkor<br>១១- អនុវត្តផែនការយុទ្ធសាស្ត្រសម្រាប់ភ្នំគូលែន | | អាជ្ញាធរអប្សរា/<br>អ្នកប្រឹក្សាយោបល់<br>ប្រធានអាជ្ញាធរអប្សរា/<br>ICC-Angkor<br>អាជ្ញាធរអប្សរា | TBD(នឹងត្រូវប្រកាស)<br><br><br><br>TBD(នឹងត្រូវប្រកាស) |

| **បុគ្គលិកអាជ្ញាធរអប្សរា** | **បុគ្គលិកផ្សេងទៀត** |
|---|---|
| - អគ្គនាយកអាជ្ញាធរអប្សរា<br>- នាយកដ្ឋានអភិរក្សប្រាសាទក្រៅឧទ្យានអង្គរ | - អ្នកជំនាញចំពោះកិច្ច<br>- អ្នកជំនាញពិគ្រោះយោបល់ខាងក្រៅ<br>- បុគ្គលិកពីគម្រោងមូលនិធិបុរាណវិទ្យានិងការអភិវឌ្ឍន៍ភ្នំគូលែន |

| **តម្រូវការបណ្តុះបណ្តាល** | **កំណត់ចំណាំ** |
|---|---|
| TBD(នឹងត្រូវប្រកាស) | កិច្ចការងារនៅភ្នំគូលែនគួរត្រូវធ្វើឡើងដោយការប្រឹក្សាយោបល់ជាមួយក្រុមការងារADF ព្រមទាំងក្រសួងនិងអ្នកដែលពាក់ព័ន្ធផ្សេងទៀត។ |

# សទ្ទានុក្រម

| | |
|---|---|
| ICC-Angkor | គណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារនិងអភិរក្សរមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ |
| HMF (Heritage Management Framework) | ក្របខ័ណ្ឌគ្រប់គ្រងបេតិកភណ្ឌអង្គរ |
| TMP (Tourism Management Plan) | ផែនការគ្រប់គ្រងទេសចរណ៍ |
| អាជ្ញាធរអប្សរា | អាជ្ញាធរដើម្បីការការពាររមណីយដ្ឋាននិងរៀបចំតំបន់អង្គរ។ អាជ្ញាធរអប្សរាក៏ទទួលខុសត្រូវគ្រប់គ្រងតំបន់ប្រាសាទក្រៅឧទ្យានអង្គរ។ |
| អង្គរ | តំបន់បេតិកភណ្ឌដ៏ធំមួយនៅភាគពាយ័ព្យប្រទេសកម្ពុជា ដែលត្រូវបានដាក់បញ្ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោកក្នុងឆ្នាំ ១៩៩២ ដោយមានបែងចែកជាតំបន់ការពារនិងតំបន់ទ្រនាប់។ |
| មជ្ឈមណ្ឌលសេវាកម្មអាជ្ញាធរអប្សរា | ច្រក "ចេញចូលតែមួយ" នៅក្នុងទីស្នាក់ការកណ្តាលអាជ្ញាធរអប្សរា សម្រាប់ផ្តល់សេវាស្នើសុំលិខិតអនុញ្ញាតនិងពាក្យស្នើសុំនានា។ |
| ឧស្សាហកម្មទេសចរណ៍ | អ្នកពាក់ព័ន្ធនានាដែលជាប់ទាក់ទងនៅក្នុងវិស័យទេសចរណ៍ រួមមានប្រតិបត្តិករទេសចរណ៍ ទីភ្នាក់ងារទេសចរណ៍ អ្នកដឹកជញ្ជូន មគ្គុទ្ទេសក៍ទេសចរណ៍ សណ្ឋាគារ និងភោជនីយដ្ឋាន។ |
| មន្ត្រីសម្របសម្រួលទំនាក់ទំនងជាមួយឧស្សាហកម្មទេសចរណ៍ | ជាបុគ្គលិកជាន់ខ្ពស់របស់អាជ្ញាធរអប្សរា ដែលទទួលបានសិទ្ធិពីអគ្គនាយក ដើម្បីសម្របសម្រួលទំនាក់ទំនងជាមួយវិស័យទេសចរណ៍ឯកជន។ |
| គណៈកម្មាធិការបច្ចេកទេស | គណៈកម្មាធិការ ដែលរួមមានបុគ្គលិកជំនាញបច្ចេកទេសរបស់អាជ្ញាធរអប្សរាទទួលបានការកសាងសមត្ថភាពគ្រប់គ្រងតំបន់ប្រាសាទនិងទទួលខុសត្រូវលើការអនុវត្តសកម្មភាពនានានៃគម្រោងក្របខ័ណ្ឌបេតិកភណ្ឌ។ |
| អ្នកបញ្ចូលទិន្នន័យក្នុង | បុគ្គលិកអាជ្ញាធរអប្សរា ដែលទទួលខុសត្រូវក្នុងការដាក់បញ្ចូល |

| | |
|---|---|
| គេហៈទំព័រ | ព័ត៌មានថ្មីៗ និងគ្រប់គ្រងគេហៈទំព័រអាជ្ញាធរអប្សរា។ |
| នគរបាលបេតិកភណ្ឌ | កម្លាំងនគរបាលដែលទទួលបានអំណាចក្នុងការការពារបុរាណវត្ថុវប្បធម៌ នៅក្នុងឧទ្យានអង្គរ។ |
| នគរបាលទេសចរណ៍ | កម្លាំងនគរបាលដែលទទួលភារកិច្ចថែរក្សាសុវត្ថិភាពនិងសន្តិសុខភ្ញៀវទេសចរនៅក្នុងឧទ្យានអង្គរ។ |
| សមត្ថភាពផ្ទុក | កម្រិតចំនួនភ្ញៀវទេសចរដែលប្រាសាទឬរមណីយដ្ឋានមួយអាចទទួលយកដោយគ្មានការរេចរិល មិនជះឥទ្ធិពលអវិជ្ជមានដល់ប្រជាជនក្នុងតំបន់ឬមិនធ្វើឲ្យគុណភាពនៃបទពិសោធអ្នកទស្សនាមានការថយចុះ។ |
| ការអភិរក្ស | គ្រប់ដំណើរការទាំងអស់ក្នុងគ្រប់គ្រងនិងថែរក្សាកន្លែងមួយដើម្បីរក្សាគុណតម្លៃបេតិកភណ្ឌ ពោលគឺអភិរក្ស ការពារឬស្តារនូវបេតិកភណ្ឌវប្បធម៌ឬធម្មជាតិឡើងវិញ។ |
| គុណតម្លៃបេតិកភណ្ឌ | បរិស្ថានធម្មជាតិនិងវប្បធម៌របស់កន្លែងមួយ ដែលមានសារៈសំខាន់ខាងសោភណភាព ប្រវត្តិសាស្ត្រ វិទ្យាសាស្ត្រ សង្គម... សម្រាប់ពេលបច្ចុប្បន្ននិងអនាគត។ |
| បេតិកភណ្ឌរូបី | បុរាណវត្ថុឬទ្រព្យសម្បត្តិវប្បធម៌ ដូចជាអគារ ប្រាសាទ ទេសភាព សៀវភៅ ស្នាដៃសិល្បៈជាដើម។ |
| បេតិកភណ្ឌអរូបី | ការប្រតិបត្តិ ការតំណាង ការបង្ហាញឲ្យឃើញ ចំណេះដឹង ជំនាញ លំហ វប្បធម៌... ដែលជាប់ទាក់ទងជាមួយប្រជាជនក្នុងតំបន់។ |
| ប្រព័ន្ធចាត់ថ្នាក់ប្រាសាទ | រចនាសម្ព័ន្ធរៀបចំឬធ្វើចំណាត់ថ្នាក់ប្រាសាទ និងតំបន់ប្រាសាទដោយផ្អែកលើលក្ខណវិនិច្ឆ័យនានាដូចជាគុណតម្លៃបេតិកភណ្ឌ ការទស្សនានិងសមត្ថភាពផ្ទុក |
| ផែនទីហានិភ័យ | ឧបករណ៍ផ្អែកលើមូលដ្ឋានប្រព័ន្ធព័ត៌មានភូមិសាស្ត្រ សម្រាប់ធ្វើការវិភាគលើហានិភ័យ រួមមានទាំងរចនាសម្ព័ន្ធរមណីយដ្ឋាន បរិស្ថាននិងសង្គមវប្បធម៌ ដើម្បីជួយសម្រួលដល់ការគ្រប់គ្រងនិងការធ្វើការសម្រេចចិត្ត។ |
| ការអភិវឌ្ឍន៍ប្រកបដោយចីរភាព | ទម្រង់នៃការប្រើប្រាស់ធនធានក្នុងការអភិវឌ្ឍន៍និងអភិរក្សដើម្បីជាប្រយោជន៍ដល់មនុស្សនាពេលបច្ចុប្បន្ននិងអនាគត។ |
| **នាយកដ្ឋាននៅក្នុងអគ្គនាយកដ្ឋានអាជ្ញាធរអប្សរា** | |
| នា-ផ្សព្វផ្សាយ | នាយកដ្ឋានផ្សព្វផ្សាយ |
| នា-វប្បធម៌ | នាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ សារមន្ទីរ និងបទដ្ឋានបេតិកភណ្ឌ |
| នា-ក្នុងឧទ្យាន | នាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យា |

| | |
|---|---|
| | បង្ការ |
| នា-ក្រៅឧទ្យាន | នាយកដ្ឋានអភិរក្សប្រាសាទក្រៅឧទ្យានអង្គរ |
| នា-បេតិកភណ្ឌក្រុង | នាយកដ្ឋានអភិវឌ្ឍន៍បេតិកភណ្ឌក្រុងក្នុងតំបន់សៀមរាប |
| នា-គណនេយ្យ | នាយកដ្ឋានហិរញ្ញកិច្ចនិងគណនេយ្យ |
| នា-គ្រប់គ្រងលំនៅដ្ឋាន | នាយកដ្ឋានរៀបចំដែនដីនិងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរ |
| នា-ព្រៃឈើ | នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន |
| នា-សណ្តាប់ធ្នាប់ | នាយកដ្ឋានសណ្តាប់ធ្នាប់និងសហប្រតិបត្តិ |
| នា-ទេសចរណ៍ | នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ |
| នា-អន្តរវិស័យ | នាយកដ្ឋានទ្រទ្រង់បច្ចេកទេសនិងគម្រោងអន្តរវិស័យ |
| នា-គ្រប់គ្រងទឹក | នាយកដ្ឋានគ្រប់គ្រងទឹក |
| មន្ត្រីអនុវត្តTMP | ជាបុគ្គលិកជាន់ខ្ពស់របស់អាជ្ញាធរអប្សរា ដែលទទួលបានសិទ្ធិពីអគ្គនាយក ដើម្បីទទួលខុសត្រូវគ្រប់គ្រងការងារអនុវត្តផែនការគ្រប់គ្រងទេសចរណ៍។ |

# កំណត់ត្រា